01595993

**Declassified to Public**
**08 April 2021**

លេខ/No: D266

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 11 / 2018
ម៉ោង (Time/Heure): 11:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**លេខសំណុំរឿង: ០០៣/០៧-០៩-២០០៩/អវតក /កសចស**

| | | |
|---|---|---|
| ចំពោះមុខ | : | **សហចៅក្រមស៊ើបអង្កេតជាតិ** |
| កាលបរិច្ឆេទ | : | **ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨** |
| ភាសា | : | **ខ្មែរ** |
| ចំណាត់ថ្នាក់ឯកសារ | : | **សម្ងាត់** |

---

## ដីកាសម្រេចលើកលែងចោទប្រកាន់ មាស មុត

---

**ផ្ញើជូន**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី មាស មុត**

អាង ឧត្តម
Michael G.KARNAVAS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Martine JACQUIN
Daniel MCLAUGHLIN
Yiqiang LIU
Lyma NGUYEN
Nushin SARKARATI

# មាតិកា

ទំព័រ

**ជំពូក ១. សេចក្ដីផ្ដើម** ....................២

ផ្នែកទី ១. ការកត់សម្គាល់អំពីដីកាដំណោះស្រាយ....................២

ផ្នែកទី ២. ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា....................៧

**ជំពូក ២. ប្រវត្តិនីតិវិធី** ....................៨

**ជំពូក ៣. អង្គហេតុ** ....................២២

ផ្នែកទី ១. ប្រវត្តិរបស់បក្សកុំម្មុយនីស្តកម្ពុជា ....................២២

ផ្នែកទី ២. រចនាសម្ព័ន្ធរដ្ឋបាល....................៤១

ក. បក្សកុំម្មុយនីស្តកម្ពុជា ....................៤១

ខ. គណៈកម្មាធិការមជ្ឈិម....................៤២

គ. គណៈកម្មាធិការអចិន្ត្រៃយ៍....................៤៧

ឃ. មន្ទីរ....................៥០

១. មន្ទីរនយោបាយ ៨៧០....................៥០

២. មន្ទីររដ្ឋបាល ឬ មន្ទីរ ស-៧១....................៥១

ង. ក្រសួងនានា....................៥៣

១. សភា....................៥៤

២. តុលាការ....................៥៤

ផ្នែកទី ៣. រចនាសម្ព័ន្ធយោធា....................៥៥

ក. ដើមកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា....................៥៥

ខ. តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា....................៥៦

គ. ស្ថាប័នទ័ពរបស់មជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា....................៥៧

១. គណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម....................៥៧

២. សេនាធិការ....................៦០

ឃ. សមាសភាពកងទ័ពបដិវត្តន៍កម្ពុជា....................៦៦

១. កងទ័ពស្រួច....................៦៦

២. កងពលនានារបស់មជ្ឈិម....................៦៧

២.១ កងពលលេខ ១៦៤....................៦៩

៣. កងទ័ពរបស់ភូមិភាគ....................៧៧

៤. កងឈ្លប....................[illegible]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

01595995

ង. ទំនាក់ទំនងរបស់កងទ័ពបដិវត្តន៍កម្ពុជា....................................................................................៧៨
ច. ទំនាក់ទំនងរវាង មាស មុត និង សេនាធិការ......................................................................៨២
ឆ. វិន័យ.............................................................................................................................៨៤
ផ្នែកទី ៤. គោលនយោបាយបោសសម្អាតនៅក្នុងជួរកងទ័ព......................................................៨៥
ក. គោលនយោបាយបោសសម្អាត.................................................................................................៨៥
ខ. ការចូលរួមរបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុងការបោសសម្អាត..............................................៩១
គ. ការចូលរួមរបស់ មាស មុត ក្នុងការបោសសម្អាត......................................................................៩៤
ផ្នែកទី ៥. តួនាទី និងការចូលរួមរបស់ មាស មុត........................................................................៩៦
ក. សាវតាររបស់ មាស មុត..............................................................................................................៩៦
ខ. អំណាច និងតួនាទីនៅក្នុងឧក្រិដ្ឋកម្ម.........................................................................................៩៧
១. មន្ទីរសន្តិសុខ ស-២១ ...........................................................................................................៩៧
២. មន្ទីរសន្តិសុខវត្តឥន្ទញាណ.........................................................................................................១០៥
៣. ការដ្ឋានវាយថ្មស្ទឹងហាវ..........................................................................................................១០៨
៤. ឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅក្នុងដែនទឹកនិងដែនកោះ ១១១
៥. ជម្លោះជាមួយវៀតណាម...............................................................................................................១១៥
៦. មន្ទីរឃុំឃាំង ៨១០ (កងពល ៨០១)...........................................................................................១១៨
៧. មន្ទីរសន្តិសុខរបស់កងទ័ពបដិវត្តន៍កម្ពុជា និងទីតាំងសម្លាប់ផ្សេងទៀត.....................................១២៧
**ជំពូក ៤. ការពិចារណាលើតំរូតាង** ..........................................................................................................១២៧
**ជំពូក ៥. លក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គល**...........................................................................................១២៩
**ជំពូក ៦. សំអាងហេតុ និងសន្និដ្ឋាន**.............................................................................................................១៤៨



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

## យើង យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិ
## នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

- **បានឃើញ** ច្បាប់ស្តីពី "ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ។

- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដែលបានប្តឹងមកសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ ដើម្បីបើកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់ប្រឆាំងនឹងឈ្មោះ មាស មុត ចំពោះបទចោទអំពីការរំលោភបំពាន ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ **អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ** ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ និង ឧក្រិដ្ឋកម្ម មនុស្សឃាត និងការធ្វើទារុណកម្ម ក្រោមមាត្រា ៥០០ , ៥០១ , ៥០៣ , ៥០៤ , ៥០៥ , ៥០៦ , ៥០៧ , និង ៥០៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣ (ថ្មី) , ៥ , ៦ , ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[1]

- **បានឃើញ** វិធាន ៥៥ , វិធាន ៦៦ និងវិធាន ៦៧ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី ៩ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ។

- **បានឃើញ** វិធាន ៦៦ ស្ទួន នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិសោធនកម្មលើកទី ៩ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ ។

- **បានឃើញ** សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ កោសលុបដាក់ជាសាធារណៈពាក់ព័ន្ធនឹងការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

- **បានឃើញ** សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ។[2]

- **បានឃើញ** ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។[3]

- **បានឃើញ** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។[4]

## ជំពូក ១. សេចក្តីផ្តើម

### ផ្នែកទី ១. ការកត់សម្គាល់អំពីដីកាដំណោះស្រាយ

១. ក្នុងដីកាដំណោះស្រាយនេះ យើងនឹងហៅ មាស មុត ថាជា "ជនត្រូវចោទ" ដោយសារថាតាមទ្រឹស្តី ជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ត្រូវបានហៅថា "ជនត្រូវចោទ" រួចទៅហើយ ទោះបីបុគ្គលទាំងនោះមិនទាន់ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យក្តី ។ នេះផ្អែកតាមរយៈការអនុវត្តកន្លងមក ក្នុងការផ្តល់សិទ្ធិសេរីភាពមួយចំនួន ដល់បុគ្គលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ដើម្បីឱ្យពួកគេមានលទ្ធភាពក្នុងការតទល់នឹងភាគីដទៃ សំដៅធានានូវសិទ្ធិ និងផលប្រយោជន៍។

២. ដីកាដំណោះស្រាយនេះបានប្រើប្រាស់នូវឯកសារ ដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង មុនថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដែលសហចៅក្រមស៊ើបអង្កេតទាំងពីរ បានឯកភាពប្រកាសបិទការស៊ើបសួរ ។ ដើម្បីធានាតម្លាភាព និងសិទ្ធិសេរីភាពរបស់ជនត្រូវចោទ យើងនឹងមិនប្រើប្រាស់នូវឯកសារដាក់ចូលក្នុងសំណុំរឿងក្រោយកាលបរិច្ឆេទបិទការស៊ើបអង្កេត

នេះទេ ។ ទោះបីជាយ៉ាងនេះក្តី វាអាចមានឯកសារណាមួយ ដែលជាផ្នែកមួយនៃកិច្ចស៊ើបអង្កេត មុនកាលបរិច្ឆេទបិទការស៊ើបអង្កេត ហើយដែលត្រូវបានដាក់ក្នុងសំណុំរឿងនេះក្នុងពេលបន្តបន្ទាប់ក្រោយមក។ ឯកសារដែលនឹងត្រូវប្រើរួមមាន៖ ឯកសារទាំងឡាយដែលមានក្នុងសំណុំរឿងលេខ ០០៣ ដែលទទួលបានមកពីការស៊ើបអង្កេត និងការផ្ទេរបញ្ចូលពីសំណុំរឿងដទៃទៀតរួមមាន សំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ ០០២ ព្រមទាំងសំណុំរឿងលេខ ០០៤ ។ ឯកសារទាំងនោះចែកចេញជា ២៣ ប្រភេទ ដូចជា សារទូរលេខ កំណត់ហេតុនៃកិច្ចប្រជុំ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលមានចំនួនច្រើនជាងគេរហូតដល់ជិត ៥០០ ។[5] ក្នុងប្រភេទឯកសារចុងក្រោយនេះ មានចម្លើយរបស់សាក្សីសំខាន់ (Insider Witness) ដូចជាកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ មានចំនួន ១៨៦ ដែលត្រូវបានបង្កើតឡើងក្នុងក្របខណ្ឌនៃសំណុំរឿងលេខ ០០៣ នេះ ។

៣. ដីកាដំណោះស្រាយនេះនឹងផ្តោតលើថាតើ **មាស មុត** ជាមេដឹកនាំ ឬជាជនទទួលខុសត្រូវខ្ពស់បំផុតស្ថិតក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ? យោងតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលនឹងបង្ហាញជូននូវក្នុងផ្នែកខាងក្រោម យើងនឹងពិចារណាលើអង្គហេតុដែលបានចោទប្រកាន់នឹង **មាស មុត** ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយផ្តោះនឹងលក្ខណៈវិនិច្ឆ័យចម្បងចំនួនពីរ ៖ ១. ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និង ២. កម្រិតនៃការចូលរួមរបស់ **មាស មុត** ដើម្បីធ្វើការសន្និដ្ឋានអំពីយុត្តាធិការបុគ្គល ។ ក្នុងន័យនេះ យើងនឹងមិនចាំបាច់បរិយាយនូវប្រភេទបទល្មើស ការចាត់ថ្នាក់នៃបទល្មើស និងទម្រង់នៃការទទួលខុសត្រូវឡើយ ។ តាមផ្លូវច្បាប់ការពិចារណានេះតម្រូវសម្រាប់ដីកាបញ្ជូនទៅជំនុំជម្រះតែប៉ុណ្ណោះ ។[6] ជាចុងក្រោយ អនុលោមតាមគោលការណ៍នៃការពិចារណាទាំងស្រុងលើភ័ស្តុតាង និងនីតិវិធីត្រឹមត្រូវតាមច្បាប់ មានតែភ័ស្តុតាងមុនបិទការស៊ើបអង្កេត ដែលត្រូវបានយកមកពិចារណាអំពីយុត្តាធិការបុគ្គលនៅក្នុងដីកានេះ។ ក្នុងករណីមានមន្ទិល ប្រយោជន៍នឹងត្រូវបានផ្តល់ជូនជនត្រូវចោទ ។

៤. ការសរសេរនូវដីកាដំណោះស្រាយ ទោះបីជាការបញ្ជូនទៅជំនុំជម្រះក្តី ទាមទារនូវពេលវេលាមួយគ្រប់គ្រាន់ ដើម្បីឱ្យធនធានមនុស្សដែលមានកម្រិតអាចបំពេញការងារបានជោគជ័យ ។ ក្នុងសំណុំរឿងលេខ ០០៣ ក៏ដូចជាក្នុងសំណុំរឿងលេខ ០០៤/២ ការិយាល័យសហចៅក្រមស៊ើបអង្កេតជាតិ មានមន្ត្រីម្នាក់គត់ទទួលបន្ទុកសំណុំរឿងនេះ ប្រសិនបើធៀបនឹងសំណុំរឿង ខុច ដែលមានមន្ត្រីទទួលបន្ទុកស្ទើរមួយការិយាល័យ (ចំនួន ៤ រូប) ។ បន្ថែមលើវិសាលភាពធំនៃសំណុំរឿង សំណុំរឿងលេខ ០០៣ នេះមានបញ្ហានីតិវិធីស្មុគស្មាញ ។ ភាគីបានដាក់ញត្តិមួយចំនួនដែលអាចនាំឱ្យមានការពន្យារដំណើរ ហើយលទ្ធផលនៃការស្នើសុំក៏នឹងត្រូវបានទាមទារដោយច្បាប់ និងវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឱ្យសហចៅក្រមស៊ើបអង្កេតជាតិពិចារណាផងដែរ ។ ជាក់ស្តែង **មាស មុត** បានដាក់ញត្តិសុំមោឃភាពភស្តុតាងទទួលបានតាមរយៈអំពើទារុណកម្ម ដែលក្នុងនោះមាន ឯកសារសក្ខីកម្មរបស់សាក្សីដែលបានដាក់ក្នុងសំណុំរឿង មុនថ្ងៃបិទការស៊ើបអង្កេត ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ។[7]

៥. សិទ្ធិក្នុងការទទួលបានការសម្រេចសេចក្តីក្នុងពេលសមស្រប គឺជាសិទ្ធិសំខាន់នៃសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយយុត្តិធម៌ ។[8] តាមខ្លឹមសារនៃមាត្រា ១៤ នៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ និងនយោបាយ វាមិនមានភាពច្បាស់លាស់ទេ ថាតើរយៈពេលនេះ ត្រូវគិតចាប់ពីពេលណាមក ។ តាមយុត្តិសាស្ត្រ ពេលវេលានេះរួមបញ្ចូលទាំងការស៊ើបអង្កេត និងសវនាការជាក់ស្តែង ។[9] អាស្រ័យហេតុនេះការវាយតម្លៃទៅលើរយៈពេល តម្រូវឱ្យពិចារណាលើទិដ្ឋភាព និងកត្តាទូទៅជារួម ដើម្បីសម្រេចថាតើមានការបំពានសិទ្ធិនេះដែរឬទេ? ។ កត្តាទាំងនោះ មានដូចជាភាពស្មុគស្មាញនៃរឿងក្តី ឬភាពយឺតយ៉ាវរបស់ជនត្រូវចោទ និងអាជ្ញាធរតុលាការជាដើម ។ ការពិចារណាត្រូវធ្វើឡើងតាមករណីសំណុំរឿងជាក់ស្តែងនីមួយៗ ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានអះអាងថា *"ភាពសមហេតុផលនៃរយៈពេលនៃនីតិវិធី ត្រូវបានវាយតម្លៃផ្អែកតាមស្ថានភាពដោយឡែកនៃសំណុំរឿងនីមួយៗ ដោយ*



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

01596000



*ពិចារណាលើ .... ជាពិសេសភាពស្មុគស្មាញនៃសំណុំរឿង ព្រមទាំងទង្វើនៃអ្នកប្តឹង និង អាជ្ញាធរពាក់ព័ន្ធ"* ។[10]

៦. ផ្អែកលើភាពស្មុគស្មាញនៃនីតិវិធីនេះ ដែលសហចៅក្រមស៊ើបអង្កេតជាតិ ត្រូវរង់ចាំនូវរយៈពេលមួយ ក្នុងការចេញដីកាដំណោះស្រាយ ហើយសហចៅក្រមស៊ើបអង្កេតទាំងពីរបានឯកភាពចេញដីកាដំណោះស្រាយនេះក្នុងពេលតែមួយ ដើម្បីកាត់បន្ថយនូវភាពស្មុគស្មាញនៃនីតិវិធី ពាក់ព័ន្ធនឹងការចេញដីកាដំណោះស្រាយពីរមុន និងក្រោយគ្នា ។ វាក៏ថែមទាំងជួយដល់ភាគីពាក់ព័ន្ធ បានយល់ដឹងខ្លឹមសារនៃដីកាដំណោះស្រាយទាំងពីរ ក្នុងពេលតែមួយ និងជួយជាមូលដ្ឋានក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ។

៧. វិធាន ៧២ នៃវិធានផ្ទៃក្នុង បានចែងអំពីជម្រើសសម្រាប់ដំណោះស្រាយខ្វែងយោបល់សម្រាប់សហចៅក្រមស៊ើបអង្កេត ។ វាអាចជាការចុះកំណត់ត្រាខ្វែងយោបល់ផ្ទៃក្នុង ដែលកន្លងមកសហចៅក្រមទាំងពីរបានធ្វើ និងការដាក់ញត្តិទៅអង្គបុរេជំនុំជម្រះ ដើម្បីសម្រេចលើបញ្ហាខ្វែងយោបល់ ។ វិធាន ៧២ បានចែងតែអំពីការខ្វែងយោបល់ពាក់ព័ន្ធនឹងកិច្ចស៊ើបអង្កេត ។ សហចៅក្រមទាំងពីរយល់ឃើញថា យន្តការដោះស្រាយការខ្វែងយោបល់នេះ មិនសម្រាប់ការខ្វែងយោបល់លើប្រភេទ និងជម្រើសនៃការចេញដីកាដំណោះស្រាយឡើយ។ ឈរលើមូលដ្ឋាននេះ សហចៅក្រមស៊ើបអង្កេតមិនបានដាក់ញត្តិទៅអង្គបុរេជំនុំជម្រះទេ ដោយគ្រាន់តែបានធ្វើកំណត់ត្រាខ្វែងយោបល់ផ្ទៃក្នុង។ [11] បន្ថែមពីលើនេះចេតនានៃការចេញដីកាដំណោះស្រាយពីរផ្សេងគ្នា ត្រូវបានបង្ហាញក្នុងសេចក្តីសម្រេច ។[12] ច្បាប់ និងកិច្ចព្រមព្រៀង ក៏មិនបានហាមពីលទ្ធភាពនៃការចេញដីកាដំណោះស្រាយពីរផ្សេងគ្នាទេ ។ ការមិនមានចែង មានន័យថាការចេញដីកាដំណោះស្រាយពីរក៏មិនខុសច្បាប់ដែរ ។

៨. ក្នុងន័យនេះ ដីកាដំណោះស្រាយចេញក្នុងឆ្នាំ ២០១៨ ក្រោយរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ និងរយៈពេល ៧ (ប្រាំពីរ) ឆ្នាំ ក្រោយពីការបិទការស៊ើបអង្កេត មិនមែនគ្មានមូលដ្ឋាននោះទេ ។ វិធានផ្ទៃក្នុង មិនបានចែងកំណត់ពីពេលវេលា

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

សម្រាប់ចេញដីកាដំណោះស្រាយ បន្ទាប់ពីបិទការស៊ើបអង្កេតឡើយ ។ បន្ថែមពីនេះ សំណុំរឿងនៅតែស្ថិតនៅក្នុងដៃរបស់សហចៅក្រមស៊ើបអង្កេត រហូតដីកាដំណោះស្រាយត្រូវបានបញ្ជូនចេញ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានចរិតលក្ខណៈពិសេស ដែលមានសហចៅក្រមស៊ើបអង្កេតចំនួនពីររូប គឺចៅក្រមជាតិ និងចៅក្រមអន្តរជាតិ ដែលមានកាតព្វកិច្ចធ្វើការងាររួមគ្នា ។

៩. ដូចដែលមានបង្ហាញជូនក្នុងជំពូក ៤ សហចៅក្រមស៊ើបអង្កេតជាតិពិចារណាថា មិនមានការខុសឆ្គងអ្វីទេ ក្នុងការបរិយាយអំពី ប្រភេទនៃភ័ស្តុតាង និងតម្លៃនៃភ័ស្តុតាង នៅក្នុងដីកាដំណោះស្រាយនេះ ។ មាត្រា ៣២១ (ការវាយតម្លៃលើភ័ស្តុតាងដោយតុលាការ) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧ និងគោលការណ៍ទទួលភ័ស្តុតាងដោយសេរីនៃប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System) មិនហាមឃាត់ទេ ។ ជាការអនុវត្តជាក់ស្តែង និងសមហេតុផល វាពិតជាមានភាពខុសគ្នារវាងប្រភេទនៃភ័ស្តុតាង ឧទាហរណ៍រវាង ភ័ស្តុតាងឮតាមគ្នា (Hearsay Evidence) និងសក្ខីកម្មរបស់សាក្សី ដែលបានឃើញព្រឹត្តិការណ៍ផ្ទាល់ ។ អ្វីជាសំខាន់ គឺការពិចារណានូវភ័ស្តុតាងជាក់ស្តែងតាមវិធានកំណត់ គឺភាពជាក់ពាក់ព័ន្ធ ភាពស្របច្បាប់ និងភាពសត្យានុម័តនៃភ័ស្តុតាង ។

១០. ពាក់ព័ន្ធនឹងភ័ស្តុតាង ត្រូវបានចោទថាទទួលបានតាមរយៈអំពើទារុណកម្ម សហចៅក្រមស៊ើបអង្កេតជាតិ មានឆន្ទានុសិទ្ធិក្នុងការកំណត់វាយតម្លៃភ័ស្តុតាងដែលប្រមូលបាន ដោយផ្អែកលើលក្ខណៈសម្បត្តិនៃភ័ស្តុតាង ភាពជាប់ពាក់ព័ន្ធ ភាពស្របច្បាប់ និងភាពសត្យានុម័ត ដោយពិចារណាលើសេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះសាលាដំបូង[13] និងអង្គជំនុំជម្រះតុលាការកំពូល[14] ដើម្បីដំណើរការនេះ អាចប្រព្រឹត្តទៅលឿនដោយមិនចាំបាច់ប្ដឹងទៅអង្គបុរេជំនុំជម្រះទេ ។

១១. នៅក្នុងសំណុំរឿងលេខ ០០៣ នេះ មានជនត្រូវចោទចំនួនពីររូប គឺ មាស មុត និង ស៊ូ ម៉េត ។[15] នៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ ស៊ូ ម៉េត បានទទួលមរណភាព ។[16] សហចៅក្រម



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ស៊ើបអង្កេតទាំងពីរបានសម្រេចបញ្ចប់សំណុំរឿងចោទប្រកាន់លើ ស៊ូម៉េត ។[17] ដោយសារមរណភាពជាមូលហេតុនៃការបញ្ចប់ការចោទប្រកាន់ សហចៅក្រមស៊ើបអង្កេតជាតិ យល់ថាមិនមានការចាំបាច់ក្នុងការសរសេរសេចក្ដីសម្រេចលំអិតក្នុងដីកានេះ លើសពីអ្វីដែលបានកំណត់ក្នុងសេចក្ដីសម្រេចក្នុងករណីនេះរួចហើយ ។

១២. យើងនឹងបង្ហាញអំពីប្រវត្តិនៃនីតិវិធី ទាក់ទងនឹងការស៊ើបអង្កេតលើសំណុំរឿងលេខ ០០៣ ។ លើសពីនេះ យើងក៏នឹងបង្ហាញផងដែរអំពីអង្គច្បាប់ជាធរមានស្ដីពីយុត្តាធិការបុគ្គលលើ **មាស មុត** និងការដែលមិនសម្រេចដាក់ **មាស មុត** ឲ្យស្ថិតនៅក្រោមការពិនិត្យ ។ បន្ទាប់មក យើងនឹងពន្យល់អំពីការវាយតម្លៃភ័ស្តុតាង ពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងអស់លើ **មាស មុត** ។ ដោយផ្អែកលើមូលដ្ឋានទាំងនេះ យើងនឹងធ្វើការសន្និដ្ឋានអំពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើ **មាស មុត** ។

## ផ្នែកទី ២. ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

១៣. បន្ទាប់ពីមានសំណើសុំជំនួយជាផ្លូវការពីព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៧[18] កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ។[19]

១៤. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបង្កើតឡើងនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា បន្ទាប់ពីមានការប្រកាសឲ្យប្រើ ច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជា



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596003



ប្រជាធិបតេយ្យ ("ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា") ។[20] អង្គជំនុំជម្រះនេះ ត្រូវបានបង្កើតឡើងជាផ្លូវការនៅថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៦ ។

## ជំពូក ២. ប្រវត្តិនៃនីតិវិធី

១៥. នៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៨ ខណៈពេលដែលសហចៅក្រមស៊ើបអង្កេត បាននឹងកំពុងធ្វើការស៊ើបសួរសំណុំរឿងលេខ ០០២ ការិយាល័យរដ្ឋបាលបានបញ្ជូន "អំណះអំណាងជាលាយលក្ខណ៍អក្សររបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីហេតុការណ៍ និងមូលហេតុនៃការខ្វែងយោបល់របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ (២)" ដែលនៅក្នុងនោះសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា "គាត់មានបំណងចង់ដាក់ជូននូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីចំនួនពីរទៀត [...]" ។ សហព្រះរាជអាជ្ញាអន្តរជាតិក៏បានរាយការណ៍ក្នុងអំណះអំណាងរបស់គាត់ថា មានការខ្វែងយោបល់គ្នាក្នុងការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្ម ដែលចង្អុលបានបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មី[21] ហើយសហព្រះរាជអាជ្ញាជាតិមិនឯកភាពចំពោះការចោទប្រកាន់បទឧក្រិដ្ឋនានា ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរថ្មីនោះទេ ។

១៦. នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ បន្ទាប់ពីពិភាក្សាយ៉ាងហ្មត់ចត់ អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រភាគច្រើនបាន លើសេចក្តីសម្រេចពាក់ព័ន្ធនឹងការខ្វែងយោបល់ ។ ដូចនេះអង្គបុរេជំនុំជម្រះបានចេញសេចក្តីពិចារណាកោសលុបដាក់ជាសាធារណៈពាក់ព័ន្ធនឹងការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៧១ ។[22] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវចាត់ទុកថាជាបានការ ។

១៧. នៅថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងមកសហចៅក្រមស៊ើបអង្កេត តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ដោយតាមរយៈដីកានេះ សហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា មាស មុត គឺជាជនសង្ស័យ និងជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋ ។[23]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១៨. នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ យោងតាមលទ្ធផលនៃការស៊ើបសួរដែលបានធ្វើឡើងកន្លងមកសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried BLUNK បានបិទការស៊ើបអង្កេត[24] និងបានចេញដីកាប្រកាសបដិសេធមិនទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងបដិសេធនូវសំណើសុំរបស់អ្នកដាក់ពាក្យសុំក្នុងការទទួលបានឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០៣ ព្រមទាំងបដិសេធសំណើសុំឱ្យមានការសម្រេចអំពីវិធានការការពារ និងសំណងផ្លូវចិត្ត ។[25] អង្គភាពគាំពារជនរងគ្រោះបានទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០៣ មានចំនួនសរុប ៦៤២ (ប្រាំមួយរយសែសិបពីរ) ពាក្យសុំ ក្រោយពីថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ២០១១ (រយៈពេល ១៥ ថ្ងៃក្រោយការបិទការស៊ើបអង្កេត) ។[26] ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ (បួន) រូប បានដាក់ពាក្យប្តឹងឧទ្ធរណ៍ ។[27] អង្គបុរេជំនុំជម្រះពុំអាចទទួលបានសំឡេងគាំទ្រភាគច្រើន[28] ហេតុដូច្នេះហើយដោយអនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង ដីកាសម្រេចដែលត្រូវបានជំទាស់ត្រូវតម្កល់ទុកជាបានការ និងបិទផ្លូវប្តឹងតវ៉ា ។

១៩. នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចេញ "សំណើបំពេញកិច្ចស៊ើបសួរលើកទីមួយ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងសំណុំរឿងលេខ ០០៣ សុំឱ្យទទួលយកឯកសារបន្ថែម និងសេចក្តីសង្កេតលើស្ថានភាពនៃកិច្ចស៊ើបសួរ" ។[29] សំណើលើកទីពីរ របស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹងលោក ស៊ូ ម៉េត ព្រមទាំងពាក់ព័ន្ធនឹងទីកន្លែងប្រព្រឹត្តបទល្មើស ។[30] សំណើលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរបន្ថែមពាក់ព័ន្ធនឹង មាស មុត និងទីតាំងឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ ។[31]

២០. នៅថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ "ដីកាពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣"[32] ដោយបង្គាប់ឱ្យសហព្រះរាជអាជ្ញាធ្វើការបំភ្លឺថាតើមុនពេលដែលដាក់សំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរ សហព្រះរាជ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

អាជ្ញាទាំងពីរមានធ្វើការសម្រេចអំពីការផ្ទេរអំណាចស្របតាមវិធាន ១៣ (៣) នៃវិធានផ្ទៃក្នុង ឬថាតើសហព្រះរាជអាជ្ញាទាំងពីរ បានធ្វើកំណត់ហេតុអំពីការខ្វែងយោបល់ស្របតាមវិធាន ៧១ (១) នៃវិធានផ្ទៃក្នុងដែរឬទេ ។

២១. នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាជាតិបានឆ្លើយតបចំពោះដីកាសម្រេចពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងបំពេញកិច្ចស៊ើបសួរនានារបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿងលេខ ០០៣ ។[33] សហព្រះរាជអាជ្ញាជាតិបានលើកឡើងថាការធ្វើសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងសំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរសហព្រះរាជអាជ្ញាជាតិមិនបានផ្ទេរអំណាចណាមួយដល់សហព្រះរាជអាជ្ញាអន្តរជាតិ និងមិនធ្លាប់មានកំណត់ហេតុនៃការខ្វែងយោបល់ទាក់ទងនឹងសំណើទាំងនេះឡើយ ។

២២. នៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិបានឆ្លើយតបចំពោះដីកាសម្រេចពាក់ព័ន្ធនឹងសំណើសុំពន្យារពេល និងបំពេញកិច្ចស៊ើបសួរនានារបស់ខ្លួននៅក្នុងសំណុំរឿងលេខ ០០៣ ។[34] សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា ដោយសារការខ្វែងយោបល់ដំបូងទាក់ទងនឹងសំណុំរឿងលេខ ០០៣ នៅតែបន្តមាននៅឡើយ ហេតុដូច្នេះហើយ សហព្រះរាជអាជ្ញាអន្តរជាតិមានសិទ្ធិធ្វើសំណើសុំពន្យារពេល និងសំណើសុំបំពេញកិច្ចស៊ើបសួរ ដោយមិនចាំបាច់មានការផ្ទេរអំណាចណាមួយដោយសហព្រះរាជអាជ្ញាជាតិ និងមិនចាំបាច់ធ្វើកំណត់ហេតុនៃការខ្វែងយោបល់ទាក់ទងនឹងសំណើទាំងនេះឡើយ ។

២៣. នៅថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេត បានបដិសេធសំណើសុំទាំងនេះ ដោយបានចេញនូវ "ដីកាសម្រេចស្តីអំពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ។ [35]

២៤. នៅថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ បន្ទាប់ពីមានការធ្វើកំណត់ហេតុខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាទាំងពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើបំពេញកិច្ចស៊ើបសួរទាំងបីម្តងទៀត ។ [36]

២៥. នៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ "បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលមានចំណងជើងថា " ដីកាសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ស្នើដោយសហព្រះរាជអាជ្ញាអន្តរជាតិពាក់ព័ន្ធនឹងសំណុំរឿង ០០៣" ។[37]

២៦. នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតបានចេញ " ដីកាសម្រេចស្តីអំពីការដាក់សារជាថ្មីនូវសំណើសុំបំពេញកិច្ចស៊ើបសួរចំនួនបី របស់សហព្រះរាជអាជ្ញាអន្តរជាតិនៅក្នុងសំណុំរឿង ០០៣ " ដោយបានបដិសេធសំណើសុំដែលដាក់ឡើងវិញដោយសហព្រះរាជអាជ្ញាអន្តរជាតិ ។ [38]

២៧. នៅថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលរងការជំទាស់ ។[39] នៅថ្ងៃទី ០២ និង ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤ (បួន) រូប យ៉ាងតិច ក្នុងការធ្វើការសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា អន្តរជាតិទាក់ទងនឹង"សេចក្តីសម្រេចស្តីពីសំណើសុំពន្យារពេលកំណត់ និងសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងសំណុំរឿង ០០៣" និង "សេចក្តីសម្រេចលើការដាក់ឡើងវិញនូវសំណើសុំបំពេញកិច្ចស៊ើបសួរទាំងបី" ។[40] អនុលោមតាមវិធាន ៧៧ (១៣) នៃវិធានផ្ទៃក្នុង នៅពេលដែលអង្គបុរេជំនុំជម្រះមិនអាចរកសំឡេងគាំទ្របាន សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានតម្កល់ និងបិទផ្លូវប្តឹងតវ៉ា។



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៨. ក្រោយពីការលាលែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried BLUNK នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១១[41] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet ដែលមិនទាន់ត្រូវបានតែងតាំងជាផ្លូវការជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១១ បានចេញដីកាសម្រេចស្តីអំពីការបើកការស៊ើបអង្កេតបឋមឡើងវិញ និងទទួលយកសំណើសុំបំពេញកិច្ចស៊ើបសួរ ដែលដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១១ ដោយអត្តនោម័តិតែម្នាក់ឯង ។[42]

២៩. នៅថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១១ សហចៅក្រមស៊ើបអង្កេតជាតិបានចេញនូវសេចក្តីថ្លែងការណ៍មួយ ដោយបដិសេធមិនទទួលស្គាល់រាល់កិច្ចទាំងឡាយណា ដែលធ្វើដោយលោកចៅក្រម Laurent Kasper-Ansermet ដោយហេតុថាគាត់ជាចៅក្រមគ្មានទីតិសម្បទាតាមផ្លូវច្បាប់ ព្រោះមិនទាន់មានការតែងតាំងជាផ្លូវការ ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា ។[43]

៣០. នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet បានផ្ញើលិខិតសុំលាលែងទៅកាន់លោកអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដោយមានអានុភាពចាប់ពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០១២ ។[44] រវាងថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១២ ដល់ថ្ងៃលាលែងតំណែងរបស់គាត់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងបានបំពេញកិច្ចមួយចំនួនតែម្នាក់ឯងដូចជា ការស៊ើបសួរ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការសាកសួរសាក្សីមួយចំនួនជាអាទិ៍។

៣១. នៅថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark B. Harmon ត្រូវបានតែងតាំងដោយសេចក្តីសម្រេចរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ ។[45]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

៣២. នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Mark B. Harmon បានធ្វើកំណត់ហេតុខ្វែងយោបល់ទាក់ទងជាមួយសំណុំរឿងលេខ ០០៣ ចំពោះបញ្ហាដូចខាងក្រោម៖

១. សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញថា ដោយសារលោកចៅក្រម យូ ប៊ុនឡេង និង Siegfried BLUNK បានជូនដំណឹងរួចហើយអំពីការបិទការស៊ើបសួរ ហើយបណ្តឹងឧទ្ធរណ៍ទាំងអស់ត្រូវបានដោះស្រាយរួចរាល់ហើយ ជាបន្ទាប់សហចៅក្រមស៊ើបអង្កេតក៏បានចេញដីកាបញ្ជូនរឿងមូលទៅពិនិត្យ អនុលោមតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង ក្រោយពីការជូនដំណឹងអំពីការបិទការស៊ើបសួរតាមវិធាន ៦៦ (១) នៃវិធានផ្ទៃក្នុង។

២. ផ្ទុយទៅវិញសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Mark B. Harmon យល់ថាការចេញដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យនេះ ដោយសហចៅក្រមស៊ើបអង្កេតជាតិដូចជាឆាប់ពេក ដោយសារសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថា ការស៊ើបសួរមិនទាន់បានពេញលេញ ។ ការស៊ើបសួរបន្ថែមជាការចាំបាច់ ជាពិសេសកិច្ចការដែលមានភ្ជាប់ជាមួយនឹងឧបសម្ព័ន្ធ ហើយម្យ៉ាងទៀតសហចៅក្រមស៊ើបអង្កេតអន្តរជាតិយល់ឃើញថាសហចៅក្រមស៊ើបអង្កេតនៅតែជាម្ចាស់នៃសំណុំរឿង ទោះបីជាសហចៅក្រមស៊ើបអង្កេតជាតិចេញដីកាបញ្ជូនរឿងមូលទៅពិនិត្យនេះរួចហើយក្តី ។

៣៣. នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតជាតិ បានបញ្ជូនសំណុំរឿងលេខ ០០៣ ទៅសហព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្តីសន្និដ្ឋានស្ថាពរតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង ។[46] នៅថ្ងៃដដែលនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចុះហត្ថលេខាលើដីកាចាត់ឲ្យស៊ើបសួរជំនួសដោយបង្គាប់ឲ្យអ្នកស៊ើបអង្កេតអន្តរជាតិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចស៊ើបសួរសំណុំរឿងលេខ ០០៣ ។[47]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៣៤. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ចម្លើយតបនឹងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។[48] សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថាកិច្ចស៊ើបសួរលើអង្គហេតុនានាដូចបានចោទប្រកាន់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ នៅតែបើកធ្វើជាងដែល ហើយជាក់ស្តែងមិនទាន់ចប់សព្វគ្រប់នៅឡើយ និងបានបញ្ជូនសំណុំរឿងត្រឡប់ទៅឱ្យសហចៅក្រមស៊ើបអង្កេតវិញ។

៣៥. នៅថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ សហចៅក្រមស៊ើបអង្កេតជាតិបានបញ្ជាក់ថា ខ្លួនចាត់ទុកចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិថាជាសេចក្តីសន្និដ្ឋានស្ថាពរ ហើយ "ខ្លួននឹងបន្តចំណាត់ការនីតិវិធីដែលមានចែងក្នុងវិធានផ្ទៃក្នុង នៅក្នុងរយៈពេលសមស្រប ប៉ុន្តែខ្លួននឹងទទួលយកមកពិចារណាផងដែរនូវ ដីកាសន្និដ្ឋានផ្សេងទៀតរបស់ការិយាល័យសហព្រះរាជអាជ្ញាដែលអាចធ្វើឡើងក្នុងរយៈពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣" ខណៈដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញសេចក្តីប្រកាសជាសាធារណៈបញ្ជាក់ថា គាត់ចាត់ទុកថាសំណុំរឿងលេខ ០០៣ នៅតែបើក និងកំពុងបន្តដំណើរការ ។[49]

## អនីយ័តភាពនៃការស៊ើបអង្កេតបឋម

៣៦. ទោះបីជាបញ្ហាខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាទាំងពីរ ត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះ ហើយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមានសុពលភាពរួចហើយក្តី សហចៅក្រមស៊ើបអង្កេតជាតិ ពិចារណាថាវាជាការចាំបាច់ក្នុងការបង្ហាញដោយសង្ខេបនូវសារៈតារនៃបញ្ហានេះ ។

៣៧. សហព្រះរាជអាជ្ញាអន្តរជាតិ បានបើកការស៊ើបអង្កេតបឋមដោយឯកឯង ខណៈបរិបទច្បាប់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គោលការណ៍ "សហ" ត្រូវបានក្លាយ



* ECCC * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ជាចំណាងតាមផ្លូវច្បាប់ ជាល័ក្ខខ័ណ្ឌកំណត់ ទោះបីជាស្ថិតក្នុងដំណាក់កាលសហព្រះរាជអាជ្ញាក៏ដោយ សហព្រះរាជអាជ្ញាត្រូវតែធ្វើការរួមគ្នា ។ គោលការណ៍នេះតម្រូវជាចាំបាច់ឲ្យគោរពនូវវិធានបញ្ញត្តិតាមច្បាប់ជាធរមានទាំងឡាយដូចមានចែងក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាអាទិ៍ ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើការស៊ើបអង្កេតបឋមតែម្នាក់ឯង ដោយបានប្រមែប្រមូលនូវឯកសារ និងធ្វើការសម្ភាសន៍ផ្សេងៗ ដោយគ្មានការចូលរួមពីសហព្រះរាជអាជ្ញាជាតិ និងមិនឆ្លងកាត់តាមនីតិវិធីនៃការខ្វែងយោបល់ឡើយ ។ មូលហេតុទាំងនេះ នៅមិនទាន់ពិចារណាដល់កំណត់ហេតុនៃការសួរយកចម្លើយទាំងនោះ ដែលគ្មានហត្ថលេខារបស់សហព្រះរាជអាជ្ញា និងជនដែលត្រូវបានសួរយកចម្លើយថែមទៀត ។

៣៨. នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាអត្តនោម័តិតែម្នាក់ឯង ក្នុងក្របខណ្ឌនៃសំណុំរឿងនេះ ដោយបានចោទប្រកាន់ **មាស មុត** ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ មិនត្រូវបានចាត់ការដោយសហចៅក្រមស៊ើបអង្កេតភ្លាមទេ ដោយហេតុថាទន្ទឹមគ្នានោះសហព្រះរាជអាជ្ញាជាតិ បានប្តឹងជំទាស់ឲ្យពិចារណាលើបញ្ហានៃការខ្វែងយោបល់ដែលជាកម្មវត្ថុនឹងត្រូវបានបញ្ជូនទៅអង្គបុរេជំនុំជម្រះ ។ ជាលទ្ធផលអង្គបុរេជំនុំជម្រះ រកសំឡេងមិនបានដែលការណ៍នេះជាផលវិបាកផ្នែកគតិយុត្តក្នុងបរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នាំឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានអានុភាពគតិយុត្តកើតឡើង ។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី បានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមកសហចៅក្រមស៊ើបអង្កេតសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើអង្គហេតុក្នុងសំណុំរឿងលេខ ០០៣ ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## សុពលភាពនៃការបិទការស៊ើបអង្កេត ដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូប

៣៩. អនុលោមតាមកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការស៊ើបអង្កេតត្រូវធ្វើឡើងដោយឈរលើគោលការណ៍សហការ ដោយឯកភាពគ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងអន្តរជាតិ លើកលែងតែមានការខ្វែងយោបល់ ។ សហចៅក្រមស៊ើបអង្កេតពីររូបបានអនុវត្តនូវឆន្ទានុសិទ្ធិពេញលេញរបស់ខ្លួនក្នុងការបិទកិច្ចស៊ើបសួរក្នុងសំណុំរឿងលេខ ០០៣ នាថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ បន្ទាប់ពីខ្លួនបានយល់ឃើញថា ការស៊ើបអង្កេតមានលក្ខណៈពេញលេញ និងចប់សព្វគ្រប់ហើយ ។[50]

៤០. ភាគីពាក់ព័ន្ធបានប្ដឹងជំទាស់ទៅអង្គបុរេជំនុំជម្រះ ពីការមិនសុខចិត្តរបស់ខ្លួនទៅនឹងសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ហើយអង្គបុរេជំនុំជម្រះក៏បានដោះស្រាយបណ្តឹងឧទ្ធរណ៍របស់គ្រប់ភាគីរួចរាល់ហើយដែរ ។ ការណ៍ដែលអង្គបុរេជំនុំជម្រះរកសំឡេងមិនបានមានន័យថា សំណើបិទការស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ ត្រូវបានតម្កល់បិទផ្លូវប្ដឹងតវ៉ា និងមានសុពលភាព[51] ដែលអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតអាចធ្វើចំណាត់ការនីតិវិធីបន្តរបស់ខ្លួនបាន ។

៤១. ការស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ រហូតមកដល់ការបិទសំណុំរឿង ០០៣ ក្នុងថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ត្រូវបានធ្វើឡើងដោយរលូន និងឯកភាពគ្នាទាំងស្រុងតាមខ្លឹមសារច្បាប់ និងនីតិវិធីតម្រូវដោយគ្មានវិការៈអ្វីឡើយ ។ តួនាទីរបស់សហព្រះរាជអាជ្ញា គឺធ្វើសេចក្តីសន្និដ្ឋានស្ថាពរ និងតវ៉ាទៅតុលាការមានសមត្ថកិច្ច គឺអង្គបុរេជំនុំជម្រះ ដែលអាចពិនិត្យ និងសម្រេចថាការស៊ើបអង្កេតពេញលេញ ឬមិនពេញលេញ ដោយសេចក្តីសម្រេច ។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងដីកាបដិសេធសំណើស៊ើបអង្កេត ។ មានន័យថាបណ្តឹងនេះមានបំណងឱ្យអង្គបុរេជំនុំជម្រះ



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

សម្រេចបើកការស៊ើបអង្កេតបន្ថែម ហើយបណ្តឹងនេះត្រូវបានដោះស្រាយដោយត្រឹមត្រូវដោយអង្គបុរេជំនុំជម្រះក្នុងសមត្ថកិច្ចរបស់ខ្លួនរួចរាល់ហើយ។

៤២. សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងថាការស៊ើបអង្កេតមិនទាន់ពេញលេញ ហើយបដិសេធមិនធ្វើដីកាសន្និដ្ឋានស្ថាពរបញ្ជូនមកសហចៅក្រមស៊ើបអង្កេត ដូចដែលបានទាមទារក្នុងអំឡុងពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីបានទទួលដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យពីសហចៅក្រមស៊ើបអង្កេត ។ ការស៊ើបអង្កេតតាមវិធីណាមួយ ឬប្រភេទឯកសារណាមួយ ដែលសហចៅក្រមស៊ើបអង្កេតសម្រេចប្រមូលយក ជារឿងឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក្នុងស្មារតីឯករាជ្យភាព និងមិនលំអៀង ។ មានឯកសារសំខាន់ៗចំនួនជាង ៣.០០០ (បីពាន់) ឯកសារ នៅក្នុងសំណុំរឿងមុនការបិទស៊ើបអង្កេតក្នុងថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ដែលក្នុងនេះក៏មានចម្លើយរបស់សាក្សីសំខាន់ៗជាច្រើននាក់ដែលត្រូវបានសម្ភាសន៍ ។

៤៣. ប្រសិនបើគេសន្មតថាការស៊ើបអង្កេតក្នុងទំហំប៉ុណ្ណេះនៅមិនទាន់ពេលលេញ ការបើកការស៊ើបអង្កេតឡើងវិញ ឬផ្តួចផ្តើមកិច្ចស៊ើបអង្កេតណាមួយ នឹងមិនត្រូវធ្វើឡើងដោយឯកច្ឆន្ទដោយមិនគោរពតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬជាពិសេសវិធានផ្ទៃក្នុងឡើយ ។ ក្រោយពីការបិទការស៊ើបអង្កេត ហើយរយៈពេលនៃបណ្តឹងឧទ្ធរណ៍បានចប់សព្វគ្រប់ហើយ ភាគីដូចជាសហព្រះរាជអាជ្ញាអាចធ្វើញត្តិស្នើសុំមោឃភាពកិច្ច ឬស្នើសុំបំពេញកិច្ចជាអាទិ៍ ទៅសហចៅក្រមស៊ើបអង្កេត ។[52] ញត្តិនេះមិនមានពេលកំណត់ឡើយ ដែលអាចធ្វើឡើងរហូតសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយ ។[53] ជនត្រូវចោទក៏អាចប្តឹងទៅអង្គបុរេជំនុំជម្រះ ផ្អែកលើមូលដ្ឋាននៃវិធាន ២១ នៃវិធានផ្ទៃក្នុង ។ *តាមវិធាន...នោះ ម្ចាស់បណ្តឹងឧទ្ធរណ៍ចាំបាច់ត្រូវបង្ហាញថា ក្នុងកាលៈទេសៈពិសេសនៃរឿងក្តីដែលបានលើកឡើងអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះជាការចាំបាច់ដើម្បីរារាំងមិនឲ្យមានព្យសនកម្ម ដែលមិនអាចជួសជុលបានចំពោះភាពយុត្តិធម៌នៃកិច្ច*

*ដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងខ្លួនរណ៍ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌* ។[54] ករណីនេះ មិនមានសេចក្តីសម្រេចណាមួយរបស់អង្គបុរេជំនុំជម្រះ សម្រេចបង្គាប់ឱ្យសហចៅក្រមស៊ើបធ្វើការអង្កេតបន្ថែមឡើយ ដូចបានបញ្ជាក់ក្នុងកថាខណ្ឌទី ៤១ ខាងលើ ។

៤៤. ស្រដៀងគ្នានេះដែរ ទាំងចៅក្រម Laurent Kasper-Ansermet ដែលមិនត្រូវបានតែងតាំងជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងលោកចៅក្រម Mark B. Harmon ក៏មិនបានប្តឹងទៅអង្គបុរេជំនុំជម្រះ ក្នុងអំឡុងពេលអនុញ្ញាតតាមវិធានផ្ទៃក្នុង ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិពេញសិទ្ធិ បានធ្វើការស៊ើបអង្កេតជាឯកច្ឆន្ទ។ សហចៅក្រមស៊ើបអង្កេតជាតិ បានផ្ញើជូនដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ នូវអនុស្សរណៈ ដោយអះអាងអំពីការបិទការស៊ើបអង្កេត និងលទ្ធភាពរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការប្តឹងទៅកាន់អង្គបុរេជំនុំជម្រះ ស្នើសុំឱ្យបើកការស៊ើបអង្កេតសំណុំរឿងលេខ 00៣ ឡើងវិញ ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានឆ្លើយតបទេ ។ កំណត់ហេតុនៃខ្វែងយោបល់រវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ មុនថ្ងៃបញ្ជូនដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ មិនមានន័យថាជាការគាំទ្រ ឬផ្ទេរសិទ្ធិដល់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឱ្យបន្តការស៊ើបអង្កេតក្នុងសំណុំរឿងលេខ 00៣ ទេ។

៤៥. សហចៅក្រមស៊ើបអង្កេតជាតិបានអះអាង និងចាត់ទុកថាការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងថ្ងៃទី 0៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ទៅនឹងដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ជាដីកាសន្និដ្ឋានស្ថាពរ [55] ទោះបីដីកានោះមិនមានខ្លឹមសារលម្អិតក្តី ។ សហចៅក្រមស៊ើបអង្កេត គ្មានសិទ្ធិវាយតម្លៃលើប្រភេទនៃដីកានេះទេ។ វាជាសមត្ថកិច្ចរបស់អង្គបុរេជំនុំជម្រះក្នុងការមោឃៈដីកាសន្និដ្ឋានស្ថាពរតាមញត្តិរបស់ជនត្រូវចោទ ដែលជាភាគីនៃសំណុំ



*E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

រឿង ។ បន្ថែមពីលើនេះ ដីកាសន្និដ្ឋានស្ពាតររបស់សហព្រះរាជអាជ្ញា មិនចងជាកាតព្វកិច្ច ដល់សហចៅក្រមស៊ើបអង្កេតទេ។

៤៦. សហចៅក្រមស៊ើបអង្កេតនៅតែប្រកាន់ជំហរថា សំណុំរឿងលេខ ០០៣ បានបិទបញ្ចប់ តាមនីតិវិធីត្រឹមត្រូវរួចរាល់ជាស្ថាពរហើយ ខណៈដែលរយៈពេលនៃការតវ៉ាក៏ត្រូវបាន បញ្ចប់ ហើយអង្គបុរេជំនុំជម្រះក៏បានដោះស្រាយបណ្តឹងឧទ្ធរណ៍ទាំងឡាយចប់សព្វគ្រប់ជា ស្ថាពរ ។ ផ្អែកលើស្មារតីនៃទឡ្ហីករណ៍គតិយុត្តទាំងនេះ សហចៅក្រមស៊ើបអង្កេតជាតិមិន បានធ្វើការឆ្លើយតបទៅលើការសុំបំភ្លឺពាក់ព័ន្ធជាមួយស្ថានភាពនៃសំណុំរឿងលេខ ០០៣ ស្នើដោយសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ។ ជាពិសេសនាពេលកន្លងមក សហចៅ ក្រមស៊ើបអង្កេតជាតិ ក៏មិនដែលធ្លាប់បានចូលរួមអះអាងថាសំណុំរឿងលេខ ០០៣ នៅបើក នៅឡើយដែរ។

## ការស៊ើបសួរ និង ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដោយសហចៅក្រមស៊ើបអង្កេត

៤៧. ការស៊ើបសួរជាភារកិច្ចចម្បងរបស់សហចៅក្រមស៊ើបអង្កេត បន្ទាប់ពីទទួលបាននូវដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។ ផ្អែកលើ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចែងយ៉ាងច្បាស់ដោយ បង្គាប់ឱ្យធ្វើការស៊ើបសួរលើគ្រប់អង្គហេតុ ដូចដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។[56] វិធីសាស្ត្រនៃការស៊ើបសួរ ជាឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ហើយវិធីសាស្ត្រ ឬកំណត់ត្រាផ្ទៃក្នុងនៃស៊ើប អង្កេត ជាឯកសារសម្ងាត់ដែលមិនត្រូវទម្លាយដល់ភាគីឡើយ។[57]

៤៨. ជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់អំពីសិទ្ធិ និងប្រយោជន៍របស់ជនត្រូវចោទ ផល ប្រយោជន៍នៃយុត្តិធម៌ និងការពន្លឿននីតិវិធី សហចៅក្រមស៊ើបអង្កេតទាំងពីរ ចៅក្រម យូ ប៊ុនឡេង និង Siegfried BLUNK បានឯកភាពគ្នាលើវិធីសាស្ត្រនៃការស៊ើបអង្កេត



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596015



ដោយពិចារណាលើឯកសារក្នុងសំណុំរឿងលេខ ០០៣ ព្រមទាំងឯកសារទាំងឡាយ ដែលត្រូវបានផ្ទេរពីសំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ ០០២ ចូលមកក្នុងសំណុំរឿងនេះ ។ សហចៅក្រមស៊ើបអង្កេតទាំងពីរ បានពិនិត្យភ័ស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុកទទួលបានពីសាក្សីសំខាន់ៗ និងឯកសារជាភ័ស្តុតាងផ្សេងៗទៀតដែលមានក្នុងសំណុំរឿង ជាអាទិ៍ ។ ម្យ៉ាងទៀតដោយហេតុថា សម្រាប់បរិបទនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានយុត្តាធិការបែបជ្រើសរើស ខណៈដែលកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតបានផ្តោតជាបឋមថា តើជនត្រូវចោទក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ ពិតជាស្ថិតចូលក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរឬទេ ?

៤៩. វិធាន ៥៥ (៤) នៃវិធានផ្ទៃក្នុង បានផ្តល់សិទ្ធិអំណាចដល់សហចៅក្រមស៊ើបអង្កេត ឱ្យដាក់បុគ្គលណាម្នាក់ក្រោមការស៊ើបសួរ ក្នុងករណីមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់បញ្ជាក់ថាជាបុគ្គល ដែលអាចទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ។[58] នៅក្នុងបរិបទរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បុគ្គលដែលរងនូវការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ត្រូវតែជាបុគ្គលដែលពិតជាស្ថិតចូលក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដ៏ពិតប្រាកដ ។ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យអាចត្រូវបានធ្វើភ្លាម ឬបន្ទាប់ពីមានការស៊ើបសួរបន្ថែមដោយសហចៅក្រមស៊ើបអង្កេត ។ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ អាចត្រូវបានធ្វើឡើងទៅលើអង្គហេតុទាំងអស់ ឬអង្គហេតុចំនួនណាមួយជាបឋមសិន។

៥០. តាមយុត្តិសាស្ត្រទាក់ទិននឹងការអនុវត្តច្បាប់ តាមប្រព័ន្ធដែលមានចៅក្រមស៊ើបសួរបានបញ្ញត្តិជាគោលការណ៍គ្រឹះគតិយុត្តដ៏រឹងមាំថា *"ចៅក្រមស៊ើបសួរ មិនអាចបញ្ជូនជនណាម្នាក់ទៅជំនុំជម្រះចំពោះអង្គហេតុដែលមិនត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យជាមុនឡើយ"*។[59] ដើម្បីធានានូវសិទ្ធិការពារខ្លួនរបស់ជនត្រូវចោទ ចំពោះការប្តឹងអង្គហេតុណា



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * JUGES D'INSTRUCTION

ទាក់ទិននឹងខ្លួននៅចំពោះមុខតុលាការ ដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា ក្នុងន័យនេះ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណាច្បាស់លាស់ពីវិធីសាស្ត្ររបស់ខ្លួន លទ្ធផលនៃការស៊ើបអង្កេតជាមុនសិន ថាតើមានការសង្ស័យធ្ងន់ធ្ងរចំពោះអង្គហេតុដែលប្តឹង និងគួរដាក់ ឬមិនដាក់ជនណាមួយឱ្យស្ថិតនៅក្រោមការពិនិត្យ ។ ដោយហេតុថាជនដែលស្ថិតនៅក្រោមការពិនិត្យ នឹងត្រូវទទួលបាននូវសិទ្ធិចម្បងៗបន្ថែមទៀតក្នុងដំណើរការនីតិវិធីតុលាការដូចជា សិទ្ធិចូលមើលសំណុំរឿង សិទ្ធិស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្តាប់ចម្លើយសាក្សី ចុះដល់ទីកន្លែងកើតហេតុ និងបង្គាប់ឱ្យធ្វើកោសល្យវិច័យជាអាទិ៍។[60] លើសពីនេះទៀត ជនដែលស្ថិតនៅក្រោមការពិនិត្យ ក៏មានសេរីភាពបុគ្គលផងដែរ ប្រសិនបើការឃុំខ្លួនរបស់គាត់មិនមែនជាការចាំបាច់ ក្នុងបំណងចូលរួមក្នុងនីតិវិធីនាពេលខាងមុខ ។ ផ្ទុយទៅវិញ វិធានការនៃការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវយកមកអនុវត្ត លុះត្រាណាវិធានការនោះត្រូវបានចាត់ទុកថាជាករណីដ៏ចាំបាច់បំផុត និងមិនអាចចៀសវាងបាន។[61]

៥១. បើទោះបីជាបុគ្គលដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យក្តី ក៏សហចៅក្រមស៊ើបអង្កេត នៅតែអាចសម្រេចលើកលែងការចោទប្រកាន់បាន ទៅលើបុគ្គលនោះចំពោះបទល្មើសណាមួយ ឬទាំងអស់ នៅក្នុងដំណាក់កាលចេញដីកាដំណោះស្រាយ ប្រសិនបើសហចៅក្រមស៊ើបអង្កេតរកឃើញថា មិនមានបទល្មើសត្រូវបានប្រព្រឹត្តដោយជនដែលស្ថិតនៅក្រោមការពិនិត្យ ឬមិនមានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះ ។[62]

៥២. ដើម្បីធានាដល់សិទ្ធិរបស់ជនត្រូវចោទ យុត្តាធិការបុគ្គលពិសេសតាមកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការបំពេញកិច្ចណាមួយ វាតម្រូវឱ្យមានការពិចារណាគ្រប់ជ្រុងជ្រោយ គឺការបំពេញកិច្ចដោយភាពប្រាកដប្រជា វិធាននីតិវិធីបែបណា អង្គហេតុណាខ្លះពាក់ព័ន្ធខ្លាំង ទីតាំងឧក្រិដ្ឋកម្មណាខ្លះ មាន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

វិមតិសង្ស័យកម្រិតណា ការប្រើប្រាស់ធនធានមនុស្ស ធនធានថវិកា ពេលវេលា និងគោលការណ៍វិនិច្ឆ័យឆាប់រហ័សផងដែរ ។ បញ្ហាបានកើតឡើងពាក់ព័ន្ធនឹងការប្រមូលអង្គហេតុឱ្យបានច្រើន តែទីបំផុតទោះបីជាមានការកាត់បន្ថយ ក៏នាំឱ្យខាតបង់ពេលវេលាស៊ើបអង្កេតដែរ ។

៩៣. ដោយសារមានភាពសង្ស័យថាតើ **មាស មុត** ស្ថិត ឬមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទើបសហចៅក្រមស៊ើបអង្កេតទាំងពីររូប បានឯកភាពជាឯកច្ឆន្ទសម្រេចមិនដាក់ **មាស មុត** ឱ្យស្ថិតនៅក្រោមការពិនិត្យនោះទេ។

៩៤. ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងកងទ័ពបដិវត្តកម្ពុជា[63] ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ មានអង្គហេតុចំនួន ១០ (ដប់)[64] ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទពីររូបគឺ **ស៊ូ ម៉េត** និង **មាស មុត** ។ ប៉ុន្តែមានតែអង្គហេតុចំនួន ៨ (ប្រាំបី) ពាក់ព័ន្ធនឹង **មាស មុត** ។ ចំណែកអង្គហេតុទាក់ទងនឹងការបង្ក្រាបក្នុងកងពលលេខ ៨០១ និងមន្ទីរសន្តិសុខ ៨១០ ជាអង្គហេតុទាក់ទងគ្នា ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតជាតិពិចារណាតែអង្គហេតុចំនួន ៧ (ប្រាំពីរ) ក្នុងដីកាដំណោះស្រាយនេះ ។ ក្រោយពីការស៊ើបសួរលើអង្គហេតុទាំងអស់លទ្ធផលបានបង្ហាញដូចខាងក្រោម៖

## ជំពូក ៣. អង្គហេតុ

## ផ្នែកទី ១. ប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជា

៩៥. អត្ថិភាពរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានប្រកាសជាផ្លូវការនាខែ កញ្ញា ឆ្នាំ ១៩៧៦ ខណៈដែលបក្សកុម្មុយនីស្តកម្ពុជានេះ បានកាន់អំណាចបានជាងមួយឆ្នាំមកហើយ ។[65]



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

៥៦. អង្គការចាត់តាំងមួយ ក្នុងចំណោមអង្គការចាត់តាំងកុំម្មុយនីស្តដំបូងនៅក្នុងតំបន់ គឺបក្សកុំម្មុយនីស្តឥណ្ឌូចិនដែលបង្កើតឡើងនៅក្នុងឆ្នាំ ១៩៣០ ដោយមានការទទួលឥទ្ធិពលយ៉ាងខ្លាំងពីជនកុំម្មុយនីស្តវៀតណាម ។ បក្សកុំម្មុយនីស្តឥណ្ឌូចិនត្រូវបានរំលាយជាផ្លូវការនៅក្នុងឆ្នាំ ១៩៥១ ។ នៅក្នុងឆ្នាំដដែលនេះ មានបក្សថ្មីមួយត្រូវបានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជា មានឈ្មោះថា "បក្សប្រជាជនបដិវត្តន៍ខ្មែរ" ដែលមានឥទ្ធិពលយ៉ាងខ្លាំងនៅក្នុងបណ្តាក្រុមខ្មែរឥស្សរៈ ដែលជាចលនាទាមទារយកឯករាជ្យពីអាណានិគមនិយមបារាំង ។[66]

៥៧. តាមរយៈសមាជបក្សនាថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ១៩៦០ បក្សប្រជាជនបដិវត្តន៍ខ្មែរត្រូវបានប្តូរឈ្មោះទៅជា "បក្សពលករខ្មែរ"[67] ដែលនេះគឺជាចំណុចចាប់ផ្តើមពិតប្រាកដនៃការបង្កើតចលនាកុំម្មុយនីស្តខ្មែរ[68] ដោយមានមនុស្សចំនួនប្រមាណ ២០ (ម្ភៃ) នាក់ បានចូលរួមក្នុងសមាជនេះ ។ សមាសភាពដែលបានចូលរួម ជាមនុស្សសំខាន់ៗ ដូចជា៖ ទូ សាមុត ជាលេខាបក្ស , នួន ជា ជាអនុលេខាបក្ស , សាឡុត ស ហៅ ប៉ុល ពត , អៀង សារី , សោ ភឹម និង វន វ៉េត[69] ជាអាទិ៍ ។ តាមរយៈការផ្សព្វផ្សាយរបស់ទស្សនាវដ្តីទង់បដិវត្តន៍ ជាទស្សនាវដ្តីមួយក្នុងចំណោមទស្សនាវដ្តីផ្លូវការរបស់បក្សកុំម្មុយនីស្តកម្ពុជា ដែលបានចេញផ្សាយនាខែ សីហា ឆ្នាំ ១៩៧៥ បានលើកឡើងថា *"មាគ៌ាជាយុទ្ធសាស្ត្រ និង ជាយុទ្ធវិធីរបស់បក្សកុំម្មុយនីស្តកម្ពុជា បានធ្វើឡើងច្បាស់លាស់ និងត្រឹមត្រូវជាមូលដ្ឋាននៅឆ្នាំ ១៩៦០ ក្នុងមហាសន្និបាតបក្សលើកទី I (ពិតមែនតែបក្សយើងកកើតតាំង ពីឆ្នាំ ១៩៥១ ម្លេះ)"* ។[70] នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ គណៈមជ្ឈិមបានសម្រេចថា *"កំណត់កំណើតបក្សពីឆ្នាំ ១៩៦០ វិញ មិនយកឆ្នាំ ១៩៥១ ទេ ដើម្បីកុំឱ្យជាប់ជាមួយគេឯងឱ្យដាច់ស្រឡះ"* ។[71]

៥៨. នាដើមទស្សវត្សរ៍ឆ្នាំ ១៩៦០ បក្សពលករខ្មែរ បានបង្កើតកងការពារសម្ងាត់របស់បក្ស[72] ដើម្បីការពារកម្មាភិបាល និងសកម្មភាពនយោបាយរបស់ខ្លួន រួមទាំងដើម្បី "កម្ទេចខ្មាំង" ។ ឌុច បានបញ្ជាក់ថា គោលនយោបាយនេះបានអនុម័តនៅក្នុងពេលមហាសន្និបាតលើកទីមួយ ដើម្បីអូសទាញកម្លាំងដែលស្ទាក់ស្ទើរ អព្យាក្រឹត្យ កម្លាំងមិនឃោរឃៅ ឯកោ ហើយកម្ទេចកម្លាំងដែលសេសសល់ ។[73]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥៩. បន្ទាប់ពីការបាត់ខ្លួនលេខាបក្សពលករខ្មែរឈ្មោះ ទូ សាមុត នៅឆ្នាំ ១៩៦២ សមាជលើកទីពីរ របស់បក្សត្រូវបានធ្វើឡើងនៅចុងខែ កុម្ភៈ ឆ្នាំ ១៩៦៣ ហើយអង្គសមាជបានសម្រេចឱ្យ សាឡុត ស ហៅ ប៉ុល ពត ឡើងជាលេខាបក្សថ្មី ចំណែក នួន ជា នៅបន្តធ្វើជាអនុលេខាបក្សដដែល ។[74] សមាជនេះ ត្រូវបានធ្វើឡើងនៅទីក្រុងភ្នំពេញ ដោយមានកម្រិតចំនួនអ្នកចូលរួមត្រឹមមនុស្សសំខាន់ៗ ដូចជា អៀង សារី , សោ ភឹម, តា ម៉ុក, វន វេត, សុន សេន, រស់ ញឹម និង គង់ សុផល ជាអាទិ៍។[75]

៦០. ប៉ុន្មានខែក្រោយមក បន្ទាប់ពីរាជរដ្ឋាភិបាលបានចេញផ្សាយនូវបញ្ជីឈ្មោះមនុស្ស ដែលគេស្គាល់ថាជា "អ្នកឆ្វេងនិយម" ចំនួន ៣៤ (សាមសិបបួន) រូប[76] សាឡុត ស ហៅ ប៉ុល ពត និងមេដឹកនាំបក្សពលករខ្មែរមួយចំនួនដែលមានឈ្មោះក្នុងបញ្ជីនោះ រួមទាំង អៀង សារី សុន សេន និងអ្នកផ្សេងមួយចំនួនទៀតបានភៀសខ្លួនចេញពីទីក្រុងភ្នំពេញដើម្បីសុវត្ថិភាព ។ អ្នកទាំងនោះបានគេចខ្លួន ដោយបានទៅជ្រកកោននៅជំរុំនៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម ដែលនៅទីនោះពួកគេបានបង្កើតមន្ទីរមួយមានឈ្មោះថា "មន្ទីរ ១០០" ។[77] មកដល់ឆ្នាំ ១៩៦៥ ប្រពន្ធរបស់បណ្តាថ្នាក់ដឹកនាំជាន់ខ្ពស់ទាំងនោះ មានដូចជា អ្នកស្រី ខៀវ ប៉ុណ្ណារី , អ្នកស្រី អៀង ធីរិទ្ធ និងអ្នកស្រី យុន យ៉ាត ក៏បានមកចូលរួមជាមួយនៅមន្ទីរ ១០០ ។[78] ដោយសារអត្តសញ្ញាណរបស់ នួន ជា មិនត្រូវបានគេស្គាល់ ហើយឈ្មោះរបស់គាត់ពុំស្ថិតនៅក្នុងបញ្ជីឈ្មោះមនុស្សទាំង ៣៤ (សាមសិបបួន) នាក់ នោះ គាត់បានបន្តស្នាក់នៅភ្នំពេញ និងទទួលបន្ទុករាល់ប្រតិបត្តិការនានារបស់បក្សពលករខ្មែរក្នុងទីក្រុងភ្នំពេញ និងតំបន់ជាច្រើន ។ [79]

៦១. នៅខែ មករា ឆ្នាំ ១៩៦៥ បក្សពលករខ្មែរ បានអនុម័តសេចក្តីសម្រេចមួយដែលបានទាត់ចោលនូវលទ្ធភាពនៃការផ្លាស់ប្តូរដោយសន្តិវិធីទៅកាន់លទ្ធិសង្គមនិយម និងបានបញ្ជាក់អះអាងថា ជាការចាំបាច់ដែលត្រូវប្រើប្រាស់ " *ហិង្សាបដិវត្តន៍* " ក្នុងការតស៊ូប្រឆាំងនឹងពួកចក្រពត្តិ ។[80] ក្នុងអង្គប្រជុំគណៈមជ្ឈិមកាលពី ខែ កញ្ញា ឬ ខែ តុលា ឆ្នាំ ១៩៦៦ មេដឹកនាំ



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បក្សពលករខ្មែរបានសម្រេចប្តូរឈ្មោះបក្សទៅជា "បក្សកុំម្មុយនីស្តកម្ពុជា" និងបានផ្លាស់ប្តូរទីតាំងរបស់មន្ទីរ ១០០ ទៅកាន់ខេត្តរតនគិរី [81] ។ ក្នុងពេលជាមួយគ្នានោះ ក៏មានការចាប់ផ្តើមរៀបចំការតស៊ូប្រដាប់អាវុធនៅតាមតំបន់នីមួយៗ[82] ហើយមន្ទីរ ១០០ នេះ មានទីតាំងស្ថិតនៅចម្ងាយប្រហែលប៉ុន្មានគីឡូម៉ែត្រពី "មន្ទីរ ១០២" ជាមន្ទីរភូមិភាគឦសាន ដែលត្រូវបានប្រើប្រាស់ដោយ អៀង សារី (គាត់ត្រូវបានតែងតាំងជាលេខាភូមិភាគឦសាន) ។ [83]

៦២. នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៦៨ តាមបញ្ជារបស់ នួន ជា កងកម្លាំងរបស់បក្សកុំម្មុយនីស្តកម្ពុជា បានវាយប្រហារបន្ទាយកងទ័ពរបស់រាជរដ្ឋាភិបាលនៅ ភូមិបាយដំរាំ ក្នុងខេត្តបាត់ដំបង ដោយរឹបអូសបានអាវុធមួយចំនួន ។[84] បន្ទាប់មកកាលបរិច្ឆេទខាងលើនេះ ត្រូវបានបក្សកុំម្មុយនីស្តកម្ពុជា ចាត់ទុកថាថ្ងៃកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា ។[85] នៅប៉ុន្មានខែបន្ទាប់ កងកម្លាំងរបស់បក្សកុំម្មុយនីស្តកម្ពុជា បានធ្វើការវាយប្រហាររបស់ខ្លួនជាបន្តបន្ទាប់នៅទូទាំងប្រទេស ។[86]

៦៣. នៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ សម្តេច នរោត្តមសីហនុ ត្រូវបានឧត្តមសេនីយ៍ លន់ នល់ និងព្រះអង្គម្ចាស់សិរីមតៈទម្លាក់ពីតំណែង ហើយពួកគេបានបង្កើតរបបមួយមានឈ្មោះជាផ្លូវការថារបប "សាធារណរដ្ឋខ្មែរ" ។[87] នៅថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៧០ សម្តេច នរោត្តមសីហនុ ទ្រង់បានប្រកាសអំពីការបង្កើត "រណសិរ្សរួបរួមជាតិកម្ពុជា" (FUNK) និងបានអំពាវនាវឲ្យអ្នកស្នេហាជាតិ ធ្វើការបះបោរប្រឆាំងនឹងរដ្ឋាភិបាលរបស់លោក លន់ នល់ ។[88] បន្ទាប់មកសម្តេច នរោត្តមសីហនុ និងបក្សកុំម្មុយនីស្តកម្ពុជា បានបង្កើតសម្ព័ន្ធភាពជាមួយគ្នា និងរាជរដ្ឋាភិបាលនិរទេសមួយ ដែលមានមូលដ្ឋាននៅទីក្រុងប៉េកាំង មានឈ្មោះថា "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា" (GRUNK) ។ រាជរដ្ឋាភិបាលនេះត្រូវបានប្រកាសជា ផ្លូវការនៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៧០ ។ សម្តេច នរោត្តមសីហនុ អតីតប្រធាន "រណសិរ្សរួបរួមជាតិកម្ពុជា" ក្លាយជាប្រមុខរដ្ឋ ។[89] លោក ប៉ែន នុត ជានាយករដ្ឋមន្ត្រីនៃ "រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា" រីឯលោក ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ។ [90]



ECCC * CETC * CO-INVESTIGATING JUDGES

៦៤. នៅខែ មករា ឆ្នាំ ១៩៧១ គណៈមជ្ឈិមនៃបក្សកុំម្មុយនីស្តកម្ពុជាបានជួបប្រជុំគ្នាជាលើកទីមួយ ចាប់តាំងពីខែ តុលា ឆ្នាំ ១៩៦៦ ដោយមានរយៈពេល ៣ (បី) ថ្ងៃ នៅមន្ទីរ ស-៧១ ក្នុងនោះមានសមាជិកចូលរួមចំនួន ២៧ (ម្ភៃប្រាំពីរ) រូប មានដូចជា ប៉ុល ពត, នួន ជា, សោ ភឹម, វន វេត, តា ម៉ុក, រស់ ញឹម, គង់ សុផល ហៅ កឺ, ជូ ជេត ហៅ ស៊ី, កង ចាប ហៅ សែ , កុយ ធួន ហៅ ធុច , កែ ពក, សឿ វ៉ាស៊ី ហៅ ឌឿន និង ឈឹម សំអោក ហៅ ប៉ង់ ។[91]

៦៥. តាមរយៈវគ្គរៀនសូត្រដែលដឹកនាំដោយ ប៉ុល ពត នាឆ្នាំ ១៩៧១ នៅឯទីស្នាក់ការក្នុងភូមិភាគឧត្តរ កម្មាភិបាលភូមិភាគ តំបន់ និងស្រុក ចំនួនប្រមាណ ២០០ (ពីររយ) នាក់ ចូលរួម ត្រូវបានជ្រើសរើស និងត្រូវបាននាំចេញទៅប៉ុន្មានគីឡូម៉ែត្រពីទីនោះ ឆ្ពោះទៅកាន់ជំរំមួយនៅក្នុងព្រៃដែលជាកន្លែងប្រារព្ធសមាជបក្សលើកទីបី ។[92] សមាជលើកនេះមានប្រតិភូចូលរួមប្រហែល ៦០ (ហុកសិប) នាក់ ក្នុងនោះរួមមាន ខៀវ សំផន, លេខាភូមិភាគ និងលេខាតំបន់ទាំងអស់, បញ្ជាការយោធា ដូចជា កែ ពក និង គង់ សុផល ជាដើម រួមទាំងអ្នកតំណាងបញ្ញវន្តដូចជា ហ៊ូ យន់ ហ៊ូ នឹម ជាអាទិ៍ ។[93] សមាជនេះបានអនុម័តនូវលក្ខន្តិកៈបក្ស ដោយទទួលយកជាផ្លូវការនូវឈ្មោះ "បក្សកុំម្មុយនីស្តកម្ពុជា" ដែលត្រូវបានប្រើប្រាស់អស់រយៈពេល ៥ (ប្រាំ) ឆ្នាំ រួចមកហើយ និងបានបោះឆ្នោតតែងតាំងគណៈមជ្ឈិមថ្មី ដែលមាន ខៀវ សំផន ជាសមាជិកនៃគណៈមជ្ឈិម ។[94]

៦៦. នៅខែ ឧសភា ឆ្នាំ ១៩៧២ គណៈមជ្ឈិមថ្មីបានជួបប្រជុំគ្នា ។ នៅក្នុងឱកាសនេះដែរ គណៈមជ្ឈិមថ្មីបានចេញសេចក្តីណែនាំទៅកាន់សមាជិកបក្សរបស់ខ្លួន ឲ្យខំពង្រឹងការតស៊ូប្រឆាំងនឹង"វណ្ណៈជិះជាន់ផ្សេងៗ" និងបានឯកភាពលើផែនការសមូហភាវូបនីយកម្មវិស័យកសិកម្ម ។[95] បក្សកុំម្មុយនីស្តកម្ពុជាបានបង្កើតឡើងជាផ្លូវការនូវសហករណ៍ នៅតាមបណ្តាតំបន់នានាដែលពួកគេបានចូលកាន់កាប់មួយឆ្នាំក្រោយមក ពោលគឺនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៣ ។[96]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

៦៧. នៅព្រឹកថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងកម្លាំងបក្សកុំម្មុយនីស្តកម្ពុជា បានសម្រុកចូលមកដល់ទីក្រុងភ្នំពេញ ។[97]

## គោលនយោបាយទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ

៦៨. របបកម្ពុជាប្រជាធិបតេយ្យបានដឹកនាំប្រទេសចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[98] ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ មានគោលដៅកសាងសង្គមកម្ពុជាទាំងមូលទៅជាប្រទេសដើរតាមមាគ៌ាសង្គមនិយមពិតប្រាកដក្នុងលោក ។[99] ដើម្បីសម្រេចគោលដៅនេះមានការដាក់ចេញនូវនយោបាយនៃការបណ្តេញប្រជាជនចេញពីទីក្រុង និងប្រជុំជន ឱ្យទៅរស់នៅតាមទីជនបទ[100] ដើម្បីចូលរួមធ្វើមហាកសិកម្ម[101] ដែលជាវិស័យដ៏សំខាន់បំផុតក្នុងការជួយជម្រុញសេដ្ឋកិច្ចឱ្យរីកចម្រើនជាអតិបរមាក្រោមការដឹកនាំ និងណែនាំពីបក្ស[102] តាមគោលជំហរ "ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន" ។[103] ម្យ៉ាងវិញទៀត នៅមានគោលបំណងដាក់វណ្ណៈជាន់ទាបជាអាទិ៍ ដែលជាវណ្ណៈកសិករក្រីក្រ ឱ្យធ្វើការត្រួតត្រានៅតាមថ្នាក់មូលដ្ឋានដោយរាប់ចាប់ពីថ្នាក់ភូមិ ។[104]

សៀវភៅក្រោមចំណងជើងថា "ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" ដែលចេញផ្សាយដោយក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យ នាឆ្នាំ ១៩៧៧ បង្ហាញថា កម្ពុជាប្រជាធិបតេយ្យមានប្រជាជនសរុបចំនួន ៧.៣០៨.000 (ប្រាំពីរលានបីសែនប្រាំបីពាន់) នាក់ ក្នុងឆ្នាំ ១៩៧៥ ដោយក្នុងនោះមានប្រមាណ ៨0 (ប៉ែតសិប) ភាគរយ ជាកសិករ នៅតាមសហករណ៍ និង ២0 (ម្ភៃ) ភាគរយ ជាកម្មករ សហជីព និងជាយុទ្ធជន យុទ្ធនារី នៃកងទ័ពបដិវត្តន៍កម្ពុជា ។[105]

៦៩. ហេតុផលខាងលើនេះបានបង្កឱ្យមានកំហឹងវណ្ណៈ[106] កើតឡើងយ៉ាងសន្ធោសន្ធៅជាប់ជានិច្ចចំពោះវណ្ណៈសក្តិភូមិ[107] វណ្ណៈនាយទុន ដែលជាវណ្ណៈធ្លាប់កាន់អំណាចជិះជាន់ប្រជាជនជាង



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D' INSTRUCTION"

២.០០០ (ពីរពាន់) ឆ្នាំ ហើយថែមទាំងរងនូវការចោទប្រកាន់ថា នាពេលកន្លងមកបានលក់ប្រទេសឱ្យចក្រពត្តិនិយមបរទេសជាបន្តបន្ទាប់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន និងបក្សពួកយ៉ាងថោកទាបជាទីបំផុត ។[108] ការណ៍នេះបានធ្វើឱ្យក្រុមវណ្ណៈជាន់ទាបនេះ ចង់ក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមកាច់ចង្កូតជោគវាសនាកម្ពុជាទាំងមូល ។[109]

៧០. រចនាសម្ព័ន្ធរដ្ឋបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្នាក់លើ ថ្នាក់ក្រោម និងថ្នាក់មូលដ្ឋានត្រូវបានបែងចែងយ៉ាងជាក់លាក់ លើការសម្រេចចាត់ចែង និងការគ្រប់គ្រងការងារដែលមានលក្ខណៈជា "**សមូហភាព**" ។[110] ក្រោមហេតុផលថា ទាល់តែកសាងប្រទេសដោយឈរលើសមូហភាព ទើបអាចកសាងប្រទេសបានឆាប់រហ័ស ។[111] ម្យ៉ាងវិញទៀត គោលនយោបាយត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈការប្រជុំនូវកម្រិត ភូមិភាគ តំបន់ ស្រុក ភូមិ ឃុំ និងសហករណ៍ ហើយត្រូវបានបញ្ជូនពីថ្នាក់លើទៅថ្នាក់ក្រោមតាមឋានានុក្រមនៃការដឹកនាំ ។[112]

៧១. ការដឹកនាំតាមបែបកុំម្មុយនីស្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានយកបក្សជាអ្នកមានអំណាចខ្ពស់បំផុត តាមរយៈស្ថាប័នដ៏មានឥទ្ធិពលបំផុត ដែលត្រូវបានគេស្គាល់ឈ្មោះថា "**គណៈកម្មាធិការមជ្ឈិមបក្ស**" ។ គណៈកម្មាធិការនេះមានសមាជិកប្រមាណ ៣០ (សាមសិប) រូប ត្រូវធ្វើការសម្រេចលើការងារចម្បងសំខាន់ៗពាក់ព័ន្ធនឹងជោគវាសនាប្រទេសជាតិ ។[113] ខណៈគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុំម្មុយនីស្តកម្ពុជា មានសមាជិកចំនួន ៧ (ប្រាំពីរ) រូបមាន ប៉ុល ពត , នួន ជា , សោ ភឹម , តា ម៉ុក , អៀង សារី , វន វ៉េត និង សុន សេន។[114]ជាក់ស្តែងអំណាចលើការសម្រេចស្ថិតនៅលើគណៈកម្មាធិការអចិន្ត្រៃយ៍[115] បើទោះបីជាមានការលើកឡើងដោយអតីតប្រធានគណៈប្រធានរដ្ឋ[116] ខៀវ សំផន ហៅ ហែម ដែលបានលើកឡើងថា ជាគោលការណ៍អង្គការដែលសំខាន់ជាងគេ គឺជា "គណៈ កម្មាធិការមជ្ឈិម"[117] ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

៧២. នៅមុនឆ្នាំ ១៩៧៥ បក្សបានតម្រូវប្រជាជនរស់នៅជាសហករណ៍ក្នុងតំបន់រំដោះ ដោយឲ្យរស់នៅរួម ធ្វើស្រែរួម ប្រមូលផលរួម រោងបាយរួម ធ្វើការរួម ហើយបក្សជាអ្នកគ្រប់គ្រង និងប្រមូលភោគផលដែលទទួលបាន ។[118] លើសពីនេះ បក្សនៅបានគ្រប់គ្រងរាល់សកម្មភាពការងារ ការរស់នៅរបស់ប្រជាជនរាប់តាំងពីការស្លៀកពាក់ របៀបនៃការប្រាស្រ័យទាក់ទង ទ្រព្យសម្បត្តិ ពេលវេលា ជំនឿ អាហារ សេរីភាព និង ការធ្វើដំណើររបស់ប្រជាជនជាអាទិ៍ ។[119]

៧៣. លោក ម៉ាត់ លី បានលើកឡើងថា សហករណ៍ត្រូវបានបង្កើតដំបូងនៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៧៣ ហើយប្រជាជនពេញចិត្តណាស់ ។[120] ប៉ុន្តែ ជាក់ស្តែងបក្សបានសម្រេចចាត់តាំងជាសហករណ៍កសិករនៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៣ ។[121] ចំពោះការរៀបចំជាសហករណ៍នេះ កសិករដែលគ្មានដីធ្លីមានការពេញចិត្តជាខ្លាំងមែន ផ្ទុយទៅវិញ កសិករដែលមានដីធ្លីច្រើនហាក់ដូចជាមិនសូវពេញចិត្ត ហើយអារម្មណ៍នឿយណាយជាមួយនឹងភាពជាសមូហភាពនេះ ។[122]

៧៤. ក្រោយពីរំដោះបានតាមមូលដ្ឋានមួយចំនួនភ្លាមៗ ភូមិខ្លះត្រូវបានរួមបញ្ចូលគ្នាទៅជា "សហករណ៍"[123] មានលក្ខណៈជាសមូហភាពទាំងលើការហូបចុក[124] និងការរស់នៅក្រោមហេតុផលថា ភាពជាសមូហភាពជាទស្សនទានមនុស្សធម៌ ដោយមនុស្សគ្រប់រូបគួរតែទទួលបានបរិមាណម្ហូបអាហារដូចគ្នាៗ ។[125] ខណៈសហករណ៍ត្រូវគេចាត់ទុកថាជាមូលដ្ឋានបង្អែកបដិវត្តន៍ដ៏រឹងមាំនៅទូទាំងប្រទេស។[126] ក្រោមការដឹកនាំនេះប្រជាជនទទួលបានរបបអាហារ ២ (ពីរ) ពេល ក្នុងមួយថ្ងៃគឺ បបរមួយពេល និងបាយមួយពេល ។[127]

៧៥. មិនតែប៉ុណ្ណោះនាពេលក្រោយមកបក្សបានកំណត់ទិសដៅបង្កើនទិន្នផល ដោយបក្សដែលជាអង្គការថ្នាក់លើបានបង្ខំឲ្យប្រជាជនធ្វើស្រូវឲ្យបាន បីតោនក្នុងមួយហិចតា[128] លើដីស្រែទំហំ ១.៥00.000 (មួយលានប្រាំសែន)ហិចតា អង្គការរំពឹងថានឹងទទួលបានស្រូវរហូតដល់ ៤.៥00.000 (បួនលានប្រាំសែន) តោន ដែលនេះជាភារកិច្ចស្នូលមួយនៅក្នុងឆ្នាំ



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១៩៧៦ ។[129] សាក្សីជាអតីតអ្នកវាយអង្គុលីលេខបានអះអាងថា *"ឯកសារភាគច្រើននិយាយពីការធ្វើស្រែឱ្យបានបីតោនក្នុងមួយហិចតា"* ។[130] ចំពោះទិន្នផលដែលប្រមូលបានភាគច្រើនបំផុតត្រូវតែប្រគល់ជូនបក្សជាដាច់ខាត សម្រាប់ធ្វើការនាំចេញក្រៅប្រទេស ។[131] ប្រធានសហករណ៍មួយចំនួនតាមមូលដ្ឋានបានបំប៉ោងតួលេខទិន្នផលដែលទទួលបាន ដើម្បីធ្វើឱ្យបក្សមើលទៅឃើញថា ខិតខំប្រឹងប្រែងដើម្បីបក្ស និងជាមនុស្សស្មោះត្រង់នឹងបក្ស ដោយបានបញ្ជូនផលស្រូវឱ្យថ្នាក់លើយ៉ាងច្រើន ខណៈប្រជាជននៅមូលដ្ឋានរបស់ខ្លួន ខ្វះខាតស្រូវអង្ករទុកបរិភោគ ។[132]

៧៦. ម្យ៉ាងវិញទៀត នៅមានករណីប្រធានសហករណ៍ខ្លះ បានរាយការណ៍ភូតកុហកអង្គការថ្នាក់លើ ដើម្បីទុកស្រូវសម្រាប់ប្រជាជនមូលដ្ឋាន ។ ជាក់ស្តែង ទង្វើនេះបក្សនឹងធ្វើការចាប់ខ្លួនកម្មាភិបាលនោះយកទៅសម្លាប់ ប្រសិនដឹងនូវទង្វើភូតកុហកនេះ ។ លើសពីនេះទៅទៀត ប្រជាជនទទួលរងនូវអំពើអមនុស្សធម៌ផ្សេងៗ ដូចទាសករ [133] ព្រមទាំងប្រឈមមុខនឹងផលវិបាកផ្សេងៗដូចជា ប្រជាជនបានស្លាប់អស់ជាច្រើននាក់ ដោយសារការអត់អាហារ និងជំងឺផ្លូវដង្ហើម ។

៧៧. កម្ពុជាប្រជាធិបតេយ្យ មានទម្រង់ដឹកនាំខុសប្លែកពីរបបដទៃទៀតក្នុងសកលលោក ។[134] សូម្បីតែ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនិយាយដែរថា "បដិវត្តន៍ខ្មែរគ្មានប្រើគំរូណាមួយពីមុនឡើយ ហើយអ្វីដែលយើងកំពុងសម្រេចទាំងនេះ មិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពីមុនទៅឡើយទេ" ។[135] បើនិយាយពីគោលជំហរគឺ កម្ពុជាប្រជាធិបតេយ្យមានលក្ខណៈដាច់ខាតបំផុត[136] ហើយប្រជាជនត្រូវបង្ខំឱ្យធ្វើការងារតាមមូលដ្ឋាន ក្នុងស្ថានភាពលំបាកក្រៃលែង[137] គ្មានពេលសម្រាកគ្រប់គ្រាន់ ។ បន្ថែមពីលើនេះ នាពេលនោះប្រជាជន គ្មានសិទ្ធិសេរីភាព[138] គ្មានសិទ្ធិទទួលបានព័ត៌មាន[139] គ្មានសិទ្ធិធ្វើដំណើរ[140] គ្មានទីផ្សារ[141] គ្មានកម្មសិទ្ធិឯកជន[142] គ្មានមន្ទីរពេទ្យ គ្មានមណ្ឌលសុខភាព និងគ្មានថ្នាំព្យាបាលជំងឺឱ្យបានគ្រប់គ្រាន់[143] ជាអាទិ៍ ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៧៨. សេដ្ឋកិច្ចជាតិទាំងមូលវិញ ត្រូវប្រឈមមុខនឹងការដាំក្បាលចុះដោយហេតុថា ប្រទេសមួយនេះត្រូវបានដឹកនាំដោយអង្គការ គ្មានការចរាចរណ៍រូបិយវត្ថុជាតិទាំងស្រុង[144] នៅក្រោមលេសថា ការចាយលុយនាំឱ្យមានការជិះជាន់ ហើយថែមទាំងអាចបង្កើតឱ្យមានអំពើពុករលួយជាដើម ដែលជាប្រភពស្នូលបញ្ហាដ៏សំខាន់បំផុត ក្នុងការបង្កឱ្យរបបនេះអាចប្រឈមមុខនឹងអស្ថិរភាពក្នុងការគ្រប់គ្រង និងដឹកនាំប្រទេស ។[145] ខណៈដែលការមានរូបិយវត្ថុនេះត្រូវអ្នកសេដ្ឋកិច្ចវិទូចាត់ទុកថាជាមូលដ្ឋានគ្រឹះចម្បង និងតែមួយគត់សម្រាប់ដំណើរការសេដ្ឋកិច្ចរបស់ប្រទេសជាតិមួយ ។

៧៩. ពាក់ព័ន្ធបញ្ហាជំនឿសាសនា កម្ពុជាប្រជាធិបតេយ្យបានចាប់បង្ខំឱ្យព្រះសង្ឃផ្សឹក[146] បើមិនព្រមនឹងសម្លាប់ចោល[147] រីឯវត្តអារាមត្រូវរងនូវការបំផ្លិចបំផ្លាញ[148] យ៉ាងគំហុក។[149] ជាក់ស្តែង ប៉ុល ពត បានអនុវត្តលទ្ធិម៉ាកដាច់ខាតទៅលើសាសនាទាំងអស់នៅកម្ពុជា។[150] សាក្សីជាច្រើនរូបអះអាងថា គ្រប់សាសនាទាំងអស់ត្រូវហាមឃាត់ ខណៈដែលវត្តអារាមក៏ត្រូវបានប្រែក្លាយជាឃ្លាំង កន្លែងរោងបាយ និងកន្លែងចិញ្ចឹមសត្វ ។[151] សាក្សីម្នាក់បាននិយាយថា *"ពេលនោះគ្រប់សាសនាទាំងអស់ត្រូវបានបំបាត់ចោលគឺ មានតែបក្សកុំម្មុយនីស្តកម្ពុជាមួយទេដែលត្រូវគោរព ។ បក្សកុំម្មុយនីស្តស្អប់ព្រះសង្ឃ ....ជាងគេ"* ។[152]

៨០. របបកម្ពុជាប្រជាធិបតេយ្យមានការបែងចែកមនុស្សតាមវ័យ តាមភេទ តាមប្រភេទការងារជាក្រុមៗ ហើយតម្រូវឱ្យប្រជាជនរស់នៅ និងធ្វើការងារកន្លែងផ្សេងពីគ្នា ។[153] ចំពោះប្រជាជនមានវ័យចំណាស់មួយចំនួនតូច មិនត្រូវបានអង្គការឱ្យនៅទំនេរទេ ដោយតម្រូវឱ្យជួយមើលថែក្មេងតូចៗ ខណៈឪពុកម្តាយពួកគេត្រូវទៅធ្វើការងារនៅតាមការដ្ឋាន ។[154] រីឯមនុស្សពេញវ័យតម្រូវឱ្យចូលរួមធ្វើកសិកម្មតាមសហករណ៍មានដូចជា ធ្វើស្រែ[155] ធ្វើចំការ ដាំដំណាំ និងដាំបន្លែ ហើយខ្លះទៀតឱ្យជីកប្រឡាយ[156] លើកទំនប់[157] ជាដើម។ ជាពិសេសពាក់ព័ន្ធការជម្រុញឱ្យលើកជាអាងទឹក មានការលើកឡើងដោយបក្សកុំម្មុយនីស្តកម្ពុជាថា "យើងមើលការប្រែប្រួលតែ ២ (ពីរ) ឆ្នាំនេះគឺលឿនណាស់ប្រៀបធៀប និង ១០០



*E.C.C.C* C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

(មួយរយ) ឆ្នាំមុន ១០០ (មួយរយ) ឆ្នាំមុនគ្មានអាងទឹកដូច្នេះឯណាទេ" ។[158] កុមារៗក៏ត្រូវគេបង្ខំឱ្យធ្វើការងារឃ្វាលគោក្របី[159] និងប្រមូលអាចម៍គោសម្រាប់ធ្វើជីកសិកម្ម [160] ។

៨១. ជាទូទៅ ប្រជាជនពុំមានសិទ្ធិក្នុងការដើរហើរមកលេងក្រុមគ្រួសារសាច់ញាតិទេ ឬធ្វើដំណើរទេប្រសិនបើគ្មានការអនុញ្ញាតពីអង្គការ ។[161] អវត្តមានពីកន្លែងរស់នៅ ឬកន្លែងការដ្ឋានធ្វើការជាការល្មើសនឹងវិន័យប្រឆាំងអង្គការ ។ ជាក់ស្តែងសមាជិកនីមួយៗតាមគ្រួសារមានពេលវេលាតិចតួចបំផុតដើម្បីបានជួបជុំគ្នា[162] ទោះបីក្នុងគ្រួសារ ឬពេលធ្វើការតាមការដ្ឋាន ។ ការនិយាយស្តីក៏ត្រូវបានអង្គការដាក់កម្រិតជាខ្លាំងផងដែរ ។ ប្រជាជនមានការភិតភ័យពាក់ព័ន្ធបញ្ហានេះជានិច្ច ដោយសារតែការនិយាយអាចនាំឱ្យមានការយកទៅអប់រំ ការចាប់ខ្លួន ឬយកទៅសម្លាប់ ក្នុងករណីមានការរិះគន់ ឬ/និង រអ៊ូរទាំទាក់ទិននឹងបញ្ហាការងារលំបាក ឬការផ្តល់អាហារឱ្យបរិភោគពុំគ្រប់គ្រាន់ ។[163] អតីតលេខាស្រុកកំពង់សៀមឈ្មោះ ប្រាក់ យុត បាននិយាយថា "*កាលពីគម្រោងធ្វើទំនប់នៅនិរតី ប្រជាជនមិនអាចប្រកែកនឹងបញ្ហាបានទេ បើប្រកែកនឹងយកទៅអប់រំណែនាំ*" ។[164]

៨២. ដើម្បីសម្រេចតាមទិសដៅរបស់របបនេះ ក្នុងការកសាងប្រទេសនាពេលអនាគតឱ្យខ្លាំងក្លា និងឈានទៅរកការដឹកនាំតាមបែបសង្គមនិយម ដែលសម្បូរសប្បាយធំធ្វើង រុងរឿងយ៉ាងឆាប់រហ័សក្រោមពាក្យស្លោកថា "មហាលោតផ្លោះមហាអស្ចារ្យ"[165] នោះ របបកម្ពុជាប្រជាធិបតេយ្យបានអនុវត្ត និងប្រកាន់យកគោលនយោបាយចម្បងៗដូចជា ការសម្រេចឱ្យមានការជម្លៀសប្រជាជន ការប្រព្រឹត្តលើក្រុមមនុស្ស ពិសេសការដ្ឋានការងារដោយបង្ខំ ការបង្ខំឱ្យរៀបការ និងការបោសសម្អាតខ្មាំងផ្ទៃក្នុង និងក្រៅបក្ស ជាអាទិ៍ ។ រហូតដល់ពាក្យថា "ខ្មាំង" ពេលខ្លះសំដៅតែលើអ្នកដែលគ្រាន់តែធ្វើឱ្យបាក់នង្គ័ល[166] បាក់ចប[167] ខូចបង្គី[168] បាក់ស្លាបព្រា[169] បែកចានឆ្នាំង[170] ស្ទូងស្រូវច្រឡំពូជ[171] លួចអាហារ[172] លួចហូបបន្លែ ផ្លែឈើ ដូចជាពោត ចេក ឬដំឡូងដែលដាំដោយខ្លួនឯង[173] បើកឡានជាន់ប្រហ្វាំងអូសកង់វែង[174] ទៅធ្វើការយឺតមិនទាន់ពេល[175] រិះគន់អង្គការ[176] ឬ ក្រោមហេតុផលថាអ្នកទាំងនោះជាអ្នកចង់បំផ្លិចបំផ្លាញបក្សកុំមុយនីស្តកម្ពុជា ។[177]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596028



៨៣. មុនឆ្នាំ ១៩៧៥ បក្សធ្វើការជម្លៀសប្រជាជនចេញពីតំបន់ក្រោមការត្រួតត្រារបស់ខ្លួន ។[178] នៅខែកុម្ភៈ ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្ស បានប្រជុំសម្រេចផែនការជម្លៀស ជាការត្រៀមទុកជាមុន ក្រោយពេលទទួលបានជ័យជម្នះ ។[179] នាពេលនោះមេដឹកនាំជាន់ខ្ពស់មាន ប៉ុល ពត , នួន ជា , អៀង សារី , និង ខៀវ សំផន ក៏បានចូលរួមកិច្ចប្រជុំ[180] ដោយបានសម្រេចធ្វើការជម្លៀស ដែលក្រោយមកមាន ៣ (បី) ដំណាក់កាល ។[181] សក្ខីកម្មរបស់សាក្សីបានដកស្រង់សំដីរបស់កម្មាភិបាលជាន់ខ្ពស់ឈ្មោះ តា ម៉ុក ថា "*ប្រជាជនទាំងអស់ត្រូវតែជម្លៀសទៅកាន់ទីជនបទ ដើម្បីកសាងសេដ្ឋកិច្ចជនបទ ។ ... ការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវបានធ្វើឡើងនៅទូទាំងប្រទេសដោយការជម្លៀសត្រូវតែឱ្យហើយក្នុងរយៈពេល ០២ (ពីរ) ថ្ងៃ*" ។[182]

៨៤. ការជម្លៀសនៅដំណាក់កាលទីមួយ បន្ទាប់ពីការរំដោះបាននាថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[183] ដោយមានអង្គភាពយោធាជាអ្នកទទួលខុសត្រូវអនុវត្តផែនការ ដោយបង្ខំឱ្យប្រជាជនចាកចេញពីផ្ទះទៅតាមផ្លូវជាតិគ្រប់ទិសជុំវិញរាប់ទាំងប៉ែកខាងលិច ខាងកើត ខាងជើង និងខាងត្បូងក្រុងភ្នំពេញ ពីទីរួមខេត្ត និងស្រុកផ្សេងទៀតឱ្យទៅតាមជនបទ ។[184] ក្នុងទិសដៅជម្រុញសេដ្ឋកិច្ច ដើម្បីកសាងរបបនេះលើមាគ៌ាសង្គមនិយមបែបសមូហភាពតាមជនបទដោយមានការកសាងប្រព័ន្ធធារាសាស្ត្រ[185] ជីកព្រែក[186] លើកទំនប់[187] ជីកប្រឡាយ[188] អាងស្តុកទឹកដើម្បីឱ្យត្រូវតាមពាក្យថា "បើមានទឹកគឺមានត្រី និងបើមានត្រីគឺមានអ្វីៗទាំងអស់" ។[189]

៨៥. លើសពីនេះនៅមានការជម្រុញឱ្យមានការធ្វើស្រែ និងការបង្កបង្កើនផលតាមសហករណ៍[190] ដែលការណ៍នេះបានរួមចំណែកមួយដ៏សំខាន់ ក្នុងការជួយពង្រឹងបញ្ហាសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ តាមរយៈការឈានទៅកំណត់បាននូវអត្តសញ្ញាណខ្មាំងរួមមាន អតីតកងទ័ព[191] អតីតមន្ត្រីរដ្ឋការរបបមុនៗ[192] សេអ៊ីអា (CIA) [193] កាហ្សេបេ (KGB) [194] ខ្មាំងយួនបង្កប់[195] ដើម្បីការពារប្រទេសពីការប្រឈមមុខនឹងប្រទេសវៀតណាមជាដើម ។[196]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៨៦. ការជម្លៀសដំណាក់កាលទីពីរ បានចាប់ផ្ដើមពីខែ កញ្ញា ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៧ ។ ប្រជាជន និងកម្មាភិបាលភូមិភាគនិរតី (ខេត្តកណ្ដាល និងខេត្តតាកែវ) ត្រូវបានជម្លៀសទៅកាន់ភូមិភាគពាយ័ព្យ (ខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់)។[197] ផែនការនេះធ្វើឡើងក្រោយពីមានដំណើរទស្សនកិច្ចទៅកាន់នៅភូមិភាគពាយ័ព្យ របស់គណៈកម្មាធិការអចិន្ត្រៃយ៍ នាខែសីហា-កញ្ញា ឆ្នាំ ១៩៧៥ ដែលបានដឹងពីតម្រូវការ និងផែនការបន្ថែមប្រជាជន ៥០០.០០០ (ប្រាំសែន) នាក់ លើចំនួនប្រជាជនដែលមានស្រាប់ក្នុងភូមិភាគ[198] ក្នុងគោលដៅជម្រុញសេដ្ឋកិច្ចសង្គមនិយមក្នុងសហករណ៍បង្កបង្កើនផល ដោយសារភូមិភាគនេះដីមានជីជាតិ ហើយអាចទទួលរ៉ាប់រងចិញ្ចឹមប្រជាជនថ្មីបានបន្ថែមទៀត ។[199] ជាក់ស្ដែងប្រជាជនរាប់សិបពាន់នាក់ត្រូវបានបញ្ជូនតាមរថភ្លើង និងរថយន្ត ដោយចេញពីភ្នំពេញឆ្ពោះទៅគោលដៅនានាក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។[200] រហូតមកដល់ឆ្នាំ ១៩៧៧ បក្សកុំម្មុយនីស្ដកម្ពុជា បានប៉ាន់ប្រមាណចំនួនប្រជាជនសរុបដែលត្រូវបានជម្លៀសថា មានចំនួនដល់ទៅ ៤.០០០.០០០ (បួនលាន) នាក់ ។[201]

៨៧. ការជម្លៀសចុងក្រោយនៅដំណាក់កាលទីបី កើតមានពីចុងឆ្នាំ ១៩៧៧-១៩៧៨ ។[202] ប្រជាជនដែលរស់នៅខេត្តព្រៃវែង និង ខេត្តស្វាយរៀងក្នុងភូមិភាគបូព៌ា ក៏ត្រូវបានអង្គការបង្ខំជម្លៀសទៅកាន់ភូមិភាគពាយ័ព្យ ។[203] ក្រៅពីប្រជាជនធម្មតានៅមានទាំងខ្មាំង និងមុខសញ្ញាខ្មាំងដែលរួមមាន អ្នកពាក់ព័ន្ធរបបមុនៗ ជាខ្មែរយៈវៀតណាម ប្រជាជន ១៧ មេសា ព្រះសង្ឃ ប្រជាជនចាម កូនកាត់ចិន កូនកាត់វៀតណាម ។[204] អ្នកដែលមកដល់លើកនេះត្រូវធ្វើប្រវត្តិរូប និងត្រូវបានបែងចែកទៅតាមសហករណ៍ និងការដ្ឋានធ្វើការងារផ្សេងៗ ។ ខណៈដែលអ្នកខ្លះក៏ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខសិន ហើយអ្នកខ្លះក៏ត្រូវបានយកទៅសម្លាប់ភ្លាមៗតែម្ដង ។[205]

៨៨. លើសពីនេះទៀត ក្រោមហេតុផលនៃការជម្លៀសប្រជាជន ថ្នាក់ដឹកនាំបក្សបានសម្រេចដកប្រជាជន និងកងទ័ពចេញពីសមរភូមិដែលកំពុងប្រយុទ្ធគ្នាជាមួយវៀតណាម ខណៈមានគួរ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES

សង្ស័យថា ជាជនក្បត់ ឬ ខ្សែរបស់ សោ ភឹម ។[206] តា ម៉ុក (គណៈកម្មាធិការភូមិភាគពាយ័ព្យ) ជាមួយវត្តមានរបស់ឈ្មោះ សារុន (គណៈកម្មាធិការតំបន់ ១០៥) និងឈ្មោះ រឹម (គណៈកម្មាធិការស្រុក) បានដឹកនាំការប្រជុំនៅខេត្តពោធិ៍សាត់ ដើម្បីចាត់ចែងអ្នកមកដល់ភូមិភាគពាយ័ព្យ ហើយបានណែនាំឱ្យមានការប្រុងប្រយ័ត្ន ចំពោះអ្នកដែលមកពីភូមិភាគបូព៌ា ពីព្រោះនៅពេលមកដល់ភ្នំពេញ មានខ្លះឆែកឃើញមានអាវុធ ហើយខ្លះទៀតក៏ជាខ្សែវៀតណាម ។[207]

៨៩. របបកម្ពុជាប្រជាធិបតេយ្យ បានធ្វើបំណែកចែកប្រជាជនតាមប្រវត្តិរូប[208] រវាងអ្នករស់ក្នុងតំបន់រំដោះ និងអ្នកក្រោយឆ្នាំ ១៩៧៥ ។ ភ្លាមៗក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ អង្គការបែងចែកប្រជាជនជាក្រុមជីវភាពជា អ្នកមាន អ្នកក្រីក្រ ឬ អ្នកចេះដឹង ។ អ្នកណាមានឋានៈផ្ទាល់ ឬសាច់ញាតិជាអ្នករដ្ឋការនៃរបប លន់ នល់ របបសង្គមរាស្ត្រនិយមត្រូវបានចាត់ថាជាអ្នកជាប់និន្នាការមិនល្អ ។[209] ចំណែកអ្នកដែលត្រូវជម្លៀសមកដល់កន្លែងថ្មីត្រូវបានអង្គការហៅថា ប្រជាជនថ្មី[210] ឬ ប្រជាជន ១៧ មេសា[211]។ រីឯអ្នកនៅទីតាំងដដែលហៅថា ប្រជាជនចាស់[212] ឬ ប្រជាជន ១៨ មេសា[213] ជារួមសំដៅលើប្រជាជនអ្នកមូលដ្ឋាន[214] ។ ប្រជាជនថ្មីត្រូវគេផ្តល់ឋានៈជា"ជនបញ្ញើ" ហើយមិនអាចកាន់តំណែងតួនាទីក្នុងរចនាសម្ព័ន្ធក្នុងកម្រិតណាមួយបានឡើយ ។[215] ផ្ទុយទៅវិញ ចំពោះប្រជាជនចាស់ ឬ អ្នកមូលដ្ឋានអាចទទួលបានឋានៈជាប្រជាជនពេញសិទ្ធិតែម្តង ឬប្រជាជនត្រៀម ប្រសិនបើមានសាច់ញាតិមានទំនាក់ទំនងជាមួយខ្មាំង ។[216]

៩០. ជាទូទៅ ប្រជាជនត្រូវបង្ខំឱ្យស្លៀកពាក់សម្លៀកបំពាក់ដែលកំណត់ដោយអង្គការ ជាខោអាវពណ៌ខ្មៅ ដោយក្នុងមួយឆ្នាំប្រជាជនអាចទទួលបានពីរសម្រាប់ ។[217] នៅតាមគ្រួសារនីមួយៗ គ្មានទ្រព្យសម្បត្តិឯកជន ផ្អែកលើគោលនយោបាយដែលត្រូវបានដាក់ឱ្យអនុវត្តចាប់តាំងពីមុនថ្ងៃរំដោះ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ មកម្ល៉េះ ។[218] ដោយមានហេតុផលថា របបកម្ពុជាប្រជាធិបតេយ្យយល់ថា ទ្រព្យសម្បត្តិឯកជន[219] ជារបបនាយទុននិយមនាំឱ្យមានអំពើពុករលួយ[220] ឬការកេងប្រវ័ញ្ចពីសំណាក់អ្នកមានទ្រព្យធនមកលើប្រជាជន ។[221]



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៩១. អង្គប្រជុំនាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ នាពហុកីឡដ្ឋានជាតិអូឡាំពិកបានសម្រេចមិនឱ្យមានទីផ្សារ និងរូបិយវត្ថុជាតិ ។[222] ជាក់ស្តែងសាក្សីជាអតីតកម្មាភិបាលដែលបានចូលរួមប្រជុំទាក់ទិនគោលនយោបាយបក្សដែលមាន ប៉ុល ពត និង នួន ជា ជាអ្នកឧទ្ទេសនាមបើកវគ្គបានអះអាងថា *"អ្នកទាំងពីរនេះនិយាយពីនយោបាយរៀបចំសហករណ៍ ហាមមិនឱ្យចាយលុយ បិទទីផ្សារ និងវត្តអារាម ហើយថ្ងៃក្រោយអាចនឹងបើកឱ្យមានវិញ"* ។[223] នៅចុងឆ្នាំ ១៩៧៨ មានសេចក្តីសម្រេចអនុញ្ញាតឱ្យមានរូបិយវត្ថុ និងទីផ្សារ ដែលមិនទាន់ត្រូវបានអនុវត្តចេញជារូបរាងផង របបក៏បានដួលរលំ ។ [224]

៩២. របបកម្ពុជាប្រជាធិបតេយ្យ បានដាក់កំហិតឱ្យមានការរៀបការដោយបង្ខំដើម្បីសម្រេចតាមគោលការណ៍នៃការការពារបដិវត្តន៍សង្គមនិយម តាមរយៈការយកអង្គការថ្នាក់លើរបស់ខ្លួនជាមេបាជំនួសឱ្យឪពុកម្តាយ។[225] ការរៀបការមិនត្រូវបានអនុញ្ញាតឱ្យធ្វើតាមប្រពៃណីទំនៀមទម្លាប់ ហើយមានការរៀបការម្តងៗជាច្រើនគូ ដោយពុំចាំបាច់មានការយល់ព្រមពីសាមីខ្លួនឡើយ ។[226] មានសាក្សីបង្ហាញ ដោយយោងដល់សារគោលនយោបាយពីថ្នាក់លើថា *"យើងត្រូវបង្កើនចំនួនប្រជាជនក្នុងរយៈពេល ១០ ទៅ ២០ ឆ្នាំ ឱ្យបានពី ២០ ទៅ ៣០ លាននាក់ ដើម្បីការពារប្រទេស"*។[227] មិនតែប៉ុណ្ណោះ នេះដើម្បីចំណេញនយោបាយគ្រប់គ្រងលើបុគ្គល និងសេដ្ឋកិច្ច ដោយទុកឱ្យឪពុកម្តាយនៅធ្វើការតាមសហករណ៍ និងការដ្ឋានការងារ ។[228]

៩៣. ចំពោះការរៀបការអង្គការបានប្រមូលចងក្រង អ្នកដែលមានឋានៈនយោបាយដូចគ្នា ដោយផ្តល់ការលើកទឹកចិត្តដល់កងទ័ព ។[229] ឯកសារជាផ្លូវការ និងសេចក្តីថ្លែងការណ៍របស់ ប៉ុល ពត បង្ហាញពីលក្ខណៈសន្មតថាការរៀបការទាំងនេះត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត ។ ការអនុវត្តប្រព័ន្ធរៀបការត្រូវបានគេរៀបរាប់នៅក្នុងការបោះពុម្ពផ្សាយជាផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជា និងបានរាយការណ៍តាមសារទូរលេខដែលត្រូវផ្ញើទៅថ្នាក់លើ ប៉ុន្តែតាម



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * JUGES D'INSTRUCTION

ការអនុវត្តជាក់ស្តែងប្រជាជនមិនអាចជំទាស់ ឬតវ៉ាបានឡើយ ដោយសារពួកគេភ័យខ្លាចនូវអំពើហិង្សា ឬការស្លាប់ ។[230]

៩៤. គោលនយោបាយធ្វើវិសុទ្ធកម្មក្នុង និងក្រៅបក្ស ត្រូវបានបង្កើតតាំងពីមុនឆ្នាំ ១៩៧៥ ក្នុងគោលបំណងបំផ្លាញនូវរចនាសម្ព័ន្ធរបបចាស់ វណ្ណៈសក្តិភូមិ នាយទុន សាសនា ពូជសាសន៍ជាដើម ។[231] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់មាត្រា ១០ បានបញ្ញត្តិថា "*ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជនត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត ។ ចំពោះបទល្មើសក្រៅពីប្រភេទខាងលើត្រូវអប់រំកសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬ ក្នុងក្របខណ្ឌអង្គការប្រជាជន*"។ [232]

៩៥. នៅក្រោយឆ្នាំ ១៩៧៥ អ្វីៗមានភាពស្មុគស្មាញពិបាកយល់បញ្ហានៅគ្រប់ជាន់ថ្នាក់ រីឯគោលនយោបាយទូទៅមានលក្ខណៈឆ្វេងនិយមជ្រុលតាមមាគ៌ាឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន ដែលត្រូវបានយកមកអនុវត្តតឹងរ៉ឹងហួសហេតុ ។[233] គោលនយោបាយសម្រិតសម្រាំងត្រូវបានស្តែងឡើង តាមរយៈសេចក្តីសម្រេចរបស់គណៈមជ្ឈិមបក្សនាឆ្នាំ ១៩៧៦ ដែលពាក់ព័ន្ធសិទ្ធិសម្រេចកម្ទេចក្នុង និងក្រៅជួរបក្ស ដោយបានថែងយ៉ាងច្បាស់ថា "***បើនៅក្នុងក្របខណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច***" ។[234]

៩៦. អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច កន្លងមកបានបកស្រាយទាក់ទិននឹងសេចក្តីសម្រេចនាឆ្នាំ ១៩៧៦ ថា "***អ្នកដែលមានសិទ្ធិនៅតាមមូលដ្ឋានមិនមែនអចិន្ត្រៃយ៍ភាគទាំងមូលទេ ... លេខាភាគមានសិទ្ធិកម្ទេចអ្នកណាត្រូវកម្ទេចអ្នកហ្នឹង លេខាភាគទុកឲ្យអ្នកណារស់គឺ អ្នកហ្នឹងរស់ ដូច្នេះអំណាចនៅលើលេខាភាគ***" ។[235] ដូចគ្នាដែរ លេខាភូមិភាគជាអ្នកគ្រប់គ្រងទាំងកងទ័ព និង កងឈ្លបដែលស្ថិតនៅក្រោមភូមិភាគ ។[236]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01596033



៩៧. នៅក្រោមការដឹកនាំរបស់បក្សកុំម្មុយនីស្តកម្ពុជា របបនេះបានបង្កើតឱ្យមានមន្ទីរសន្តិសុខជាច្រើនកន្លែងសម្រាប់ចាប់ឃុំឃាំង និងសម្លាប់មនុស្សដែលសរុបមានរហូតដល់ ១៩៥ (មួយរយកៅសិបប្រាំ) មន្ទីរសន្តិសុខនៅទូទាំងប្រទេស ។ មន្ទីរសន្តិសុខជាកន្លែងសម្រាប់ឃុំខ្លួន ធ្វើការលត់ដំ អប់រំ កែប្រែ ធ្វើទារុណកម្ម ដើម្បីរកខ្សែក្បត់ ឬសម្លាប់ទាំងគ្រួសារ ។[237] កម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវតែអនុវត្តតាមមាគ៌ារបស់បក្ស តាមរយៈការផ្សព្វផ្សាយគោលនយោបាយបក្ស ការសម្របសម្រួលលើការចាប់ខ្លួន ការបញ្ជូនខ្លួន តាមបញ្ជាថ្នាក់លើដែលត្រូវគេស្គាល់ជាទូទៅថាជា"អង្គការ" ។[238] មិនតែប៉ុណ្ណោះ អង្គការថ្នាក់លើតែងតែបំបាក់ស្មារតីរបស់ប្រជាជន តាមរយៈប្រយោគដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់ថា "*កង់ប្រវត្តិសាស្ត្រគេវិល បើយើងលូកដៃគឺដាច់ដៃ លូកជើងគឺដាច់ជើង អ្នកឯងកសាងខ្លួនបានល្អអាហ្នឹងមានអនាគតទៅមុខទៀត បើអ្នកឯងរត់មិនទាន់គេទេ ទុកក៏មិនចំណេញ ដកចេញក៏មិនខាតដែរ*" ។[239]

៩៨. អ្វីៗទាំងអស់សុទ្ធតែជាបញ្ជាពី "ថ្នាក់លើ"[240] ខណៈថ្នាក់ក្រោមពុំបានយល់ពីផែនការ ឬ កម្មវិធីនយោបាយបន្តិចផង ។[241] ប៉ុន្តែប្រសិនបើមិនធ្វើតាមគោលនយោបាយថ្នាក់លើ ពួកគេត្រូវចាត់ទុកជា "ខ្មាំង" ហើយអាចត្រូវគេយកទៅសម្លាប់ចោល ។[242] ក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ បញ្ជាថ្នាក់លើត្រូវតែគោរពដាច់ខាត បើហ៊ានតែបដិសេធអ្នកនឹងត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ។[243] ជាក់ស្តែងកម្មាភិបាលដែលហ៊ានរិះគន់មាគ៌ារបស់បក្សត្រូវបានអង្គការចាត់ទុកជា "ជនក្បត់ជាតិ" ។[244]

៩៩. ក្នុងរបបនោះមាន "ការប្រជុំស្វ័យទិតៀន" ដែលតម្រូវឱ្យអ្នកប្រព្រឹត្តខុសនិយាយពីកំហុសខ្លួនចេញមកក្រៅ ដើម្បីឱ្យអង្គប្រជុំជួយឱ្យយោបល់ដើម្បីកុំឱ្យធ្វើកំហុសដដែលៗ ។[245] បក្សកុំម្មុយនីស្តកម្ពុជា បានកំណត់ឱ្យមានប្រជុំជីវភាពបក្សជាទៀងទាត់ ដោយលើកហេតុផលថា "បើប្រជុំទៀងទាត់គឺចម្រើន ចម្រើនលឿន ចម្រើនយឺតគឺចម្រើន"។[246] តាមរយៈការប្រជុំទាំងនោះ អង្គការបានឃោសនាពង្រឹងស្មារតីប្រជាជនឱ្យខិតខំធ្វើការ ហើយកុំឱ្យក្បត់បក្ស និងក្បត់អង្គការ បើមិនដូច្នេះទេអ្នកទាំងនោះនឹងត្រូវយកទៅអប់រំ បើអង្គការយកអ្នក



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ណាទៅអប់រំ ឬកសាងមិនបាន អ្នកនោះនឹងត្រូវយកទៅសម្លាប់ចោល ស្របតាមពាក្យថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។[247] នៅឆ្នាំ ១៩៧៦ ហ៊ូ នឹម ត្រូវចាប់យកទៅសម្លាប់ ដោយសារគាត់មានយោបល់លើការស្នើឱ្យចាយលុយ បើកទីផ្សារឡើងវិញ ដែលយោបល់នេះផ្ទុយនឹងការសម្រេចកន្លងមករបស់ ប៉ុល ពត , នួន ជា និង តា ម៉ុក ។[248]

១០០. ការអនុវត្តនូវគោលនយោបាយបក្សកុំម្មុយនីស្តកម្ពុជាខាងលើ បណ្តាលឱ្យប្រជាជនប្រឈមមុខនឹងផលវិបាកជាច្រើនឥតគណនា ពិសេសប្រជាជនខ្វះខាតអាហាររូបត្ថម្ភ និងបណ្តាលឱ្យមានជំងឺ ។[249] នៅពេលឈឺមិនមានមណ្ឌលសុខភាព មន្ទីរពេទ្យ និងថ្នាំព្យាបាលឱ្យបានគ្រប់គ្រាន់ ហើយពេលខ្លះក៏បណ្តាលឱ្យអ្នកជំងឺជាច្រើនស្លាប់ ។[250] លើសពីនេះ នៅមានការស្លាប់របស់ប្រជាជន ដែលកើតចេញពីការបង្ក្រាបស្របតាមគោលនយោបាយវិសុទ្ធកម្ម ។ ប្រជាជន និងកម្មាភិបាលដែលត្រូវបានចាត់ថាជាខ្មាំង ឬមិនគោរពតាមបទបញ្ជាអង្គការក៏ត្រូវបានសម្លាប់ ។[251] នាពេលនោះ គ្មានការបន្ធូរបន្ថយវិធានការវិន័យ ឱ្យតែមិនស្របតាមគោលនយោបាយ បើទោះបីជាកម្មាភិបាលថ្នាក់ណា ក៏ត្រូវទទួលទោសកំចាត់ចោល ដូចជា ហ៊ូ យន់[252] , ហ៊ូ នឹម[253], វន វេត[254], កុយ ធួន[255] ,រស់ ញឹម[256] និង សោ ភឹម[257] ជាអាទិ៍ ។

១០១. ជាក់ស្តែងក្នុងអំឡុងពេលគ្រប់គ្រងអំណាចអស់រយៈពេល ៣ (បី) ឆ្នាំ ៨ (ប្រាំបី) ខែ ២០ (ម្ភៃ) ថ្ងៃ មានកម្មាភិបាលជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យយ៉ាងតិចចំនួន ៦០ (ហុកសិប) រូបត្រូវបានចាប់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ។[258] ជាសរុបមានប្រជាជនប្រមាណជាង ១.៧00.000 (មួយលានប្រាំពីរសែន) នាក់ [259] ត្រូវបានសម្លាប់ និងស្លាប់ដោយសារការអត់ឃ្លាន[260] ជំងឺ[261] និងការធ្វើការងារហួសកម្លាំង[262] ។

១០២. នយោបាយដែលត្រូវបានដាក់ចេញដោយបក្សកុំម្មុយនីស្តកម្ពុជា ដូចបានរៀបរាប់ខាងលើបានបង្ហាញថា នៅទូទាំងប្រទេសកម្ពុជាមានការបង្កើតឱ្យមាននូវប្រព័ន្ធតាមដានគ្រប់រូបភាព ។ ពាក្យថា "អង្គការភ្នែកម្នាស់" មានន័យថាអង្គការថ្នាក់លើមានមធ្យោបាយរិតត្បិត



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

គ្រប់សព្វមិនត្រឹមតែលើប្រជាជនទេ រួមទាំងកម្មាភិបាលផងដែរ ។[263] មិនតែប៉ុណ្ណោះ ប្រសិនបើមានការដើរខុសគន្លងនៃគោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជា បុគ្គលនោះនឹងក្លាយជាខ្មាំងរបស់អង្គការ និងពេលខ្លះគេថាជាខ្មាំងបដិវត្តន៍ ។ អ្វីដែលចម្លែកត្រង់ថាការបំបាត់របបកម្មសិទ្ធិឯកជន បើសូម្បីតែដំណាំដាំជុំវិញផ្ទះ ក៏ជាកម្មសិទ្ធិសហករណ៍ដែរ ។ នេះរហូតដល់មានពាក្យស្លោកថា **"ជាកម្មសិទ្ធិសមរម្យគឺស្បៀងមួយតូច"** ។

១០៣. អង្គហេតុទាំងអស់នេះមានលក្ខណៈជាសត្យានុម័ត ដែលបានដឹងឮជាសាធារណៈ ពោលគឺប្រជាជនកម្ពុជា ដែលនាពេលនេះមានអាយុចាប់ពី ៥០ (ហាសិប) ឆ្នាំ (គិតត្រឹមឆ្នាំ ២០០៨ នេះ) ឡើងទៅ កាលបើរស់នៅក្នុងរបបនោះសុទ្ធតែបានដឹងឮ និងឃើញទាំងអស់ដោយមិនចាំបាច់មានភស្តុតាងបញ្ជាក់ ។

១០៤. បរិបទនៃការប្រព្រឹត្ត និងទម្រង់នៃការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺខុសពីអ្វីដែលកើតមាននៅប្រទេសយូហ្គោស្លាវី (Yogoslavia), រ៉្វាន់ដា (Rwanda) , និង សេរ៉ាឡេអូន (Sierra Leone) ដែលបង្កើតឱ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិស្រដៀងគ្នានឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែរ ។ របបកម្ពុជាប្រជាធិបតេយ្យជារបបប្រកាន់និន្នាការដឹកនាំរដ្ឋមួយជាក់លាក់ ផ្តុះបញ្ចាំងក្នុងគោលនយោបាយ ធ្វើទុក្ខបុកម្នេញកម្រិតជាតិ អនុវត្តជារូបរាងទូទៅក្នុងប្រទេស មានរចនាសម្ព័ន្ធដឹកនាំសមូហភាព ដែលកម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវតែគោរព និងធ្វើតាមបញ្ជា ។

១០៥. ជាក់ស្តែងពាក្យថា "សត្រូវ" ឬ "ខ្មាំងបដិវត្តន៍" មានវិសាលភាពធំធេង គ្របដណ្តប់លើប្រជាពលរដ្ឋស្លូតត្រង់ខ្លួនឯងតែម្តង ។ នេះខុសគ្នានឹងជម្លោះពូជសាសន៍រវាង ហ៊ូទូ (Hutus) និង ទុតស៊ី (Tutsi) ដែលនាំឱ្យមានអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដា (Rwanda) ។[264] អ្វីៗដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ ក៏ខុសគ្នានឹងអំពើប្រល័យពូជសាសន៍ដោយពួកជាតិនិយមស៊ែប (Serb) ដែលដឹកនាំដោយអតីតប្រធានាធិបតីស្លូបូដាន ម៉េឡូស្សូវិច (Slobodan Milosevic) ទៅលើប្រជាជនក្រូអាត (Croat) និងបូស្នៀ (Bosnia) ។[265]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ផ្នែកទី ២. រចនាសម្ព័ន្ធរដ្ឋបាល

### ក. បក្សកុម្មុយនីស្តកម្ពុជា

១០៦. មកទល់ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគ្រប់គ្រងដោយលក្ខន្តិកៈ ដែលដំបូងឡើយត្រូវបានអនុម័ត ក្នុងឱកាសសមាជលើកទីមួយ របស់បក្សនៅខែកញ្ញា ឆ្នាំ ១៩៦០ ។[266] លក្ខន្តិកៈថ្មីនៃបក្សកុម្មុយនីស្តកម្ពុជា[267] ត្រូវបានអនុម័តដោយសមាជបក្សលើកទីបួន[268] នៅក្នុងខែ មករា ឆ្នាំ១៩៧៦ ។ លក្ខន្តិកៈថ្មីនេះបានរៀបរាប់អំពីមនោគមវិជ្ជា លក្ខខណ្ឌនៃការចូលជាសមាជិក រចនាសម្ព័ន្ធ និងអង្គការចាត់តាំងនៃបក្សកុម្មុយនីស្តកម្ពុជា និងមានចែងផងដែរអំពីស្ថាប័នរដ្ឋមួយចំនួន មានដូចជា កងទ័ពបដិវត្តន៍កម្ពុជា[269] គណៈកម្មាធិការបក្សថ្នាក់ជាតិ[270] គណៈកម្មាធិការមជ្ឈិមបក្ស[271] រួមទាំងមន្ទីរ និង ក្រសួងផ្សេងៗជុំវិញគណៈកម្មាធិការមជ្ឈិមបក្ស[272]។ បក្សត្រូវបានគ្រប់គ្រងដោយគណៈកម្មាធិការមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃគណៈមជ្ឈិម ។[273]

១០៧. លក្ខន្តិកៈនេះក៏បានគូសបញ្ជាក់ទៀតថា បក្សកុម្មុយនីសកម្ពុជាត្រូវដើរតាមប្រព័ន្ធ "*របបដឹកនាំសមូហភាព*"[274] ដែលផ្អែកលើគោលការណ៍ "*ប្រជាធិបតេយ្យប្រមូលផ្តុំ*"[275]។ នៅពេលគេយកគោលការណ៍នេះមកអនុវត្តចំពោះប្រព័ន្ធគណៈកម្មាធិការនេះ វាមានន័យថាសមាជិកត្រូវធ្វើសេចក្តីសម្រេចរួមជាមួយសមាជិកផ្សេងទៀត និងពុំអាចធ្វើការសម្រេចជាលក្ខណៈបុគ្គលបានឡើយ ។[276] មិនតែប៉ុណ្ណោះសមាជិកតាមផ្នែកនីមួយៗត្រូវបានចាត់ឱ្យទទួលខុសត្រូវតាមការកំណត់យ៉ាងជាក់លាក់ ។ ជាក់ស្តែង នៅក្នុងកំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ បានសរសេរថា "*តាំងពីទូរលេខឡើងទៅពេលទទួលបានភ្លាមមន្ទីរត្រូវប្រគល់ឱ្យផ្នែកទទួលខុសត្រូវភ្លាម ឱ្យគេពិនិត្យ ពិចារណា ហើយស្នើរអចិន្ត្រៃយ៍បញ្ហាខ្លះត្រូវប្រញាប់*" ។[277] ឯកសារនេះបង្ហាញឱ្យឃើញពីបំណែងចែកភារកិច្ចក្នុងមន្ទីរនីមួយៗយ៉ាងច្បាស់លាស់ ពាក់ព័ន្ធនឹងសារទូរលេខ មន្ទីរមានភារកិច្ច



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

ប្រគល់ជូនទៅសមាជិកនៃផ្នែកទទួលខុសត្រូវ ហើយផ្នែកនេះនឹងពិចារណាបញ្ជូនបន្តទៅខាងអចិន្ត្រៃយ៍ប្រសិនបើជាករណីប្រញាប់ ។

## ខ. គណៈកម្មាធិការមជ្ឈិម

### ១. សមាសភាព

១០៨. គណៈកម្មាធិការមជ្ឈិម ឬ គណៈមជ្ឈិម[278] មានសមាជិកដូចជា ប៉ុល ពត (លេខាគណៈកម្មាធិការមជ្ឈិម)[279], នួន ជា (អនុលេខាគណៈកម្មាធិការមជ្ឈិម)[280], អៀង សារី, ខៀវ សំផន, កុយ ធួន (ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[281]), តា ម៉ុក[282], ម៉ែន សាន ហៅ យ៉ា (ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[283]) និង កែ ពក[284] ជាអាទិ៍។ សឿ វ៉ាស៊ី ហៅ ឌឿន ជាប្រធានមន្ទីរ ៨៧០ (ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[285]) ក៏ជាសមាជិកមួយរូបនៃគណៈកម្មាធិការមជ្ឈិម ។[286] ចំណែក ឈឹម សំអោក ហៅ ប៉ង់ ត្រូវបានប្រាប់ឱ្យដឹងថាជាសមាជិកគណៈកម្មាធិការមជ្ឈិម និងពេលខ្លះទៀតជាជំនួយការនៃ គណៈកម្មាធិការមជ្ឈិម ។[287]

១០៩. ទោះបីជាសមាជិកបក្សមានការប្រែប្រួលក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏គណៈកម្មាធិការមជ្ឈិមមានសមាជិកប្រហែលច្រើនជាង ៣០ (សាមសិប) រូប រួមមានសមាជិកពេញសិទ្ធិ និងសមាជិកត្រៀមចូលបក្ស ដែលភាគច្រើនជាលេខាភូមិភាគ លេខាតំបន់ អនុលេខាភូមិភាគ និងសមាជិកភូមិភាគ ដែលភារកិច្ចតាមលក្ខន្តិកៈគឺត្រូវដឹកនាំអនុវត្តយ៉ាងជិតដល់នូវគោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជា ពីលើដល់ក្រោមគ្រប់កម្រិតទាំងអស់របស់សង្គម និងរាយការណ៍ទៅឋានានុក្រមថ្នាក់លើរហូតដល់គណៈកម្មាធិការមជ្ឈិម ។ ការប្រជុំមានចែងនៅក្នុងលក្ខន្តិកៈជាញឹកញាប់ប្រហែលមួយឆមាសម្តង[288] ហើយការប្រជុំនេះបានអនុវត្តជាទៀងទាត់រហូតដល់ចុងឆ្នាំ ១៩៧៨ នៃសមាជបក្សលើកទីប្រាំ [289] ដើម្បីរៀនសូត្រនយោបាយ ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

១១០. សក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច និងសាក្សីផ្សេងៗទៀត បានបង្ហាញឲ្យដឹងថា បក្សកុំម្មុយនីស្តកម្ពុជា បានលើកឡើងថាគណៈកម្មាធិការមជ្ឈិមបក្សមានច្រើនថ្នាក់[290] ថ្នាក់ខ្ពស់បំផុតគឺ គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្ស[291] ជាអង្គការដែលមានសិទ្ធិអំណាច ។ កម្រិតទីពីរ គឺសមាជិកមជ្ឈិមពេញសិទ្ធិ ដែលមានសិទ្ធិចូលរួមពិភាក្សា និងបោះឆ្នោតសម្រេច ។[292] កម្រិតទីបី គឺសមាជិកត្រៀម ឬបម្រុងនៃគណៈកម្មាធិការមជ្ឈិមដែលមានសិទ្ធិជូនយោបល់ពេលមានការពិភាក្សា ប៉ុន្តែមិនមានសិទ្ធិបោះឆ្នោតសម្រេច ។ ចំណែកឯកម្រិតទីបួន ដែលជាកម្រិតទាបជាងគេបំផុត[293] គឺជំនួយការនៃគណៈកម្មាធិការមជ្ឈិម ។ អនុលោមតាមលក្ខន្តិកៈបក្សកុំម្មុយនីស្តកម្ពុជា គណៈកម្មាធិការមជ្ឈិមមានតួនាទីក្នុងការ "អនុវត្តមាគ៌ានយោបាយរបស់បក្ស និងលក្ខន្តិកៈរបស់បក្ស នៅក្នុងបក្សទាំងមូល" ព្រមទាំង "ណែនាំអង្គការភូមិភាគ តំបន់" ក៏ដូចជា "គ្រប់គ្រង និងចាត់ចែងកម្មាភិបាល និងបក្ខជនក្នុងបក្សទាំងមូល" ។[294]

១១១. ពាក់ព័ន្ធនឹងក្រុមជំនួយការនៃគណៈកម្មាធិការមជ្ឈិម ឌុច បានលើកឡើងថា គាត់បានដឹងពីអត្ថិភាពនៃក្រុមជំនួយការនេះនៅក្នុងឆ្នាំ ១៩៧៥ តាមរយៈ ណាត , កុយ ធួន និង ប៉ង់។ [295] ឌុច បានលើកឡើងថា "*គណៈជំនួយការគណៈកម្មាធិការមជ្ឈិម* " ស្ថិតនៅក្រោមមន្ទីរ ៨៧០ ដែលមានមន្ទីររដ្ឋបាល (មន្ទីរ ស-៧១) គ្រប់គ្រងដោយ ឈឹម សំអោក ហៅ ប៉ង់ [296] ហើយត្រូវបានជំនួសដោយ ឈ្មោះ ខាន់ លីន ហៅ កែន ហៅ លីន[297] ។ សមាសភាពក្រុមជំនួយការនៃគណៈកម្មាធិការមជ្ឈិមមានដូចជាឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ , ចេង អន , សំ ប៊ិត, មាស មុត , ស៊ូ ម៉េត, ពេទ្យ សឿង, វៀន អែម ហៅ សារុន[298] ។ ទោះបីជាមន្ទីររដ្ឋបាល ស-៧១ ត្រូវបានគ្រប់គ្រងដោយ ប៉ុល ពត ខ្លួនឯងផ្ទាល់[299] ក៏ប៉ុន្តែសក្ខីកម្មផ្សេងទៀតបានបង្ហាញថា មន្ទីររដ្ឋបាល ស-៧១ ជាទូទៅក៏បាន "*រាយការណ៍ទៅមជ្ឈិម* " ផងដែរ ។[300]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

១១២. ឯកសារច្បាប់ និងលក្ខន្តិកៈរបស់បក្សកុំម្មុយនីស្តកម្ពុជា មិនមានចែងអំពីស្ថាប័នដំណើរការប្រព្រឹត្តទៅ និងសិទ្ធិអំណាចរបស់គណៈជំនួយការនៃគណៈកម្មាធិការមជ្ឈិមទេ។[301] យោងតាមសក្ខីកម្មរបស់ ឌុច កំរិតទាបជាងគេបំផុតនៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស[302] គឺក្រុមជំនួយការដែលអាចចូលរួមរៀនសូត្រ និងធ្វើការកត់ត្រា ប៉ុន្តែប្រសិនបើមានការពិភាក្សាពួកគេមិនមានសិទ្ធិចូលរួមពិភាក្សា និងបោះឆ្នោតសម្រេចឡើយ[303]។ ជាទូទៅសមាជិកជំនួយការមជ្ឈិម សមាជិកបម្រុង និង សមាជិកពេញសិទ្ធិ មិនមានសិទ្ធិចូលរួមនៅក្នុងកិច្ចប្រជុំប្រចាំសប្តាហ៍ និងការពិភាក្សាទេ លើកលែងតែសមាជិកអចិន្ត្រៃយ៍តែប៉ុណ្ណោះ។[304]

១១៣. ចំណែក ខៀវ សំផន ក៏បានលើកឡើងដែរថា នៅក្នុងគណៈកម្មាធិការមជ្ឈិម អ្នកដែលមានអំណាចពិតប្រាកដ គឺជាលេខាភូមិភាគ ឬ លេខាតំបន់ និង អ្នកដែលទទួលខុសត្រូវអង្គភាពយោធា។[305]

១១៤. **មាស មុត** ត្រូវបានចោទថាជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុំម្មុយនីស្តកម្ពុជាដែលតាមរយៈឋានៈនេះ គាត់ជាសមាជិកម្នាក់នៃឋានានុក្រមជាន់ខ្ពស់នៃបក្សកុំម្មុយនីស្តកម្ពុជា ហើយមានគណៈអចិន្ត្រៃយ៍តែមួយគត់ដែលមានឋានៈខ្ពស់ជាងគេនៅក្នុងឋានានុក្រមបក្សកុំម្មុយនីស្តកម្ពុជា ។ **មាស មុត** ក៏ត្រូវបានចោទថាជាសមាជិកនៃគណៈជំនួយការនៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុំម្មុយនីស្តកម្ពុជាដែលមានការទទួលខុសត្រូវផ្នែកនយោបាយនៅក្នុងបក្សកុំម្មុយនីស្តកម្ពុជា ហើយមានសិទ្ធិក្នុងការទទួលបាននូវការហ្វឹកហាត់នៅមន្ទីរ ៨៧០ ជាមួយសមាជិកគណៈមជ្ឈិម ។[306]

១១៥. សក្ខីកម្មរបស់សាក្សីមួយចំនួន បានបង្ហាញអំពីសមាជិកភាពរបស់ **មាស មុត** នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សដែលបានចាប់ផ្តើមនៅឆ្នាំ ១៩៧៥។[307] ខៀវ សំផន បានអះអាងថា លេខាភូមិភាគផ្សេងៗ និងយ៉ាងហោចណាស់លេខាតំបន់ខ្លះក៏ជាសមាជិកគណៈកម្មាធិការមជ្ឈិមផងដែរ ជាមួយនឹងកម្មាភិបាលយោធាមួយចំនួនបន្ថែមទៀតរួមទាំង **មាស**



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

មុត ។[308] ពាក់ព័ន្ធនឹងបញ្ហានេះ មាស មុត ផ្ទាល់មិនបានទទួលស្គាល់ថាគាត់ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សទេ តែគាត់បន្ថែមថាគាត់គ្រាន់តែជាសមាជិកធម្មតានៅក្នុងបក្សតែប៉ុណ្ណោះ[309] ហើយមានសាក្សីជាច្រើន និងឯកសារផ្សេងទៀត ដែលបានរៀបរាប់ពីរចនាសម្ព័ន្ធរបស់មជ្ឈិមបក្ស តែមិនមានវត្តមានរបស់ មាស មុត ទេ ។[310] ហេតុដូច្នេះ ដើម្បីបង្ហាញឲ្យបានច្បាស់លាស់ពីការអះអាងផ្ទុយគ្នាបែបនេះ យើងត្រូវសិក្សាទៅលើរចនាសម្ព័ន្ធរដ្ឋបាលរបស់បក្សកុំម្មុយនីស្តកម្ពុជា។

១១៦. អនុលោមតាមមាត្រា ២៤ នៃលក្ខន្តិកៈរបស់បក្សកុំម្មុយនីស្តកម្ពុជា ចំនួនសមាជិកពេញសិទ្ធិ និងសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមត្រូវកំណត់ឡើងដោយមហាសន្និបាតតំណាងទូទាំងប្រទេស ។ សមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិម ចូលរួមប្រជុំគណៈកម្មាធិការមជ្ឈិមបានតែមិនមានសិទ្ធិសម្រេចទេ ។ តាមការចាំបាច់នៃការងារ បើខ្វះសមាជិកពេញសិទ្ធិ នោះគណៈកម្មាធិការមជ្ឈិមត្រូវជ្រើសតាំងសមាជិកត្រៀមមកបំពេញ ។[311]

១១៧. ទាក់ទងនឹងសមាជិកភាពរបស់ មាស មុត នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្សនៅឆ្នាំ ១៩៧៥ គឺមានលក្ខណៈស៊ីសង្វាក់ដូចគ្នាទៅនឹងការអះអាងរបស់ ឌុច[312] ដែលថាមានមហាសន្និបាតមួយនៅចុងឆ្នាំ ១៩៧៥ ដើម្បីសម្រេចចាត់តាំងអចិន្ត្រៃយ៍មជ្ឈិមបក្សមានដូចជា ប៉ុល ពត, នួន ជា, សោ ភឹម , តា ម៉ុក, អៀង សារី និង វន វេត ។ សមាជិកពេញសិទ្ធិមានដូចជា រស់ ញឹម, គង់ សុផល ហៅ កឺ , ជូ ជេត ហៅ ស៊ី , ហ្វួត ហេង ហៅ ប៉ាល់ សារុន, តាភ្លូង , សេង ហុង ហៅ ចាន់ , ម៉ែន សាន ហៅ យ៉ា , កែ ពក , កុយ ធួន, កង ចាប និង ខៀវ សំផន ។ សមាជិកត្រៀមមានដូចជា សុន សេន , សៀត ឆែ ហៅ ទុំ និង សឿ វ៉ាស៊ី ហៅ ឌឿន ។ សមាជិកជំនួយការមជ្ឈិមមានដូចជា ឈឹម សំអោក ហៅ ប៉ង់ , ចេង អន, ពេទ្យ សឿង , សំ ប៊ិត , មាស មុត និង ស៊្វ ម៉េត ។

១១៨. ឌុច នៅតែរក្សាជំហរដដែលតាំងពីដើមក្នុងការបញ្ជាក់ថា មាស មុត មិនមែនជាសមាជិកពេញសិទ្ធិ ហើយក៏មិនមែនជាសមាជិកត្រៀមរបស់គណៈកម្មាធិការមជ្ឈិមផងដែរ[313] គាត់



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

មានតួនាទីត្រឹមតែជាសមាជិកជំនួយការកម្រិតទាបជាងគេ នៃគណៈកម្មាធិការមជ្ឈិមតែប៉ុណ្ណោះ ។[314] រីឯ ណាត និង សុន សេន ក៏បានប្រាប់ ឌុច ដូចគ្នា ។[315] ខៀវ សំផន ខ្លួនឯងក៏បានទទួលស្គាល់ថា ខ្លួនគាត់ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ។ ពីដំបូងគាត់ជាសមាជិកត្រៀមនៅឆ្នាំ ១៩៧១ និងក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ ១៩៧៦ ។[316]

១១៩. នៅឆ្នាំ ១៩៧៦ សូម្បីតែ ខៀវ សំផន ដែលមានតួនាទីជាប្រធានគណៈប្រធានរដ្ឋ ក៏គាត់បានត្រឹមជាសមាជិកមជ្ឈិមពេញសិទ្ធិ ហើយ សុន សេន ដែលជាអគ្គសេនាធិការ និងទទួលបន្ទុកខាងកងកម្លាំងប្រដាប់អាវុធ ទាំងយោធា និងនគរបាល មានតួនាទីជាសមាជិកគណៈអចិន្ត្រៃយ៍របស់មជ្ឈិមបក្ស[317]។ បន្ថែមពីនេះទៀត សៀត ឆែ ហៅ ទុំ ឬ បង ៨១ ដែលជាអនុលេខាអគ្គសេនាធិការ មានតួនាទីត្រឹមតែជាសមាជិកត្រៀមនៃគណៈកម្មាធិការមជ្ឈិមបក្ស ។[318] នៅក្នុងសមាជគណៈកម្មាធិការមជ្ឈិមបក្សឆ្នាំ ១៩៧៥ នោះ[319] មានចែងតែអំពីការតែងតាំងគណៈជំនួយការ និងការបង្កើតកងទ័ពជើងទឹក[320] តែប៉ុណ្ណោះ ប៉ុន្តែឈ្មោះ **មាស មុត** មិនត្រូវបានរំលេចទាំងនៅក្នុងកំណត់ហេតុនៃការប្រជុំសមាជរបស់មជ្ឈិមបក្ស ទាំងនៅក្នុងឆ្នាំ ១៩៧៥[321] និងក្នុងឆ្នាំ ១៩៧៨[322] ។

១២០. ដើម្បីកំណត់អំពីកម្រិតនៃទំនួលខុសត្រូវ និងអំណាចជាក់ស្តែងរបស់ **មាស មុត** នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស យើងត្រូវពិចារណាទៅលើតួនាទីរបស់គាត់ក្នុងនាមជាជំនួយការ ។

១២១. **មាស មុត** ក្នុងនាមជាសមាជិកនៃគណៈជំនួយការនៃគណៈកម្មាធិការមជ្ឈិម មាន "ការទទួលខុសត្រូវផ្នែកនយោបាយ" ដូចដែលមានចែងនៅក្នុងមាត្រា ២៣ នៃលក្ខន្តិកៈ[323] ដែល ឌុច បានលើកឡើងនោះ[324]។ ឌុច[325] បានរៀបរាប់អំពីតួនាទីរបស់ **មាស មុត** ដែលបានធ្វើការក្នុងនាមជាជំនួយការរបស់គណៈកម្មាធិការមជ្ឈិម ។ **មាស មុត** តែងតែរាយការណ៍ជាប្រចាំអំពីតំបន់ដែលគាត់កាន់កាប់ដូចជា លេខាកងពលផ្សេងទៀតដែរទៅ សុន សេន ដោយមានចម្លងជូន ប៉ុល ពត , នួន ជា និង វន វ៉េត[326] ហើយគាត់ទាក់ទងជាប្រចាំជាមួយ



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

នឹង សុន សេន[327] និងអមដំណើរម្តងគត់ជាមួយ អៀង សារី នៅពេលមានការចរចាទាក់ទងនឹងបញ្ហាព្រំដែនសមុទ្រជាមួយវៀតណាម[328] និងបានទទួលទស្សនកិច្ចម្តងរបស់គណៈប្រតិភូចិន នៅទីក្រុងកំពង់សោម[329]។

## ២. អំណាច

១២២. ទាក់ទងនឹងសិទ្ធិអំណាចជាក់ស្តែងរបស់គណៈកម្មាធិការជំនួយការនៃគណៈកម្មាធិការមជ្ឈិម សមាជិកមិនពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម រួមទាំងជំនួយការគណៈកម្មាធិការមជ្ឈិម មិនមានអំណាចធ្វើសេចក្តីសម្រេចក្នុងការកម្ទេចមនុស្សឡើយ[330] ព្រោះជាអំណាចផ្លូវការហើយដែលត្រូវបានផ្តល់ឱ្យសមាជិកគណៈកម្មាធិការមជ្ឈិមមួយចំនួនប៉ុណ្ណោះ[331]។ ឌុច បានបញ្ជាក់ថា "*មាស មុត ឬ បង មុត គាត់ធ្វើជាលេខាតំបន់ឯករាជ្យកំពង់សោម។ គាត់ចូលជាជំនួយការមជ្ឈិមទេ មិនទាន់ទៅសមាជិកមជ្ឈិមពេញសិទ្ធិទេ។ ដូច្នេះ តែកាលណាមិនទាន់ទៅជាសមាជិកមជ្ឈិមពេញសិទ្ធិមិនមានសិទ្ធិសម្រេចចាប់បេក្ខជនទៅដាក់គុកបានទេ* "។[332] ម្យ៉ាងវិញទៀត នៅពេលដែលមានបញ្ហាពាក់ព័ន្ធដែនទឹកជាមួយវៀតណាម សុន សេន ក៏បានរាយការណ៍ទៅអង្គការអំពីសេចក្តីសម្រេចបញ្ជូន មាស មុត ទៅពិនិត្យស្ថានការណ៍ និង ស្នើយោបល់ពីអង្គការ និង តា ម៉ុក ផងដែរ ។[333]

## គ. គណៈកម្មាធិការអចិន្ត្រៃយ៍

១២៣. គណៈកម្មាធិការអចិន្ត្រៃយ៍ ឬ គណៈអចិន្ត្រៃយ៍ គឺជាក្រុមដឹកនាំការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការមជ្ឈិម ដែលមានសមាសភាពសុទ្ធសឹងតែជាថ្នាក់ដឹកនាំជាន់ខ្ពស់បំផុតនៃបក្សកុំមុយនីស្តកម្ពុជា ។ ខៀវ សំផន បានអះអាងថា យោងទៅតាមលក្ខន្តិកៈ គណៈមជ្ឈិមជាគោលការណ៍មានអំណាចសម្រេច ប៉ុន្តែជាក់ស្តែងអំណាចនេះត្រូវបានអនុវត្តដោយគណៈអចិន្ត្រៃយ៍ ដែលមានភារកិច្ចគ្រប់គ្រងការងារប្រចាំថ្ងៃ ។[334]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១២៤. ឧត្តមានុភាពរបស់គណៈអចិន្ត្រៃយ៍ត្រូវបានបង្ហាញឡើងជាពិសេស តាមរយៈសិទ្ធិអំណាចរបស់អង្គការនេះ ក្នុងការបញ្ជាឲ្យមានការចាប់ខ្លួនសមាជិកគណៈមជ្ឈិម ។[335] មាគ៌ានយោបាយ និងការចេញសេចក្តីសម្រេចត្រូវបានធ្វើ និងសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ បន្ទាប់មកព័ត៌មាននេះនឹងត្រូវបានផ្សព្វផ្សាយបន្តទៅគណៈកម្មាធិការមជ្ឈិមដែលនឹងណែនាំបន្តទៀតទៅកាន់មូលដ្ឋាន ។[336]

## ១. ការបង្កើត និងសមាសភាព

១២៥. នៅក្នុងអង្គប្រជុំមួយនាថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ គណៈកម្មាធិការអចិន្ត្រៃយ៍បានប្រគល់ជូនដល់កម្មាភិបាលជាន់ខ្ពស់បក្ស ដែលក្នុងចំណោមនោះក៏មានសមាជិកគណៈអចិន្ត្រៃយ៍ផងដែរ នូវការទទួលខុសត្រូវប្រតិបត្តិលើវិស័យផ្សេងៗ ក្នុងសកម្មភាពរបស់រដ្ឋាភិបាលរួមមានដូចជា យោធា សេដ្ឋកិច្ច សន្តិសុខ កិច្ចការបរទេស និងសង្គមកិច្ច ជាអាទិ៍។[337] កម្មាភិបាលទាំងនោះត្រូវរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាស្ថាប័នមានអំណាចក្នុងការសម្រេច ។ ហេតុដូច្នេះហើយ បានជានៅក្នុងកំណត់ហេតុនៃការប្រជុំនេះ មានសរសេរថា *"ក្នុងការលើកគម្រោង ត្រូវសួរយោបល់អចិន្ត្រៃយ៍ ដើម្បីសម្រេច និងអនុម័ត"* ។[338]

១២៦. សមាជិកគណៈអចិន្ត្រៃយ៍ដែលបានចាត់តាំងដោយមហាសន្និបាត ឆ្នាំ ១៩៧៦[339] រួមមាន ប៉ុល ពត (លេខា)[340], នួន ជា (អនុលេខាទីមួយ)[341], សោ យ៉ាន់ ហៅ សោ ភឹម (អនុលេខាទីពីរ)[342](ដែលបានធ្វើអត្តឃាតនៅក្នុងឆ្នាំ ១៩៧៨ [343]), តា ម៉ុក (អនុលេខាទីបី)[344], អៀង សារី ហៅ វ៉ាន់ (សមាជិកពេញសិទ្ធិ)[345], វន វេត (សមាជិកត្រៀមដែលក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់[346]) និង សុន សេន (សមាជិកត្រៀម)[347] ។

១២៧. បន្ទាប់ពីមានការបោសសម្អាត នៅខែ សីហា ឆ្នាំ ១៩៧៨ មហាសន្និបាតវិសាមញ្ញ ឆ្នាំ ១៩៧៨ បានសម្រេចចាត់តាំងគណៈអចិន្ត្រៃយ៍ថ្មី រួមមាន[348] ប៉ុល ពត (ជាលេខា), នួន ជា



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

(អនុលេខាទីមួយ) , តា ម៉ុក (អនុលេខាទីពីរ), អៀង សារី [349], សុន សេន[350], ខៀវ សំផន[351] ។ សមាជបក្សលើកទីប្រាំនាខ្ទង់ខែ សីហា ឆ្នាំ ១៩៧៨ បានរំលេចសមាសភាពរបស់គណៈអចិន្ត្រៃយ៍ រួមមាន[352] ប៉ុល ពត (លេខា) , នួន ជា (អនុលេខាទីមួយ) , តា ម៉ុក (អនុលេខាទីពីរ) , អៀង សារី (សមាជិកពេញសិទ្ធិ) , វន វេត (សមាជិកពេញសិទ្ធិ) , សុន សេន (សមាជិកត្រៀម) និងគង់ សុផល ហៅ កឹ (សមាជិកត្រៀម) ។

១២៨. កំណត់ហេតុនៃអង្គប្រជុំដែលនៅមានរបស់គណៈកម្មាធិការអចិន្ត្រៃយ៍[353] មានតែកំណត់ហេតុនៃអង្គប្រជុំ ១៥ (ដប់ប្រាំ) ប៉ុណ្ណោះ ដែលមានកត់ត្រាអំពីអ្នកចូលរួម[354] បានបង្ហាញថា មាស មុត មិនដែលមានវត្តមាននៅក្នុងអង្គប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ឡើយ ព្រោះគាត់មិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ។

## ២. អំណាច

១២៩. ខៀវ សំផន និង ឌុច បានអះអាងស្របគ្នាថា ប៉ុល ពត គឺជាអ្នកដែលមានអំណាចខ្ពស់នៃបក្សកុំម្មុយនីស្តកម្ពុជាក្នុងឋានៈជាលេខាគណៈអចិន្ត្រៃយ៍[355] ចំណែក នួន ជា ជាបុគ្គលទីពីរ និង ឈិត ជឿន ហៅ តា ម៉ុក ជាបុគ្គលទីបី[356]។ កំណត់ហេតុនៃការប្រជុំបង្ហាញថា នៅពេល ប៉ុល ពត អវត្តមាន នួន ជា ជាអធិបតីនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ ។[357] ឌុច បានបន្ថែមថា សេចក្តីសម្រេចកម្ទេចក្នុងជួរ ក្រៅជួរ និងនៅក្នុងតំបន់ឯករាជ្យ គឺចេញពីគណៈកម្មាធិការអចិន្ត្រៃយ៍ទេ ។[358]

១៣០. ឌុច ក៏បានបង្ហាញដែរថា[359] អ្នកដែលមានអំណាចចាប់ខ្លួនក៏មានអំណាចសម្រេចលើការសម្លាប់ផងដែរ ដូចបានលើកឡើងនៅក្នុងសេចក្តីសម្រេច នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ថាមានមនុស្ស ៤ (បួន) ប្រភេទ "សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ លេខាភូមិភាគ លេខាសេនាធិការ និងលេខានៃគណៈកម្មាធិការមន្ទីរ ៨៧០"[360] គឺ ប៉ុល ពត , នួន ជា ,



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES * CO JUGES D'INSTRUCTION

សោ ភីម , តា ម៉ុក , សុន សេន , ខៀវ សំផន , ម៉ែន សាន ហៅ យ៉ា , រស់ ញឹម , កែ ពក , ជូ ជេត ហៅ ស៊ី និង កង ចាប ហៅ សែ។

១៣១. ឌុច ក៏បានពន្យល់ថា "*ពាក្យអចិន្ត្រៃយ៍នេះៗ មិនមែនសំដៅស្ទីទេ គឺសំដៅអចិន្ត្រៃយ៍មជ្ឈិម ដែលមាន ប៉ុល ពត ជាកំពូលដឹកនាំធំ ។ តំបន់ឯករាជ្យ មិនត្រូវសម្រេចខ្លួនឯងទេ ត្រូវឱ្យ អចិន្ត្រៃយ៍សម្រេច*" ។[361]

**ឃ. មន្ទីរ**

១៣២. នៅថ្នាក់មជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ឯកសារដែលសរសេរមក "មន្ទីរ ៨៧០" ឬ "ម.៨៧០" ឬ "គណៈ ៨៧០" គឺសំដៅទៅលើថ្នាក់ខ្ពស់បំផុតរបស់មជ្ឈិមបក្សកុម្មុយនីស្ត កម្ពុជា[362] ហើយនៅក្នុងករណីខ្លះ គឺ ប៉ុល ពត តែម្តង[363]។ អង្គភាពនៅក្នុងមន្ទីរ ៨៧០ បំពេញការងារពាក់ព័ន្ធនឹងវិស័យនយោបាយ រដ្ឋបាល យោធា ទំនាក់ទំនង និងសន្តិសុខ ក្នុង នាមគណៈអចិន្ត្រៃយ៍ ឬជួយគណៈអចិន្ត្រៃយ៍ក្នុងការអនុវត្តការងារទាំងអស់នេះ ។ អង្គភាព ទាំងនេះ ត្រូវរាយការណ៍ជូនសមាជិកគណៈអចិន្ត្រៃយ៍ ដែលនៅទីក្រុងភ្នំពេញ ។ [364]

១៣៣. ឈ្មោះផ្លូវការរបស់ស្ថាប័នពីរដែលសំខាន់បំផុតនៅក្នុងនោះ គឺ "មន្ទីរនយោបាយ ៨៧០" [365] និង "មន្ទីររដ្ឋបាល"[366] ដែលគណៈអចិន្ត្រៃយ៍ផ្តល់ឈ្មោះថា "មន្ទីរ ស-៧១" ឬ "ក្រសួង ស-៧១" [367]។

**១. មន្ទីរនយោបាយ ៨៧០**

១៣៤. ប្រធានមន្ទីរនយោបាយ ៨៧០ ដំបូងគេ គឺ សឿ វ៉ាស៊ី ហៅ ឌឿន ដែលបានកាន់មុខតំណែង នេះរហូតដល់មានការចាប់ខ្លួនគាត់នៅឆ្នាំ ១៩៧៧ ។[368] មានសក្ខីកម្មរបស់សាក្សីមួយចំនួន បានអះអាងថា ខៀវ សំផន ក៏ធ្លាប់ជាប្រធានមន្ទីរ ៨៧០ ដែលពីមុនស្ថិតនៅក្រោមការ គ្រប់គ្រងរបស់ ឌឿន ក្នុងកំឡុងពេលមួយ[369] ប៉ុន្តែ ខៀវ សំផន ផ្ទាល់ បានអះអាងថាធ្លាប់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D' INSTRUCTION"

បានធ្វើការនៅមន្ទីរនេះដោយទទួលបន្ទុកចម្បងលើបញ្ហាភ័ស្តុភារប៉ុណ្ណោះ តែមិនមានពេលណាមួយដែលគាត់ធ្លាប់ជាប្រធានមន្ទីរនេះនោះទេ[370] ។

១៣៥. មន្ទីរនយោបាយ ៨៧០ មានតួនាទីសំខាន់ក្នុងការធានាការធ្វើទំនាក់ទំនងរវាងបុគ្គលនានាដែលមានអំណាចសម្រេចរបស់មជ្ឈិម ព្រមទាំងត្រួតពិនិត្យការអនុវត្តសេចក្តីសម្រេចនានាតាមរយៈប្រព័ន្ធទំនាក់ទំនងព័ត៌មានមួយដែលមានលក្ខណៈទៀងទាត់ និងផ្ទាល់ទៅកាន់មន្ទីរនយោបាយ ៨៧០ ។[371] ទាក់ទងនឹងមន្ទីរដែលដឹកនាំដោយ ខៀន កំណត់ហេតុនៃការប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ បានបង្ហាញថា "*មន្ទីរអចិន្ត្រៃយ៍ទាក់ទងពីផ្នែកមួយទៅផ្នែកមួយ ។ អចិន្ត្រៃយ៍តាមដានផ្នែកនីមួយៗក្នុងការអនុវត្តមាគ៌ា។ ខាងមន្ទីរមានភារកិច្ចតាមដានការអនុវត្ត*" ។[372]

## ២. មន្ទីររដ្ឋបាល ឬ មន្ទីរ ស-៧១

១៣៦. មន្ទីររដ្ឋបាល ស-៧១ (មន្ទីរ ស-៧១) គឺជាអង្គភាពមួយក្រោមឱវាទរបស់មន្ទីរ ៨៧០ ហើយដែលត្រូវបានគ្រប់គ្រងដោយ ឈឹម សំអោក ហៅ ប៉ង់[373] ជាប្រធានមន្ទីររដ្ឋបាល ស-៧១ ចាប់តាំងពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ការបាត់ខ្លួនរបស់គាត់នៅចុងឆ្នាំ ១៩៧៧ ឬ ដើមឆ្នាំ ១៩៧៨ ។[374] នាពេលក្រោយមក តួនាទីជាប្រធានជាមន្ទីររដ្ឋបាល ស-៧១ ត្រូវបានជំនួសដោយ ឈ្មោះ ខាន់ លីន ហៅ លីន ហៅ កែន [375] ដែលបានកាន់កាប់តួនាទីនេះរហូតដល់ ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ ។ ទោះបីជាមានសាក្សីបានអះអាងថាមន្ទីរ ស-៧១ ត្រូវបានគ្រប់គ្រងដោយ ប៉ុល ពត ខ្លួនឯងផ្ទាល់[376] ក៏ប៉ុន្តែសក្ខីកម្មផ្សេងទៀតបានបង្ហាញថាមន្ទីរ ស-៧១ ជាទូទៅក៏បាន "*រាយការណ៍ទៅមជ្ឈិម*"ផងដែរ ។[377]

១៣៧. មន្ទីររដ្ឋបាល ស-៧១ ដើរតួនាទីជាគណៈកម្មាធិការនៃក្រុមការងារជុំវិញមន្ទីរ ៨៧០[378] ដែលមានភារកិច្ចផ្សេងៗ ដូចជា ត្រូវទទួលខុសត្រូវលើកិច្ចការរដ្ឋបាល ការងារជំនួយការផ្សេងៗទៀត[379] ការពារមន្ទីរមជ្ឈិម និងកម្មាភិបាលនៃមន្ទីរនេះ ទទួលភ្ញៀវ ទូរគមនាគមន៍



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

(ដែលមានទាំងនិរសា និងសារទូរលេខ) ភ័ស្តុភារ ស្បៀង និងការដឹកជញ្ជូន ជាអាទិ៍[380] ។ ប៉ុន្តែមន្ទីរ ស-៧១ នេះ ក្នុងនាមគណៈអចិន្ត្រៃយ៍ ក៏មានភារកិច្ចក្នុងការតាមដានលើសមាជិករបស់បក្ស ក្រសួងនានា គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ខ្លួនឯងផងដែលខ្លួនមានការសង្ស័យ ព្រមទាំងធ្វើការចាប់ខ្លួនអ្នកដែលត្រូវបានចាត់ទុកថាជាជនក្បត់ និងបញ្ជូនពួកគេទាំងនោះទៅកាន់មន្ទីរសន្តិសុខ ស-២១ ។[381]

១៣៨. នៅក្នុងរចនាសម្ព័ន្ធរបស់មន្ទីររដ្ឋបាល ស-៧១ មានមន្ទីរចំណុះមួយចំនួនដែលមានឈ្មោះសម្គាល់សម្ងាត់ ផ្តើមជាមួយព្យញ្ជនៈ "ក" នៅខាងមុខ ហើយក្នុងចំណោមមន្ទីរទាំងនោះ មន្ទីរសំខាន់ៗ មានដូចជា មន្ទីរ ក-១ , មន្ទីរ ក-៣ , មន្ទីរ ក-៧ និង មន្ទីរ ក-១៨ ជាអាទិ៍ ដែលទទួលខុសត្រូវលើការងាររដ្ឋបាល ការងារផ្នែកភ័ស្តុភារ ដើម្បីជាជំនួយដល់គណៈមជ្ឈិមក្នុងការបំពេញការងារ ។[382] មន្ទីរ "ក" ទាំងនេះស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ ប៉ង់ ។[383] មន្ទីរ ក-៧ គឺជាអង្គភាពនិរសា ជាកន្លែងឆ្លងកាត់ការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរនានា ដែលផ្ញើទៅកាន់ "*មន្ទីរ ៨៧០*" ឬ "*គណៈ ៨៧០*" មុននឹងបញ្ជូនទៅឲ្យ ប៉ុល ពត នៅមន្ទីរ ក-១ ក៏ដូចជាទៅឲ្យសមាជិកគណៈ ៨៧០ ឬ សមាជិកពាក់ព័ន្ធរបស់គណៈ ៨៧០ អាស្រ័យលើការទទួលខុសត្រូវតាមផ្នែករបស់ខ្លួន ។[384] ចំណែកឯមន្ទីរ ក-១៨ គឺជាអង្គភាពទូរលេខ ដែលមានភារកិច្ចទទួលការទាក់ទងតាមវិទ្យុ រួចបញ្ជូនទៅកាន់មន្ទីរ ក-១ ។[385]

១៣៩. បើទោះបីជាមន្ទីរនយោបាយ ៨៧០ មានភារកិច្ចទទួលបន្ទុកខាងផ្នែកនយោបាយ ខុសពីមន្ទីររដ្ឋបាល ស-៧១ ដែលមានភារកិច្ចទទួលខុសត្រូវលើកិច្ចការរដ្ឋបាលក្តី ក៏ប៉ុន្តែមន្ទីរនយោបាយ ៨៧០ និង មន្ទីររដ្ឋបាល ស-៧១ ជារឿយៗត្រូវបានគេដឹងឮជាទូទៅ និងផ្តល់ឈ្មោះឲ្យថា "មន្ទីរ ៨៧០" ឬ "មន្ទីររបស់អង្គការ"ដោយមិនមានការបញ្ជាក់ច្បាស់ទេថា តើគេសំដៅដល់មន្ទីរណាមួយនោះឡើយ ។ ខៀវ សំផន និង ឌុច ក៏ដូចជាសាក្សីជាច្រើនទៀតបានបញ្ជាក់ថា ពាក្យ "*មន្ទីរ ៨៧០*" "*អង្គការ ៨៧០*" "*គណៈ ៨៧០*" ឬ "*អង្គការ*" ត្រូវបានប្រើប្រាស់ដោយមិនមានការបែងចែកដើម្បីសំដៅដល់ស្ថាប័នដឹកនាំនានារបស់មជ្ឈិម



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

បក្ស ។[386] សាក្សីមួយចំនួនបានលើកឡើងថា "*គណៈ ៨៧០*" ឬ "*មន្ទីរ ៨៧០*" ត្រូវបានប្រើសំដៅដោយផ្ទាល់ទៅគណៈមជ្ឈិម[387] ខណៈដែលមានសាក្សីផ្សេងៗទៀតបានលើកឡើងថា សំដៅទៅដល់គណៈអចិន្ត្រៃយ៍ទៅវិញ[388] ឬទៅ ប៉ុល ពត[389] , នួន ជា , អៀង សារី , វន វេត , សុន សេន និងថ្នាក់ដឹកនាំជាន់ខ្ពស់ផ្សេងទៀត[390] ដោយរួមទាំង ខៀវ សំផន ផងដែរ គឺអាស្រ័យលើខ្លឹមសារនៃលិខិតទំនាក់ទំនងទាំងនោះ[391]។

## ខ. ក្រសួងនានា

១៤០. តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ គណៈមជ្ឈិមបានធ្វើការកំណត់សមាសភាពរបស់ស្ថាប័នរដ្ឋ ដើម្បីបង្កើតរដ្ឋាភិបាលផ្លូវការជំនួសឲ្យរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា (GRUNK) ។[392] មានការប្រកាសថារដ្ឋាភិបាល "ត្រូវជាអង្គការរបស់បក្សសុទ្ធសាធ ។ ជារដ្ឋរបស់យើងផ្ទាល់" ។ ឈ្មោះរបស់រដ្ឋមន្ត្រីទាំងអស់ត្រូវបានប្រកាសជាសាធារណៈ នៅថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៦ ។[393]

១៤១. ទោះបីជាសមាសភាពនេះ អាចត្រូវបានផ្លាស់ប្តូរក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក៏ជាគោលការណ៍រដ្ឋាភិបាលត្រូវបានរៀបចំឡើងក្នុងបែបផែនដូចតទៅ[394] ប៉ុល ពត ជានាយករដ្ឋមន្ត្រី , អៀង សារី ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស , សុន សេន ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការពារជាតិ , វន វេត ជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកសេដ្ឋកិច្ច , នួន ជា ជាប្រធានសភាតំណាងប្រជាជន[395] , ហ៊ូ នឹម ជារដ្ឋមន្ត្រីក្រសួងឃោសនាការ , យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងអប់រំ , តូច ភឿន ជារដ្ឋមន្ត្រីក្រសួងសាធារណការ ដឹកជញ្ជូន និងប្រៃសណីយ៍ , កុយ ធួន ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម , ចេង អន ជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម[396] , អៀង ធីរិទ្ធ ជារដ្ឋមន្ត្រីទទួលបន្ទុកការងារសង្គមកិច្ច , ជួន ជឿន ជារដ្ឋមន្ត្រីទទួលបន្ទុកសុខាភិបាល និង ខៀវ សំផន ជាប្រធានគណៈ



* E.C.C.C. * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596049



ប្រធានរដ្ឋ ដែលធ្លាប់ទទួលបន្ទុកផ្នែកពាណិជ្ជកម្ម ទាក់ទងទៅនឹងគណនេយ្យ និងការកំណត់តម្លៃ [397]។

## ១. សភា

១៤២. យោងតាមរដ្ឋធម្មនុញ្ញនៃបក្សកុំម្មុយនីស្តកម្ពុជា[398] អំណាចធ្វើច្បាប់ ជាអំណាចរបស់សភាតំណាងប្រជាជន កម្មករ កសិករ ពលករកម្ពុជា និងកងទ័ពបដិវត្តកម្ពុជា ។ សភា ត្រូវបានគេឲ្យឈ្មោះជាផ្លូវការថា "សភាតំណាងប្រជាជនកម្ពុជា" ដែលមានសមាជិកសរុបទាំងអស់ ២៥០ (ពីររយហាសិប) នាក់។ សមាជិកសភាតំណាងប្រជាជនកម្ពុជានេះ ត្រូវបានប្រជាជនជ្រើសតាំងតាមរយៈការបោះឆ្នោតទូទាំងប្រទេសដោយផ្ទាល់ និងដោយសម្ងាត់ ក្នុងរយៈកាល ៥ (ប្រាំ) ឆ្នាំ ម្តង ។ សភាតំណាងប្រជាជនមានភារកិច្ចសម្រេចច្បាប់ និងកំណត់មាគ៌ានយោបាយផ្សេងៗក្នុងប្រទេស និងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ ។

១៤៣. ក្នុងសម័យប្រជុំដំបូងនៃសភាតំណាងប្រជាជនកម្ពុជា ដែលបានប្រារព្ធធ្វើឡើងពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៧៦ ខៀវ សំផន ត្រូវបានតែងតាំងជាប្រធានគណៈប្រធានរដ្ឋ ។[399] នៅក្នុងតួនាទីនេះគាត់បានទទួលតំណែងជាប្រមុខរដ្ឋ បន្តពីសម្តេចនរោត្តម សីហនុ ។[400] ឯកសារទាំងនេះមានភាពស៊ីសង្វាក់ជាមួយនឹងចម្លើយរបស់ ឌុច ដែលបានលើកឡើងថា នៅឆ្នាំ ១៩៧៦ មានការប្រជុំប្រកាសបង្កើតសភាតែម្តងគត់ ដើម្បីបង្ហាញពិភពលោកថាកម្ពុជាមានសភា ហើយរដ្ឋធម្មនុញ្ញបង្កើតមុនសភា ។[401]

## ២. តុលាការ

១៤៤. យោងតាមរដ្ឋធម្មនុញ្ញនៃបក្សកុំម្មុយនីស្តកម្ពុជា "តុលាការជាតុលាការរបស់ប្រជាជនតំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជា



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋ របស់ប្រជាជន ឬ ដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន ។ តុលាការគ្រប់ជាន់ថ្នាក់ ត្រូវសភាតំណាងប្រជាជនជ្រើសរើស និងតែងតាំង"។[402] យើងសង្កេតឃើញថា មិនមានឯកសារណាដែលមានចែងអំពីការរៀបចំ និងដំណើរការរបស់អង្គតុលាការប្រជាជនឡើយ។ ម្យ៉ាងទៀត មាត្រានេះសបញ្ជាក់ឱ្យឃើញថា អំណាចនីតិបញ្ញត្តិ និងអំណាចតុលាការ មិនមានការបែងចែកដាច់ដោយឡែកគ្នាឡើយ ។

## ផ្នែកទី ៣. រចនាសម្ព័ន្ធយោធា

### ក.ដើមកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជា

១៤៥. ប្រវត្តិផ្លូវការនៃបក្សកុំម្មុយនីស្តកម្ពុជា បង្ហាញថាកម្លាំងប្រដាប់អាវុធរបស់ខ្លួនមានដើមកំណើតចេញពី "កងការពារសម្ងាត់" ។[403] នៅឆ្នាំ ១៩៦៨ កងកម្លាំងទាំងនេះត្រូវបានប្រែក្លាយទៅជា "កងឈ្លបប្រដាប់អាវុធ" ។[404] នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៦៨ ជាថ្ងៃនៃការចាប់ផ្តើមធ្វើការតស៊ូជាផ្លូវការដោយអាវុធ និងជាថ្ងៃកំណើត "កងទ័ពបដិវត្តន៍" របស់បក្សកុំម្មុយនីស្តកម្ពុជា ។[405] ក្រោយមកបក្សកុំម្មុយនីស្តកម្ពុជាចាត់ទុកថា ចាប់ពីឆ្នាំ ១៩៦៩ មានការបង្កើតលក្ខខណ្ឌ ដែលអនុគ្រោះសម្រាប់កងទ័ពមានរួចជាស្រេចហើយ នៅភូមិភាគសំខាន់ៗខ្លះ មានកងអនុសេនាធំជាច្រើនរួចទៅហើយ ។ នៅកន្លែងផ្សេងទៀត មានត្រឹមតែអនុសេនាតូច ក្រុម និងពួក ។ ប៉ុន្តែកងកម្លាំងទាំងនោះ គឺស្ថិតនៅក្នុងជួរកងទ័ពបដិវត្តន៍ ។[406] នៅក្នុងខែ មីនា ឆ្នាំ ១៩៧០ កងកម្លាំងទាំងនោះត្រូវបានកំណត់ឈ្មោះជាផ្លូវការថា "កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា" ។[407]

១៤៦. ការរៀបចំចាត់តាំងជាផ្លូវការឡើងវិញ នៃកងកម្លាំងប្រដាប់អាវុធនេះត្រូវបានប្រកាសជាសាធារណៈនៅក្នុងខែ កក្កដា ឆ្នាំ ១៩៧៥ ក្នុងការជួបជុំគ្នាមួយ ដែលត្រូវបានគេហៅជាផ្លូវការថា "សន្និសីទនយោបាយដ៏សំខាន់នៃមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា" ដែលមានតំណាង



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

មកពីអង្គភាពនានានៃកងទ័ពបដិវត្តន៍ចូលរួមប្រហែល ៣.០០០ (បីពាន់) នាក់ និងមាន "សមមិត្តប្រធានគណៈឃោធាកំពូលរបស់បក្ស"[408] ដែលបានថ្លែងទៅកាន់អ្នកចូលរួមនៅពេលនោះ ។ ការចាត់តាំងនេះបានបញ្ចូលកងពលតូចគ្រប់តំបន់ ដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការមជ្ឈិម ជាពិសេសស្ថិតនៅក្រោមការបញ្ជារបស់សេនាធិការដែលមាន សុន សេន ជាអគ្គសេនាធិការ ។[409]

## ខ. តួនាទីរបស់កងទ័ពបដិវត្តន៍កម្ពុជា

១៤៧. តាំងពីដើមដំបូងមកបក្សកុំម្មុយនីស្តកម្ពុជាបានគិតថា "*ដើម្បីការពារខ្លួន និងដើម្បីរំដោះខ្លួនត្រូវប្រើហិង្សា ទោះជាហិង្សានយោបាយក្តី ជាហិង្សាអាវុធក្តី ត្រូវមានប្រជាជនបំពាក់អាវុធគឺត្រូវតែមានកងទ័ព*" ។[410] កងទ័ពបដិវត្តន៍កម្ពុជា គឺជាស្ថាប័នដ៏សំខាន់មួយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលស្ថិតនៅក្រោមការដឹកនាំផ្តាច់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុំម្មុយនីស្តកម្ពុជា ។[411]

១៤៨. យោងតាមឯកសាររបស់មជ្ឈិមបក្សសំខាន់ៗ ចំនួនពីរ គឺ រដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈបក្សដែលជាឯកសាររៀបរាប់ស្តីអំពីអង្គការចាត់តាំងរបស់កម្ពុជាប្រជាធិបតេយ្យ កងទ័ពបដិវត្តន៍កម្ពុជាមានកាតព្វកិច្ចចម្បងពីរ គឺ "ការពាររដ្ឋអំណាចរបស់ប្រជាជនកម្ពុជា" និង "រួមចំណែកកសាងប្រទេស" ។[412] កងទ័ពបដិវត្តន៍កម្ពុជា ក៏មានការទទួលខុសត្រូវខាងផ្នែកសន្តិសុខខាងក្រៅ ឬការការពារជាតិ និងផ្នែកសន្តិសុខខាងក្នុង[413] ប្រឆាំងនឹងបុគ្គលដែលសន្មតថាជាខ្មាំងសត្រូវក្នុងជួរកងកម្លាំងប្រដាប់អាវុធ ក្នុងបក្ស និង ក្នុងប្រទេសទាំងមូល ព្រមទាំងទទួលខុសត្រូវក្នុងការកសាងប្រទេស តាមរយៈការចូលរួមជួយកសាងវិស័យកសិកម្មផងដែរ [414]។



CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION" E.C.C.C * C.E.T.C.

១៤៩. ឯកសារបោះពុម្ពផ្សាយរបស់បក្សកុំម្មុយនីស្តកម្ពុជា ព្រមទាំងការប្រជុំគណៈកម្មាធិការបក្សនានា ក៏បានលើកឡើងជារឿយៗផងដែរ អំពីតួនាទីសំខាន់របស់កងទ័ពបដិវត្តន៍កម្ពុជាក្រោមការដឹកនាំរបស់ ប៉ុល ពត ដែលជាអ្នកទទួលខុសត្រូវក្តាប់រួមលើផ្នែកសន្តិសុខ និងយោធា (លេខាគណៈកម្មាធិការមជ្ឈិម/លេខាគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រធានគណៈកម្មាធិការយោធា) និងតាមរយៈសេនាធិការដឹកនាំដោយ សុន សេន ។[415]

១៥០. ដើម្បីបំពេញតួនាទីដែលបានចាត់តាំង ផ្នែកសន្តិសុខ និងយោធារបស់កងទ័ពបដិវត្តន៍កម្ពុជា អគ្គសេនាធិការតែងតែចេញបញ្ជា និងណែនាំដល់ស្ថាប័នយោធាទាំងអស់នៅគ្រប់កម្រិតឱ្យមានការប្រុងប្រយ័ត្នចំពោះខ្មាំងខាងក្រៅ និងខាងក្នុង[416] ឈានទៅបោសសម្អាតនៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា ។ មិនតែប៉ុណ្ណោះសេនាធិការបានដាក់កំហិតចំពោះកងទ័ពបដិវត្តន៍កម្ពុជានូវការទទួលខុសត្រូវដើម្បីធានានូវការអភិវឌ្ឍឈានឡើង និងដើម្បីបង្កើនកម្រិតនៃការរស់នៅរបស់ប្រជាជន[417] និងថែមទាំងធ្វើឱ្យកម្លាំងទ័ពខិតខំបំពេញសមិទ្ធិផលនៃគោលដៅផែនការ ៤ (បួន) ឆ្នាំ ក្នុងការផលិតស្រូវឱ្យបានបីតោនក្នុងមួយហិចតា[418] ដើម្បីគាំទ្រអង្គភាពយោធានីមួយៗ លើកលែងតែទ័ពនៅតាមព្រំដែន[419]។ ផែនការចុងក្រោយបណ្តាលឱ្យមានការបង្កើតការដ្ឋានការងារផ្សេងៗ ស្ថិតក្រោមការដឹកនាំគ្រប់គ្រងរបស់អង្គភាពយោធានីមួយៗ។

**គ. ស្ថាប័នទ័ពរបស់មជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា**

**១. គណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម**

**១.១. រចនាសម្ព័ន្ធ**

១៥១. នៅក្នុងគណៈកម្មាធិការមជ្ឈិមបក្ស គឺមានគណៈកម្មាធិការយោធាពិសេសមួយ[420] ដែលជាគណៈកម្មាធិការយោធាជាន់ខ្ពស់[421] ឬហៅថា "គណៈកម្មាធិការយោធា"[422] ដែលត្រូវបានបង្កើតឡើងយ៉ាងហោចណាស់ចាប់តាំងពីនៅឆ្នាំ ១៩៧០ ដើរតួនាទីជាស្ថាប័នមួយ ធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយរបស់បក្ស ទទួលខុសត្រូវលើការគ្រប់គ្រងកងទ័ពបដិវត្តន៍

កម្ពុជាតាមរយៈមជ្ឈិម[423]។ គណៈកម្មាធិការយោធាត្រូវបានគេហៅថា "គណៈកម្មាធិការសន្តិសុខ"[424] ឬ "គណៈកម្មាធិការយោធា និងសន្តិសុខ"[425] ទទួលខុសត្រូវទាំងផ្នែកយោធា និងសន្តិសុខរបស់បក្សកុំម្មុយនីស្តកម្ពុជា រួមទាំង "ការសម្លាប់" "ការប្រតិបត្តិការនៃមន្ទីរសន្តិសុខ ស-២១" "កន្លែងសម្លាប់ផ្សេងទៀត" "ភ្នាក់ងារសម្លាប់" និង "បញ្ហាទូទៅ" ។ អៀង សារី បានអះអាងថា គណៈកម្មាធិការនេះរាយការណ៍ជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ បន្ទាប់ពីបានទទួលរបាយការណ៍ពីភូមិភាគនានា នៅពេលនោះហើយដែលគាត់ផ្ទាល់ខ្លួនក៏បានឮរបាយការណ៍អំពីបញ្ហាសន្តិសុខ ។[426]

១៥២. គណៈកម្មាធិការយោធាដើរតួនាទីជាអង្គការមជ្ឈិមបក្ស ហើយដូច្នេះគណៈកម្មាធិការយោធាធានាលើការគ្រប់គ្រងកងទ័ពបដិវត្តន៍កម្ពុជាតាមរយៈមជ្ឈិម ។[427] គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធាជួនកាលជួបប្រជុំរួមគ្នា ដើម្បីធ្វើសេចក្តីសម្រេចអំពីបញ្ហាយោធានានា[428] ដែលត្រូវអនុវត្តបទបញ្ជាជាយុទ្ធសាស្ត្រជារួម ទៅលើកងកម្លាំងប្រដាប់អាវុធ [429]។

## ១.២. សមាសភាព

១៥៣. សមាសភាពនៃគណៈកម្មាធិការយោធា មានដូចជា ប៉ុល ពត ជា ប្រធាន, នួន ជា ជាអនុប្រធាន ទទួលខុសត្រូវបញ្ហានយោបាយ , តា ម៉ុក ជាអនុប្រធាន ទទួលខុសត្រូវបញ្ហាយោធា[430], អៀង សារី ជាសមាជិកគណៈកម្មាធិការយោធា [431] , សុន សេន ហៅ ខៀវ ហៅ បង ៨៩ ជាសមាជិកគណៈកម្មាធិការយោធា [432] និង សោ ភឹម ជាសមាជិកគណៈកម្មាធិការយោធា[433]។ ចំណែក កែ ពក[434] និង វន វេត[435] ក៏ត្រូវបានអះអាងថាជាសមាជិកនៃគណៈកម្មាធិការយោធាផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ការទទួលខុសត្រូវជាផ្លូវការរបស់សមាជិកនៃគណៈកម្មាធិការយោធា គឺ សោ ភឹម និង តា ម៉ុក អាចមានលក្ខណៈតូចជាងនេះ ។ [436] បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប៉ុល ពត បានបន្តដឹកនាំគណៈកម្មាធិការយោធា ។[437] នួន ជា បានបញ្ជាក់ថា "*មានគណៈកម្មាធិការយោធា ១ របស់បក្ស*



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*ដែលមាន ប៉ុល ពត ជាប្រធាន សុន សេន និង តា ម៉ុក ជាអនុប្រធាន និង កែ ពក ជាសមាជិក* " ។[438] នួន ជា មិនបានទទួលស្គាល់ពីសមាជិកភាពរបស់គាត់នៅក្នុងគណៈកម្មាធិការនេះទេ ប៉ុន្តែមានសាក្សីជាច្រើន និងឯកសារជាភ័ស្តុតាងមួយចំនួនបានលើកឡើងថា នួន ជា ក៏ត្រូវបានរាប់បញ្ចូលជាសមាជិកនៃគណៈកម្មាធិការនេះដែរ ។[439] ចំណែក មាស មុត មិនមានឈ្មោះក្នុងចំណោមសមាជិករបស់គណៈកម្មាធិការយោធាមជ្ឈិមបក្សឡើយ ។

## ១.៣. តួនាទី និងមុខងារ

១៥៤. ដោយពិនិត្យមើលពីតួនាទីរបស់ថ្នាក់ដឹកនាំនៅក្នុងគណៈកម្មាធិការយោធា[440] ប៉ុល ពត, នួន ជា និង សុន សេន ទំនងជាទទួលខុសត្រូវរួមលើមន្ទីរសន្តិសុខ ស-២១ និងនយោបាយសន្តិសុខជាទូទៅ [441]។ សុន សេន បានជួប និងសម្របសម្រួលការងាររបស់គាត់ជាប្រចាំជាមួយនឹងសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ផ្សេងទៀត ដោយធានាថាមេដឹកនាំរបស់បក្សកុំម្មុយនីស្តកម្ពុជាអាចគ្រប់គ្រង និងដឹងជាប្រចាំអំពីសកម្មភាពរបស់កងទ័ពបដិវត្តន៍កម្ពុជា ។ [442]

## ១.៤. អំណាច

១៥៥. យោងតាមសក្ខីកម្មរបស់ ឌុច គណៈកម្មាធិការយោធានេះហើយ ដែលមានសិទ្ធិសម្រេចទាំងអស់ទាក់ទងនឹងការកម្ទេច និងសម្លាប់ ។[443] ទាក់ទងនឹងការបែងចែកអំណាច ឌុច បានលើកឡើងថា "*ក្នុងទ្រឹស្តី ការបែងចែកអំណាចត្រូវបានកំណត់ច្បាស់នៅក្នុងសេចក្តីសម្រេច ៣០ មីនា ១៩៧៦ : ការបែងចែកមុខងារនៅក្នុងការកម្ទេចខ្មាំងត្រូវបានរៀបចំឡើងរវាងលេខាភូមិភាគ ប្រធានគណៈកម្មការមន្ទីរ ៨៧០ តំបន់ឯករាជ្យ និង លេខាសេនាធិការ (មានករណីដោយឡែក ២ គឺ ក្រសួងការបរទេស និងក្រសួងសេដ្ឋកិច្ច ដែលមិនមានការថែងទាក់ទងនឹងបញ្ហាសន្តិសុខនោះទេ)។ នៅក្នុងការអនុវត្តជាក់ស្តែង អំណាចទាំងអស់គឺនៅក្នុងដៃរបស់ ប៉ុល ពត*" ។[444]



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ២. សេនាធិការ

១៥៦. ក្នុងនាមជាលេខាកងពលលេខ ១៦៤ មាស មុត ត្រូវបានចោទប្រកាន់ថាជាសមាជិកសេនាធិការ ដែលជាអ្នករាយការណ៍ដោយផ្ទាល់ទៅកាន់អគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជាដឹកនាំដោយ សុន សេន ហៅ ខៀវ ឬ បង ៨៩ ។[445] មាស មុត បានចូលរួមកិច្ចប្រជុំអគ្គសេនាធិការជាញឹកញាប់ទាក់ទងនឹងផែនការបោសសម្អាតនៅក្នុងកងពលនៃកងទ័ពបដិវត្តន៍កម្ពុជា ។[446]

## ២.១. រចនាសម្ព័ន្ធនៃសេនាធិការ

១៥៧. អង្គការកណ្ដាលរបស់កងទ័ពបដិវត្តន៍កម្ពុជា គឺសេនាធិការ ។ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥ ប៉ុល ពត ប្រធានគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស បានធ្វើជាគណៈអធិបតីនៅក្នុងពិធីចាត់តាំងកងទ័ពបដិវត្តន៍របស់គណៈកម្មាធិការមជ្ឈិមបក្ស ។[447] អង្គភាពសេនាធិការនេះ ត្រូវបានបង្កើតឡើងនៅក្នុងខែ សីហា ឆ្នាំ ១៩៧៥ ដើម្បីធ្វើជាទីបញ្ជាការយោធាជាតិ ។[448] បើយោងតាមសេចក្ដីសម្រេចរបស់អង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ សុន សេន ជា "អ្នកទទួលខុសត្រូវលើសេនាធិការ និងសន្តិសុខ"[449] ដោយមានជំនួយការជាមនុស្សទទួលបន្ទុកផ្នែកការងារនយោបាយ យោធា និងភ័ស្តុភារ[450]។ កម្មាភិបាលដែលអាចក្លាយជាជំនួយការរបស់សេនាធិការ គឺជាក្រុមមានចំនួនច្រើនជ្រើសរើសចេញមកពីកម្មាភិបាល "ត្រឹមវរៈសេនាតូច វរៈសេនាធំ" ហើយ សុន សេន និងលេខាកងពលអាចជួយអប់រំពួកគេបាន ។[451] ឌុច បាននិយាយថាលេខាកងពលជាជំនួយការរបស់សេនាធិការ ។[452]

១៥៨. អនុលោមតាមមាត្រា ១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ សេនាធិការគ្រប់គ្រងកងទ័ពចំនួន ៣ (បី) ប្រភេទ របស់កងទ័ពបក្សកុំម្មុយនីស្តកម្ពុជា ដែលមាន ទ័ពស្រួច ទ័ពតំបន់ និង



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ល្អប ។[453] កងពលទាំងអស់រាប់ទាំងកងពលតូចតំបន់និរតី និងតំបន់បូព៌ា ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសេនាធិការ ។[454] តាមរយៈសេនាធិការ គណៈកម្មាធិការយោធា និងគណៈកម្មាធិការអចិន្ត្រៃយ៍ កងទ័ពទាំងបីប្រភេទដែលបានបញ្ជាក់ខាងលើនេះ គឺ "*ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់មុខ ដាច់ខាត និងគ្រប់ផ្នែករបស់បក្សកុំម្មុយនីស្តកម្ពុជា*" ។[455]

## ២.២. សមាសភាព

១៥៩. នៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍នៃសេនាធិការ មានបុគ្គល ៣ (បី) នាក់ សំខាន់ជាងគេបំផុត[456] ដែលមាន សុន សេន ហៅ ខៀវ ឬ បង ៨៩ ជាអគ្គសេនាធិការ[457] ឬជាលេខានៃអគ្គសេនាធិការ[458] , ម៉ែន សាន ហៅ យ៉ា ជាអនុលេខានៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃសេនាធិការ និងជាសមាជិកមជ្ឈិមពេញសិទ្ធិ (ដែលបីបួនខែក្រោយមកត្រូវបានគេផ្លាស់ឲ្យទៅកាន់តំណែងជាលេខាភូមិភាគពាយ័ព្យ)[459] និង សៀត ឆែ ហៅ ទុំ ហៅ បង ៨១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃសេនាធិការ និងជាសមាជិកមជ្ឈិមត្រៀម[460] (ដែលក្រោយមកបានឡើងជាអនុលេខារបស់ សុន សេន ជំនួស ម៉ែន សាន ហៅ យ៉ា)[461] ។

១៦០. នៅអង្គភាពសេនាធិការ មានមន្ទីរជាច្រើន[462] និងមានបុគ្គលិកសរុបទាំងអស់ប្រហែល ៣០ (សាមសិប) នាក់ [463] ទៅ ៤០ (សែសិប) នាក់[464] ។ សមាជិកភាពក្នុងអង្គភាពសេនាធិការមានដូចជា មាស មុត ទទួលបន្ទុកខាងកងទ័ពជើងទឹក , ស៊ូ ម៉េត ទទួលបន្ទុកខាងកងទ័ពជើងអាកាស[465] ចំណែកខាងកងទ័ពជើងគោកមិនមានអ្នកទទួលបន្ទុកទេ [466]។ ក្រៅពីនេះនៅក្នុងមន្ទីរសេនាធិការ មានក្រុមជំនួយការមួយចំនួនដែលទទួលបន្ទុកគ្រប់គ្រងការងារខុសៗគ្នាដូចជា អ៊ិន លន ហៅ ណាត[467] ទទួលបន្ទុករត់ការងារបញ្ជូនមនុស្សមកមន្ទីរសន្តិសុខស-២១[468], ស៊ុន ទី ហៅ ទាញ ជាប្រធានគណៈមន្ទីរភស្តុភារនៃសេនាធិការ [469], ចាន់ ចក្រី ហៅ មាន[470], ពេជ្រ ឆន ឬ ឆាន់ ហៅ សោម[471] ជាសមាជិកនៃគណៈមន្ទីរ ៦២ ដែលជាគណៈមន្ទីរភស្តុភារនៃសេនាធិការ[472], ឈូក សៅ ដែលជាប្រធានភស្តុភារកងពល



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

លេខ ១៧០ ត្រូវបាន សុន សេន សម្រេចដកឲ្យទៅនៅផ្នែកគណៈមន្ទីរភស្តុភារនៃសេនាធិការ[473] និង រ៉េន[474] ជាជំនួយការសេនាធិការក្នុងអំឡុងពេលមួយ[475] ។

១៦១. ក្រៅពីក្រុមជំនួយការនៃសេនាធិការនៅមានបុគ្គលិកដទៃទៀត ដែលកាន់កាប់ផ្នែកផ្សេងៗ ដូចជា ថាស ជាអ្នកមើលខុសត្រូវមន្ទីរសេនាធិការ និងធ្វើការក្នុងមន្ទីរនីរសាររបស់សេនាធិការ[476] , ឡុង ជាប្រធានផ្នែកវិទ្យុទាក់ទង និងទូរស័ព្ទនៅសេនាធិការ[477] , ឡុញ ដុស ជាសមាជិកផ្នែកខាងវិទ្យុទាក់ទង និងទូរស័ព្ទនៅសេនាធិការ[478], រ៉ន ជាអ្នកទទួលទូរស័ព្ទប្រចាំថ្ងៃរបស់មន្ទីរសេនាធិការ[479], នឿន ធ្វើការក្នុងមន្ទីរនីរសាររបស់សេនាធិការ[480] និងជាប្រធានផ្នែកព័ត៌មាន[481], ម៉ែន កែវ ជាអ្នកបើកបរនៅមន្ទីរសេនាធិការ[482] , ផន ជាអ្នកបើកឡានឲ្យ សុន សេន ផ្ទាល់[483] , កែ ពេជ្រវណ្ណៈ ហៅ ថា ហៅ យុទ្ធ ជាអ្នកបើកបរឡានដឹកស្បៀងពីភ្នំពេញទៅកាន់ស្វាយរៀង សម្រាប់ផ្គត់ផ្គង់ មន្ទីរសេនាធិការនៅខេត្តស្វាយរៀង[484], ព្រមទាំងឈ្មោះ និត, ឡា និង ទូច ដែលជាស្ត្រីចុងភៅ [485]។

១៦២. **មាស មុត** អាចត្រូវបានតែងតាំងជាគណៈជំនួយការផ្នែកនយោបាយរបស់សេនាធិការនៅក្នុងអំឡុងពេលនៃសមាជរបស់មជ្ឈិមបក្សនាឆ្នាំ ១៩៧៥ ដែលតាមរយៈសមាជនោះបានតែងតាំង សុន សេន ឲ្យទទួលខុសត្រូវផ្នែកយោធា និងសន្តិសុខ ចាត់ចែងបង្កើតកងទ័ពជើងទឹក និងជើងអាកាស ។[486]

១៦៣. ទាក់ទងនឹងសមាជិកភាពរបស់ **មាស មុត** នៅក្នុងសេនាធិការ យើងឃើញថាចំណុចនេះនៅមានវិមតិសង្ស័យច្រើន ។ បើយោងតាម "ឯកសារស្តីពីសមាជលើកទី ៥ របស់ ប៉ុល ពត-អៀង សារី" នៅថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨[487] **មាស មុត** មិនមានឈ្មោះក្នុងសមាសភាពគណៈកម្មាធិការសេនាធិការ ដោយហេតុថាក្នុងសមាសភាពគណៈកម្មាធិការសេនាធិការ មានតែឈ្មោះ ប៉ុល ជាប្រធាន, ម៉ែត ជាសមាជិក , ម៉ុក ជា សមាជិក និង រួន ជាសមាជិកតែប៉ុណ្ណោះ ។ ប៉ុន្តែយោងតាមសក្ខីកម្មរបស់ ឌុច បានលើកឡើងថា ប្រហែលជាទាល់តែ យ៉ា និង ទុំ ត្រូវបានកម្ទេច[488] ទើបមានសមាជិក ស៊ូ ម៉ែត និង **មាស មុត** [489]។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ទោះបីជាការសន្មតរបស់ ឌុច អាចនឹងត្រឹមត្រូវក៏ដោយ ក៏ការក្លាយខ្លួនជាសមាជិកសេនាធិការតាមរយៈមហាសន្និបាតបក្សនាថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ គឺមានរយៈពេលមិនដល់ ៥០ (ហាសិប) ថ្ងៃ ផងមុនពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ។

### ២.៣. តួនាទី និង មុខងារ

១៦៤. ឌុច បានបញ្ជាក់ថា *"អគ្គសេនាធិការ ទទួលបន្ទុកអនុវត្តតាមបញ្ជារបស់ ប៉ុល ពត ហើយ សុន សេន ជាអ្នកអនុវត្តបញ្ជាទាំងនោះ"* ។[490] ប៉ុល ពត ជាអ្នកទទួលខុសត្រូវទូទៅលើយោធា ។[491] ក្នុងឋានៈជាអគ្គសេនាធិការ សុន សេន ជាអ្នកទទួលសេចក្តីរាយការណ៍ ហើយគាត់ក៏ជាអ្នកបន្តផ្សាយបញ្ជា ។[492] ដូច្នេះហើយ សេនាធិការគឺជាស្ថាប័នប្រតិបត្តិការរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលទទួលបញ្ជាផ្ទាល់ពីគណៈកម្មាធិការយោធា និង/ឬ គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលជាអ្នកធ្វើគោលនយោបាយអចិន្ត្រៃយ៍តំណាងឲ្យគណៈកម្មាធិការមជ្ឈិម ។ បន្ទាប់មកសេនាធិការអនុវត្តបទបញ្ជាទាំងនោះ តាមរយៈការប្រជុំជាញឹកញាប់ជាមួយមេបញ្ជាការកងពលមជ្ឈិមនានា និងកងវរៈសេនាធំឯករាជ្យ ដែលពេលប្រជុំនោះមាន សុន សេន ជាអគ្គសេនាធិការបានពាំនាំបន្ត និងប្រកាសដាក់ចេញនូវមាគ៌ារបស់ថ្នាក់លើ ឬរបស់បក្សដល់មេបញ្ជាការទាំងនោះ ទន្ទឹមនឹងនោះក៏មានការស្តាប់នូវការរាយការណ៍ពីពួកគេផងដែរ ដែលនៅក្នុងករណីខ្លះអង្គប្រជុំក៏បានសម្រេចដាក់ចេញជាបទបញ្ជាភ្លាមៗលើបញ្ហាសំខាន់ៗមួយចំនួន ។[493]

១៦៥. ចាប់តាំងពីការបង្កើតដំបូង សេនាធិការសម្របសម្រួលភារកិច្ចផ្សេងៗ ដូចជា ការរៀបចំកងពល បញ្ជាការដ្ឋានចាត់តាំង ភ្នាក់ងារស៊ើបការណ៍ ការរៀបចំទីតាំងកងទ័ព ការរៀបចំផែនការ និងការដឹកនាំប្រតិបត្តិការយោធា ភ័ស្តុភារ អាវុធ គ្រាប់រំសេវ ការផ្គត់ផ្គង់ស្បៀងអាហារ សម្លៀកបំពាក់ ការដឹកជញ្ជូន ថ្នាំពេទ្យ[494] ការចេញបញ្ជាចល័តកងទ័ពទៅកាន់កងពលនានា[495] និងការដាក់ចេញនូវវិធានការផលិតស្រូវដល់គ្រប់កងពល[496]។

១៦៦. មាស មុត នាពេលកន្លងមកបានទទួលស្គាល់តួនាទីរបស់គាត់ខ្លះៗដែរ ដោយបានបញ្ជាក់ថា គាត់បានជួប សុន សេន បាន "ប៉ុន្មានដង" ដើម្បីអនុវត្តបញ្ជារបស់គណៈកម្មាធិការមជ្ឈិម ។ មាស មុត ថែមទាំងបានបញ្ជាក់ថា *"ភាគច្រើនយើងនិយាយអំពីបញ្ហាព្រំដែន"* ។[497] ម្យ៉ាងទៀត រាល់ការប្រាស្រ័យទាក់ទងរបស់គាត់ជាលាយលក្ខណ៍អក្សរជាមួយ សុន សេន គឺពាក់ព័ន្ធតែនឹងការបញ្ជូនកងទ័ពជាធម្មតា ការផលិតស្រូវ[498] ហើយមិនមានការពាក់ព័ន្ធនឹងការចាប់ខ្លួនទេ[499]។

១៦៧. កំណត់ហេតុនៃអង្គប្រជុំយោធាបានឱ្យដឹងថា[500] ក្នុងនាមជាមេបញ្ជាការកងពល បន្ទាប់ពីបានទទួលការរាយការណ៍ផ្ទៃក្នុងកងពល[501] មាស មុត បានរាយការណ៍បន្ត និងទទួលបញ្ជាពី សុន សេន ទាក់ទងនឹងការបង្កបង្កើនស្រូវ បញ្ហាយោធាជុំវិញស្ថានភាពនៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រង[502] ក្នុងនោះរួមបញ្ចូលទាំងការចាប់ខ្លួនមនុស្ស និងទូក ដែលរំលោភចូលអធិបតេយ្យភាពនៃដែនសមុទ្រកម្ពុជាដោយខុសច្បាប់[503] និងការចាប់ខ្លួនខ្មាំងតាមចម្លើយសារភាពដែលបានឆ្លើយដាក់[504] ដូចជាមេបញ្ជាការកងពលដ៏ទៃទៀតដែរ[505]។ បន្ទាប់មក សុន សេន ជាអ្នករាយការណ៍បន្តទៅកាន់អង្គការ[506] និងជាអ្នកចេញបញ្ជាឱ្យ មាស មុត អនុវត្តតាមផងដែរដូចជា ករណីចេញបញ្ជាឱ្យកម្ទេចខ្មាំងដែលចូលមកដែនទឹករបស់ប្រទេសកម្ពុជាដោយខុសច្បាប់[507] បញ្ជាឱ្យកងទ័ពធ្វើស្រូវឱ្យបានតាមផែនការ ឬ លើសពីផែនការដែលបានកំណត់[508]។

## ២.៤. អំណាច

១៦៨. ការតែងតាំងមុខតំណែងដឹកនាំនៅក្នុងកងពលមជ្ឈិមនានា ត្រូវបានធ្វើឡើងក្នុងនាមគណៈមជ្ឈិម ដោយ ប៉ុល ពត, នួន ជា, អៀង សារី និង សុន សេន ។[509] សេនាធិការក៏មានអំណាចផង ដែរក្នុងការដកមុខតំណែងពីលេខាកងពល និងកម្មាភិបាលផ្សេងទៀតនៅកងពលមជ្ឈិម។[510] ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង បានបង្ហាញឱ្យឃើញថាសូម្បីតែការដកតំណែងអនុលេខាកងពលមជ្ឈិម ឬកម្មាភិបាលថ្នាក់ទាបជាងនេះ ក៏ត្រូវមានសេចក្តី



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

សម្រេចពីអង្គការ ដែលមានន័យថាជា សុន សេន ឬ ក៏ជាស្ថាប័នដែលមានឋានៈខ្ពស់ជាងនេះ ។[511]

១៦៩. តាមរយៈសេចក្ដីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[512] សិទ្ធិកម្ទេចខាងក្នុង និងខាងក្រៅជួរកងទ័ពមជ្ឈិម ត្រូវតែសម្រេចដោយសេនាធិការ ។ លើសពីនេះទៀត ឌុច[513] ក៏បានលើកឡើងពីមនុស្សចំនួន ១៣ (ដប់បី) នាក់[514] រួមមាន ប៉ុល ពត , នួន ជា , សោ ភឹម , ឈិត ជឿន ឬ អ៊ុង ជឿន ហៅ ម៉ុក , វន វ៉េត , សុន សេន , ខៀវ សំផន , កុយ ធួន , ម៉ែន សាន ហៅ យ៉ា , វស់ ញឹម , កែ ពក , ជូ ជេត ហៅ ស៊ី , កង ចាប ហៅ សែ ដែលមានសិទ្ធិពេញលេញក្នុងការកម្ទេច ហើយបើតាមឯកសារនេះ **មាស មុត** មិនបានស្ថិតនៅក្នុងចំណោមអ្នកទាំងនោះទេ ។

១៧០. នៅក្នុងរចនាសម្ព័ន្ធរបស់សេនាធិការ ឌុច បានលើកឡើងថា គ្មាននរណាផ្សេងមានសិទ្ធិចាប់ខ្លួនដោយកងទ័ពពិសេសរបស់មជ្ឈិមក្រៅពី សុន សេន ទេ ។[515] ឌុច បានអះអាងថា *"សេនាធិការ គឺសំដៅតែលើលេខានៃអគ្គសេនាធិការ និយាយឱ្យចំទៅគឺ សុន សេន។ ប៉ុន្តែ សុន សេន ខ្លួនឯង ពេលខ្លះត្រូវសុំការអនុញ្ញាតជាគោលការណ៍ពី ប៉ុល ពត ។ ហើយ សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ។ នៅមានឯកសារច្រើនដែលទាក់ទងនឹងការអនុវត្តនេះ ដូចជា ករណីសុំការពិនិត្យពី មិត្ត ណាត និង ពីន ជាដើម។ ក្នុងករណីដែលមេកងពលនោះ សុំរក្សាទុកឈ្មោះអ្នកណាមួយមិនទាន់បញ្ជូន មេកងពលនោះត្រូវទទួលខុសត្រូវក្នុងករណីនេះ។ ចំពោះ ស្វ៊ី ម៉េត និង* ***មាស មុត*** *មិនមានឯកសារបញ្ជាក់ពីការសុំការពិនិត្យនេះទេ"* ។[516]

១៧១. យោងតាមកំណត់ហេតុនៃការប្រជុំរវាងកងពលដែលពាក់ព័ន្ធ សុន សេន និង ឌុច មានលក្ខណៈស៊ីសង្វាក់ទៅនឹងអ្វីដែល ឌុច បានអះអាងខាងលើ ដែលបញ្ជាក់ថាកងពលមិនមានសិទ្ធិសម្រេចចាប់ខ្លួនឡើយ គឺកងពលត្រូវរាយការណ៍ទៅ សុន សេន ដែលជាអ្នកកំណត់ឈ្មោះបុគ្គលដែលត្រូវចាប់ខ្លួន ហើយអង្គប្រជុំនឹងសម្រេចតាមអ្វីដែល សុន សេន បានស្នើ



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឡើង ។ បន្ទាប់មកទៀត ឌុច បានផ្តល់មតិទាក់ទងនឹងនីតិវិធីនៃការចាប់ខ្លួនដូចជា មន្ទីរសន្តិសុខ ស-២១ និងកងពលសហការគ្នាចាប់ពីកន្លែងដាក់ឡានតែម្តង ឬ មន្ទីរសន្តិសុខ ស-២១ និងកងពលពិគ្រោះគ្នាដោយយកវិធានការជាក់ស្តែង ។[517]

## ឃ. សមាសភាពកងទ័ពបដិវត្តន៍កម្ពុជា

១៧២. តាមខ្លឹមសារនៃមាត្រា ១៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ កងទ័ពបដិវត្តន៍កម្ពុជាមាន ៣ (បី) ប្រភេទ គឺ កងទ័ពស្រួច កងទ័ពតំបន់ និងកងឈ្លប ។[518] កងកម្លាំងទ័ពទាំងបីប្រភេទនេះស្ថិតនៅ "*ក្រោមការដឹកនាំផ្តាច់មុខ និងផ្តាច់ការរបស់បក្សកុម្មុយនីស្តកម្ពុជា* "[519] និងត្រូវបានចាត់ទុកថាជា "*ឧបករណ៍ផ្តាច់ការរបស់បក្ស* "[520] ។ កងទ័ពបដិវត្តន៍កម្ពុជារួមមាន "កងទ័ពស្រួចរបស់មជ្ឈិម" និងអង្គភាពយោធាមូលដ្ឋានទាំងអស់[521] ដែលចុងក្រោយស្ថិតនៅក្រោមការបញ្ជារបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការយោធារបស់មជ្ឈិម[522]។

### ១. កងទ័ពស្រួច

១៧៣. សមាសភាពកងទ័ពស្រួច មានកងទ័ពនៅតាមកងពលនានា[523] និងកងទ័ពនៅតាមបណ្តាកងវរៈសេនាធំឯករាជ្យ ។ ជាក់ស្តែង កងពលត្រូវបានបែងចែកជា ២ (ពីរ) ប្រភេទ រួមមានកងពលមជ្ឈិម និងកងពលភូមិភាគ ខណៈដែលកងពលមជ្ឈិមមានសិទ្ធិរាយការណ៍ដោយផ្ទាល់ទៅមជ្ឈិម ។[524]

១៧៤. ជាទូទៅក្នុងកងពលមួយមានយ៉ាងហោចណាស់ ៣ (បី) កងវរៈសេនាធំ[525] ដែលមានចំនួនយោធាចាប់ពី ១.០០០ (មួយពាន់) នាក់ ទៅ ១.៨០០ (មួយពាន់ប្រាំបីរយ) នាក់។ នៅក្នុងកងវរៈសេនាធំនីមួយៗមានកងវរៈសេនាតូចចំនួន ៣ (បី) ទៅ ៤ (បួន) ដែលកងវរៈសេនា



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

តូចនីមួយៗមានសមាជិកចាប់ពី ៣៥០ (បីរយហាសិប) នាក់ ទៅ ៦០០ (ប្រាំមួយរយ) នាក់ ។[526] នៅក្នុងកងវរៈសេនាតូចនីមួយៗ មានកងអនុសេនាធំចំនួន ៣ (បី) ទៅ ៤ (បួន) ដែលមានយោធាចន្លោះពី ១០០ (មួយរយ) នាក់ ទៅ ២០០ (ពីររយ) នាក់ ។[527] ចំណែកនៅក្នុងកងអនុសេនាធំនីមួយៗមានចំនួន ៣ (បី) ឬ ៤ (បួន) កងអនុសេនាតូច ដែលមានសមាជិកប្រហែល ៣៦ (សាមសិបប្រាំមួយ) នាក់ [528] និងមានក្រុមបច្ចេកទេសមួយ[529] ។ នៅក្នុងកងអនុសេនាតូចនីមួយៗ មានក្រុមចំនួន ៣ (បី) ដែលក្រុមនីមួយៗមានសមាជិកចំនួន ១២ (ដប់ពីរ) នាក់ ។[530]

១៧៥. ការរៀបចំឡើងវិញនូវកងពលនានាបានកើតឡើងផងដែរ ក្រោយពីមានភាពតានតឹងនៃជម្លោះប្រដាប់អាវុធជាមួយវៀតណាមចាប់តាំងពីចុងឆ្នាំ ១៩៧៧ មក ។[531] ការណ៍នេះកើតឡើងរួមជាមួយនឹងការបង្កើតកងពលមជ្ឈិមថ្មីមួយចំនួន ដែលកើតចេញមកពីការពង្រីក និងការរៀបចំឡើងវិញនូវអង្គភាពយោធានានារបស់ភូមិភាគនិរតី ដែលកងពលទាំងនេះមានដូចជា កងពលលេខ ៣៤០ , កងពលលេខ ២២១ , កងពលលេខ ៤៤០ , កងពលលេខ ៤៦០ , កងពលលេខ ២១០ , កងពលលេខ ២៣០ , កងពលលេខ ២៥០ និងកងពលលេខ ២៧០ ។[532]

## ២. កងពលនានារបស់មជ្ឈិម

១៧៦. កងទ័ពជើងគោក កងទ័ពជើងទឹក និងកងទ័ពជើងអាកាសថ្មី ត្រូវបានរៀបចំឡើងតាមរយៈអង្គប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥ ។[533]

១៧៧. កងទ័ពបដិវត្តន៍កម្ពុជា បានបង្កើតឡើងផងដែរនូវបញ្ជាការដ្ឋានសមរភូមិចំនួនពីរ ដែលបញ្ជាការដ្ឋានសមរភូមិនីមួយៗ ត្រួតពិនិត្យដោយផ្ទាល់លើប្រតិបត្តិការនានារបស់កងពលជាច្រើន ។ បញ្ជាការដ្ឋានសមរភូមិទាំងពីរនេះត្រូវបានបង្កើតឡើងនៅភូមិភាគបូព៌ា ។ បញ្ជាការដ្ឋានសមរភូមិទីមួយមានទីតាំងនៅតាមផ្លូវជាតិលេខ ១ ក្នុងតំបន់ ២៣ ។ បញ្ជាការដ្ឋាននេះត្រូវ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

បានបញ្ជាដោយ សុន សេន[534] ហើយរួមមានដូចជា កងពល ៧0៣ , កងពល ៣៤0 , កងពល ២២១ , កងពល ៤៦0 , កងពល ៨0៥ , កងពល ២១0 , កងពល ២៣0 , កងពល ២៥0 និងកងពល ២៧0 ។[535] បញ្ជាការដ្ឋានសមរភូមិទីពីរ មានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ ៧ ដែលស្ថិតនៅក្នុងភូមិភាគបូព៌ាផងដែរ។ បញ្ជាការដ្ឋាននេះរួមមាន កងពល ២0៧ (អតីតកងពលលេខ ៣១0 )[536] , កងពល ៦0៣ (អតីតកងពល ៤៥0 )[537], កងពល ២៨0[538] , កងពល ១៧៥[539] រួមបញ្ចូលជាមួយសមាសភាពមកពីកងពល ៥0២[540] និងកងកម្លាំងនៃភូមិភាគកណ្តាល (ភូមិភាគឧត្តរចាស់)[541]។

១៧៨. បញ្ជាការដ្ឋានសមរភូមិផ្លូវជាតិលេខ ៧ ស្ថិតនៅក្រោមបញ្ជារបស់ សោ ភឹម ជាប្រធាន ជាមួយនឹង កែ ពក ដែលជាអនុប្រធាន។ សោ ភឹម ត្រូវបានជំនួសដោយ សុន សេន បន្ទាប់ពីការបោសសម្អាត និងការធ្វើអត្តឃាតរបស់គាត់ ។ កងពលមជ្ឈិមត្រូវបានបោសសម្អាត ដែលនាំទៅដល់ការរៀបចំចាត់តាំងឡើងវិញជាបន្តបន្ទាប់ និងការបញ្ចូលគ្នាទៅជាមួយនឹងកងពលផ្សេងៗ ។ ករណីនេះមានជាពិសេសចំពោះកងពលលេខ ៣១0 , កងពលលេខ ៤៥0 និងកងពលលេខ ៩២0 នៅក្នុងក្របខណ្ឌនៃការបោសសម្អាតក្នុងភូមិភាគឧត្តរ ដែលអង្គភាពទាំងនេះមានដើមកំណើតចេញមកពីភូមិភាគឧត្តរ ។ បន្ទាប់ពីដំណើរការបោសសម្អាតនេះ កងពលលេខ ៣១0 និងកងពលលេខ ៤៥0 ត្រូវបានរៀបចំចាត់តាំងឡើងវិញជាកងពលលេខ ២0៧[542] និងកងពលលេខ ៦0៣[543] ។

## រចនាសម្ព័ន្ធនៃកងទ័ពមជ្ឈិម

១៧៩. កងពលនានារបស់មជ្ឈិមត្រូវបានបញ្ជាផ្ទាល់ដោយមជ្ឈិម ហើយកងវរៈសេនាធំឯករាជ្យក៏ទទួលបញ្ជាតាមរបៀបដូចគ្នានេះដែរ ។ កងពលមជ្ឈិម គឺជាកងកម្លាំងយោធាដ៏ចម្បងរបស់កងទ័ពបដិវត្តន៍កម្ពុជា ។ ដូចនេះហើយ កងពលមជ្ឈិមបានធ្វើប្រតិបត្តិការយោធាជាចម្បងក្នុងការការពារជាតិប្រឆាំងទៅនឹងខ្មាំងសត្រូវខាងក្រៅ ។ ជាក់ស្តែងស្ថានភាពរបស់កងពល



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

មជ្ឈិមនានាជារឿយៗ ត្រូវបានគេរៀបចំចាត់តាំងឡើងវិញ ត្រូវបានរំលាយ ឬត្រូវបានបញ្ចូលគ្នាទៅវិញទៅមក នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

១៨០. ចាប់តាំងពីខែ មីនា ឆ្នាំ ១៩៧៧ កងកម្លាំងទ័ពរបស់មជ្ឈិមរួមមាន កងពលលេខ ៨០១ , កងពលលេខ ៧០៣ , កងពលលេខ ៣១០ , កងពលលេខ ៤៥០ , កងពលលេខ ១៧០ , កងពលលេខ ៦៩០ , កងពលលេខ ៥០២ , កងពលលេខ ៩០០ , កងពលលេខ ១៦៤ និងកងវរៈសេនាធំឯករាជ្យលេខ ១៥២ , កងវរៈសេនាធំឯករាជ្យលេខ ៣៧៧ និងកងវរៈសេនាធំឯករាជ្យលេខ ៤៨៨ ។[544]

១៨១. **មាស មុត** ត្រូវបានចោទថាជាលេខាកងពលលេខ ១៦៤ នៃកងទ័ពបដិវត្តន៍កម្ពុជា ដែលមានមូលដ្ឋាននៅកំពង់សោម រាម និង កំពត ។ គាត់ជាលេខាកងពលលេខ ១៦៤ យ៉ាងហោចណាស់ចាប់ពីខែ មករា ឆ្នាំ ១៩៧៦ រហូតដល់យ៉ាងហោចណាស់ខែ មេសា ឆ្នាំ ១៩៧៨ ។ សាក្សីខ្លះជឿថាគាត់ជាលេខាចាប់ពីក្រោយខែ មេសា បន្តិច ក្នុងឆ្នាំ ១៩៧៥ រហូតដល់ ខែ មករា ឆ្នាំ ១៩៧៩ ។[545]

## ២.១. កងពលលេខ ១៦៤

### ប្រវត្តិនៃការកកើតចេញពីកងពលលេខ ៣

១៨២. កងពលលេខ ១៦៤ មានដើមកំណើតចេញពីកងពលលេខ ៣ ជាកងទ័ពដែលមានប្រភពមកពីភូមិភាគនិរតី[546] និងត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៧៣ ឬដើមឆ្នាំ ១៩៧៤[547] ។ **មាស មុត** ដែលត្រូវជាកូនប្រសារ តា ម៉ុក ត្រូវបានតែងតាំងជាប្រធានកងពលលេខ ៣ (ទទួលបន្ទុកផ្នែកនយោបាយ) [548] និងមាន ម៉ែន ង៉ែត ហៅ ង៉ែត និង ឡុង សារឿន ហៅ រឿន ឬ រិន[549] ត្រូវជាអនុប្រធានកងពលរបស់ **មាស មុត** ។[550]



E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១៨៣. ក្នុងកងពលលេខ ៣ អង្គភាពក្រោមបង្គាប់នីមួយៗទទួលបញ្ជាផ្ទាល់ពីថ្នាក់លើរបស់ខ្លួន ហើយកងវរៈសេនាធំ និងកងវរៈសេនាតូចត្រូវបានគ្រប់គ្រងដោយ មាស មុត ។[551] កងពលលេខ ៣ នេះ មានកងវរៈសេនាធំនៅក្រោមបង្គាប់ចំនួន ៣ (បី) [552] គឺ កងវរៈសេនាធំលេខ ២០ , កងវរៈសេនាធំលេខ ២១ , កងវរៈសេនាធំលេខ ២២[553]។

១៨៤. កងវរៈសេនាធំលេខ ២០ មានឈ្មោះ ម៉ែន ង៉ែត ជាប្រធានកងវរៈសេនាធំ [554] ដោយមានកងវរៈសេនាតូចចំនួន ៣ (បី) នៅក្រោមការគ្រប់គ្រងរបស់ខ្លួន គឺកងវរៈសេនាតូចលេខ ៣២០ , កងវរៈសេនាតូចលេខ ៣៣០ និងកងវរៈសេនាតូចលេខ ៣៧០ ។ កងវរៈសេនាធំលេខ ២០ នេះ ឈរជើងនៅស្ទឹងហាវ ។ [555]

១៨៥. កងវរៈសេនាធំលេខ ២១ មានឈ្មោះ តា មាញ ជាប្រធានកងវរៈសេនាធំ [556] ដោយមានកងវរៈសេនាតូចចំនួន ៣ (បី) នៅក្រោមការគ្រប់គ្រងរបស់ខ្លួន គឺកងវរៈសេនាតូចលេខ ៤១០ , កងវរៈសេនាតូចលេខ ៤២០ និងកងវរៈសេនាតូចលេខ ៤៨០ ។ កងវរៈសេនាធំលេខ ២១ មានទីបញ្ជាការនៅជិតរាម និងត្រូវបានបញ្ជូនឲ្យឈរជើងនៅតាមដែនកោះនៅក្នុងសមុទ្រដែលជាដែនអធិបតេយ្យរបស់កម្ពុជា ដូចជា កោះតាង កោះព្រីង កោះពូលូវៃចាស់ និងកោះពូលូវៃថ្មី ជាដើម។[557]

១៨៦. កងវរៈសេនាធំលេខ ២២ មានឈ្មោះ ម៉ម ជឹម ហៅ យ៉ាន ជាប្រធានកងវរៈសេនាធំ[558] ដោយមានកងវរៈសេនាតូចចំនួន ២ (ពីរ) នៅក្រោមបង្គាប់ គឺកងវរៈសេនាតូចលេខ ៥២០ និងកងវរៈសេនាតូច៥៤០ ដែលមានទីតាំងមូលដ្ឋាននៅកោះសេះ កោះថ្មី និងនៅកំពង់សោម ។[559]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01596066



**ការប្រែក្លាយមកជាកងពលលេខ ១៦៤**

១៨៧. នៅក្នុងឆ្នាំ ១៩៧៥ កងពលលេខ ៣ បានមកបោះទីតាំងនៅជិតព្រលានយន្តហោះពោធិ៍ចិនតុង ។[560] ប៉ុន្តែក្រោយថ្ងៃរំដោះ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ កងពលលេខ ៣ ត្រូវបានបញ្ជាឲ្យទៅបោះទីតាំងនៅកំពង់សោម ។[561] បន្ទាប់ពីផ្លាស់ប្តូរទៅកាន់កំពង់សោម[562] កងពលលេខ ៣ បានផ្លាស់ប្តូរឈ្មោះទៅជា កងពលមជ្ឈិមលេខ ១៦៤ តាមរយៈការប្រជុំធំមួយធ្វើឡើងនៅស្តាតអូឡាំពិក នាថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ១៩៧៥[563] ហើយក្រោយមកក៏បានប្រែក្លាយជាកងទ័ពជើងទឹក នៅថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៧៥[564] ដែលដឹកនាំដោយ **មាស មុត**[565]។ កងទ័ពជើងទឹកនេះ មានតួនាទីឈរជើងនៅតាមដែនកោះនានា ដូចជា កោះពូលូវៃ កោះតាង កោះព្រីង កោះរ៉ុង កោះរ៉ុងសន្លឹម កោះសេះ កោះថ្មី និងកោះតូចៗផ្សេងទៀត[566] និងឈរជើងនៅដីគោកផងដែរដូចជានៅ កងកេង រាម ទឹកសាប ស្ទឹងហាវ កំពង់សោម និងមានវ៉ាដានៅបូកគោ។[567]

១៨៨. **មាស មុត** បានក្លាយទៅលេខាកងពលលេខ ១៦៤ នៃកងទ័ពជើងទឹក[568] ប្រចាំនៅកំពង់សោម[569] (បច្ចុប្បន្ន ខេត្តព្រះសីហនុ) ដែលបែងចែងជាកងកម្លាំងថ្មើរជើង និងកងនាវា[570] យ៉ាងហោចណាស់រវាងខែ មករា ឆ្នាំ ១៩៧៦[571] ដល់ខែ មេសា ឆ្នាំ១៩៧៨[572] និងជាប្រធានគណៈកម្មាធិការតំបន់កំពង់សោមផងដែរ[573]។ នៅពេលដែល **មាស មុត** បានក្លាយជាលេខាកងពលលេខ ១៦៤ គាត់ក៏ដូចជាលេខាកងពលផ្សេងៗទៀតដែរ បានរាយការណ៍ផ្ទាល់ទៅសេនាធិការ និងទៅមជ្ឈិមបក្សទាក់ទងនឹងបញ្ហាយោធា រដ្ឋបាល និងបញ្ហាផ្សេងៗទៀត ។[574]

១៨៩. តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបានចោទប្រកាន់ថា **មាស មុត** គ្រប់គ្រងលើបុគ្គលិកជាកងទ័ព និងជាប្រជាជនធម្មតា ចំនួន ១៧.000 (មួយម៉ឺនប្រាំពីរពាន់)[575]នាក់ ដោយក្នុងនោះមានកងទ័ពប្រហែលចំនួនពី ៨.៥00 (ប្រាំបីពាន់ប្រាំរយ)[576] នាក់ ទៅ ១០.000 (មួយម៉ឺន)[577]នាក់ ឬ ១២.000 (មួយម៉ឺនពីរពាន់) នាក់ នៅចុងឆ្នាំ ១៩៧៥[578],



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៨.៦១១ (ប្រាំបីពាន់ប្រាំមួយរយដប់មួយ) នាក់ នៅខែតុលា ឆ្នាំ ១៩៧៦[579] និង ៨.៥៦៨ (ប្រាំបីពាន់ប្រាំរយហុកសិបប្រាំបី) នាក់ នៅខែ មីនា ឆ្នាំ ១៩៧៧ [580]។ តាមបែបបទរដ្ឋបាល កំពង់សោមគឺជាតំបន់ឯករាជ្យដែលដឹកនាំដោយ **មាស មុត** និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិមបក្ស ។[581] តាមបែបបទយោធា តំបន់នេះតំបន់យោធាស្វយ័ត ហើយស្ថិតនៅក្រោមសេនាធិការ ។[582]

### សមាសភាពកងពលលេខ ១៦៤

១៩០. បន្ទាប់ពីទៅដល់កំពង់សោម ហឹង ខឿន ហៅ ខឹម[583] និង ជ័យ ហាន ហៅ ឆាន់ ឬ នង ចាន់ បានក្លាយទៅជាអនុប្រធានរបស់ **មាស មុត** ជំនួស ឡុង សារឿន ហៅ រឿន ឬ រិន ដែលបានក្លាយទៅជាប្រធានកងវរៈសេនាធំលេខ ១៤០[584] និង ម៉ែន ង៉ែត ហៅ ង៉ែត ដែលក្លាយទៅជាប្រធានកងវរៈសេនាធំលេខ ១៦១[585] ។ ហឹង ខឿន ហៅ ខឹម មកពីភូមិភាគបូព៌ា ជាអនុប្រធានកងពល[586] ទទួលបន្ទុកខាងយោធា ត្រូវបានចាប់ខ្លួននៅក្នុងថ្ងៃទី ២១ ខែមេសា ឆ្នាំ ១៩៧៧ និងត្រូវបានកម្ទេចនៅមន្ទីរសន្តិសុខ ស-២១ ក្នុងឆ្នាំដដែល[587] ។ ចំណែក ជ័យ ហាន ហៅ ឆាន ហៅ នង ចាន់ ដែលជាអនុប្រធានម្នាក់ទៀតកងពល[588] ត្រូវបានកម្ទេចនៅឆ្នាំ ១៩៧៦[589] ។ រីង ញ៉ែត ញ៉ាន់ ហៅ តាញ៉ាន់ ដែលទទួលខុសត្រូវខាងសេដ្ឋកិច្ច បានក្លាយទៅជាអនុប្រធានកងពល ចាប់ពីចុងឆ្នាំ ១៩៧៨ រហូតដល់ឆ្នាំ ១៩៧៩ បន្ទាប់ពី ហឹង ខឿន ហៅ ខឹម ត្រូវបានចាប់ខ្លួន។

១៩១. ក្រោយពីការផ្លាស់ប្តូរឈ្មោះមកជាកងពលលេខ ១៦៤ ការរៀបចំរចនាសម្ព័ន្ធកងទ័ពនៅក្រោមបង្គាប់ក៏ត្រូវបានរៀបចំផងដែរ ។ កងវរៈសេនាធំទាំងបីរបស់កងពលលេខ ៣ ត្រូវបានផ្លាស់ប្តូរឈ្មោះដូចជា កងវរៈសេនាធំលេខ ២០ ប្តូរទៅជាកងវរៈសេនាធំលេខ ១៦១ , កងវរៈសេនាធំលេខ ២១ ប្តូរទៅជាកងវរៈសេនាធំលេខ ១៦២ និងកងវរៈសេនាធំលេខ ២២ ប្តូរទៅជាកងវរៈសេនាធំលេខ ១៦៣ ។[590] ឈ្មោះកងវរៈសេនាធំដែលត្រូវបានផ្លាស់ប្តូរជាថ្មី



*E.C.C.C* *C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

នេះត្រូវបានគេដឹងឮ និងហៅជាទូទៅថា កងវរៈសេនាធំលេខ ៦១ , កងវរៈសេនាធំលេខ ៦២ និងកងវរៈសេនាធំលេខ ៦៣[591] តាមលំដាប់រៀងគ្នា រួមទាំងកងវរៈសេនាធំថ្មីមួយទៀត ដែលទើបតែរៀបចំបង្កើត គឺអង្គភាពលេខ ១៤០ [592]។

១៩២. កងវរៈសេនាធំលេខ ១៦១, ១៦២ និង ១៦៣ ជាអង្គភាពមានតួនាទីប្រចាំការ និងប្រយុទ្ធលើគោក ចំណែកឯកងវរៈសេនាធំលេខ ១៤០ ជាអង្គភាពប្រយុទ្ធលើទឹក ។[593] ទោះបីជាមានការផ្លាស់ប្តូរឈ្មោះកងពល និងកងវរៈសេនាធំយ៉ាងណាក៏ដោយ ក៏ប៉ុន្តែមេបញ្ជាការប្រចាំកងវរៈសេនាធំនីមួយៗ មិនមានការផ្លាស់ប្តូរសមាសភាពឡើយ ។[594]

១៩៣. កងវរៈសេនាធំលេខ ១៦១ មានឈ្មោះ ម៉ែន ង៉ែត នៅតែជាប្រធានកងវរៈសេនាធំនេះដដែល បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ។[595] ប៉ុន្តែបន្ទាប់មកគាត់ត្រូវគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ក្នុងអំឡុងឆ្នាំ ១៩៧៧ ។[596] សុខ ភាព ត្រូវបានជំនួសជាប្រធានកងវរៈសេនាធំ ។[597] កងវរៈសេនាធំលេខ ១៦១ គ្រប់គ្រងកងវរៈសេនាតូចចំនួន ៣ (បី) គឺ កងវរៈសេនាតូចលេខ ៦១១ , កងវរៈសេនាតូចលេខ ៦១២ និងកងវរៈសេនាតូចលេខ ៦១៣ ។[598] កងវរៈសេនាធំលេខ ១៦១ មានមូលដ្ឋាននៅកំពង់ផែកំពង់សោម។[599] នៅពេលដែលមជ្ឈិមបក្សបានសម្រេចកសាងកំពង់ផែយោធានៅស្ទឹងហាវ នៅដើមឆ្នាំ១៩៧៦ កងវរៈសេនាធំលេខ ១៦១ មានទីតាំងនៅទីនោះ ។[600]

១៩៤. ចំណែកកងវរៈសេនាធំលេខ ១៦២ មានឈ្មោះ អៀក មាញ ឬ តា មាន ឬ តា មាយ ធ្លាប់ធ្វើជាប្រធានកងវរៈសេនាធំនេះ ។[601] អៀក មាញ ត្រូវបានចាប់ខ្លួននៅអំឡុងឆ្នាំ ១៩៧៧ ក្រោយរងការចោទប្រកាន់ថាជាជនក្បត់ ។[602] បន្ទាប់មក សុន បានធ្វើឡើងជាប្រធាន និងបានធ្វើការបញ្ជាកម្លាំងនៅលើកោះតាងក្នុងអំឡុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ ហើយក្រោយមកគាត់បានចាកចេញពីកោះតាងទៅបញ្ជាកងទ័ព ដើម្បីប្រយុទ្ធនៅតាមព្រំដែនវៀតណាមវិញ។[603] មេបញ្ជាការបន្ទាប់មកទៀតឈ្មោះ យាង ដែលបានដឹកនាំកងវរៈសេនាធំលេខ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

១៦២ ។[604] កងវរៈសេនាធំលេខ ១៦២ មានកងវរៈសេនាតូច ចំនួន ៣ (បី) គឺ កងវរៈសេនាតូចលេខ ៦២១ , កងវរៈសេនាតូចលេខ ៦២២ និងកងវរៈសេនាតូចលេខ ៦២៣ ។ [605] កងវរៈសេនាធំលេខ ១៦២ នេះ មានទីតាំងនៅរាម[606] និងបញ្ជូរជើងនៅកោះពូលូវៃចាស់ កោះពូលូវៃថ្មី កោះតាង កោះព្រីង និងកោះក្រចកសេះ។[607]

១៩៥. កងវរៈសេនាធំលេខ ១៦៣ មានឈ្មោះ ម៉ម ជឹម ហៅ យ៉ាន ជាប្រធានកងវរៈសេនាធំដដែល ។[608] យ៉ាន ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ក្នុងខែ ឧសភា ឆ្នាំ ១៩៧៧ ។[609] ក្រោយការចាប់ខ្លួនរបស់ យ៉ាន នាឆ្នាំ ១៩៧៧ ស៊ិន ជន បានក្លាយទៅជាប្រធានកងវរៈសេនាធំលេខ ១៦៣ ។[610] កងវរៈសេនាធំលេខ ១៦៣ មានកងវរៈសេនាតូចចំនួន ៣ (បី) រួមមាន កងវរៈសេនាតូចលេខ ៦៣១ , កងវរៈសេនាតូចលេខ ៦៣២ និងកងវរៈសេនាតូចលេខ ៦៣៣ ។[611] កងវរៈសេនាធំលេខ ១៦៣ នេះ មានមូលដ្ឋានរបស់ខ្លួននៅកងកេង[612] បន្ទាប់មកទៀតនៅទឹកសាប[613] រហូតដល់ពេលរបបខ្មែរក្រហមដួលរលំ[614]។

១៩៦. ចំណែកឯកងវរៈសេនាធំលេខ ១៤០ ត្រូវបានដឹកនាំដោយប្រធានកងវរៈសេនាធំ ឈ្មោះ ឡុង សារឿន ហៅ រឿន ឬ រិន ។[615] ក្រោយមកឈ្មោះ សារឿន នេះ បានបាត់ខ្លួន ។[616] កងវរៈសេនាធំលេខ ១៤០ បានចាប់ផ្ដើមប្រតិបត្តិការតាំងពីខែ កក្កដា ឬ ខែ សីហា ឆ្នាំ ១៩៧៥ ។[617] កងវរៈសេនាធំលេខ ១៤០ នេះមានកងវរៈសេនាតូចចំនួន ៤ (បួន) គឺ កងវរៈសេនាតូចលេខ ១៤១ , កងវរៈសេនាតូចលេខ ១៤២ , កងវរៈសេនាតូចលេខ ១៤៣ និងកងវរៈសេនាតូចលេខ ១៤៤ ។[618]

១៩៧. កងវរៈសេនាតូចលេខ ១៤១ គឺជាកងប្រដេញទទួលខុសត្រូវខាងនាវាចុនប្រដេញ[619] ដែលគ្រប់គ្រងដោយឈ្មោះ ស មឿន ជាប្រធានកងវរៈសេនាតូច[620] និងមានជំនួយការឈ្មោះ គន់ ខឹម ( គុន ខឹម ឬ គុណ ខឹម) [621] រហូតទាល់តែគាត់ត្រូវបានគេចាប់ខ្លួននៅថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៧៧ និងត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ



ECCC CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * C.E.T.C.

១៩៧៧ ។[622] ឬ ជាប្រធានរបស់កងនាវាធុនប្រដេញ[623] ដែលនៅរស់រានមានជីវិត[624] ។ កងវរៈសេនាតូចលេខ ១៤១ មាននាវាធុនប្រដេញប្រហែលជាង ១០ (ដប់) គ្រឿង ។ [625] កងនាវាប្រដេញនេះពុំមានភារកិច្ចទទួលខុសត្រូវក្នុងការចាប់មនុស្សឡើយ[626] ហើយមិនប្រចាំការនៅគ្រប់ទីកន្លែងនោះទេ ដោយកងនេះរង់ចាំតែបញ្ជាប្រយុទ្ធជាមួយនាវាចម្បាំងតែប៉ុណ្ណោះ[627] ដែលជាទូទៅការចេញបញ្ជាគឺពីប្រធានកងនាវា មិនមែនចេញពីកងពលឡើយ[628]។ កងនាវាប្រដេញមានទីតាំងបញ្ជាការនៅអូរឈើទាល និងធ្វើការសំចតតាមការបញ្ជា នាវាខ្លះចតនៅកោះរ៉ុង ឆ្នេរអូរឈើទាល និងខ្លះទៀតបោះយុថ្កានៅក្នុងសមុទ្រ ។[629]

១៩៨. កងវរៈសេនាតូចលេខ ១៤២ គឺជាកងទទួលខុសត្រូវខាងផ្នែកនាវាការពារ[630] ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រធានកងវរៈសេនាតូចឈ្មោះ គង់ សឿន ហៅ សាង បន្ទាប់មកគាត់ត្រូវបានគេចាប់ខ្លួន និងស្លាប់ដោយជម្ងឺនៅមន្ទីរសន្តិសុខ ស-២១ ។[631] ប្រធានរបស់កងនាវាការពារមានឈ្មោះថា ហន ។[632] នៅក្នុងកងនាវាការពារនេះមាននាវាប្រហែលជាចំនួន ៨ (ប្រាំបី) ទៅ ១០ (ដប់) គ្រឿង ។[633] កងនាវាការពារមានភារកិច្ចប្រចាំការនៅកន្លែងផ្សេងៗ នៅតាមកោះ ហើយរង់ចាំបញ្ជាសម្រាប់ប្រយុទ្ធ ។[634] កងវរៈសេនាតូចលេខ ១៤២ នេះមានមូលដ្ឋាននៅកំពង់ផែរាម និងទីកន្លែងផ្សេងៗទៀតដូចជា អូរឈើទាល កោះតាង កោះកុង កោះរុងសន្លឹម ។[635]

១៩៩. កងវរៈសេនាតូចលេខ ១៤៣ គឺជាកងទទួលខុសត្រូវខាងនាវាធុនប្រឆាំងនឹងនាវាមុជទឹក[636] ស្ថិតក្រោមបង្គាប់របស់ប្រធានកងវរៈសេនាតូចឈ្មោះ នៀវ រ៉ែម ហៅ រ៉ែម[637] កងនាវាធុនប្រឆាំងនឹងនាវាមុជទឹកនេះមានភារកិច្ចនៅមួយកន្លែង មិនរាយទៅតាមកន្លែងផ្សេងៗទេ ពោលគឺ ត្រៀមខ្លួនសម្រាប់ទទួលបញ្ជាប្រយុទ្ធ ។ ប្រធានកងនាវាធុនប្រឆាំងនឹងនាវាមុជទឹកមានឈ្មោះ ឆន ឬ ជន (ស្លាប់) និង ឡុន (នៅរស់)[638] និងមាននាវាចំនួនតែ ២ (ពីរ)គ្រឿងប៉ុណ្ណោះ[639] ដើម្បីធានាប្រតិបត្តិការរបស់ខ្លួន ។



*E.C.C.C* C.E.T.C. CO-INVESTIGATING JUDGES

២០០. កងវរៈសេនាតូចលេខ ១៤៤ ជាកងនាវាបោសសម្អាតមីន[640] ស្ថិតនៅក្រោមបញ្ជារបស់ប្រធានកងវរៈសេនាតូចឈ្មោះ ហាន រហូតដល់ពាក់កណ្តាលឆ្នាំ ១៩៧៨ នៅពេលដែលគាត់បានក្លាយជាប្រធានកងវរៈសេនាធំលេខ ១៤០ ។[641] នៅក្នុងកងនាវាបោសសម្អាតមីនមាននាវាចាស់ៗចំនួន ៤ (បួន) គ្រឿង ចតនៅប៉ុស្តិ៍យាមមើលជួរមុខនៅតំបន់កែប ត្រូវបានប្រើប្រាស់ដើម្បីកម្ទេចមីននៅក្រោមសមុទ្រ និងនៅទន្លេមេគង្គ ។[642]

២០១. ក្រៅពីកងវរៈសេនាធំក្រោមបង្គាប់ កងពលលេខ ១៦៤ ក៏មានកងវរៈសេនាតូចឯករាជ្យចំនួន ៦ (ប្រាំមួយ) ដូចជា កងវរៈសេនាតូចលេខ ១៦៥ (អតីតកងវរៈសេនាតូចលេខ ៤៥០) , កងវរៈសេនាតូចលេខ ១៦៦ , កងវរៈសេនាតូចលេខ ១៦៧ , កងវរៈសេនាតូចលេខ ១៦៨ , កងវរៈសេនាតូចលេខ ១៦៩ និងកងវរៈសេនាតូចលេខ ១៧០ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ **មាស មុត** និងគណៈកម្មាធិការរបស់កងពលលេខ ១៦៤ ។[643]

២០២. ចំពោះកងវរៈសេនាតូចលេខ ១៦៥ មាន ស មឿន ហៅ មឿន ដែលបានក្លាយជាប្រធានកងវរៈសេនាតូចលេខ ៤៥០ តាំងពីមុនឆ្នាំ ១៩៧៥ ហើយបានកាន់តួនាទីនេះរហូតដល់ពេលដែលគេបង្កើតកងវរៈសេនាធំលេខ ១៤០ នៅខែ សីហា ឆ្នាំ ១៩៧៥ គាត់ក៏បានក្លាយជាប្រធានកងវរៈសេនាតូចលេខ ១៤១ ។[644] ប្រធានកងវរៈសេនាតូចលេខ ១៦៥ បន្ទាប់ពីខែ សីហា ឆ្នាំ ១៩៧៥ មានឈ្មោះ ឈុន លុន ហៅ សំអាត ហៅ ស៊ុន ដែលក្រោយមកត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ បន្ទាប់ពី **មាស មុត** បានរាយការណ៍អំពីករណីរបស់គាត់ទៅ សុន សេន ហើយគាត់ត្រូវបានគេកម្ទេចនៅថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៧៦ ។[645] កងវរៈសេនាតូចលេខ ១៦៥ នេះ គឺជាកងអន្តរាគមន៍ពិសេសរបស់កងពលលេខ ១៦៤ ដែលជាកងឯករាជ្យ[646] ហើយដែលត្រូវរាយការណ៍ផ្ទាល់ទៅ **មាស មុត** ។ កងនេះមានតួនាទីទទួលខុសត្រូវផ្នែកសន្តិសុខ និងការការពារតែប៉ុណ្ណោះ ។[647]



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596072



២០៣. កងវរៈសេនាតូចលេខ ១៦៥ មានសមាសភាពដូចជា និរសា និងកងអង្គរក្ស ។ យោងតាមស្ថិតិបានបញ្ជាក់ថានៅចុងឆ្នាំ ១៩៧៦ កងនេះមានទាហានផ្ទើមចំនួន ២៦៥ (ពីររយហុកសិបប្រាំ) នាក់ ។[648]

## ៣. កងទ័ពរបស់ភូមិភាគ

២០៤. នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា សាខាធំទីពីរគឺកងទ័ពរបស់ភូមិភាគ ដែលជាទូទៅត្រូវបានរៀបចំជាកងពល ។[649] ទោះបីជាកងពលទាំងនោះត្រូវរាយការណ៍ជាចុងក្រោយទៅមជ្ឈិមក៏ដោយ ក៏កងពលទាំងនោះគឺជាផ្នែកមួយនៃរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ដែលស្ថិតនៅក្រោមភូមិភាគផ្ទាល់តែម្តង ។[650] ភារកិច្ចរបស់កងពល មានការទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងសកម្មភាពរបស់ភូមិភាគដែលខ្លួនឈរជើង រួមមាន ការការពារទឹកដី និងសន្តិសុខផ្ទៃក្នុងជាអាទិ៍ ។ កងទ័ពរបស់ភូមិភាគនៅតាមព្រំដែនថៃ និងព្រំដែនវៀតណាម មានការជាប់ពាក់ព័ន្ធខ្លាំងនៅក្នុងការប្រយុទ្ធនានា ដែលបានកើតឡើងនៅតាមបណ្តោយព្រំដែនទាំងនោះ ។[651] នៅថ្នាក់ក្រោមកងពល ស្រុកនានាក៏មានសាមីកងកម្លាំងមូលដ្ឋានរបស់ខ្លួនដែរ ដែលចំណុះឱ្យថ្នាក់កងវរៈសេនាតូច ។

២០៥. ពេលខ្លះកងពលមជ្ឈិម និងកងទ័ពភូមិភាគស្ថិតនៅក្នុងតំបន់ជាមួយគ្នា ។ ជាឧទាហរណ៍ កងពលមជ្ឈិមលេខ ៩២០ មានទីតាំងមូលដ្ឋាននៅមណ្ឌលគីរី ដែលត្រូវបានចាត់ទុកថាជាកងទ័ពស្រួច ខណៈដែលនៅមណ្ឌលគិរីក៏មានកងវរៈសេនាតូចចំនួនពីរ ឬកងវរៈសេនាធំដែលចាត់ទុកថាជាកងទ័ពភូមិភាគដែលស្ថិតនៅក្រោមបញ្ជារបស់មេបញ្ជាការនៃតំបន់ ១០៥ ឬ មណ្ឌលគិរី ។[652] មានកងពលមួយទទួលខុសត្រូវផងដែរនៅតំបន់ក្រចេះ ឬតំបន់ស្វយ័ត ៥០៥ ។[653]

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរសព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES "CO-JUGES D' INSTRUCTION"

## ៤. កងឈ្លប

២០៦. កងកម្លាំងទីបី គឺយោធានៅតាមមូលដ្ឋាន ដែលត្រូវបានគេនិយាយសំដៅថាជា "កងឈ្លប"។ កងឈ្លបបានរស់នៅក្នុងចំណោមប្រជាពលរដ្ឋនៅតាមភូមិនានា ដោយបំពេញភារកិច្ចទាក់ទងទៅនឹងសន្តិសុខនៅតាមមូលដ្ឋាន ។[654] ក្នុងចំណោមភារកិច្ចទាំងនេះរួមមាន ការចាប់ខ្លួន[655] ការសម្លាប់[656] ព្រមទាំងភារកិច្ចដែលទាក់ទងទៅនឹងការងារយោធាបន្ថែមទៀត ដូចជា ការងារត្រៀមការពារភូមិ និងសហករណ៍[657]។ កងឈ្លបរាយការណ៍ផ្ទាល់ទៅ ភូមិ គណៈឃុំ និងគណៈស្រុក[658] ហើយត្រូវបានគេហៅឱ្យទៅបំពេញការងារសន្តិសុខរដ្ឋបាលស៊ីវិល ។[659]

## ខ. ទំនាក់ទំនងរបស់កងទ័ពបដិវត្តន៍កម្ពុជា

### ១. ទំនាក់ទំនងរវាងកងពល និងគណៈកម្មាធិការមជ្ឈិម

២០៧. អៀង សារី បានបញ្ជាក់ថា គណៈកម្មាធិការយោធាជាទូទៅរាយការណ៍ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ បន្ទាប់ពីទទួលរបាយការណ៍ពីភូមិភាគ ហើយគាត់ក៏ធ្លាប់បានឮដោយផ្ទាល់អំពីរបាយការណ៍ស្តីពីសន្តិសុខ ។[660] ទំនាក់ទំនងការងាររវាងកងពល និងមជ្ឈិមត្រូវបានធ្វើជាប្រចាំ ដោយមានទំនាក់ទំនងច្រើនដងក្នុងមួយថ្ងៃៗ ។[661] អង្គភាពបញ្ជាការនៅថ្នាក់មជ្ឈិម បានធ្វើទំនាក់ទំនងការងារជាទៀងទាត់ជាមួយនឹងកងពលនានា[662] ហើយផ្អែកទៅលើកងពលទាំងនេះហើយ ដើម្បីបញ្ជូនបន្តនូវបញ្ជារបស់ខ្លួនទៅកាន់អង្គភាពនានា ដែលមានថ្នាក់ទាបជាង ។ សេចក្តីសម្រេចសំខាន់នានារបស់ថ្នាក់កងពល ត្រូវបានទុកឱ្យអង្គភាពបញ្ជាការនៅថ្នាក់មជ្ឈិមធ្វើការសម្រេច។[663]កងពលនានាផ្ញើសេចក្តីរាយការណ៍ទៅអង្គភាពបញ្ជាការថ្នាក់មជ្ឈិមជាទៀងទាត់ ជាទូទៅសេចក្តីរាយការណ៍ទាំងនោះបរិយាយអំពីបញ្ហានានាដូចជាការប្រយុទ្ធគ្នា ការរកឃើញខ្មាំងផ្ទៃក្នុង រួមជាមួយនឹងបញ្ហាផ្សេងៗទៀតផង ។[664]



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596074



២០៨. ទំនាក់ទំនងការងារត្រូវបានសម្របសម្រួលតាមមធ្យោបាយផ្សេងៗជាច្រើន ។ បណ្ដាញទំនាក់ទំនងដែលប្រើប្រាស់ជាញឹកញាប់គឺ តាមរយៈវិទ្យុទាក់ទង និងតាមទូរលេខ រាប់បញ្ចូលផងដែរទាំងទំនាក់ទំនងផ្ទាល់មាត់ ក៏ដូចជាការផ្ញើសារ ។[665] ដើម្បីសម្រេចគោលបំណងនេះសេនាធិការ[666] ក៏ដូចជាកងពលនីមួយៗ[667] មានអង្គភាពវិទ្យុទាក់ទង និងអង្គភាពសារទូរលេខ ។ សារនានាត្រូវបានផ្ញើ និងទទួលដោយកងទ័ពបដិវត្តន៍កម្ពុជាជាលេខសម្ងាត់ ។[668] ជាទូទៅនិរសាត្រូវបានប្រើប្រាស់ជាញឹកញាប់ផងដែរដើម្បីបញ្ជូនសារ[669] ហើយកងពលនីមួយៗមានអង្គភាពនិរសាររបស់ខ្លួនដើម្បីធ្វើការងារនេះ[670] ។ ចំពោះការផ្ញើសារទំនាក់ទំនងរវាងសេនាធិការ ឬគណៈកម្មាធិការយោធា និងសាររវាងកងពលផ្សេងៗ ត្រូវបានបញ្ជូនជាញឹកញាប់ទៅឱ្យសមាជិកនៃគណៈកម្មាធិការមជ្ឈិម ។[671]

២០៩. កិច្ចប្រជុំផ្ទាល់ជាមធ្យោបាយដែលត្រូវបានប្រើប្រាស់ជាញឹកញាប់ ដើម្បីទាក់ទងការងាររវាងអង្គភាពបញ្ជាការថ្នាក់មជ្ឈិម និងកងពលនានា ។[672] ការប្រជុំទាំងនេះអាចមានការប្រជុំទ្រង់ទ្រាយតូច[673] ឬអាចជាការការប្រជុំទ្រង់ទ្រាយធំ[674]។ ជាក់ស្ដែងការប្រជុំធំសំខាន់ៗ មានដូចជាការប្រជុំដែលធ្វើឡើងនៅមុនពេលវាយប្រហារផ្ដាច់ព្រ័ត្រយកភ្នំពេញ[675] ឬមុនពេលបោសសម្អាតភូមិភាគបូព៌ា[676]។ នៅក្នុងការប្រមូលផ្ដុំប្រជុំទ្រង់ទ្រាយធំជាញឹកញាប់មានការធ្វើសុន្ទរកថាដោយមេដឹកនាំបក្ស ។[677] សាក្សីខ្លះបានរាយការណ៍ថាមានការប្រជុំធំផ្នែកយោធា ដែលធ្វើឡើងនៅពហុកីឡាដ្ឋានជាតិអូឡាំពិកនៅទីក្រុងភ្នំពេញ សម្រាប់មេបញ្ជាការអង្គភាពនានា ចាប់ពីថ្នាក់វរៈសេនាតូចឡើងទៅ ដោយមាន សុន សេន ជាអ្នកដឹកនាំការប្រជុំ ។[678]

២១០. ចំពោះកងពលលេខ ១៦៤ ជាកងពលមួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់មជ្ឈិម ។[679] សេនាធិការស្ថិតនៅក្រោមការគ្រប់គ្រងទូទៅរបស់មជ្ឈិមបក្ស និងទទួលបន្ទុកផ្នែកកិច្ចការយោធា រួមមាន ការផ្គត់ផ្គង់សម្ភារៈ ភ័ស្តុភារ អាវុធ ទាហាន ទំនាក់ទំនង និងព័ត៌មាន ។[680] ក្នុងនាមជាលេខាកងពលលេខ ១៦៤ មាស មុត រាយការណ៍ផ្ទាល់ទៅសេនាធិការ ។[681]



CO-INVESTIGATING JUDGES *E.C.C.C* C.E.T.C* CO-JUGES D'INSTRUCTION

ប្រសិនបើគេឃើញនាវាបរទេសល្ពានពានចូលមកក្នុងដែនទឹកជាអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាដោយខុសច្បាប់ គេត្រូវរាយការណ៍ទៅអង្គការថ្នាក់លើភ្លាម ហើយត្រូវរង់ចាំបញ្ជាពីថ្នាក់លើត្រឡប់មកវិញ ។[682]

២១១. **មាស មុត** រាយការណ៍អំពីជម្លោះប្រដាប់អាវុធជាមួយវៀតណាមនៅកោះត្រល់[683] សភាពការណ៍យោធា និងមនុស្សដែលបានចាប់ខ្លួន ទៅកាន់ សុន សេន ផ្ទាល់ បន្ទាប់មក សុន សេន ជាអ្នករាយការណ៍បន្តទៅកាន់អង្គការថ្នាក់លើ[684]។ ជាក់ស្តែង **មាស មុត** បានរាយការណ៍ថា " *យើង [...]ចាប់បានទូក ២ គ្រឿង។ [...] ចាប់បាននៅកៀកកោះកុងប្រហែល ២ គ.ម។ ក្រោយមក យើងបានសាកសួរ។ [...] ទាំង ៥ នាក់នេះ មានខ្មែរម្នាក់ ក្រៅពីនេះសៀម* " ។[685] លើសពីនេះទៅទៀត សុន សេន ក៏បានធ្វើចំណារនៅលើសេចក្តីរាយការណ៍នេះដែរថា "*ជូន អ/ក (អង្គការ) យើងខ្ញុំ ឲ្យសួមរកខ្សែខាងក្នុង រកផ្លូវចេញចូល សភាពការណ៍ពួកអាក្បត់នៅតាមព្រំដែន* "។[686]

២១២. បើយោងតាមកំណត់ហេតុនៃការប្រជុំយោធាមួយចំនួន បានបង្ហាញឲ្យឃើញថា **មាស មុត** បានរាយការណ៍ទៅ សុន សេន ពីការចាប់បានអ្នកនេសាទថៃ[687] ការបោសសម្អាតអង្គភាពឃ្លាំងមួយអនុសេនាតូច[688] និងសភាពការណ៍យោធា[689]។ សេនាធិការជាអ្នកចេញបញ្ជា និងមតិណែនាំត្រឡប់មកកងពលនីមួយៗ រួមមានទាំងកងពលលេខ ១៦៤ផងដែរ ដូចជាការកម្ទេចសត្រូវជាដាច់ខាតទាំងនៅដែនគោក និងដែនទឹករបស់កម្ពុជាប្រជាធិបតេយ្យ ។ ម៉្យាងវិញទៀត សុន សេន ក្រោយពីបានទទួលរបាយការណ៍ពីកងពលរួចហើយ ក៏បានចម្លងរបាយការណ៍ដែលទទួលបានពីកងពលនីមួយៗ ផ្ញើបន្តទៅកាន់មន្ទីរ ក-១ ។

២១៣. ការទាក់ទងតែងតែត្រូវបានធ្វើឡើងជាប្រចាំ ជារៀងរាល់ថ្ងៃរវាងកងពល និងមជ្ឈិម។[690] សេនាធិការប្រើប្រាស់វិទ្យុទាក់ទងដើម្បីធ្វើការទាក់ទងជាមួយនឹងកងពល ។[691] ចំណែកទូរស័ព្ទ និងសារទូរលេខ ត្រូវបានប្រើប្រាស់នៅពេលដែលមានព័ត៌មានសម្ងាត់ ។[692]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

២១៤. ជាទូទៅ មាស មុត ធ្វើការទាក់ទងទៅកាន់មជ្ឈិម តាមរយៈសារទូរលេខ[693] ទូរស័ព្ទ[694] សំបុត្រ[695] និងនិរសា។[696] ពាក់ព័ន្ធនឹងរបាយការណ៍ប្រចាំខែ នៅពេលខ្លះត្រូវបានផ្ញើតាមរថភ្លើងផងដែរ ។[697] សារទូរលេខ សំបុត្រ និងការរាយការណ៍តាមទូរស័ព្ទរវាង មាស មុត និង សុន សេន (បង ៨៩) សុទ្ធតែត្រូវបានចម្លងជូន នួន ជា (បង នួន , អ៊ំ ឬ អ៊ំ នួន) , វន វើត (បង ៨៧) , បង ណាត, បង សោម, សៀត ឆែ (បង ៨១) និង បង តាត ។[698]

២១៥. មាស មុត រាយការណ៍ទៅមជ្ឈិមទាក់ទិននឹងការចូលរួមរបស់កងទ័ព[699] សកម្មភាពរបស់សត្រូវ និងទូកនេសាទ[700] ការរកឃើញខ្មាំងខាងក្នុង និងសកម្មភាពនៅក្នុងកងពល[701] ការដាំដុះស្រូវ[702] សុខភាពរបស់កងទ័ព[703] ជាអាទិ៍។

២១៦. របាយការណ៍ និងសារទូរលេខ បានបង្ហាញឱ្យដឹងថា កងពលមជ្ឈិមអនុវត្តតាមមតិណែនាំដែលទទួលបានពីអង្គការថ្នាក់លើ ឬស្នើសុំឱ្យមានការពន្យល់ពីមេដឹកនាំផ្នែកនយោបាយ និងយោធារបស់មជ្ឈិម ។[704] ជាក់ស្តែង មាស មុត បានរាយការណ៍ទៅ សុន សេន ទាក់ទងនឹងការវាយប្រហារទូកនេសាទ និងការចាប់ខ្លួនទូកវៀតណាម ព្រមទាំងស្នើសុំយោបល់អំពីវិធានការណ៍ដែលខ្លួនត្រូវធ្វើ ។[705]

## ២. ទំនាក់ទំនងនៅក្នុងកងពល

២១៧. ទំនាក់ទំនងការងារនៅក្នុងកងពលនានា ត្រូវធ្វើតាមរចនាសម្ព័ន្ធនៃការបញ្ជាដោយមានមេបញ្ជាការ ដែលជាធម្មតាធ្វើការទំនាក់ទំនងជាមួយថ្នាក់លើ និងថ្នាក់ក្រោមបង្គាប់ ។ លេខាកងពលរាយការណ៍ជូនថ្នាក់លើអំពីបញ្ហានានា និងទទួលបញ្ជាពីថ្នាក់លើត្រឡប់មកវិញ[706]។ សម្រាប់ទំនាក់ទំនងការងារប្រចាំថ្ងៃ ជារឿយៗត្រូវបានធ្វើឡើងតាមវិទ្យុទាក់ទងចល័ត[707] ប៉ុន្តែមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត ដូចជា និរសា[708] ទូរលេខ[709] និងការប្រជុំនានា[710] ក៏ត្រូវបានគេប្រើប្រាស់ផងដែរ ។



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២១៨. មូលដ្ឋានរបស់កងពលលេខ ១៦៤ នៅកំពង់សោម មានទាំងនិរសា[711] វិទ្យុទាក់ទង[712] និងទូរស័ព្ទ ។[713] ការរាយការណ៍ទាំងនោះភាគច្រើនទាក់ទងទៅនឹងស្ថានភាពយោធា[714] ទូក និងមនុស្សដែលចាប់បាន[715] ព្រមទាំងបញ្ហានានាដែលបានកើតឡើងនៅក្នុងកងរបស់ខ្លួន[716] រាប់បញ្ចូលទាំងបញ្ហាភស្តុភារ ដូចជា ខ្វះខាតសាំង ការជួសជុលទូក[717] ការសាងសង់[718] ការផលិតស្រូវ[719] និងបញ្ហាសុខភាព[720]។ នៅពេលដែល **មាស មុត** អវត្តមាន ឌឹម ដែលជាអនុលេខារបស់គាត់នឹងរាយការណ៍ទៅកាន់ **មាស មុត** ផ្ទាល់ ។[721]

២១៩. កងពលលេខ ១៦៤ ក៏មានកាំជា ដែលមានទីតាំងនៅភ្នំបូកគោ និងនៅលើកោះតាង ហើយក៏មានការសហការណ៍គ្នាជាមួយនឹងកងពលលេខ ១ ដែលមានកាំជាស្ថិតនៅកោះកុង ។[722]

### ច. ទំនាក់ទំនងរវាង មាស មុត និង សេនាធិការ

២២០. បើយោងតាមឯកសារដែលមាននៅក្នុងសំណុំរឿងលេខ ០០៣ មានឯកសារជាប្រភេទចម្លើយសារភាពរហូតទៅដល់ចំនួន ៨៣ (ប៉ែតសិបបី) [723] ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ដែលត្រូវបានគេដាក់បញ្ចូលក្នុងសំណុំរឿងនេះនៅមុនថ្ងៃបិទការស៊ើបសួរ ។ ប៉ុន្តែក្រោយពីការសិក្សាលើចំណាររលើចម្លើយសារភាពទាំងអស់នោះឃើញថា មានចម្លើយសារភាពតែចំនួន ២ (ពីរ)[724] ប៉ុណ្ណោះ ដែលមានចំណារនៅលើក្របមុខនៃចម្លើយសារភាព ដែលក្នុងនោះមានចំណារលើចម្លើយសារភាពមួយច្បាប់បញ្ជាក់អំពីអត្តសញ្ញាណបុគ្គលដែលត្រូវបានចាប់ខ្លួននោះ ថាជាសមាជិកម្នាក់នៃកងពលរបស់ **មាស មុត** ។ ចំណែកឯចំណារលើចម្លើយសារភាពមួយច្បាប់ទៀត គ្រាន់តែបានធ្វើការបញ្ជាក់ថាមានសមាជិកដទៃទៀតក្នុងកងពលរបស់ **មាស មុត** បានជាប់ពាក់ព័ន្ធនឹងខ្សែក្បត់ ។

២២១. ចម្លើយសារភាពភាគច្រើន ទាក់ទិនកងទ័ពវៀតណាម ដែលត្រូវបានខ្មែរក្រហមចាប់ខ្លួនបានទាំងនោះតាមបណ្តោយព្រំដែនគោក និងសមុទ្រកម្ពុជា ។ រីឯចម្លើយសារភាពផ្សេងទៀត



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

ភាគច្រើនទាក់ទិននឹងអ្នកបំរើការងារនៅក្នុងជួររដ្ឋបាល ដែលមានតំណែងចាប់ពីលេខាភូមិភាគរហូតចុះទៅដល់ថ្នាក់មូលដ្ឋាន ។

២២២. យោងទៅលើឯកសារនៅសំណុំរឿងលេខ ០០៣ យើងឃើញថាក្នុងសំណុំរឿងនេះមានប្រភេទឯកសារជាសារទូរលេខមានសរុបចំនួន ១៤៥ (មួយរយសែសិបប្រាំ) សារទូរលេខ[725] ដែលត្រូវបានគេដាក់បញ្ចូលក្នុងសំណុំរឿងនេះនៅមុនថ្ងៃបិទការស៊ើបសួរ។ ក្រោយពីការសិក្សាលើខ្លឹមសារនៃសារទូរលេខទាំងអស់នោះឃើញថា មានសារទូរលេខចំនួន ៣ (បី) [726] នោះទេ ដែលមានឈ្មោះ **មាស មុត** បានផ្ញើចេញ ខណៈដែលសារទូរលេខសរុបមានរហូតដល់ជាងមួយរយ ។ ម្យ៉ាងវិញទៀត ចំពោះចំនួនសារទូរលេខមានតែចំនួន ៧ (ប្រាំពីរ)[727] ប៉ុណ្ណោះដែលត្រូវបានគេផ្ញើមកឲ្យ **មាស មុត** ដែលក្នុងចំណោមនោះមានសារទូរលេខតែមួយគត់[728] ដែល សុន សេន ផ្ញើទៅកងពល ១៦៤ ត្រឡប់ទៅវិញ ដោយបានគូសបញ្ជាក់យ៉ាងច្បាស់ថាជាមតិណែនាំឲ្យទៅកាន់ **មាស មុត** ។

២២៣. ឯកសារជាកំណត់ហេតុនៃការប្រជុំមានសរុបចំនួន ៥០ (ហាសិប)[729] កំណត់ហេតុនៃការប្រជុំ ដែលត្រូវបានគេដាក់បញ្ចូលក្នុងសំណុំរឿងនេះនៅមុនថ្ងៃបិទការស៊ើបសួរ។ បន្ទាប់ពីបានសិក្សាលើកំណត់ហេតុនៃការប្រជុំទាំងនោះឃើញថា មានកំណត់ហេតុនៃការប្រជុំទាក់ទងនឹងឈ្មោះ **មាស មុត** ចំនួន ៣ (បី)[730] ដែលបង្ហាញថា **មាស មុត** បានចូលរួមប្រជុំជាមួយ ។

២២៤. ក្នុងសំណុំរឿងលេខ ០០៣ មានឯកសារជាសារតាមទូរស័ព្ទសម្ងាត់មានចំនួន ៨ (ប្រាំបី)[731] ទូរស័ព្ទសម្ងាត់ ដែលត្រូវបានគេដាក់បញ្ចូលក្នុងសំណុំរឿងនេះនៅមុនថ្ងៃបិទការស៊ើបសួរ។ ប៉ុន្តែពាក់ព័ន្ធនឹងសារទូរស័ព្ទសម្ងាត់ ដែលត្រូវបានផ្ញើចេញដោយ **មាស មុត** មានចំនួន ៦ (ប្រាំមួយ) [732] សារទូរស័ព្ទសម្ងាត់ ។



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

២២៥. ដូចគ្នាផងដែរ ទាក់ទិននឹងបញ្ហាទូរស័ព្ទសម្ងាត់ ចំនួនសារទូរស័ព្ទសម្ងាត់ ដែលមានក្នុងសំណុំរឿងមានចំនួន ៨ (ប្រាំបី) យើងឃើញថាមានចំនួនទូរស័ព្ទសម្ងាត់ដែលត្រូវបានផ្ញើចេញដោយ **មាស មុត** ក្រោមឈ្មោះថា "មុត" មានចំនួន ៦ (ប្រាំមួយ) ។ **មាស មុត** ទទួលបន្ទុករាយការណ៍សភាពការណ៍ជាក់ស្តែង និងពាំនាំនូវបទបញ្ជាដែលថ្នាក់បានដាក់ចុះ ។ ខណៈដែលគ្មានសារទូរស័ព្ទសម្ងាត់ណាមួយ ត្រូវបានរកឃើញថា ត្រូវទទួលនូវការចោទលើ **មាស មុត** ក្នុងការចេញបញ្ជាយកអ្នកណាមួយទៅសម្លាប់ឡើយ ។

២២៦. ក្នុងចំណោមឯកសារកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់ មានឯកសារមិនច្រើនទេ ដែលអាចបង្ហាញនូវទំនាក់ទំនងជាមួយជនត្រូវចោទឈ្មោះ **មាស មុត** ។ ខណៈដែលឯកសារសំខាន់ៗដែលទាក់ទិននឹងអង្គប្រជុំ ក៏បានបង្ហាញនូវកម្រិតនៃការចូលរួមរបស់សាមី **មាស មុត** ក្នុងការចូលរួមប្រជុំជាមួយថ្នាក់លើរបស់ខ្លួន ដើម្បីទទួលបទបញ្ជា និងអនុវត្តបទបញ្ជាដែលថ្នាក់លើបានដាក់ចុះ ។

## ឆ. វិន័យ

២២៧. កងទ័ពបដិវត្តន៍កម្ពុជាបានដាក់របបវិន័យដ៏តឹងរ៉ឹងទៅលើមេបញ្ជាការ និងកងទ័ពរបស់ខ្លួន ដែលរបបវិន័យនេះបានចែងពីមធ្យោបាយនានានៃការតាមដានត្រួតពិនិត្យ ព្រមទាំងការដាក់ទណ្ឌកម្ម ។ ការប្រជុំទិតៀន និងស្វ័យទិតៀន ត្រូវបានធ្វើឡើងនៅក្នុងអង្គភាពយោធា ដែលកងទ័ពត្រូវបានរំពឹងឲ្យធ្វើការទិតៀនពីកំហុសខ្លួនឯង និងទិតៀនពីអ្នកដទៃ។[733] បច្ចេកទេសនៃការត្រួតពិនិត្យ និងការដាក់វិន័យនេះត្រូវបានប្រើប្រាស់ផងដែរនៅក្នុងការប្រជុំដែលត្រូវបានរៀបចំដោយសេនាធិការ ។[734]

២២៨. មានទម្រង់ផ្សេងៗនៃទណ្ឌកម្មដើម្បីដាក់ទៅលើកងទ័ព នៅពេលណាដែលមានការប្រព្រឹត្តខុស ។ មានការដាក់ទណ្ឌកម្មនៅក្នុងអង្គភាពនានា[735] ដែលរួមមានការបញ្ជូនទៅអប់រំកែប្រែ[736] ឬទៅការដ្ឋានការងារ[737] ឬត្រូវបានគេសម្លាប់ចោល[738]។ មេបញ្ជាការដែលមិន



E.C.C.C. C.E.T.C. CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

01596080



គោរពបញ្ជា ឬត្រូវបានគេចាត់ទុកថាក្បត់ នឹងត្រូវបានចាប់ខ្លួន និងក្រោយមកត្រូវបានគេសម្លាប់ ។[739] ចំពោះការចាប់ខ្លួន និងការសួរចម្លើយជនដែលគេសន្មតថាជាជនក្បត់នោះ អង្គភាពនានារបស់កងទ័ពបដិវត្តន៍កម្ពុជា បានប្រើប្រាស់នូវទីតាំងរបស់មន្ទីរផ្សេងៗ ដូចជាទីតាំងរបស់មន្ទីរសន្តិសុខ ស-២១[740] និងអង្គភាពមួយចំនួនបានប្រើប្រាស់មន្ទីរសន្តិសុខរបស់ខ្លួនផ្ទាល់[741]។

## ផ្នែកទី ៤. គោលនយោបាយបោសសម្អាតនៅក្នុងជួរកងទ័ព
## ក. គោលនយោបាយបោសសម្អាត

២២៩. ការ "បោសសម្អាត" ឬ "ការធ្វើវិសុទ្ធកម្ម" មានន័យថាធ្វើឱ្យបរិសុទ្ធផ្នែកគោលនយោបាយ តាមរយៈការដាក់ទណ្ឌកម្ម ដែលមានចាប់តាំងពីការទម្លាក់ឋានន្តរសក្តិបុគ្គលណាម្នាក់រហូតដល់យកទៅលត់ដំ ឬកម្ទេចចោល ។[742] សាក្សីឈ្មោះ ឈូក រីន បានអះអាងថា "*ប៉ុល ពត បាននិយាយជាញឹកញាប់ពីភាពចាំបាច់ដើម្បីធ្វើការបោសសម្អាត ដែលមានន័យថាចាប់ខ្លួន ហើយ នួន ជា បាននិយាយពីសត្រូវផ្ទៃក្នុង*" ។[743]

២៣០. នៅក្នុងការប្រជុំជាផ្លូវការរបស់កងទ័ពបដិវត្តន៍កម្ពុជានាខែ កក្កដា ឆ្នាំ ១៩៧៥ ប្រធាននៃគណៈកម្មាធិការយោធាជាន់ខ្ពស់របស់បក្ស បានប្រកាសថាកងទ័ពបដិវត្តន៍ត្រូវការពារប្រទេសប្រឆាំងនឹង "*ខ្មាំងស៊ីរូងផ្ទៃក្នុង*" និងថាកាតព្វកិច្ចកងទ័ពបដិវត្តន៍ គឺ "បន្តការកម្ទេច" នៅភ្នំពេញ ហើយភារកិច្ចចម្បងបំផុតបន្ទាប់ពីរំដោះភ្នំពេញរួច គឺការពារប្រទេសទាំងមូលទាំងដែនដីសមុទ្រ និងដែនអាកាស ។[744] នៅក្នុងពេលប្រជុំលេខា និងអនុលេខាកងពល និងកងវរៈសេនាធំឯករាជ្យ វិធានការនានាត្រូវបានលើកយកមកពិភាក្សាផងដែរ រួមទាំងការបោសសម្អាត "សមាសភាពមិនល្អ" ។[745]

២៣១. នាថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៥ មានកិច្ចប្រជុំមួយដើម្បីលាតត្រដាងសត្រូវផ្ទៃក្នុងដែលមានវត្តមានរបស់ សុន សេន , ណាត និង ឌុច ដោយ សុន សេន បានអានចម្លើយសារភាព



*E.C.C.C* C.E.T.C* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

របស់ យ៉ា , សុត , ប៉ាង និង ចម្លើយសារភាពមួយផ្នែករបស់ កុយ ធួន ។[746] ឌុច សន្និដ្ឋានថា[747] ការសម្រិតសម្រាំងផ្ទៃក្នុងនោះបានចាប់ផ្តើមឡើងពីខែ មេសា ឆ្នាំ ១៩៧៦ ដោយសារព្រឹត្តិការណ៍បោកគ្រាប់បែកក្រោយព្រះបរមរាជវាំងនៅថ្ងៃទី ០២ ខែ មេសា ឆ្នាំ ១៩៧៦ និងបន្ទាប់ពី កុយ ធួន ត្រូវបានដាក់ឃុំក្នុងផ្ទះកាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៧៦ ។

២៣២. នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ គណៈមជ្ឈិមបានរាយការណ៍អំពី "ការកម្ទេចក្នុងជួរ និងក្រៅជួរ" ថា *"បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវគណៈអចិន្ត្រៃយ៍ភូមិភាគសម្រេច។ នៅជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច។ នៅតំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច។ នៅកងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច"* [748]។ នៅក្នុងរយៈពេលប៉ុន្មានខែក្រោយមក ឯកសារផ្ទៃក្នុងរបស់បក្សកុំម្មុយនីស្តកម្ពុជា បានតម្រូវឲ្យមានការលើកកម្ពស់នូវ *"ការប្រុងប្រយ័ត្នបដិវត្តន៍"* ដើម្បីទប់ស្កាត់ខ្មាំងមិនឲ្យស៊ីរូងផ្ទៃក្នុងបក្ស និងកងទ័ពបានឡើយ[749]។ នៅក្នុងការអនុវត្តន៍ មានការលេចឡើងដែលថាតំបន់ចេញសេចក្តីសម្រេច "កម្ទេច"[750] ឬត្រួតពិនិត្យសេចក្តីសម្រេចកម្ទេចនៅតាមថ្នាក់ស្រុក[751]។ នៅកន្លែងផ្សេងទៀត ស្រុកហាក់បីដូចជាធ្វើការសម្រេចរបៀបនេះ ដោយកម្មាភិបាលរបស់ខ្លួនដោយផ្ទាល់[752]។ គោលការណ៍នេះត្រូវបានអនុវត្តទាំងចំពោះសមាជិក និងមិនមែនសមាជិកបក្ស។ ក្នុងឋានៈជាអ្នកទទួលខុសត្រូវលើសន្តិសុខផ្ទៃក្នុងកងទ័ព កងទ័ពបដិវត្តន៍កម្ពុជាបានអនុវត្តន៍គោលនយោបាយវិសុទ្ធកម្មនេះ តាមបញ្ជារបស់មជ្ឈិមបក្ស។

២៣៣. សុន សេន ដែលជាអគ្គសេនាធិការ បាននាំយកគោលនយោបាយបោសសម្អាតរបស់បក្សកុំម្មុយនីស្តកម្ពុជាមកអនុវត្ត និងបញ្ជាឲ្យលេខាកងពលទាំងអស់ត្រូវចាត់វិធានការ ។ ជាលទ្ធផលមានកងពលជាច្រើនដែលបានរាយការណ៍ទៅ សុន សេន អំពីការសម្រិតសម្រាំងនេះ។[753] នៅក្នុងពេលប្រជុំរួមមួយជាមួយកងពលលេខ ៧០៣ និងមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ សុន សេន បានស្តាប់ស្ថានការណ៍ដែលបានរាយការណ៍ដោយអង្គភាពយោធា និងលើសពីនេះបានបញ្ជាដល់ពួកគេ *"ត្រូវឃើញភារកិច្ចធ្ងន់ធ្ងរ*



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*ខំអប់រំនយោបាយសតិអារម្មណ៍ឲ្យជាប់ ។ ក្តាប់ប្រវត្តិរូប ក្តាប់សតិអារម្មណ៍ឲ្យជាប់ (...) សន្តិសុខ ស្មើតាមដានសភាពការណ៍ខ្មាំងថែម"* ។ [754]

២៣៤. នៅក្នុងខែ មិថុនា ឆ្នាំ ១៩៧៨ គណៈកម្មាធិការមជ្ឈិមបក្ស បានចេញផ្សាយនូវសេចក្តីណែនាំមួយពាក់ព័ន្ធនឹងមាគ៌ារបស់បក្សចំពោះខ្មាំង និងសមាសភាពមិនល្អ ដែលសេចក្តីណែនាំនោះមានចំណងជើងថា "*សេចក្តីណែនាំរបស់ គណៈមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា អំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភ័ន្តច្រឡំចូល សេអ៊ីអា ឬធ្វើភ្នាក់ងារយួន ឬចូល កាសេបេ ប្រឆាំងបក្ស ប្រឆាំងបដិវត្តន៍ ប្រឆាំងប្រជាជន និងប្រឆាំងនឹងកម្ពុជាប្រជាធិបតេយ្យ*"។[755] ខ្លឹមសារនៃសេចក្តីណែនាំបានបញ្ជាក់អំពីគោលនយោបាយរបស់បក្ស ក្នុងការអប់រំកសាងកម្លាំងទាំងអស់ដែលអាចកសាងបាន តាមរយៈការអនុគ្រោះចំពោះបុគ្គលដែលភ័ន្តច្រឡំចូលរួមជាមួយ សេអ៊ីអា (CIA) កាហ្សេបេ (KGB) និងវៀតណាម នៅមុនខែ កក្កដា ឆ្នាំ ១៩៧៨ ដោយបង្គាប់ឲ្យបក្ស និងប្រជាជនទូទៅខិតខំកសាងអ្នកដែលភ័ន្តច្រឡំនោះ ដើម្បីរួមកម្លាំងកសាងប្រទេសឲ្យបានរីកចម្រើនលើគ្រប់វិស័យ ។[756]

២៣៥. សាក្សីម្នាក់បានគូសបញ្ជាក់ថា សេចក្តីណែនាំរបស់គណៈកម្មាធិការមជ្ឈិម នាខែ មិថុនា ឆ្នាំ ១៩៧៨ បានផ្តល់ឲ្យគណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា នូវអំណាចដើម្បីកម្ទេចខ្មាំង ដែលកាលពីមុនអំណាចនេះត្រូវបានផ្ទេរពីមជ្ឈិមទៅកាន់មូលដ្ឋាន តាមរយៈសេចក្តីណែនាំចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ។[757] សេចក្តីណែនាំនាខែ មិថុនា ឆ្នាំ ១៩៧៨ នេះត្រូវបានបោះពុម្ពផ្សាយនៅក្រោមទម្រង់ជាសារាចរនៅក្នុងទស្សនាវដ្តីទង់បដិវត្តន៍។[758] ទស្សនាវដ្តីទង់បដិវត្តន៍ចេញផ្សាយនាខែ កក្កដា ឆ្នាំ ១៩៧៨ បានជម្រុញសមាជិកបក្សឲ្យ "*បន្តបោសសម្អាតពួកក្បត់បង្កប់ស៊ីរូងផ្ទៃក្នុង និងសម្រិតសម្រាំងពួកសមាសភាពអន្តរាយឲ្យអស់រលីងពីក្នុងជួរយើងដាច់ខាត*" ។[759]

២៣៦. នាខែ កញ្ញា ឆ្នាំ ១៩៧៨ ប៉ុល ពត បានផ្សព្វផ្សាយគោលនយោបាយថ្មីនេះ នៅក្នុងសន្និបាតទូទាំងប្រទេសនៅបូរីកីឡា ក្នុងទីក្រុងភ្នំពេញ ដោយមានសមាសភាពសមាជិកគណៈមជ្ឈិម

ទាំងអស់ចូលរួមជាមួយនឹងកម្មាភិបាលបក្សមានទាំងយោធា ទាំងស៊ីវិល ចាប់ពីថ្នាក់វរៈសេនាតូច និងគណៈស្រុកឡើងទៅ ។[760] សក្ខីកម្មរបស់សាក្សីបានអះអាងថា " *ក្នុងការធ្វើសន្និបាតនេះ ប៉ុល ពត បានប្រកាសថា ទាំងយោធា ទាំងមូលដ្ឋាន លែងមានសិទ្ធិចាប់ ឬចងអ្នកណាទៀតហើយ នៅខេត្តមិនមានតុលាការទេ ខេត្តមានសិទ្ធិត្រឹមសួរនាំប៉ុណ្ណោះ មិនអាចគំរាមកំហែងអ្នកណាបានទេ ខេត្តត្រូវសួរនាំ ហើយនិងបញ្ជូនរបាយការណ៍នៃការសួរនាំទៅឲ្យមជ្ឈិម* " ។[761] ចំណែកឯ ឌុច វិញបានផ្តល់ភ័ស្តុតាងថា ការផ្លាស់ប្តូរនៅក្នុងគោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជាដែលគេបានអះអាងនេះមិនមែនជាគោលនយោបាយអនុគ្រោះនោះទេ ប៉ុន្តែវាគ្រាន់តែជាការបោកបញ្ឆោត ដែលគេធ្វើឡើងដើម្បីធ្វើឲ្យប្រជាជនស្ងប់ចិត្តប៉ុណ្ណោះ ។[762]

## ការបោសសម្អាតនៅភូមិភាគបូព៌ា

២៣៧. គំនិតផ្តួចផ្តើមរៀបចំផែនការបោសសម្អាតភូមិភាគបូព៌ា ប្រហែលជាបានធ្វើឡើងស្របនឹងគោលនយោបាយទូទៅនៃការបោសសម្អាត ហើយក៏ប្រហែលជាបានចាប់ផ្តើមដំបូងនៅ ចុងខែ តុលា ឬ ខែ វិច្ឆិកា ឆ្នាំ ១៩៧៧ តាមរយៈការប្រជុំយោធាមួយនៅខេត្ត តាកែវ ក្រោមបេសកកម្មដើម្បីវាយពួកវៀតណាមនៅកម្ពុជា និងបោសសម្អាតពួកអ្នកចូលដៃចូលជើងជាមួយវៀតណាមនៅភូមិភាគបូព៌ា។[763] ក្រោមការចោទប្រកាន់ថាបានពាក់ព័ន្ធជាមួយវៀតណាម កម្មាភិបាលភូមិភាគបូព៌ាជាច្រើននាក់ ត្រូវបានរងការបោសសម្អាត[764] ហើយការបោសសម្អាតនៅភូមិភាគបូព៌ានេះ មិនមែនកំណត់តាមភូមិសាស្ត្រត្រឹមកម្មាភិបាលរបស់ភូមិភាគបូព៌ាតែប៉ុណ្ណោះទេ ប៉ុន្តែក៏រាប់បញ្ចូលទាំងកម្មាភិបាលដែលមានប្រភពមកពីភូមិភាគបូព៌ា ហើយដែលត្រូវបានគេឲ្យទៅធ្វើការនៅទីកន្លែងដទៃៗទៀត ដោយរួមទាំងនៅក្នុងបណ្តាក្រសួងនានា ដូចជាក្រសួងសង្គមកិច្ចជាដើម ក៏ត្រូវបានគេកំណត់មុខសញ្ញារហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។[765]

២៣៨. សក្ខីកម្មរបស់សាក្សីឈ្មោះ ឈូក រីន បានបង្ហាញថា សេចក្តីសម្រេចជាផ្លូវការឲ្យធ្វើការបោសសម្អាតភូមិភាគបូព៌ានេះ ប្រហែលជាត្រូវបានធ្វើឡើងគំណាលគ្នានឹងការធ្វើមហា



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

សន្និបាតប្រចាំឆ្នាំរបស់បក្ស នាដើមឆ្នាំ ១៩៧៨ នៅពហុកីឡាដ្ឋានអូឡាំពិកក្នុងទីក្រុងភ្នំពេញ ។ សេចក្តីសម្រេចនេះធ្វើឡើងតាមរយៈការប្រជុំពិសេសមួយនៅទីបញ្ជាការយោធានៅជិតបឹងត្របែក ជាមួយមេបញ្ជាការយោធាកងពលធំ និងកងវរៈសេនាធំប្រហែល ៤០ (សែសិប) នាក់ ទៅ ៥០ (ហាសិប) នាក់ ដូចជា មាស មុត , អៀង ផាន , សុខ ឈាន , ធីឌី , ធី ពូសេស និងសាក្សីខ្លួនឯងផ្ទាល់ក៏បានចូលរួមដែរ[766] ដើម្បីផ្តល់ការណែនាំអំពីផែនការក្នុងការបោសសម្អាត ។ សេចក្តីសម្រេចបោសសម្អាតភូមិភាគបូព៌ា ត្រូវបានធ្វើឡើងដោយដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមាន សុន សេន ជាអ្នកប្រតិបត្តិតាមបញ្ជារបស់ ប៉ុល ពត ហើយ នួន ជា និង តា ម៉ុក[767] ក៏មានវត្តមានទាំងអស់នៅក្នុងអង្គប្រជុំ។

២៣៩. ចំណែកសាក្សីឈ្មោះ ឡាញ ដុស ដែលធ្លាប់ធ្វើការងារជាមួយ សុន សេន នៅឯមន្ទីរវិទ្យុទាក់ទង និងផ្នែកភស្តុភាររបស់អគ្គសេនាធិការ យល់ថាមានតែ ប៉ុល ពត ម្នាក់ប៉ុណ្ណោះដែលអាចចេញបញ្ជាឲ្យមានការបោសសម្អាតបែបនេះក្នុងភូមិភាគបូព៌ា ។[768] សាក្សី ឡាញ ដុស ក៏បានអះអាងផងដែរថា ការសម្រេចឲ្យមានការបោសសម្អាតភូមិភាគបូព៌ា ត្រូវបានធ្វើឡើង និងអនុវត្តក្រោមការត្រួតពិនិត្យរបស់គណៈមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា ព្រោះ សុន សេន *"ភាគច្រើនគាត់ឡើងមករាយការណ៍ផ្ទាល់នៅគណៈមជ្ឈិម ហើយករណីតិចតួចធ្វើតាមទូរស័ព្ទសម្ងាត់ ទាំងពីរសមរភូមិនៅស្វាយរៀង និងស្ទួង។ ខ្ញុំយល់ថាការសម្រេចចាប់ខ្លួនកម្មាភិបាលដែលគេឆ្លើយដាក់ មិនមែនជាការសម្រេចត្រឹមតែ សុន សេន តែឯងទេ គឺទាល់តែមានការសម្រេចពីគណៈមជ្ឈិមទៀត"* ។[769]

២៤០. នួន ជា មានការជាប់ពាក់ព័ន្ធតាំងពីដំបូង ទាក់ទិននឹងការបោសសម្អាតភូមិភាគបូព៌ា ជាក់ស្តែង គឺការចាប់ខ្លួនអតីតលេខាតំបន់ ២៤ ឈ្មោះ សួស នៅ ហៅ ឈូក[770] និង ចាន់ ចក្រី ហៅ នៅ មាន ដែលជាអតីតកម្មាភិបាលកងពល ១៧០ នៃភូមិភាគបូព៌ា[771] តាមសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍[772]។ នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៧ សៀត ឆែ ហៅ ទុំ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596085



ជាអតីតលេខាតំបន់ ២២ ត្រូវបានគេចាប់ខ្លួនបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ហើយចម្លើយសារភាពរបស់គាត់បាននាំឱ្យមានការបោសសម្អាតធំមួយនៅតំបន់ ២២ ។[773]

២៤១. ចាប់ពីពាក់កណ្តាល ខែ សីហា ឆ្នាំ ១៩៧៧ តាមរយៈចម្លើយសារភាពទាំងឡាយដែលទទួលបាន សុន សេន និង កែ ពក[774] និងបុគ្គលិកមន្ទីរសន្តិសុខ ស-២១ តាមរយៈការប្រើប្រាស់កងកម្លាំងអចិន្ត្រៃយ៍របស់គណៈមជ្ឈិម អង្គភាពមកពីភូមិភាគកណ្តាល និងកងទ័ពរបស់អតីតភូមិភាគនិរតី ដែលស្ថិតនៅក្រោមបញ្ជារបស់គណៈមជ្ឈិម[775] បានបង្កើនការដេញតាមចាប់អ្នកដែលត្រូវបានគេចោទថាជាជនក្បត់ដូចជា ភ្នាក់ងារសេអ៊ីអា (CIA) កាហ្សេបេ (KGB) និងជាខ្មាំងជាប់ពាក់ព័ន្ធជាមួយវៀតណាម[776] ។ អ្នកទាំងនោះ ត្រូវបានគេចាប់បញ្ជូនទៅកាន់មន្ទីរសន្តិសុខ ស-២១[777] ឬត្រូវបានសម្លាប់នៅនឹងកន្លែង ឬដាក់ឱ្យធ្វើការនៅតាមការដ្ឋានដើម្បី "លត់ដំ" ដូចជានៅការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង[778] ជាអាទិ៍។ ឌុច បានអះអាងថា តាមរយៈការអនុវត្តគោលនយោបាយនេះ មានយុទ្ធជនមកពីភូមិភាគបូព៌ា កម្មាភិបាលភូមិភាគ និងតំបន់ចំនួន ៣00 (បីរយ) នាក់ ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ដើម្បីកម្ទេច ។[779] ភស្តុតាងជាច្រើនបានបង្ហាញតួនាទីក្នុងការបោសសម្អាត ជាតួនាទីរបស់ ប៉ុល ពត , នួន ជា , តា ម៉ុក , អៀង សារី និង សុន សេន ជាពិសេស តួនាទីរបស់ នួន ជា ។[780]

២៤២. សកម្មភាពនៃការបោសសម្អាតកាន់តែកើនឡើង ជាក់ស្តែងនៅក្នុងខែ មេសា ឆ្នាំ ១៩៧៨ មានការបោសសម្អាតយ៉ាងធំមួយលើកម្មាភិបាល និងយុទ្ធជននៅភូមិភាគបូព៌ា នៅស្វាយរៀង (តំបន់ ២៣) ។[781] ក្រោយមកមានការចាប់ខ្លួន និងការសម្លាប់ចោលកាន់តែច្រើនឡើងៗ ចាប់ពីខែ ឧសភា ដល់ ខែ មិថុនា ឆ្នាំ ១៩៧៨ នៅតាមបណ្តាទីកន្លែងផ្សេងៗទៀតនៅក្នុងភូមិភាគបូព៌ា[782] ដែលក្នុងអំឡុងពេលនោះដែរ លេខាភូមិភាគបូព៌ា សោ ភឹម បានធ្វើអត្តឃាតដោយមិនចង់ឱ្យគេចាប់ខ្លួន[783]។ ចំណែក ឌុច ក៏បានអះអាងផងដែរថា ចលនានៃការបោសសម្អាតទូទៅនៅភូមិភាគបូព៌ា មានលក្ខណៈទ្រង់ទ្រាយធំដែលមិនធ្លាប់មាន ជាពិសេសនៅក្នុងអំឡុងខែ មិថុនា ឆ្នាំ ១៩៧៨ ។[784]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៤៣. ទាក់ទងនឹងសមាសភាពដែលបានចូលរួមក្នុងការប្រជុំយោធាមួយនៅខេត្ត តាកែវ នាពាក់កណ្ដាល ឆ្នាំ ១៩៧៧ ដើម្បីរៀបចំផែនការទៅវាយនៅពួកវៀតណាម និងអ្នកដែលចូលជើងជាមួយពួកវៀតណាមនៅភូមិភាគបូព៌ា សាក្សីឈ្មោះ ឈូក រីន បានបញ្ជាក់ថា មានមេទ័ពនិរតីទាំងអស់បានចូលរួម ប៉ុន្តែ **មាស មុត** ដែលគ្រប់គ្រងកងពលលេខ ១៦៤ ខាងជើងទឹកនៅកំពង់សោមមិនបានចូលរួមទេ ហើយ **មាស មុត** ក៏មិនចំណុះឲ្យភូមិភាគនិរតីដែរ ។[785]

២៤៤. បន្ទាប់ពីការប្រជុំនេះហើយសាក្សីខ្លួនឯងផ្ទាល់ និងមេបញ្ជាការយោធាផ្សេងទៀតដូចជា កងពលលេខ ៤៦0 ដែលជាកងកម្លាំងជើងទឹកមកពីកំពង់សោម បានទទួលបញ្ជាតាមទូរលេខឲ្យធ្វើដំណើរទៅភូមិភាគបូព៌ា ដើម្បីចាប់ខ្លួនមេបញ្ជាការដែលត្រូវចាត់ទុកថាក្បត់បញ្ជូនមកភ្នំពេញ ហើយកូនទាហានវិញត្រូវបញ្ជូនឲ្យទៅធ្វើការនៅការដ្ឋានព្រលានយន្តហោះខេត្តកំពង់ឆ្នាំង។[786] សាក្សី ឈូក រីន ក៏បានបញ្ជាក់ផងដែរថាមានកងកម្លាំងមកពីកងពលលេខ ១៦៤ ចូលរួមក្នុងការបោសសម្អាតភូមិភាគបូព៌ាដែរ តែស្ថិតនៅក្រោមការបញ្ជារបស់ សុន សេន ដែលនេះគឺជាកាតព្វកិច្ចយោធាដែលត្រូវតែគោរពតាម ។[787] រីឯ **មាស មុត** មិនបានទៅភូមិភាគ បូព៌ាជាមួយ ឈូក រីន ទេ ។[788]

## ខ. ការចូលរួមរបស់កងទ័ពបដិវត្តន៍កម្ពុជានៅក្នុងការបោសសម្អាត

២៤៥. យោងតាមសក្ខីកម្មរបស់សាក្សី ឈូក រីន បានបង្ហាញថា សេចក្ដីសម្រេចឲ្យអនុវត្តការបោសសម្អាតនៅក្នុងជួរយោធា ត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ដោយមាន សុន សេន ជាអ្នកធ្វើតាមបញ្ជានានារបស់ ប៉ុល ពត, នួន ជា និង តា ម៉ុក[789]។ សាក្សីដដែលនេះរៀបរាប់ថា រាល់ពេលមានការកោះហៅប្រជុំ ដែលដឹកនាំដោយ ប៉ុល ពត , នួន ជា , តា ម៉ុក និង សុន សេន ជាមួយនឹងមេបញ្ជាការយោធានានា ការបញ្ជាឲ្យបោសសម្អាតក៏ត្រូវបានធ្វើឡើងនាពេលនោះដែរ ។[790]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

២៤៦. អង្គភាពដែលមានតួនាទីសំខាន់ក្នុងការអនុវត្តគោលនយោបាយបោសសម្អាត គឺសេនាធិការ ដែលមាន សុន សេន ជាអគ្គមេបញ្ជាការ ។ ភ័ស្តុតាងយ៉ាងច្បាស់ពាក់ព័ន្ធនឹងតួនាទីរបស់សេនាធិការក្នុងការសម្រេចបោសសម្អាត ឬកម្ទេចនៅក្នុងកងពលមជ្ឈិម គឺសេចក្ដីសម្រេចរបស់គណៈមជ្ឈិមបក្ស ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ។[791] តាមរយៈសេចក្ដីសម្រេចនៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ នេះសិទ្ធិកម្ទេចខាងក្នុង និងខាងក្រៅជួរកងទ័ពមជ្ឈិមត្រូវតែសម្រេចដោយសេនាធិការ ។[792]

២៤៧. សេនាធិការបានចាប់ផ្ដើមអនុវត្តគោលនយោបាយបោសសម្អាត ក្រោមរូបភាពធ្វើការពិនិត្យជីវប្រវត្តិជាដំបូង បន្ទាប់មកកំណត់អត្តសញ្ញាណខ្មាំង និងចុងក្រោយ គឺធ្វើការកម្ទេចពួកគេចោល ។[793] ក្នុងការអនុវត្តការបោសសម្អាត សុន សេន ដែលជាអគ្គសេនាធិការ បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយនឹងមន្ទីរសន្តិសុខ ស-២១ និងកងពលមជ្ឈិមទាំងអស់ ។[794] ចំពោះកងពលមជ្ឈិម សុន សេន បានបញ្ជាថារាល់កងពលទាំងអស់ យកសេចក្ដីសម្រេចនាមហាសន្និបាតលើកទីបី ធ្វើជាមូលដ្ឋានពាក់ព័ន្ធនឹងខ្មាំង ដាក់ចេញវិធានការណ៍ប្រឆាំងនឹងខ្មាំង ដាក់ចេញនូវការងារបក្ស និងបញ្ជាឱ្យរៀបចំកងពិសេសអន្តរាគមន៍ ដោយជ្រើសរើសឱ្យបានល្អ ហើយកងអន្តរាគមន៍ពិសេសនេះអាចចេញប្រតិបត្តិការបាន លុះត្រាតែមានបទបញ្ជាពីសេនាធិការទៅកងពល ។[795]

២៤៨. មិនតែប៉ុណ្ណោះសេនាធិការ ថែមទាំងធ្វើការគ្រប់គ្រង ត្រួតពិនិត្យ និងដាក់កំហិតដល់កងពលទាំងអស់ ដោយធ្វើការរៀបចំឱ្យមានវគ្គសិក្សាសម្រាប់កម្មាភិបាលដែលត្រូវបានជ្រើសរើសសម្រាំងមួយចំនួន[796] ព្រមទាំងជួបប្រជុំជាប្រចាំជាមួយថ្នាក់ដឹកនាំកងពល និងកងវរៈសេនាធំឯករាជ្យ ដើម្បីរាយការណ៍ និងដាក់ចេញបទបញ្ជាលើបញ្ហាផ្សេងៗ ដើម្បីអនុវត្តមាគ៌ា និងគោលនយោបាយរបស់បក្សប្រឆាំងនឹងខ្មាំង[797] ដោយមានការបោសសម្អាតនូវ "សមាសភាពមិនល្អ" ។[798]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

២៤៩. ជាក់ស្តែងក្នុងឋានៈជាអគ្គសេនាធិការ សុន សេន ជាបុគ្គលតែម្នាក់គត់ដែលបានចេញបញ្ជា និងណែនាំកងពលមជ្ឈិមទាំងអស់ នៅរាល់ពេលមានកិច្ចប្រជុំជាមួយលេខា និងអនុលេខា កងពល និងកងវរៈសេនាធំឯករាជ្យ[799] ឱ្យអនុវត្តយ៉ាងដាច់ខាត និងយ៉ាងតឹងតែងចំពោះការបោសសម្អាតខ្មាំងផ្ទៃក្នុងនៅក្នុងកងពលនីមួយៗ[800]។ ការចាត់វិធានការដើម្បីស្វែងរកខ្មាំង និងការចាត់វិធានការនានា ចំពោះជនដែលត្រូវបានចាត់ទុកជាសមាសភាពមិនល្អ ដូចជា "*(...) សមាសភាពមិនល្អប្រមូលផ្តុំមួយកន្លែង អប់រំដោយឡែក ដោយមានកម្មាភិបាលទទួលខុសត្រូវរឹងប៉ឹងគ្រប់គ្រង កុំឱ្យទៅមូលដ្ឋានឱ្យសោះ*" [801] ឬ "*ត្រូវបន្តអប់រំនយោបាយសតិអារម្មណ៍តទៅទៀត តែត្រឹមអប់រំមិនគ្រប់គ្រាន់ទេ ត្រូវបន្តសម្រិតសម្រាំងដាច់ខាតតទៅទៀត ។ (...) វិធានការចំពោះកងទ័ព ត្រូវសម្រិតសម្រាំងសមាសភាពឱ្យស្អាតដាច់ខាត ។ (...) សម្រិតសម្រាំងកងទ័ព ចំពោះសមាសភាពខ្មាំងត្រូវដកដាច់ខាត។ ពួកសេរីប្រមូលឱ្យបង្កើនផលមួយអង្គភាពទៅ។ ពួកជំពាក់ជំពិនត្រូវអប់រំ ហើយប្រមូលផ្តុំ*" ។[802]

២៥០. ក្នុងការអនុវត្តគោលនយោបាយវិសុទ្ធកម្មប្រកបដោយប្រសិទ្ធភាព កងទ័ពបដិវត្តន៍កម្ពុជាទទួលបញ្ជា តាមរយៈរចនាសម្ព័ន្ធនៃការបញ្ជាតាមឋានានុក្រម ដែលត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈរចនាសម្ព័ន្ធក្នុងការធ្វើទំនាក់ទំនងការងាររបស់ខ្លួន។ ជាទូទៅរបាយការណ៍ត្រូវបានប្រមូលនៅក្នុងកងពល ហើយបន្ទាប់មករបាយការណ៍ទាំងនោះត្រូវបានបញ្ជូនទៅអង្គការបញ្ជាការថ្នាក់មជ្ឈិម គឺ សេនាធិការ ។ ជាការឆ្លើយតបនឹងរបាយការណ៍ដែលទទួលបាន សេនាធិការធ្វើការបញ្ជាទៅកាន់កងពលនានាវិញ ហើយបញ្ជាទាំងនោះត្រូវបានបញ្ជូនបន្តទៀត ទៅកាន់មេបញ្ជាការថ្នាក់ទាបជាងតាមលំដាប់ឋានានុក្រម ដែលជាអ្នកទាំងនោះជាអ្នកអនុវត្តនូវបទបញ្ជាទាំងនោះ ។

២៥១. កងពលលេខ ១៦៤ បានទទួលបទបញ្ជាពី សុន សេន អំពីបញ្ហាផ្សេងៗរួមមាន បញ្ហាយោធា និងការរៀបចំស្បៀង ដូចជា "*រៀបចំស្តុកទឹក និងអង្ករឱ្យបាន ១ ខែ គ្រប់កៅទាំងអស់។ អាវុធ និងគ្រាប់រំសេវ ថ្នាំសង្កូវ ក៏ត្រូវម្ចាស់ការ និងត្រៀមលក្ខណៈប្រយុទ្ធឱ្យបានសព្វគ្រប់ មានទីតាំងប្រយុទ្ធជាដើម សំខាន់គឺ កោះតាង កោះវៃ កោះព្រីង ។ ត្រូវយាម តាមដានខ្មាំង*



*E.C.C.C.*C.E.T.C.* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

*ម៉ត់ចត់ ។ ត្រូវរាយការណ៍ឱ្យជាប់ និងអប់រំបងប្អូនឱ្យលើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន*"។ [803] "*អំពីពួកខាងលិច ដែលយើងចាប់បាននៅកោះវ៉ៃ ត្រូវស្ទាត់ឱ្យមែនទែន ហើយត្រូវរៀបចំប្រយុទ្ធ ក្រែងវាមកតាម ។ ត្រូវតាមដានខាងកើតឱ្យជាប់ដែរ ហើយពិនិត្យ តើវាបាញ់រឿងអ្វីនៅកោះត្រល់។ សុំតាមដានសភាពការណ៍តទៅទៀត*" ។[804]

២៥២. **មាស មុត** បានទំនាក់ទំនងដោយផ្ទាល់ជាមួយ សុន សេន ដែលតាមរយៈទំនាក់ទំនងនេះ **មាស មុត** បានទទួលបញ្ជានានាពី សុន សេន លើបញ្ហាផ្សេងៗ មានទាំងស្ថានភាពរបស់ខ្មាំង[805] ដោយបានបញ្ជាក់ថា "*ជំហររបស់យើងត្រូវកម្ទេចវាឱ្យបាន ក្នុងពេលវាចូលដែនទឹក ឬដែនគោករបស់យើង។ ឧទាហរណ៍ នៅកោះក្រសា ត្រូវមានកម្លាំងទៅពិនិត្យ ដើម្បីមានវិធានការកម្ទេចវា បើវាមានដាក់មនុស្សមែន*" ។[806]

២៥៣. វិធានការដែលចេញដោយ សុន សេន ទាំងនេះបានបង្ហាញអំពីការប្រមូលផ្តុំនូវអំណាចផ្តាច់ការរបស់មជ្ឈិមបក្ស ក្នុងការរៀបចំយុទ្ធសាស្ត្របោសសម្អាត តាមគោលនយោបាយដាក់ចេញដោយបក្ស ព្រមទាំងការអភិវឌ្ឍន៍ផ្នែកវិស័យកសិកម្ម និងការជ្រើសរើសកងទ័ព។

## គ. ការចូលរួមរបស់ មាស មុត ក្នុងការបោសសម្អាត

២៥៤. កងទ័ពបដិវត្តន៍កម្ពុជា ទទួលខុសត្រូវលើសន្តិសុខផ្ទៃក្នុងតាមរយៈការបោសសម្អាត ក្រោមការបញ្ជារបស់បក្សកុំម្មុយនីស្តកម្ពុជា ។[807] សេចក្តីសម្រេចកម្ទេចយោធានៅក្នុងកងពលមជ្ឈិមត្រូវបានធ្វើឡើងដោយសេនាធិការ ដែលមាន សុន សេន ជាអគ្គសេនាធិការ ដូចមានបញ្ជាក់នៅក្នុងឯកសារ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ។[808] ឌុច បានបញ្ជាក់ទទួលស្គាល់សេចក្តីសម្រេចនេះ ដែលបានផ្តល់អំណាចក្នុងធ្វើសេចក្តីសម្រេចកម្ទេច ឱ្យបុគ្គលចំនួន ១៣ (ដប់បី) រូប ដែលក្នុងនោះមិនមានវត្តមានរបស់ **មាស មុត** ឡើយ ។[809]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៥៥. កងពលលេខ ១៦៤ ជាអង្គភាពមួយក្នុងចំណោមអង្គភាពយោធាទាំង ១២ (ដប់ពីរ) អង្គភាព ដែលមានតួនាទីប្រតិបត្តិការទប់ទល់នឹងខ្មាំងខាងក្រៅ និងរាយការណ៍ផ្ទាល់ទៅមជ្ឈិម ឬសេនាធិការ ។[810] ឌឹម ដែលជាអនុរបស់ **មាស មុត** និង ស៊ីម ដែលទទួលបន្ទុកនាវា ប៉េ សេ អេហ្វ (PCF) និងជាអ្នកទទួលខុសត្រូវលើការចាប់ចងអ្នកនេសាទថៃ និងវៀតណាម ដែលបាននេសាទចូលមកក្នុងដែនទឹករបស់កម្ពុជា ហើយក៏ធ្លាប់បានរាយការណ៍ផ្ទាល់ទៅ សុន សេន ផងដែរ ។[811]

២៥៦. ការអះអាងរបស់ **មាស មុត** បញ្ជាក់ថាថ្នាក់ក្រោមត្រូវតែគោរពតាមបញ្ជា ។ [812] ដូចជាមេបញ្ជាការកងពលផ្សេងទៀតដែរ ក្នុងឋានៈជាមេបញ្ជាការកងទ័ពជើងទឹករបស់កងទ័ពបដិវត្តន៍កម្ពុជា **មាស មុត** ធ្លាប់បានសរសេរលិខិតទៅកាន់មន្ទីរ ៨៧០ បង្ហាញនូវការប្តេជ្ញាចិត្តចំពោះបក្ស ដោយបានសរសេរថា *"ប្តេជ្ញាកសាងកម្លាំងជាឧបករណ៍ការពារបក្ស ការពាររដ្ឋអំណាច កម្មករ កសិករ សមូហភាព នឹងការពារមាតុភូមិកម្ពុជា សង្គមនិយមដាច់ខាត ។ ដោយបោសសម្អាតគ្មានស្នាក់ស្ទើរសមាសភាពបង្កប់របស់ខ្មាំង ជាយួននឹងខ្មាំងដ៏ទៃទៀត"* ។ [813] **មាស មុត** ក៏បានធ្វើការប្តេជ្ញាបង្ហាញពីជំហររបស់ខ្លួនផងដែរថា *"ឯកភាពទាំងស្រុងជាមួយបក្ស"* ។ [814]

២៥៧. កំណត់ហេតុនៃការប្រជុំយោធាបានបង្ហាញឲ្យឃើញថា ក្នុងនាមជាលេខាកងពលលេខ ១៦៤ ក៏ដូចជាលេខាកងពលផ្សេងៗទៀតដែរ **មាស មុត** បានរាយការណ៍ និងទទួលបញ្ជាពី សុន សេន[815] ទាក់ទិននឹងបញ្ហាផ្សេងៗ ដូចជាទាក់ទងនឹងការបង្កបង្កើនផលស្រូវ[816] សភាពការណ៍វាយខ្មាំង[817] មនុស្សដែលត្រូវបានចាប់ខ្លួន[818] ទូកនេសាទថៃ និងវៀតណាមដែលចាប់បាន[819] ការប្រយុទ្ធគ្នា[820] ការបោសសម្អាតអង្គភាពឃ្លាំងមួយអនុសេនាតូច[821] និងសភាពការណ៍យោធា[822] ជាអាទិ៍។



CO-INVESTIGATING JUDGES * E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION

២៥៨. **មាស មុត** បានរាយការណ៍ប្រាប់ សុន សេន ថា *"អង្គភាពឃ្លាំងបានសម្រិតសម្រាំង មួយ អនុសេនាតូចតែនៅពុំទាន់អស់ និងធានានៅឡើយ "*[823] សុន សេន បានបញ្ជាឱ្យចាត់វិធានការបន្តការអប់រំ បោសសម្អាត និងដកចេញនូវកងអនុសេនាតូចដែលគាត់បានសម្រិតសម្រាំង តែ **មាស មុត** គ្រាន់តែបន្តសម្រិតសម្រាំងមិនបានសម្លាប់ឡើយ ដោយដកកងទ័ពទាំងនោះដាក់នៅកងផលិត ធ្វើស្រែ និងនេសាទ ។[824] ឯកសារនេះ គឺស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្មរបស់សាក្សីភាគច្រើន ដែលបានកត់សម្គាល់ពីការបាត់ខ្លួនរបស់មេអង្គភាពនៅពេលមានការបោសសម្អាត ប៉ុន្តែចំពោះកូនទាហានដែលនៅក្នុងអង្គភាពមិនត្រូវបានសម្លាប់ទេ គឺគេត្រូវបានដកចេញពីកងពល[825] ព្រោះការអស់ទំនុកចិត្តដោយត្រូវបានគេយកទៅអប់រំ[826] យកទៅដាក់កងផលិតឱ្យបង្កបង្កើនផលដូចប្រជាជនសាមញ្ញ ឱ្យធ្វើការងារនេសាទ ធ្វើស្រែ[827] ឬទៅធ្វើការនៅកន្លែងផ្សេង[828] រីឯសមាសភាពល្អគេរើសទុកជាអ្នកយាមឃ្លាំង ហើយការប្រព្រឹត្តបែបនេះបានកើតមានឡើងនៅគ្រប់ទីកន្លែងនៅប្រទេសកម្ពុជា នៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ ។

## ផ្នែកទី ៥. តួនាទី និងការចូលរួមរបស់ មាស មុត

២៥៩. មុននឹងឈានចូលដល់ការរៀបរាប់អំពីការចូលរួមរបស់ **មាស មុត** នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ យើងនឹងរៀបរាប់អំពីសាវតាររបស់គាត់ជាមុនសិន។

### ក. សាវតាររបស់ មាស មុត

២៦០. **មាស មុត** ហៅ ខែ មុត ឬ មុត [829] កើតនៅភូមិ ពោធិ៍ ឃុំ ស្រែសំរោង ស្រុក ជុំគិរី ខេត្តកំពត[830] នៅឆ្នាំ ១៩៣៨ ។ **មាស មុត** ជាកូនប្រសារច្បងបង្អស់របស់ ឈិត ជឿន ហៅ តាម៉ុក ដែលជាលេខាភូមិភាគនិរតី ។[831] ប្រពន្ធរបស់ **មាស មុត** មានឈ្មោះថា ខុំ ឬ ខុម



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

(ស្លាប់)[832] ដែលមានតួនាទីជាចៅហ្វាយស្រុក ត្រាំកក់ លេខាស្រុក ១០៥ រហូតដល់ដើមឆ្នាំ ១៩៧៦ ។[833]

២៦១. **មាស មុត** បានចូលរួមជាមួយចលនាខ្មែរកុំម្មុយនីស្តនៅក្នុងឆ្នាំ ១៩៧០ ។[834] ពីឆ្នាំ ១៩៧០ រហូតដល់ឆ្នាំ ១៩៧៣ **មាស មុត** ជាអនុលេខាតំបន់ ១៣ ក្នុងខេត្តតាកែវ ភូមិភាគនិរតី ។[835] នៅឆ្នាំ ១៩៧៣ គាត់ត្រូវបានតែងតាំងជាលេខាកងពលលេខ ៣ ភូមិភាគនិរតី ។[836]

## ខ. អំណាច និងតួនាទីនៅក្នុងឧក្រិដ្ឋកម្ម

២៦២. យើងនឹងលើកយកតែទីតាំងឧក្រិដ្ឋកម្មទាំងឡាយណា ដែលត្រូវបានចោទប្រកាន់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ហើយដែលអង្គហេតុនៃទីតាំងឧក្រិដ្ឋកម្មទាំងនោះមាននៅមុនការបិទការស៊ើបសួរ ដែលទទួលស្គាល់ដោយសហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried BLUNK តែប៉ុណ្ណោះ។

### ១. មន្ទីរសន្តិសុខ ស-២១

២៦៣. **មាស មុត** ត្រូវបានចោទប្រកាន់ចំពោះការទទួលខុសត្រូវលើការបោសសម្អាតនៅក្នុងកងពលលេខ ១៦៤ តាមរយៈការបញ្ជូនកងទ័ពទៅកម្ទេចនៅមន្ទីរសន្តិសុខ ស-២១ ឬ មន្ទីរ ស-២១ និងការចូលរួមក្នុងការបោសសម្អាតបុគ្គលិកមកពីអគ្គសេនាធិការ ។[837]

### ១.១. ការបង្កើតមន្ទីរសន្តិសុខ ស-២១

២៦៤. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៧៥ សុន សេន បានធ្វើការកោះហៅ ឌុច និង អ៊ិន លន ហៅ ណាត ដែលមកពីកងពលធំ ៧០៣ នៃកងទ័ពបដិវត្តន៍កម្ពុជា ឲ្យទៅប្រជុំនៅស្ថានីយ៍រថភ្លើងក្រុងភ្នំពេញ ក្នុងគោលបំណងដើម្បីរៀបចំផែនការបង្កើតមន្ទីរសន្តិសុខ ស-២១ ។[838]



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៦៥. មន្ទីរសន្តិសុខ ស-២១ មានទីតាំងស្ថិតនៅទីក្រុងភ្នំពេញ នៅចន្លោះផ្លូវលេខ ១១៣ , ផ្លូវលេខ ៣២០ និងផ្លូវលេខ ៣៥០ ហើយបានដំណើរការនៅលើទីតាំងនេះរហូតដល់ថ្ងៃទី 0៦ ខែ មករា ឆ្នាំ ១៩៧៩ ។[839]

២៦៦. សុន សេន បានតែងតាំង អ៊ិន លន ហៅ ណាត ជាប្រធានមន្ទីរសន្តិសុខ ស-២១ និងជាលេខាគណៈកម្មាធិការរបស់មន្ទីរនេះ ហើយ ឌុច ជាអនុប្រធានមន្ទីរសន្តិសុខ ស-២១ ទទួលបន្ទុកក្រុមអ្នកសួរចម្លើយ ។[840] នៅក្នុងខែ មីនា ឆ្នាំ ១៩៧៦ ណាត ត្រូវផ្លាស់ទៅសេនាធិការ ហើយតួនាទីជាប្រធាន និងលេខាមន្ទីរសន្តិសុខ ស-២១ ក៏បានធ្លាក់ទៅលើឌុច ។ ឌុច បានបញ្ជាក់ថា មន្ទីរសន្តិសុខ ស-២១ មានសមត្ថកិច្ចក្នុងរង្វង់ភ្នំពេញ (បូករួមទាំង ព្រៃស និងជើងឯក) ប៉ុន្តែមន្ទីរសន្តិសុខ ស-២១ ជាអង្គភាពមួយនៅក្រោមគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានសមត្ថកិច្ចទូទាំងប្រទេស។[841]

## ១.២. មុខងាររបស់មន្ទីរសន្តិសុខ ស-២១

២៦៧. លក្ខណៈពិសេសរបស់មន្ទីរសន្តិសុខ ស-២១ គឺមន្ទីរនេះស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការមជ្ឈិម ហើយគ្រប់អ្នកទោសទាំងអស់ដែលបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ គឺតាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ជាក់ស្តែងតាមសេចក្តីសម្រេច របស់ ប៉ុល ពត ឬ នួន ជា ។[842] ឌុច ដែលជាប្រធានមន្ទីរសន្តិសុខ ស-២១ ក៏បានលើកឡើងថា "*តាំងពីពេលដែលខ្ញុំបានតែងតាំងជាប្រធានមក មេខ្ញុំគឺលោកគ្រូសុន សេន ប្រគល់ជនរងគ្រោះចូល ស-២១ តែតាមរយៈខ្ញុំតែម្នាក់គត់ ហើយក៏គ្មានកម្មាភិបាលណាម្នាក់របស់ ស-២១ (រួមទាំងរូបខ្ញុំផង) មានសិទ្ធិទទួលយកជនរងគ្រោះចូល ស-២១ ពីនរណាម្នាក់ផ្សេងទៀតបានដែរ*"។[843]

២៦៨. សក្ខីកម្មរបស់ ឌុច បានបង្ហាញថា ដោយសារមន្ទីរសន្តិសុខ ស-២១ ជាអង្គភាពនៅក្រោមគណៈកម្មាធិការអចិន្ត្រៃយ៍ដែលមានសមត្ថកិច្ចទូទាំងប្រទេស ដូច្នេះគឺគណៈកម្មាធិការ



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

អចិន្ត្រៃយ៍ជាអ្នកចេញបញ្ជាឱ្យ ឌុច ទៅចាប់នៅក្រៅភ្នំពេញ ហើយ ឌុច ជាអ្នកបញ្ជាបន្តទៅកាន់ឈ្មោះ ហ៊ី រួចហើយ ហ៊ី បានបញ្ជូនបញ្ជាបន្តទៅ ហ៊ឹម ហ៊ុយ ។[844]

២៦៩. ផ្អែកតាមគោលនយោបាយក្នុងការ "បោសសម្អាត" ខ្លាំង របស់បក្សកុម្មុយនីស្តកម្ពុជា អ្នកទាំងឡាយដែលបានបញ្ជូនមក និងជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវតែសម្លាប់ចោលទាំងអស់ គ្មានអ្នកជាប់ឃុំណាម្នាក់ត្រូវបានដោះលែងឡើយ។[845] ក្រៅពីការសម្លាប់អ្នកទោសដែលត្រូវបានចោទប្រកាន់ជាមុនថាជាខ្មាំង ឬជាជនក្បត់ មន្ទីរសន្តិសុខ ស-២១ មានតួនាទីយ៉ាងសំខាន់ក្នុងការប្រើប្រាស់គ្រប់វិធី ដើម្បីយកចម្លើយសារភាពពីអ្នកទោស ក្នុងគោលបំណងដើម្បីរែកមុខបណ្តាញក្បត់ផ្សេងៗ ។ ក្នុងនាមជាប្រធានមន្ទីរសន្តិសុខ ស-២១ ឌុច បានអះអាងថា "*អត្ថន័យនៃចម្លើយសារភាព គឺជាការងារចម្បងរបស់មន្ទីរសន្តិសុខ ស-២១*" ។[846]

២៧០. តួនាទីមួយក្នុងចំណោមតួនាទីផ្សេងៗទៀតរបស់មន្ទីរសន្តិសុខ ស-២១ ដែលបានកំណត់ឱ្យអនុវត្តនៅក្នុងការគ្រប់គ្រងសន្តិបាល គឺការសួរចម្លើយ និងការសម្លាប់កម្មាភិបាលជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាដែលជាទូទៅត្រូវបានឃុំខ្លួននៅក្នុងគុកពិសេសនេះ ។[847]

## ១.៣. ការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់

២៧១. ដូចបានបង្ហាញតាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិម នៅថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦[848] សិទ្ធិកម្ទេចខាងក្នុង និងខាងក្រៅជួរកងទ័ពមជ្ឈិម ត្រូវតែសម្រេចដោយសេនាធិការ ។ ឌុច បានអះអាងថា "*អគ្គសេនាធិការ គឺសំដៅតែលើលេខានៃអគ្គសេនាធិការ និយាយឱ្យចំគឺ សុន សេន។ ប៉ុន្តែ សុន សេន ខ្លួនឯងពេលខ្លះត្រូវសុំការអនុញ្ញាតជាគោលការណ៍ពី ប៉ុល ពត។* " ។[849] សិទ្ធិកម្ទេចខាងក្នុង និងខាងក្រៅជួរនៅតំបន់ឯករាជ្យត្រូវតែសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍ ។ ឌុច បានពន្យល់ថា "*ពាក្យអចិន្ត្រៃយ៍នេះៗ មិន*



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*មែនសំដៅស្អីទេ គឺសំដៅអចិន្ត្រៃយ៍មជ្ឈិមដែលមាន ប៉ុល ពត ជាកំពូលដឹកនាំធំ ។ តំបន់ឯករាជ្យ មិនត្រូវសម្រេចខ្លួនឯងទេ ត្រូវឲ្យអចិន្ត្រៃយ៍សម្រេច។ (...)"* ។[850]

២៧២. យោងតាម ឌុច[851] បានបញ្ជាក់ថា គ្រប់ការងារដែលអនុវត្តនៅមន្ទីរសន្តិសុខ ស-២១ ត្រូវធ្វើតាមការណែនាំរបស់ សុន សេន ដែលតាំងខ្លួនជាតំណាង "អង្គការ" (ការងារបង្កបង្កើនផលស្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់សេនាធិការ និងការងារសន្តិសុខនៅក្រោមអង្គការ) ។ ចំពោះគោលការណ៍នៃការចាប់ខ្លួន ឌុច បានអះអាងថា គ្មានការចាប់ខ្លួនណាមួយអាចធ្វើបាននៅមន្ទីរសន្តិសុខ ស-២១ ដោយមិនមានការបញ្ជាជាមុនពី សុន សេន ពីដំបូង និង នួន ជា នាពេលបន្ទាប់មកនោះទេ ។[852] ឌុច បានអះអាងថា *" ខាង ស-២១ មានតែខ្លួនគាត់ទេជាប្រធាន ដែលអាចរាយការណ៍ឯកសារសន្តិបាលជូនអចិន្ត្រៃយ៍មជ្ឈិមបាន។ [853] ខាងអចិន្ត្រៃយ៍មជ្ឈិម មានតែ សុន សេន ហើយធំពីលើសុន សេន គឺ នួន ជា ដែលមានភារកិច្ចជាប្រចាំគ្រប់គ្រង ស-២១ ខាងការងារសន្តិបាល"* ។[854]

២៧៣. បន្ថែមពីនេះសមាជិកដ៏ទៃទៀតនៃគណៈកម្មាធិការអចិន្ត្រៃយ៍ដូចជា តា ម៉ុក, សោ ភឹម, អៀង សារី និង វន វេត មិនមានសិទ្ធិទាក់ទង និងបញ្ជាដោយផ្ទាល់ជាមួយមន្ទីរសន្តិសុខ ស-២១ ទេ ។ មានតែ សុន សេន ប៉ុណ្ណោះ ដែលអាចធ្វើបាន ដោយ សុន សេន មាន នួន ជា ជាថ្នាក់លើ ប៉ុន្តែនៅក្រោម ប៉ុល ពត ។

២៧៤. នៅមុនឆ្នាំ ១៩៧៧ បុគ្គលិករបស់មន្ទីរសន្តិសុខ ស-២១ រ៉ាប់រងការដឹកជញ្ជូនអ្នកទោសដោយបានទៅទទួល និងចាត់ចែងការដឹកជញ្ជូនអ្នកទោសដែលថ្នាក់លើចាប់ខ្លួនរួចទៅហើយមកកាន់មន្ទីរសន្តិសុខ ស-២១ ។ បុគ្គលិករបស់មន្ទីរសន្តិសុខ ស-២១ ចុះទៅដល់អង្គភាពផ្ទាល់ និងទទួលដឹកយកអ្នកទោសចេញ[855] ដូចជាករណីយោធាធម្មតា មន្ទីរសន្តិសុខ ស-២១ ចេញទៅដឹកអ្នកទោសតាមមន្ទីរសន្តិសុខគ្រប់ភូមិភាគដោយខ្លួនឯង ដោយមានឈ្មោះ ហ៊ា[856] ក្រោមបញ្ជារបស់ ឌុច ពេលខ្លះកងពលជាអ្នកបញ្ជូនមក ព្រោះមន្ទីរសន្តិសុខ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

ស-២១ មិនមានលទ្ធភាពទៅដឹកអ្នកទោសនៅគ្រប់ភូមិភាគ ។ ឌុច បានយល់ស្របទៅនឹងសក្ខីកម្មរបស់ ហ៊ុយ ដែលថាគាត់មានលិខិតដើរផ្លូវពិសេសមួយចុះហត្ថលេខាដោយ សុន សេន ហើយពួកគេមានភារកិច្ចទទួលអ្នកទោសតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ តែប៉ុណ្ណោះ មិនមែនទៅចាប់ខ្លួនទេ ។[857]

២៧៥. ចាប់តាំងពីឆ្នាំ ១៩៧៧ មក កងពល និងក្រសួងនានាជាអ្នកទទួលបន្ទុកដឹកជញ្ជូនពីអង្គភាពទៅមន្ទីរសន្តិសុខ ស-២១ វិញ ។[858] ចំពោះបុគ្គលិកជាកម្មាភិបាលនៃបក្សកុំម្មុយនីស្តកម្ពុជា ត្រូវបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ តាមរយៈការកោះហៅមកប្រជុំនៅភ្នំពេញរបស់មន្ទីរ ៨៧០ ឬ ដោយ នួន ជា ឬការចាត់តាំងឱ្យទៅធ្វើការនៅកន្លែងផ្សេងៗ ហើយពួកគេបានបាត់ខ្លួនជារៀងរហូត ។[859] ក្នុងករណីខ្លះ ការបោសសម្អាតបុគ្គលិករបស់បក្សកុំម្មុយនីស្តកម្ពុជា តាមរយៈការបញ្ជូនទៅរៀនសូត្រ ដោយឆ្លងកាត់តាមមន្ទីរ ក-៧ ដែលជាមន្ទីរនិរសាមជ្ឈិម មុននឹងបញ្ជូនទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ។[860] មានករណីខ្លះទៀត បុគ្គលិកក្រសួងនានាដែលត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ ជាសម្ងាត់ ក្រោមការកុហកបោកប្រាស់ ជាក់ស្តែង ឈ្មោះ យ៉ា ត្រូវបាននាំខ្លួនដោយគេប្រាប់ថាមកពិនិត្យសុខភាព ។[861] រីឯកម្មាភិបាលយោធាថ្នាក់ខ្ពស់ដូចជាអនុលេខាកងពល ប្រធានយោធាតំបន់ អនុប្រធានយោធាតំបន់ ជាអាទិ៍ គឺ សុន សេន ឬ នួន ជា ជាអ្នកចេញបញ្ជាចាប់ក្រោមរូបភាពហៅមកប្រជុំ ដោយមិនឃើញអ្នកទាំងនោះវិលត្រឡប់មកវិញទេ ។[862] ក្នុងករណីពិសេសមួយចំនួនត្រូវតែមានរៀបចំពិភាក្សាជាមួយមន្ទីរសន្តិសុខ ស-២១ ដើម្បីរៀបចំធ្វើការចាប់ខ្លួន ។[863]

២៧៦. ប៉ុន្តែ ចំពោះការដឹកជញ្ជូនជនជាតិវៀតណាមទាំងជនស៊ីវិល និងទាហាន គឺបុគ្គលិករបស់មន្ទីរសន្តិសុខ ស-២១ ជាអ្នកទៅដឹកជញ្ជូនអ្នកទោសដោយខ្លួនឯង[864] ដោយមានលិខិតដើរផ្លូវពិសេស ប៉ុន្តែក្រោយមកមន្ទីរសន្តិសុខ ស-២១ រង់ចាំទទួលមនុស្សដែលចាប់ខ្លួនរួចតែប៉ុណ្ណោះ គឺអង្គភាពជាអ្នកដឹកជញ្ជូនមកមន្ទីរសន្តិសុខ ស-២១ ខ្លួនឯងផ្ទាល់ដោយមិនមានការជ្រើសរើសសម្រាំងជាមុនទេ ។[865]



E.C.C.C. CO-INVESTIGATING JUDGES

២៧៧. បន្ទាប់ពីទទួលបានចម្លើយសារភាពពីអ្នកទោសទាំងនោះហើយ ឌុច មានតួនាទីរៀបចំឯកសារហើយទាក់ទងថ្នាក់លើគាត់គឺ អចិន្ត្រៃយ៍ ឬ សុន សេន រួចគាត់អានចម្លើយសារភាពដើម្បីរកខ្សែបណ្តាញខ្មាំងដែលត្រូវបានឆ្លើយដាក់[866] ហើយ សុន សេន ចេញបញ្ជាទៅថ្នាក់កងពល ហើយកងពលចេញបញ្ជាទៅថ្នាក់ក្រោមដើម្បីអនុវត្តបញ្ជា[867] ដោយទាក់ទងអង្គភាពឱ្យជួយចាប់ ។

### ១.៤. ការចូលរួមរបស់ មាស មុត ក្នុងការបោសសម្អាតនៅមន្ទីរសន្តិសុខ ស-២១

២៧៨. ក្នុងឋានៈជាលេខាកងពលលេខ ១៦៤ **មាស មុត** ត្រូវបានចោទប្រកាន់ថាបានចូលរួមក្នុងការធ្វើការបោសសម្អាតកងពល ដែលខ្លួនគ្រប់គ្រងតាមរយៈ ការរាយការណ៍ពីសត្រូវផ្ទៃក្នុង[868] ការបាត់ខ្លួន[869] និង តាមរយៈបញ្ជីឈ្មោះអ្នកទោសពីមន្ទីរសន្តិសុខ ស-២១ ។[870]

២៧៩. **មាស មុត** បានបញ្ជាក់ថា "មេដឹកនាំថ្នាក់លើ" បានផ្ញើលិខិតឱ្យគាត់ ស្នើឱ្យគាត់បញ្ជូនមនុស្ស ១០០ (មួយរយ) នាក់ ទៅតំបន់ផ្សេងនៅក្នុងប្រទេស ប៉ុន្តែគាត់បានអះអាងថា គាត់មិនបានដឹងថាមានអ្វីបានកើតឡើងចំពោះអ្នកទាំងនោះឡើយនៅពេលដែលពួកគេបានចេញពីភូមិភាគរបស់គាត់ ។ **មាស មុត** បញ្ជាក់ថា *"ខ្ញុំមិនដែលបញ្ជូននរណាម្នាក់ទៅ ស-២១ ទេ។ មានមនុស្សត្រូវបានចាប់ខ្លួនពីកងពលរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងថាប៉ុន្មាននាក់ទេ។ ឌុច បានទៅចាប់ខ្លួនផ្ទាល់។ គេមានលិខិតចាប់ខ្លួន"* ។[871]

២៨០. ការអះអាងរបស់ **មាស មុត** ដែលថាមិនបានពាក់ព័ន្ធនឹងការបញ្ជូនសមាជិកកងពលលេខ ១៦៤ ទៅមន្ទីរសន្តិសុខ ស-២១ នេះ មានភាពស៊ីសង្វាក់ទៅនឹងសក្ខីកម្មរបស់សាក្សីដែលជាអតីតអ្នកដឹកអ្នកទោសនៃមន្ទីរសន្តិសុខ ស-២១ ដែលបានលើកឡើងពីភារកិច្ចរបស់មន្ទីរសន្តិសុខ ស-២១ ក្នុងការចុះទៅចាប់មនុស្សដល់អង្គភាព។ សាក្សីរូបនេះបានអះអាងថាគាត់ធ្លាប់ធ្វើដំណើរនៅពេលយប់ជាមួយនិរសាម្នាក់ឈ្មោះ ផល ដែលមានសំបុត្របញ្ជាឱ្យ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

ចាប់ខ្លួនរបស់ ឌុច ទៅចាប់មនុស្សនៅ តាកែវ កំពង់សោម នៅក្នុងអំឡុងឆ្នាំ ១៩៧៧-១៩៧៨ ។[872]

២៨១. ក្នុងករណីនេះ ឌុច បានយល់ឃើញថា ពាក់ព័ន្ធនឹងសិទ្ធិអំណាចក្នុងការចាប់ និងបញ្ជូនខ្លួនមនុស្ស **មាស មុត** មិនមានសិទ្ធិសម្រេចចាប់ខ្លួនមនុស្សឡើយ ជាក់ស្តែង ឌុច បានអះអាងថា *"(...) បង មុត ឈ្មោះដើម មាស មុត នោះគាត់ធ្វើជាលេខាតំបន់ឯករាជ្យកំពង់សោម។ គាត់ចូលជាជំនួយការមជ្ឈិមទេ មិនទាន់ទៅជាសមាជិកពេញសិទ្ធិទេ។ ដូច្នេះតែកាលណាមិនទាន់ទៅជាសមាជិកមជ្ឈិមពេញសិទ្ធិ មិនមានសិទ្ធិសម្រេចចាប់បេក្ខជនយកទៅដាក់គុកបានទេ"* ។[873]

២៨២. ចំពោះការទំនាក់ទំនងដោយផ្ទាល់រវាងកងពលលេខ ១៦៤ និងមន្ទីរសន្តិសុខ ស-២១ ឌុច ក៏បានបញ្ជាក់ដែរថា *"ទំនាក់ទំនងរវាងអង្គភាពទាំងពីរខ្ញុំមិនដឹងទេ ប៉ុន្តែបើមើលតាមរចនាសម្ព័ន្ធចាត់តាំង គឺមិនមានការទាក់ទងគ្នាផ្ទាល់ទេ ។ ស-២១ គោរពតាមបញ្ជារបស់អគ្គសេនាធិការ មុនបញ្ជូនមក ស-២១ មេសម្រេចរួចហើយ ទើបឱ្យណាតមកប្រាប់ និងចាត់ចែងនេះ ជាអ្វីដែលកើតឡើងស្ទើរតែ ៩៥%"* ។[874] ជាក់ស្តែង សហចៅក្រមស៊ើបអង្កេតមិនបានរកឃើញឯកសារ ឬលិខិតដែលបង្ហាញអំពីទំនាក់ទំនងដោយផ្ទាល់របស់ ឌុច និង **មាស មុត** ឡើយ។

២៨៣. មិនតែប៉ុណ្ណោះ ចំណារនានានៅលើចម្លើយសារភាព និងសេចក្តីរាយការណ៍មួយចំនួន[875] មានភាពស៊ីសង្វាក់ទៅនឹងសក្ខីកម្មរបស់ ឌុច និងអតីតអ្នកដឹកអ្នកទោសទៅមន្ទីរសន្តិសុខ ស-២១ ដែលបង្ហាញថា **មាស មុត** មិនអាចធ្វើសេចក្តីសម្រេចដោយខ្លួនឯងបានទេ នៅពេលមានការសង្ស័យថា នរណាម្នាក់ពីកងពលរបស់គាត់ថាជាជនក្បត់ **មាស មុត** មាននាទីតាមដានពីជននោះ និងធ្វើការរាយការណ៍ជូនទៅថ្នាក់លើរបស់គាត់ គឺ តាមរយៈសុន សេន ដើម្បីស្នើសុំការសម្រេចពីអង្គការ បើមិនមានការសម្រេចពី សុន សេន ទេ **មាស មុត** មិនអាចធ្វើការចាប់ខ្លួនមនុស្សពីកងពលរបស់ខ្លួនឡើយ ។[876] ពេលខ្លះ សុន សេន ក៏ត្រូវសុំ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

យោបល់ឯកភាពពី តា ម៉ុក ដើម្បីចាប់ទូកថៃ និងវៀតណាមដែលបានរំលោភចូលមកក្នុងដែនទឹកកម្ពុជា[877] ហើយមានពេលខ្លះ សុន សេន ក៏ត្រូវសុំយោបល់ពី នួន ជា បន្ទាប់ពីរាយការណ៍ជូន តា ម៉ុក រួចហើយ មុននឹងសម្រេចធ្វើការចាប់ខ្លួនយោធានៅក្នុងកងពលលេខ ១៦៤ ។[878]

២៨៤. ទាក់ទិននឹងបញ្ហាចាប់មនុស្សនេះ ជាគោលការណ៍ប្រសិនបើថ្នាក់លើចេញបទបញ្ជាឱ្យចាប់បញ្ជូនហើយ ការមិនអនុវត្តតាមបញ្ជា ឬធ្វើការសម្រេចចាប់មនុស្សដោយខ្លួនឯង នឹងនាំឱ្យមានបញ្ហាដូចជា ត្រូវទទួលរងការដាក់ទណ្ឌកម្មធ្ងន់ពីសំណាក់ ប៉ុល ពត ដូចករណី ណាត ជាដើម ។[879] ពេលខ្លះ សុន សេន ក៏ត្រូវសុំការអនុញ្ញាតពី ប៉ុល ពត មុនពេលសម្រេច និងមានករណីមួយចំនួន សុន សេន ក៏សុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់ដែរ ដូចករណី ណាត និង ពីន ។ សក្ខីកម្មរបស់ ឌុច បានបង្ហាញថាមិនមានការសុំយោបល់ និងការសម្រេចនេះចំពោះករណី **មាស មុត** ទេ ។ ឌុច បានបញ្ជាក់ថា *"(...) ហើយ សុន សេន មុនពេលសម្រេច គាត់តែងតែសុំយោបល់ និងការជួយសម្រេចពីប្រធានកងពលផ្ទាល់នោះ ។...ចំពោះ ស៊ូ ម៉ែត និង* ***មាស មុត*** *មិនមាន ឯកសារបញ្ជាក់ពីការសុំការពិនិត្យនេះទេ"* ។[880]

២៨៥. ទោះបីយ៉ាងណា ក្នុងនាមជាលេខាកងពលលេខ ១៦៤ **មាស មុត** ទទួលបានការជូនដំណឹងអំពីការចាប់ខ្លួន ។ ជាក់ស្តែង **មាស មុត** ត្រូវបានជូនដំណឹងអំពីមនុស្សដែលត្រូវបានចាប់ខ្លួន ដោយទទួលដំណឹងពីអនុលេខារបស់គាត់ ឈ្មោះ ឌឹម នៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៧៦ ។ នៅក្នុងរបាយការណ៍នោះ ឌឹម បានរាយការណ៍ថា *"សភាពនីគោកនៅឃុំរាម និងបបុល ពីយើងមានវិធានការចំពោះខ្មាំងមួយដែលបងសម្រេច វាមានរត់ចូលព្រៃ ៥ នាក់ ឥឡូវយើងតាមចាប់បានទាំងអស់..."* ។[881] របាយការណ៍នេះក៏ត្រូវបានចម្លងជូនទៅបង នួន បង ខៀវ និងបង មុត ។



E.C.C.C. C.E.T.C. CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

២៨៦. មិនតែប៉ុណ្ណោះការរាយការណ៍អំពីការចាប់ខ្លួនមនុស្ស ក៏ត្រូវបានលើកឡើងនៅក្នុងអង្គប្រជុំយោធា ដូចជាក្នុងកិច្ចប្រជុំយោធាសមមិត្ត ១៦៤ នៅថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ គេបានរាយការណ៍ថា *"សភាពការណ៍ផ្ទៃក្នុងថ្ងៃ ២៥-៨ កម្លាំងទៅពីជ្រោយចង្វារនៅស្ទឹងហាវ បានប្រជុំគ្នាដាក់ផែនការរត់ ។ មេដឹកនាំឈ្មោះ វង់ ស្រួល កម្មាភិបាលអនុសេនាតូច ។ គ្នាចូលរួមមាន ៤០ នាក់...គណៈកងពលបានបំបែកពួកមិនល្អឲ្យនៅដោយឡែក ដើម្បីកុំឲ្យច្របូកច្របល់នឹងពួកល្អ "* ។[882] នៅក្នុងអង្គប្រជុំនេះ បង ៨៩ គឺសុន សេន បានបញ្ជាថា *"ឈ្មោះ វង់ ស្រួល នោះ ចាប់សួរចម្លើយទៅ "* ។[883] ឯកសារនេះបានបង្ហាញឲ្យឃើញថា សេចក្ដីសម្រេចកម្ទេចមនុស្សមិនអាចធ្វើបានភ្លាមៗទេ គឺចាំបាច់ត្រូវតែរាយការណ៍ទៅថ្នាក់លើ ហើយរង់ចាំអនុវត្តតែតាមបញ្ជាវិញ ជាក់ស្ដែង សុន សេន ជាអ្នកបង្គាប់ឲ្យ មាស មុត ចាប់ខ្លួនអ្នកទាំងនោះដើម្បីសួរចម្លើយជាមុន ។ ឌុច ក៏អះអាងដែរថា ធ្លាប់មានករណីចាប់ខ្លួនទាំងឈុតនៅក្នុងអង្គភាពតែមួយ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ឌុច បានប្រាប់ទៅ ហ៊ី ឲ្យពិភាក្សាជាមួយអ្នកទទួលខុសត្រូវអង្គភាព ដើម្បីកុំឲ្យមានការជ្រួលច្របល់ ។[884]

២៨៧. ជាក់ស្ដែងនៅឆ្នាំ ១៩៧៦ មានមនុស្សប្រហែល ៥៥ (ហាសិបប្រាំ) នាក់ មកពីកងពលលេខ ១៦៤ ត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខ ស-២១ ។[885] បញ្ជីឈ្មោះអ្នកទោសពីកងពលលេខ ១៦៤ នេះ ត្រូវបានធ្វើឡើងដោយមន្ទីរសន្តិសុខ ស-២១ តែប៉ុណ្ណោះ ។[886] នៅក្នុងបញ្ជីនេះ មិនបានបញ្ជាក់ថាតើនរណាជាអ្នកចាប់ខ្លួនបុគ្គលិកកងពលលេខ ១៦៤ ហើយបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ នោះឡើយ ។

## ២. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

២៨៨. **មាស មុត** ត្រូវបានចោទប្រកាន់ក្នុងនាមជាលេខាកងពលលេខ ១៦៤ ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទាក់ទងនឹងការទទួលខុសត្រូវលើមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណដែលស្ថិតក្រោមការគ្រប់គ្រងរបស់កងពលលេខ ១៦៤ ។[887]



*E.C.C.C.* C.E.T.C. CO-INVESTIGATING JUDGES

## ២.១. ទីតាំង និងការបង្កើតមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ

២៨៩. មន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ជាអតីតវត្តមួយដែលមានទីតាំងនៅកំពង់សោម (បច្ចុប្បន្ន ខេត្តព្រះសីហនុ) ។[888] តាមប្រវត្តិរបស់វត្តឥន្ទញ្ញាណនេះ វត្តត្រូវបានកសាងឡើងនៅក្នុងឆ្នាំ ១៩៦៣ ។[889] រីឯមន្ទីរសន្តិសុខវត្តឥន្ទញ្ញាណ ត្រូវបានបង្កើតឡើងនៅពេលណានោះ គឺមិនមានឯកសារជាភ័ស្តុតាងណាមួយបញ្ជាក់ឱ្យបានច្បាស់លាស់ពីបញ្ហានេះទេ ។[890]

២៩០. សាក្សីម្នាក់បានអះអាងថា "កុដិទីពីរ" ដែលជាកន្លែងដាក់អ្នកទោសនៅជាន់ផ្ទាល់ដីនៅក្នុងឆ្នាំ ១៩៧៧ ។[891] ចំណែកឯសាក្សីម្នាក់ទៀត បានបង្ហាញថា "កុដិទីបី" ដែលជាកន្លែងគាត់ឃើញខ្មោះ និងស្នាមឈាមនៅលើជញ្ជាំងនៅឆ្នាំ ១៩៧៨ ។[892]

## ២.២. រចនាសម្ព័ន្ធ និង ដំណើរការប្រព្រឹត្តទៅ

២៩១. សាក្សីម្នាក់ បានបង្ហាញពី "កុដិទីមួយ" គឺជាកុដិដែលគាត់បានស្នាក់នៅជាមួយមេបញ្ជាការកងវរៈសេនាតូចលេខ ៤៥០[893] ដែលជាអង្គភាពយាមវត្តឥន្ទញ្ញាណ[894] ស្ថិតក្រោមការទទួលខុសត្រូវរបស់ តា នន[895]។ កងវរៈសេនាតូចលេខ ៤៥០[896] គឺជាអង្គភាពដែលគ្រប់គ្រងវត្តឥន្ទញ្ញាណ ហើយជាអង្គភាពដែលមានមុខងារទទួលខុសត្រូវខាងសន្តិសុខទូទៅសម្រាប់កងពលលេខ ១៦៤[897]។

## ២.៣. មុខងារ

២៩២. សាក្សីបានបញ្ជាក់ថានៅរបបកម្ពុជាប្រជាធិបតេយ្យ ទីតាំងវត្តនេះត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខ ។[898] សាក្សីម្នាក់ បានគូសបញ្ជាក់ថាវត្តឥន្ទញ្ញាណ "*គឺជាកន្លែងឃុំបណ្តោះអាសន្នចំពោះអ្នកដែលគេសង្ស័យ ឬជាប់ចោទរឿងរ៉ាវផ្សេងៗ*" ។[899] គាត់បានបញ្ជាក់បន្ថែមទៀត



E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ថា *"បន្ទាប់ពីគេរកឃើញកំហុសរបស់ជននោះហើយ គេបញ្ជូនចេញទៅភ្នំពេញ ឬកន្លែងផ្សេងទៀត "* ។[900] ទោះបីជាយ៉ាងណាក៏ដោយសាក្សីរូបនេះបានអះអាងថា តាមដែលគាត់ធ្លាប់បានស្នាក់នៅវត្តនោះ (រហូតដល់ខែ សីហា ឬ កញ្ញា ឆ្នាំ ១៩៧៥) គាត់មិនបានឃើញមនុស្សជាប់ឃុំឃាំងឡើយ ។[901]

២៩៣. សាក្សីម្នាក់បានធ្វើការបញ្ជាក់ទាក់ទងនឹងវត្តឥន្ទញាណថា វត្តនេះហាក់ដូចជាមិនមែនកន្លែងឃុំឃាំងមនុស្សទេ ។[902] សាក្សីម្នាក់ផ្សេងទៀតបានអះអាងថា វត្តឥន្ទញាណ គឺត្រូវបានវាយកម្ទេចចោល ទីធ្លាទុកសម្រាប់ផលិតជី ហើយមានកងទ័ពឈរជើងនៅក្នុងវត្តដើម្បីការពារកំពង់ផែ និងកងទ័ពជើងទឹក។[903]

## ២.៤. ការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់អ្នកទោស

២៩៤. ពាក់ព័ន្ធនឹងស្ថានភាពរបស់អ្នកទោសនៅក្នុងមន្ទីរសន្តិសុខវត្តឥន្ទញាណ មានសាក្សីម្នាក់បានអះអាងថា *"រូបរាង និង ទឹកមុខរបស់អ្នកជាប់ឃុំឃាំងនោះមានស្ថានភាពខុសពីធម្មតា ប៉ុន្តែមិនមែនធ្លាក់ដល់ស្ថានភាពស្គមស្គាំងខ្លាំងពេកនោះទេ "* ។[904] សាក្សីម្នាក់ទៀតអះអាងថា គាត់បានចូលទៅក្នុងវត្តនៅខែ មេសា ឆ្នាំ ១៩៧៩ និងបានឃើញខ្នោះប្រហែល ១០ (ដប់) និងឈាម ហើយមានជញ្ជាំងមួយសម្រាប់ដាក់ច្រវ៉ាក់ ព្យួរកអ្នកទោស និងបាននិយាយថា អ្នកទោសត្រូវបានធ្វើទារុណកម្មនៅក្នុងកុដិធំ ។[905]

២៩៥. សាក្សីម្នាក់បានបញ្ជាក់ថា *" នៅវត្តនោះនៅខែ សីហា ឆ្នាំ ១៩៧៩ មានខ្នោះប្រហែល ៥០ ទៅ ៦០ នៅក្នុងកុដិវែង បែរមុខទៅកើតលិច នៅខាងត្បូងវត្ត ។ ក៏មានរបារដែក និងឈាមនៅលើជញ្ជាំង ខ្នោះដាក់គន្លឹះជាប់ជាមួយនឹងរបារដែក ហើយមានបន្ទប់សម្រាប់ដាក់មនុស្សប្រហែល ១០ នាក់ក្នុងមួយជួរ"* ។[906]



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៩៦. សាក្សីម្នាក់បានបញ្ជាក់ថា នៅរវាងឆ្នាំ ១៩៨០ ទៅដល់ឆ្នាំ ១៩៨២ មានសាកសពប្រហែល ២០០ (ពីររយ) សាកសព ត្រូវបានគាស់រកឃើញនៅចម្ងាយប្រហែល ១០០ (មួយរយ) ម៉ែត្រខាងត្បូងវត្ត ។[907] ប៉ុន្តែសាក្សីម្នាក់ទៀតជឿថាមិនមានការសម្លាប់មនុស្សនៅក្នុងវត្តឥន្ទញាណទេ ។[908] គាត់បានឱ្យដឹងថា "*ប្រសិនបើមានការសម្លាប់នៅកន្លែងនោះមែន គឺគេមិនអាចលាក់ជិតទេ ពីព្រោះនៅតំបន់ជុំវិញនោះមានមនុស្សរស់នៅច្រើន* " ។[909] ប៉ុន្តែរហូតមកដល់ពេលនេះ យើងមិនមានភស្តុតាង ឬទិន្នន័យច្បាស់លាស់ណាមួយ ដើម្បីបញ្ជាក់ថាសាកសពទាំងនេះពិតជាជនរងគ្រោះ ដែលត្រូវគេសម្លាប់នៅក្នុងមន្ទីរសន្តិសុខវត្តឥន្ទញាណនេះទេ ។

## ២.៥. ការចូលរួម និងអំណាច

២៩៧. កងវរៈសេនាតូចលេខ ៤៥០ បានឈរជើងនៅជិតស្ទឹងហាវ នៅក្នុងឆ្នាំ ១៩៧៥ និងមានភារកិច្ចទទួលបន្ទុកកសាងផែស្ទឹងហាវ ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨ ។[910] កងវរៈសេនាតូច ៤៥០ នេះ ប្រហែលជាបានមកកាន់វត្តឥន្ទញាណក្នុងអំឡុងចុងខែ មេសា ឬ ដើមខែ ឧសភា ឆ្នាំ ១៩៧៥ [911] និងមានមុខងារខាងសន្តិសុខទូទៅផងដែរសម្រាប់កងពលលេខ ១៦៤ ។[912] ។ តា នន ជាអ្នកទទួលខុសត្រូវក្នុងអង្គភាពសន្តិសុខ ៤៥០ ។[913] មិនមានឯកសារបង្ហាញពីវត្តមានរបស់ **មាស មុត** នៅពេលចាប់ខ្លួន ឬការត្រួតពិនិត្យជាទៀតទាត់នៅវត្តឥន្ទញាណឡើយ ។

## ៣. ការដ្ឋានវាយថ្មស្ទឹងហាវ

២៩៨. **មាស មុត** ត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទាក់ទងនឹងការទទួលខុសត្រូវលើការគ្រប់គ្រងការដ្ឋានការងារដោយបង្ខំឱ្យធ្វើការជាទម្ងន់ នៅការដ្ឋានវាយថ្មស្ទឹងហាវ ។[914]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

## ៣.១. ទីតាំង ការបង្កើត រយៈពេល និងរចនាសម្ព័ន្ធ

២៩៩. ការដ្ឋានវាយថ្មស្ទឹងហាវ និងទីតាំងពាក់ព័ន្ធមានទីតាំងនៅក្នុងឃុំ ស្ទឹងហាវ កំពង់សោម (បច្ចុប្បន្ន ខេត្តព្រះសីហនុ)។[915] ទីតាំងការដ្ឋានវាយថ្មទាំងនេះ មានទីតាំងស្ថិតនៅតាមបណ្តោយឆ្នេរខាងលិចនៃជ្រោយស្ទឹងហាវតូចនេះ ហើយមានកន្លែងវាយថ្មដែលមានរណ្តៅយ៉ាងហោចណាស់ចំនួន ៣ (បី) កន្លែង ដែលគេជីកយកថ្ម និងទីតាំងមូលដ្ឋានមួយកន្លែងរបស់ទាហានកងពលលេខ ១៦៤ ។[916] កន្លែងវាយថ្មនេះ ស្ថិតនៅជិតនឹងកំពង់ផែកងទ័ពជើងទឹក ដែលជាផ្នែកមួយនៃគម្រោងកសាងកំពង់ផែនាវារបស់កម្ពុជាប្រជាធិបតេយ្យ ។[917] ចម្ងាយពីកន្លែងវាយថ្ម ទៅទីបញ្ជាការដ្ឋានរបស់កងពលលេខ ១៦៤ នៅក្នុងក្រុងកំពង់សោម គឺមានចម្ងាយប្រវែងប្រហែល ១៧,៥៣ (ដប់ប្រាំពីរក្បៀសហាសិបបី) គីឡូម៉ែត្រ និង ២,៣ (ពីរក្បៀសបី) គីឡូម៉ែត្រ ទៅកាន់ទីបញ្ជាការកងវរៈសេនាធំរបស់កងពលលេខ ១៦៤ នៅស្ទឹងហាវ ។ [918]

៣០០. ការដ្ឋានវាយថ្មស្ទឹងហាវ បានចាប់ផ្តើមប្រហែលដំណើរការលើទីតាំងនេះនៅអំឡុងរវាងឆមាសទីពីរ ក្នុងឆ្នាំ ១៩៧៥ ឬ នៅដើមឆ្នាំ ១៩៧៦ ។[919] នៅឆ្នាំ ១៩៧៥ បន្ទាប់ពីត្រូវបញ្ជូនមកពីកោះតាង កងវរៈសេនាតូចលេខ ៤៥០ បានឈរជើងនៅជិតស្ទឹងហាវ ។[920] សាក្សីម្នាក់បានបញ្ជាក់ថា កងវរៈសេនាតូចលេខ ៤៥០ នេះ ទទួលបន្ទុកខាងកសាងផែស្ទឹងហាវចាប់ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨ ។[921]

## ៣.២. មុខងារ

៣០១. ការដ្ឋានវាយថ្មស្ទឹងហាវ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅក្នុងអំឡុងពេលមានតម្រូវការសម្ភារៈសំណង់សម្រាប់កសាងកំពង់ផែនៅស្ទឹងហាវ និងសម្រាប់ធ្វើផ្លូវមួយដែលតភ្ជាប់កំពង់ផែស្ទឹងហាវទៅកាន់កន្លែងចម្រាញ់ប្រេងកាតនៅកំពង់សោម[922] ហើយបានធ្វើរួចរាល់នៅឆ្នាំ ១៩៧៦ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ[923]។ ការងារនៅការដ្ឋានស្ទឹងហាវ តម្រូវឱ្យមានការដឹកជញ្ជូនថ្មទៅមាត់សមុទ្រ ហើយដាក់ចូលក្នុងទឹក ដោយប្រើដៃ ឬក៏ប្រើម៉ាស៊ីន ។[924]

៣០២. ការដ្ឋានវាយថ្មស្ទឹងហាវនេះ ត្រូវបានបង្កើតឡើងជាការដ្ឋានការងារសម្រាប់ទាំងកងទ័ព និងប្រជាជនដែលរស់នៅក្រោមការគ្រប់គ្រងរបស់កងពលលេខ ១៦៤ ។[925] មានមនុស្សប្រហែល ១០០ (មួយរយ) នាក់ ដែលធ្វើការនៅកន្លែងវាយថ្ម ។[926] កម្មករភាគច្រើននៅការដ្ឋានស្ទឹងហាវ គឺជាកងទ័ពមកពីកងពលលេខ ១៦៤ ប៉ុន្តែក៏មានសមាសភាពជាប្រជាជនជាប់និន្នាការមិនល្អ កងទ័ព កម្មករ ក្រុមអ្នកនេសាទ សមាជិកកងនាវា សមាជិកក្រុមគ្រួសារកងទ័ព សមាជិកក្រុមគ្រួសារមន្ត្រីរដ្ឋការសម័យមុន[927] និងស្ត្រីក៏ត្រូវបានគេប្រើឱ្យធ្វើផ្លូវនោះដែរ[928]។

## ៣.៣. ស្ថានភាពការងារ និងរស់នៅ

៣០៣. ពាក់ព័ន្ធនឹងស្ថានភាពការងារនៅស្ទឹងហាវ កម្មករនៅការដ្ឋានស្ទឹងហាវ ត្រូវបានប្រើឱ្យធ្វើការងាររែក និងសែងថ្ម ។[929] ក្រៅពីការប្រើកម្លាំងពលកម្មមនុស្ស គេក៏មានប្រើប្រាស់ផងដែរនូវគ្រឿងចក្រ ម៉ាស៊ីនស្ទូច និងគ្រឿងផ្ទុះមួយចំនួន ។[930]

៣០៤. ក្រោយឆ្នាំ ១៩៧៥ មានជំនាញការចិនបានចូលមកក្នុងប្រទេសកម្ពុជា ដើម្បីផ្តល់ជាជំនួយទាំងថវិកា និង បច្ចេកទេសដល់កម្ពុភិបាលបក្ស ។[931] អ្នកប្រឹក្សាជនជាតិចិន បានបង្រៀនមនុស្សមកពីកងពលលេខ ១៦៤ អំពីរបៀបបំបែកថ្មចេញពីភ្នំ ទាក់ទងនឹងបច្ចេកទេស ទំហំ និងរូបរាង ។[932] ចំពោះរបបអាហារសម្រាប់កម្មករបម្រើការងារនៅក្នុងគម្រោងកសាងផ្លូវស្ទឹងហាវ គឺដូចគ្នានឹងរបបដែលយោធាទទួលបានដែរ ប៉ុន្តែការងាររបស់កម្មករមានស្ថានភាពលំបាកជាង ។[933]

## ៣.៤. ការចូលរួមរបស់ មាស មុត

៣០៥. ការដ្ឋានវាយថ្មស្ទឹងហាវ ស្ថិតក្រោមការគ្រប់គ្រងរបស់កងវរៈសេនាតូចលេខ ៤៥០ ដែលស្ថិតក្រោមកងពលលេខ ១៦៤ ។[934] បើទោះបីជា **មាស មុត** ជាលេខាកងពលក៏ដោយ តែក៏មិនមានសក្ខីកម្ម ឬភ័ស្តុតាងជាក់លាក់ណាមួយបញ្ជាក់ពីការត្រួតពិនិត្យការដ្ឋានដោយ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

មាស មុត ឡើយ ។ ម្យ៉ាងទៀតទាក់ទងនឹងអំណាចក្នុងការចាប់ចង និងសួរចម្លើយ មាស មុត បានត្រឹមតែរាយការណ៍ និងទទួលបញ្ជាពី សុន សេន ប៉ុណ្ណោះ ហើយគាត់បាននាំនាំបញ្ជានេះទៅឱ្យកងវរៈសេនាតូចលេខ ៤៥០ ជាអ្នកអនុវត្តបញ្ជាបន្ត ។ ជាក់ស្តែងដូចជានៅក្នុងអង្គប្រជុំនាថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ មាស មុត បានរាយការណ៍ថា "*សភាពការណ៍ផ្ទៃក្នុងថ្ងៃ ២៥-៨ កម្លាំងទៅពីជ្រោយចង្វារនៅស្ទឹងហាវ បានប្រជុំគ្នាដាក់ផែនការរត់ ។ (...) គណៈកងពលបានបំបែកពួកមិនល្អឱ្យនៅដោយឡែក ដើម្បីកុំឱ្យច្របូកច្របល់នឹងពួកល្អ*" ។[935] បន្ទាប់មកបង ៨៩ គឺសុន សេន បានបញ្ជាទៅ មាស មុត ថា "*ឈ្មោះ វង់ ស្រួលនោះ ចាប់សួរចម្លើយទៅ*" ។[936]

## ៤. ឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យនៅក្នុងដែនទឹក និងដែនកោះ

៣០៦. មាស មុត ត្រូវបានចោទប្រកាន់ទាក់ទងនឹងឧក្រិដ្ឋកម្មក្នុងការចាប់ ឬកម្ទេចនាវាបរទេសដូចជានាវារបស់ថៃ ឬវៀតណាមដែលបានរំលោភចូលមកក្នុងដែនទឹកកាន់កាប់ដោយកម្ពុជាប្រជាធិបតេយ្យ ។[937]

### ៤.១. ឧប្បត្តិហេតុ

៣០៧. បញ្ជីអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ចង្អុលបង្ហាញថា បានទទួលជនជាតិវៀតណាម ចំនួន ១០ (ដប់) នាក់ ពីកំពង់សោម ដែលអាចបញ្ជូនពីកងពលលេខ ១ និង ចំនួន ២ (ពីរ) នាក់ ពីកងពលលេខ ១៦៤ ។[938]

៣០៨. ស៊ឹម ដែលត្រូវបានអះអាងថាជាអ្នកគ្រប់គ្រងកប៉ាល់ ប៉េ សេ អេហ្វ (PCF) ដែលទទួលខុសត្រូវក្នុងការចាប់ទូកថៃ និងវៀតណាម[939] ធ្លាប់ធ្វើការរាយការណ៍ទៅ មាស មុត , បង ៨៩

និងមន្ទីរ ៨៧០ អំពីការចាប់បានទូកថៃចំនួន ២ (ពីរ) គ្រឿង នៅខាងត្បូងកោះកុង អំពីសម្ភារៈរឹបអូសបាន ប៉ុន្តែមិនបានចាប់មនុស្សទេព្រោះមនុស្សខ្លះលោតធ្លាក់ទឹក ហើយមនុស្សខ្លះទៀតត្រូវបានកម្ទេចចោលអស់ ។[940]

៣០៩. ឧប្បត្តិហេតុកប៉ាល់ ម៉ៃយ៉ាហ្គេស (Mayaguez) បានកើតឡើងនៅអំឡុងខែ ឧសភា ឆ្នាំ ១៩៧៥ ។[941] ឯកសារខ្លះបង្ហាញថា កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានចាប់ជនជាតិអាមេរិកម្នាក់ដែលមិនស្គាល់អត្តសញ្ញាណ ហើយការចាប់ខ្លួននេះបានរក្សាការសម្ងាត់តាមបញ្ជារបស់កងពលលេខ ១៦៤ ដែលការពារដែនសមុទ្រកម្ពុជា ។[942]

៣១០. សាក្សី ឈូក រីន បានអះអាងថា *"ខ្ញុំដឹងថាមានការចាប់កប៉ាល់មួយរបស់អាមេរិកាំងឈ្មោះ ម៉ៃយ៉ាហ្គេស ហើយ មាស មុត អាចដឹងច្បាស់ណាស់ពីរឿងនេះ "* ។[943] សាក្សីមួយចំនួន[944] បានឲ្យដឹងថាទោះបីជា **មាស មុត** ជាអតីតលេខាកងពលលេខ ១៦៤ (អតីតកងពលលេខ ៣) យ៉ាងណាក៏ដោយ សាក្សីមិនជឿថាគាត់មាន *" ព័ត៌មានលម្អិតអំពីសង្គ្រាម ឬជោគវាសនារបស់កងកម្លាំងអាមេរិកដែលបានបាត់ខ្លួនដែរ"* ។ សាក្សីរូបនេះបានបន្ថែមថា *" កងពលលេខ ៣ គ្មានការបញ្ជាទាក់ទងនឹងការប្រព្រឹត្តទៅលើអ្នកទោសឡើយ ពីព្រោះថាគេមិនដែលបានចាប់ជនជាតិអាមេរិកនៅក្នុងសង្គ្រាមឡើយ"* ។[945]

៣១១. ឯកសារខ្លះ បង្ហាញថា **មាស មុត** បានចូលសម្រាកពេទ្យនៅភ្នំពេញ ពីខែ ឧសភា ដល់ ខែ កក្កដា នៅក្នុងអំឡុងពេលឧប្បត្តិហេតុកប៉ាល់ម៉ៃយ៉ាហ្គេស ។ គាត់បានត្រឡប់មកកំពង់សោម នៅខែ កក្កដា ឬខែ សីហា ឆ្នាំ ១៩៧៥ ។ គាត់បានបញ្ជាក់ថា គាត់ទទួលព័ត៌មានពីប្រពន្ធរបស់គាត់ និងពី ឆាន ទាក់ទងនឹងការចាប់កប៉ាល់ម៉ៃយ៉ាហ្គេស និងការវាយប្រហាររបស់អាមេរិក បន្ទាប់ពីឧប្បទ្ទវហេតុបានកើតឡើង និងមិនបានដឹងពីរឿងនេះពិស្តារទេ។[946]

៣១២. ទូកឈ្មោះ "ស្ត្រីកញ្ជ្រោង" (Foxy Lady) ដឹកជនជាតិអង់គ្លេសម្នាក់ឈ្មោះ ចន ឌេវរើស (John Dewhirst) ជនជាតិញូហ្សេឡែនម្នាក់ឈ្មោះ ខេរី ហាមីល (Kerry Hamill) និងជន



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

ជាតិកាណាដាម្នាក់ឈ្មោះ ស្ទួអាត គ្លាស (Stuart Glass) ត្រូវចាប់បាននៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៧៨ ។[947]

## ៤.២. ចំនួនជនរងគ្រោះ

៣១៣. **មាស មុត** ធ្លាប់រាយការណ៍ទៅ សុន សេន ទាក់ទងនឹងការបាញ់ទូកវៀតណាម ១ (មួយ) គ្រឿង នៅកោះខ្យង ការចាប់ទូកថៃ ១ (មួយ) គ្រឿង ដែលមានមនុស្សចំនួន ២១ (ម្ភៃមួយ) នាក់ នៅកោះវៃ និងការចាប់ទូកវៀតណាមចំនួន ២ (ពីរ) គ្រឿង ដែលមានមនុស្សចំនួន ៧៦ (ចិតសិបប្រាំមួយ) នាក់ នៅកោះតាង ។[948]

៣១៤. **មាស មុត** ក៏បានរាយការណ៍ទៅថ្នាក់លើស្ដីពីការចាប់ និងសម្លាប់ជនជាតិវៀតណាមចំនួន ១២០ (មួយរយម្ភៃ) នាក់ និងបានរាយការណ៍ពីការរឹបអូសទូក អាវុធ ព្រមទាំងការដោះដូរអ្នកនេសាទថៃ ។[949]

## ៤.៣. អំណាចរបស់ មាស មុត ក្នុងការចាប់ទូកនេសាទ និងការសម្លាប់អ្នកនេសាទ

៣១៥. ទីបញ្ជាការកងទ័ពជើងទឹក ធ្វើការប្រាស្រ័យទាក់ទងផ្ទាល់ជាមួយនឹងទីបញ្ជាការសេនាធិការនៅភ្នំពេញ និងជាមួយភូមិភាគនិរតីដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ តា ម៉ុក ។[950] ប៉ុន្តែការប្រាស្រ័យទាក់ទងជាមួយ តា ម៉ុក ត្រូវបានធ្វើឡើងតែក្នុងគោលបំណងខាងសេដ្ឋកិច្ច ឬភ័ស្តុភារតែប៉ុណ្ណោះ ។[951]

៣១៦. នៅក្នុងករណីខ្លះយើងឃើញថា បន្ទាប់ពីបានទទួលការរាយការណ៍ពី **មាស មុត** សុន សេន ក៏បានសុំមតិឯកភាពពី តា ម៉ុក និងបានសម្រេចបញ្ជូន **មាស មុត** ទៅពិនិត្យស្ថានការណ៍ និងដោះស្រាយបញ្ហានានាទាក់ទងនឹងទូកវៀតណាម និងថៃ ដែលបានចូលមកក្នុងដែនទឹកកម្ពុជា ។[952]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01596109



៣១៧. ទោះបីជាមិនមានការប្រកាសអំពីតួនាទី និងមុខតំណែងរបស់ តា ម៉ុក នាពេលនោះក៏ដោយ តា ម៉ុក ត្រូវបានគេស្គាល់ថាជាអគ្គបញ្ជាការកងទ័ព ព្រោះគាត់តែងតែមានសកម្មភាពចុះផ្ទាល់ទៅសមរភូមិដើម្បីបញ្ជាផ្ទាល់ទៅលើប្រធានកងពល ។[953]

៣១៨. ទាក់ទងនឹងការចាប់ខ្លួនមនុស្ស ជាទូទៅអង្គភាពប្រដេញគ្មានសិទ្ធិអំណាចចាប់មនុស្សទេ[954] ។ សាក្សីដែលជាអតីតមេបញ្ជាការនៅកងនាវាប្រដេញបានអះអាងថា ភារកិច្ចចម្បងរបស់នាវាប្រដេញនេះ តាមការណែនាំរបស់ថ្នាក់លើ គឺរង់ចាំការបញ្ជាពីថ្នាក់លើនៅពេលណាមានការប្រយុទ្ធ[955] ហើយអាចបើកការប្រយុទ្ធជាមួយតែនាវាណាដែលមានអាវុធទេ[956]។ នៅពេលដែលមិនមានការប្រយុទ្ធ អង្គភាពនេះបោះយុថ្ការង់ចាំ និងត្រៀមខ្លួនទទួលបញ្ជាដើម្បីប្រយុទ្ធនៅពេលសភាពការណ៍តម្រូវ ។ សាក្សីអះអាងថា "*នៅពេលចេញប្រយុទ្ធ គឺខ្ញុំមិនបានទទួលបញ្ជាផ្ទាល់ចេញពីកងពល (មុត ឬ ឌឹម) ទេ ការចេញបញ្ជាគឺធ្វើឡើងចេញពីប្រធានកងនាវា (ឈ្មោះ បូ) ប្រដេញផ្ទាល់របស់ខ្ញុំ*" ។[957] សាក្សីបានបញ្ជាក់បន្ថែមទៀតថា "*សូម្បីតែត្រូវទៅបោះយុថ្កានៅកន្លែងណាមួយក៏ត្រូវតែមានបញ្ជាឲ្យធ្វើតាមដែរ ។ ការចេញបញ្ជាគឺ ពីប្រធានកងនាវា មិនមែនចេញមកពីកងពលទេ*" ។[958]

៣១៩. ចំពោះអ្នកទោសទថៃ និងវៀតណាមដែលចាប់បានត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ឌុច បានអះអាងថា មានតែ សុន សេន ទេដែលមានសិទ្ធិបញ្ជូន ។[959] សក្ខីកម្មរបស់អតីតអ្នកយាមនៅមន្ទីរសន្តិសុខ ស-២១ បានលើកឡើងថា គាត់ធ្លាប់ធ្វើដំណើរជាមួយនិរសាដែលមានសំបុត្របញ្ជាឲ្យចាប់ខ្លួនរបស់ឌុច ទៅចាប់ទាំងខ្មែរ និងវៀតណាមនៅកំពង់សោម ។[960] មាស មុត ក៏បានអះអាងដែរថា និរសាដែលមកទទួលអ្នកទោសមានលិខិតចាប់ខ្លួន ។[961]

៣២០. ឈ្មោះ ស៊ីម ជាអ្នកទទួលខុសត្រូវនាវា ប៉េ សេ អេហ្វ (PCF) ទទួលខុសត្រូវខាងចាប់ចងអ្នកទោស និងរាយការណ៍ទៅថ្នាក់លើដែលរួមមាន បង ៨៩ (សុន សេន) បង មុត និងមន្ទីរ ៨៧០ តែសាក្សីមិនអាចដឹងថា ស៊ីម ទទួលបញ្ជាពីនរណាឡើយ ។[962] សក្ខីកម្មរបស់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

អតីតទាហាននៅកងពលលេខ ១៦៤[963] បានបង្ហាញថា លេខាកងពលគឺជាអ្នកទទួលខុសត្រូវទាំងអស់ តែគាត់មិនបានដឹងច្បាស់ពីរចនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងកងពលច្បាស់លាស់ និងអំណាចពិតប្រាកដក្នុងការបញ្ជាឲ្យចាប់ចង ឬសម្លាប់ឡើយ ។

៣២១. ឯកសារ និង សក្ខីកម្មមួយចំនួនបានបង្ហាញថា **មាស មុត** មិនអាចធ្វើការសម្រេចចិត្តតែម្នាក់ឯងបានទេទាក់ទងនឹងការចាប់ និងសម្លាប់អ្នកនេសាទដែលចាប់បាន ។ រាល់ការសម្រេចចិត្តអ្វីមួយ គេត្រូវមានការចូលរួមពីសមាជិកដទៃទៀតជារួម[964] និងត្រូវមានការអនុញ្ញាត និងសម្រេចពីថ្នាក់លើ[965]។ ជាក់ស្តែង នៅពេលប្រតិបត្តិការរួមគ្នា តា សឿង ដែលជាមេបញ្ជាការកងពលលេខ ១ និង តារ៉ន ដែលជាគណៈតំបន់ ៣៧ នៃភូមិភាគបស្ចិម ព្រមទាំង **មាស មុត** បានពិភាក្សារួមគ្នាមុននឹងធ្វើរបាយការណ៍ទៅ សុន សេន ទាក់ទងនឹងការចាប់ទូកនេសាទថៃ ។[966]

៣២២. **មាស មុត** ទទួលបានរបាយការណ៍ទាក់ទងនឹងការចាប់ទូក ឬសម្លាប់អ្នកនេសាទថៃ និងវៀតណាមហើយ[967] គាត់ក៏បានរាយការណ៍បន្តទៅភ្នំពេញ[968] ដើម្បីទទួលបញ្ជា និងវិធានការនានាពី សុន សេន[969] ហើយ សុន សេន ក៏ត្រូវរាយការណ៍ទៅអង្គការបន្តទៀតដែរ[970] ហើយពេលខ្លះ សុន សេន ក៏បានសុំយោបល់ឯកភាព ពី ម៉ុក និង ទិត[971]។ អគ្គសេនាធិការ សុន សេន ជាអ្នកពាំនាំនូវសេចក្តីសម្រេចមកពីគណៈអចិន្ត្រៃយ៍ ហើយបញ្ជាបន្តដល់លេខាកងពលនានា ក្នុងនោះមាន **មាស មុត** ផងដែរ ដែលជាអ្នកពាំនាំបញ្ជាបន្តដើម្បីអនុវត្តនៅថ្នាក់ក្រោមក្នុងការការពារដែនទឹកកម្ពុជា ។[972]

## ៥. ជម្លោះជាមួយវៀតណាម

៣២៣. ក្នុងនាមជាលេខាកងពលលេខ ១៦៤ **មាស មុត** ត្រូវបានចោទប្រកាន់ថា បានដឹកនាំកងទ័ពមកពីកងពលផ្សេងៗ ទៅកាន់ភូមិភាគបូព៌ា ដើម្បីវាយប្រហារវៀតណាមនៅចុងឆ្នាំ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

១៩៧៧ រហូតដល់ ឆ្នាំ ១៩៧៨ ដោយបានចាប់ និងសម្លាប់កងទ័ព ប្រជាជនវៀតណាម ព្រមទាំងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិផងដែរ ។[973]

៣២៤. កម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានទទួលស្គាល់ជាផ្លូវការថា នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៧ ជម្លោះប្រដាប់អាវុធជាអន្តរជាតិរវាងប្រទេសទាំងពីរបានកើតឡើង ដែលព័ត៌មាននេះបានបង្ហាញឲ្យដឹងតាមរយៈសេចក្តីថ្លែងការណ៍របស់រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា ដែលបានបញ្ជាក់ពីការផ្តាច់រាល់ទំនាក់ទំនងការទូតរវាងរដ្ឋទាំងពីរ ។[974] ទោះបីជាមានសេចក្តីថ្លែងការណ៍យ៉ាងនេះក្តី ក៏គេអាចចាត់ទុកបានថា ជម្លោះប្រដាប់អាវុធនេះ បានកើតមានឡើងតាំងពីឆ្នាំ ១៩៧៥[975] មកម្ល៉េះ ហើយជម្លោះនេះចេះតែឆាបឆេះសន្ធោសន្ធៅខ្លាំងឡើងៗជាបន្តបន្ទាប់[976] នៅគ្រប់កម្រិតរហូតដល់ពេលដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ[977]។

៣២៥. កងទ័ពបដិវត្តន៍កម្ពុជា និងកងទ័ពប្រជាជនវៀតណាម បានបើកការវាយប្រយុទ្ធប្រដាប់អាវុធ ក្រោមរូបភាពដូចជាការវាយលុក និងការចូលលុកលុយចូលទាំងក្នុងដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ[978] ក៏ដូចជាក្នុងដែនដីរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមផងដែរ[979]។ ការលុកលុយ និងការវាយប្រយុទ្ធគ្នានេះ ក៏បានកើតឡើងផងដែរនៅតាមកោះនានាក្នុងអំឡុងដើមឆ្នាំ ១៩៧៦ ។[980]

៣២៦. ជម្លោះប្រដាប់អាវុធនេះកាន់តែឆាបឆេះសន្ធោសន្ធៅខ្លាំងឡើងៗ រហូតបណ្តាលឲ្យកងទ័ពវៀតណាម បានចូលលុកលុយជាទ្រង់ទ្រាយធំចំនួន ២ (ពីរ) លើក ទៅក្នុងដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ ដោយលើកទីមួយនាខែ ធ្នូ ឆ្នាំ ១៩៧៧ និងលើកទីពីរនាខែ ធ្នូ ឆ្នាំ ១៩៧៨ ។ ការវាយលុកចូលលើកចុងក្រោយនេះ បានជម្រុញឲ្យកម្ពុជាប្រជាធិបតេយ្យប្តឹងទៅក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៧៨ ។[981]



* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

៣២៧. នៅចុងឆ្នាំ ១៩៧៧ រ៉ែន កូនប្រសាររបស់ តា ម៉ុក បានកោះប្រជុំ អៀង ផាន[982] និងមេកងពលភូមិភាគនិរតី ឲ្យមកប្រជុំនៅផ្ទះ តា ម៉ុក ដើម្បីប្រមូលទ័ពត្រៀមរៀបចំប្រយុទ្ធជាមួយវៀតណាម[983]។ ឈូក រីន ក៏បានចូលរួមប្រជុំនៅផ្ទះ តា ម៉ុក ផងដែរនៅឆ្នាំ ១៩៧៧ ដោយបានបញ្ជាក់នៅក្នុងសក្ខីកម្មអំពី ការត្រៀមប្រយុទ្ធ និងវត្តមាន ការបញ្ជាដោយ រ៉ែន/សុន សេន ។[984] អតីតមេបញ្ជាការឈ្មោះ ឃុន គីម ហៅ ប៉ែត បានចូលរួមប្រជុំថ្នាក់មេបញ្ជាការនៅចុងឆ្នាំ ១៩៧៧ នៅឯផ្ទះរបស់ តា ម៉ុក ដែលនៅទីនោះ សុន សេន និង តា ម៉ុក បានពន្យល់ពីផែនការក្នុងការវាយប្រហារវៀតណាម ។[985] សាក្សី ឈូក រីន បានអះអាងថា *"កាលពីវាយគ្នាដំបូងគឺរប៉េះរប៉ោះ ប៉ុន្តែក្រោយមកមានការវាយគ្នាទៅវិញទៅមកយ៉ាងខ្លាំង ហើយបានក្លាយទៅជាសង្គ្រាម ។ លោក មាស មុត ប្រហែលជាមិនបានចូលរួមទេ ពីព្រោះគាត់នៅជើងទឹក ហើយអ្នកដែលទៅបញ្ជានៅស្វាយរៀង គឺកូនប្រសាររបស់ តា ម៉ុក ឈ្មោះ រ៉ែន ដែលបានស្លាប់ទៅហើយ ហើយពេលអត់មាន សុន សេន រ៉ែន ជាអ្នកបញ្ជាផ្ទាល់។ ខ្ញុំមិនបានជួប មាស មុត ទេ"* ។[986]

៣២៨. សាក្សីម្នាក់បានបញ្ជាក់ថា នៅខែ ធ្នូ ឆ្នាំ ១៩៧៨ មានការប៉ះទង្គិចគ្នារវាងកងទ័ពជើងទឹកខ្មែរក្រហម និងកងទ័ពជើងទឹកវៀតណាម ។[987] គាត់បានបន្ថែមថា វៀតណាមជាច្រើននាក់ត្រូវបានបញ្ជូនទៅកងពល។ គាត់មិនដឹងថាមានអ្វីកើតឡើង ចំពោះពួកគេបន្ទាប់ពីនោះ ។[988] អតីតអ្នកដឹកអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ បានអះអាងថាគាត់ធ្លាប់បានរួមដំណើរជាមួយនិរសាឈ្មោះ ផល និង ហ៊ី តាមបញ្ជា ឌុច ដើម្បីទៅចាប់អ្នកទោសជាទាហានវៀតណាម ដែលចាប់បានពេលវាយគ្នានៅ តាកែវ និងកំពង់សោមដើម្បីបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ នៅអំឡុងឆ្នាំ ១៩៧៧ - ១៩៧៨ ។[989]

៣២៩. សាក្សី ឈូក រីន បានអះអាងថា *"មិនមានការចាប់ទុកថៃ និងវៀតណាមទេ ។ មានតែនៅឆ្នាំ ១៩៧៦ ទាហានវៀតណាមបានវាយយកកោះពូលូវៃ និងបានចាប់ទាហានខ្មែរក្រហម ប្រហែល ៦០០ ទៅ ៧០០ នាក់"* ។[990]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

## ៦. មន្ទីរឃុំឃាំង ៨១០ (កងពលលេខ ៨០១)

៣៣០. កងពលលេខ ៨០១ មាន កងវរៈសេនាធំចំនួន ៣ (បី) កងវរៈសេនាធំ[991] នៅក្រោមបង្គាប់ គឺ កងវរៈសេនាធំលេខ ៨១ , កងវរៈសេនាធំលេខ ៨២ និងកងវរៈសេនាធំលេខ ៨៣ ដែលមានកម្មាភិបាលដឹកនាំរួមមាន កែវ សារឿន[992], ប៉ាវ សំអុន[993], អ៊ុង វ៉ែន[994] និង ឌី ធិន[995]។ កងពលលេខ ៨០១ មានយ៉ាងហោចណាស់ចំនួន ៥ (ប្រាំ) កងវរៈសេនាតូចឯករាជ្យ[996] ដែលមិនស្ថិតនៅក្រោមកងវរៈសេនាធំឯករាជ្យទាំងបីរបស់កងពល រួមមាន កងវរៈសេនាតូចឯករាជ្យលេខ ៨០២ ជាកងពិសេស[997], កងវរៈសេនាតូចឯករាជ្យលេខ ៨០៣ ជា អង្គភាពកាំភ្លើងធំ[998], កងវរៈសេនាតូចឯករាជ្យលេខ ៨០៤ ជាកងស្ត្រី[999] , កងវរៈសេនាតូចឯករាជ្យលេខ ៨០៥[1000] ជាអង្គភាពមន្ទីរពេទ្យ ដែលទទួលខុសត្រូវការងារសម្រាប់មន្ទីរពេទ្យកងពល និងកងវរៈសេនាតូចឯករាជ្យលេខ ៨០៦ ជាអង្គភាពកាន់កាប់ឃ្លាំង ភ័ស្តុភារ និង ដឹកជញ្ជូន[1001]។

### ៦.១. ទំហំនៃការទទួលខុសត្រូវ

៣៣១. កងពលលេខ ៨០១ ត្រូវបានបង្កើតឡើងដោយមានការបញ្ចូលគ្នារវាងកម្មាភិបាល និងកងទ័ពដកយកមកពី ២ (ពីរ) អង្គភាព ដែលមានមុនថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ នៃភូមិភាគពិសេសរបស់បក្សកុំម្មុយនីស្តកម្ពុជា គឺ កងពលលេខ ១១ និងកងពលលេខ ១៤ ។[1002] កងពលលេខ ១១ បានបង្កើតឡើងដោយមានចំនួនពាក់កណ្តាលមកពីភូមិភាគពិសេស ដែលឈរជើងនៅភាគខាងត្បូងទីក្រុងភ្នំពេញ ក្រោយមកកងពលលេខ ១១ នេះត្រូវបានរួមបញ្ចូលគ្នាជាមួយនឹងកងពលលេខ ១៤ ។[1003] ក្រោយពីការរួមបញ្ចូលគ្នាបង្កើតបានជាអង្គភាពថ្មី មានឈ្មោះថាកងពលលេខ ៨០១ កងពលនេះត្រូវបានសម្រេចបញ្ជូនទៅខេត្តរតនគិរីក្នុងអំឡុងពេលនៃមហាសន្និបាតនៅស្តាតអូឡាំពិក ក្នុងទីក្រុងភ្នំពេញ នាចុងឆ្នាំ ១៩៧៥ [1004] ដោយមានឈ្មោះ ស៊ូ សារឿន ឬ សួរ សារឿន ហៅ តា សារឿន ឬ តា ០៥ ជាលេខាកងពល និងមាន តា សាន ហៅ តា ០៦ ជាអនុលេខាកងពល[1005] ។ នាខែ កក្កដា ឆ្នាំ ១៩៧៧



*E.C.C.C* *C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

សាន ត្រូវបានចាត់តាំងឱ្យទៅឈរជើងនៅខេត្តមណ្ឌលគិរី ហើយ អ៊ុង វ៉ែន បានឡើងកាន់តួនាទីជាអនុលេខាកងពលវិញ ។[1006]

៣៣២. កម្មាភិបាលដឹកនាំថ្នាក់ក្រោមនៅកម្រិតកងវរៈសេនាធំ ជាក់ស្តែងមានឈ្មោះដូចជា កែវ សារឿន[1007], ប៉ាវ សំអុន ហៅ តា សំអុន[1008], អ៊ុង វ៉ែន[1009] , ឌី ធិន[1010] និង សុន[1011]។ នៅឆ្នាំ ១៩៧៤ កងពលលេខ ១១ បានចូលមកកាន់ទីក្រុងភ្នំពេញតាមព្រលានយន្តហោះពោធិ៍ចិនតុង ។[1012] កងពលនេះត្រូវចាត់តាំងជាកងពលលេខ ៨០១ ភ្លាម បន្ទាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ពេលនោះ សូរ សារឿន និង សាន បានចូលរួមការប្រជុំជាមួយសេនាធិការនៅជិតស្ថានីយរថភ្លើងភ្នំពេញ[1013]ជាកន្លែងធ្វើការដំបូងរបស់ សុន សេន នៅទីក្រុងភ្នំពេញ[1014]ហើយដែលបន្ទាប់មកជាកន្លែងប្រជុំរួមសម្រាប់មេដឹកនាំជាន់ខ្ពស់របស់បក្ស[1015]។ ចាប់ពីពេលនេះមក កងពលនេះមាន ៣ (បី) កងវរៈសេនាធំ គឺ កងវរៈសេនាធំលេខ ៨១ , កងវរៈសេនាធំលេខ ៨២ និងកងវរៈសេនាធំលេខ ៨៣ ។

៣៣៣. ក្រោយពីឆ្នាំ ១៩៧៥ កងពលលេខ ៨០១ ត្រូវបានផ្ទេរឱ្យមកឈរជើងនៅភូមិភាគឦសាននៅក្នុងខេត្តរតនគិរី ប្រហែលជាចន្លោះពី ខែតុលា និងវិច្ឆិកា ឆ្នាំ ១៩៧៥ ដោយបានបោះទីតាំងជាបណ្តោះអាសន្ននៅក្នុងខេត្តក្រចេះមុននឹងមកដល់ខេត្តរតនគិរី ។[1016] កងពលនេះបានបង្កើតទីបញ្ជាការដ្ឋានដំបូងនៅតំបន់បានលុង ដែលបច្ចុប្បន្នជាស្រុកមានឈ្មោះ បានលុង ក្នុងខេត្តរតនគិរី និងក្រោយមកបានផ្លាស់ប្តូរទីតាំងមក វ៉ឺន សៃ ក្នុងខេត្តរតនគិរីវិញ ។[1017] យោងតាមប្រព័ន្ធកំណត់ទីតាំងភូមិសាស្ត្ររដ្ឋបាលរបស់បក្សកុម្មុយនីស្តកម្ពុជា ទីតាំងស្រុកបានលុងនេះ នៅក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ស្ថិតនៅក្នុងតំបន់ ១០២ នៃភូមិភាគឦសាន ។[1018]

៣៣៤. កងពលលេខ ៨០១ ជាអង្គភាពមជ្ឈិមតែមួយគត់ ដែលមានមូលដ្ឋានឈរជើងនៅខេត្តរតនគិរី [1019] ប៉ុន្តែភូមិភាគឦសានក៏មានកងកម្លាំងទ័ពផ្ទាល់ខ្លួន[1020] ខណៈដែលនៅថ្នាក់ស្រុក និងតំបន់មួយចំនួនក៏មានកម្លាំងទ័ពរបស់ខ្លួនដែរ[1021] ។ កងវរៈសេនាធំផ្សេងៗនៃកង



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596115



ពលលេខ ៨០១ ត្រូវបានដាក់ឱ្យពង្រាយឱ្យឈរជើងនៅផ្នែកផ្សេងៗនៃភូមិភាគឦសាន ដោយកងវរៈសេនាធំលេខ ៨១ មានទីតាំងនៅអណ្ដូងមាស[1022] ក្នុងស្រុកបរកែវ[1023] និង ប្រតិបត្តិការនៅអូរយ៉ាដាវ តាមផ្លូវលេខ ១៩[1024] ក្នុងតំបន់ ១០៧ ។ កងវរៈសេនាធំលេខ ៨២ ឈរជើងនៅសៀមប៉ាង ជិតព្រំដែនឡាវ[1025] តំបន់ ១០៤ និងកងវរៈសេនាធំលេខ ៨៣ ឈរជើងនៅអូរដំបូក[1026] តំបន់កន្ទុយនាគ ស្រុកវ៉ឺនសៃ[1027]។

៣៣៥. អំឡុងឆ្នាំ ១៩៧៦ ទីបញ្ជាការដ្ឋានកងពលលេខ ៨០១ បានផ្លាស់ប្ដូរទីតាំងមកកាន់តំបន់វ៉ឺនសៃ វិញ[1028] ក្នុងតំបន់ ១០១[1029] ហើយកងវរៈសេនាតូចឯករាជ្យដែលចំណុះឱ្យកងពលលេខ ៨០១ នេះក៏ត្រូវបានប្ដូរទីតាំងទៅកាន់ទីនោះដែរ[1030]។ លេខាភូមិភាគឦសានដែលមានកងពលលេខ ៨០១ ស្ថិតនៅភូមិភាគនេះ មានឈ្មោះថា ម៉ែន សាន ហៅ យ៉ា ដែលគាត់ត្រូវបានចាប់បញ្ជូនខ្លួនមកមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៦ ។[1031]

៣៣៦. អំឡុងចន្លោះពីចុងឆ្នាំ ១៩៧៦ និងដើមឆ្នាំ ១៩៧៧[1032] មានការបង្កើតឡើងនូវអង្គភាពសន្តិសុខមួយដែលមានឈ្មោះថា "មន្ទីរសន្តិសុខអូរកន្សែង"[1033] និងត្រូវបានគេស្គាល់ឈ្មោះផ្សេងៗទៀតដូចជា "មន្ទីរ ៨១០" ឬ "មន្ទីរអប់រំកែប្រែអូរកន្សែង"[1034] ឬ "សាលាកែប្រែ ៨១០ " ឬ "សាលាកែប្រែកងពល ៨០១"[1035] ឬ "គុក ៨១០" [1036] ឬ "គុកកងពល"[1037] ។ មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងក្រោមជាទម្រង់ "មន្ទីរអប់រំ និងកែប្រែ" ដោយស្ថិតនៅចំណុះក្រោមកងពលលេខ ៨០១[1038] និងបានបោះទីតាំងបញ្ជាការដ្ឋាននៅក្នុងតំបន់បានលុង[1039]។ វាបង្កើតដំបូងក្រោមរូបភាពជាអង្គភាពវិន័យ ដែលស្ថិតនៅតំបន់បានលុងតែម្ដង ប៉ុន្តែនៅក្នុងឆ្នាំ ១៩៧៧ បន្ទាប់ពីទីបញ្ជាការដ្ឋានកងពលលេខ ៨០១ បានប្ដូរទីតាំងមកតំបន់វ៉ឺនសៃ មន្ទីរនេះក៏បានប្ដូរមកកាន់ទីតាំងថ្មីនេះដែរ[1040] ដែលស្ថិតនៅក្នុងភូមិ ០៦ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនគិរី និងនៅជិតអូរមួយដែលមានឈ្មោះថា អូរកន្សែង[1041] ។

៣៣៧. មន្ទីរសន្តិសុខអូរកន្សែង ត្រូវបានគេជឿជាក់ថាបានបង្កើតឡើងដោយកងពលលេខ ៨០១ អនុលោមទៅតាមគំនិត និងផែនការរបស់គណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដើម្បីដំណើរការជាមន្ទីរអប់រំកែប្រែសម្រាប់អង្គភាពនេះ ។[1042] អំឡុងពេលដែលវាត្រូវបានបង្កើតឡើងហាក់មាន ឬតាមបញ្ជា ឬតំណាលគ្នានឹងបទបញ្ជារបស់ សុន សេន ដែលកងពលលេខ ៨០១ មានទំនាក់ទំនងជាញឹកញាប់ យ៉ាងជិតស្និទ្ធពាក់ព័ន្ធបញ្ហាសន្តិសុខជាមួយនឹងកងពល និងមូលដ្ឋាននានានៅក្នុងភូមិភាគឦសាន ។ នៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ១៩៧៦ សារឿន បានចូលរួមប្រជុំជាមួយកងពលមជ្ឈិម និងកងវរៈសេនាធំឯករាជ្យ តាមការកោះហៅរបស់ សុន សេន ដែលនៅក្នុងការប្រជុំនោះ សារឿន បានរាយការណ៍អំពីបញ្ហាអ្នករត់ចោលជួរ ដោយបានលើកឡើងថាម្នាក់ដែលចាប់បាន និងសួរចម្លើយបានឆ្លើយថាបដិវត្តន៍គឺ "តឹង និងពិបាក"។[1043] សុន សេន បានព្រមានថា "ខ្មាំង សេ អ៊ី អា" កំពុងប្រមូល "សមាសភាពមិនល្អ" ក្នុងចំណោមប្រជាជនថ្មី និងអ្នកផ្សេងទៀតដើម្បីប្រឆាំងនឹងបដិវត្តន៍ និងបានបញ្ជាថា *"ត្រូវសម្រិតសម្រាំងសមាសភាពមិនល្អតទៅទៀត"* ដោយគិតគូរផងដែរក្នុងការប្រមូលផ្តុំពួកគេដាក់មួយកន្លែងជាពិសេស ដើម្បីធ្វើការអប់រំដោយឡែក ។[1044]

៣៣៨. នៅក្នុងកិច្ចប្រជុំមួយផ្សេងទៀត នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ១៩៧៦ សុន សេន បានបញ្ជាក់អំពី *"ខ្មាំងលើផ្ទៃក្នុងប្រទេស និងក្នុងជួរយើង"* ដោយបានប្រកាសឱ្យមានការចាត់វិធានការថា*"ត្រូវមានជំហរដាច់ខាត សម្រិតសម្រាំងសមាសភាពប្រឆាំងបដិវត្តន៍កុំស្ទាក់ស្ទើរ"* ។[1045] នៅថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៧៦ សុន សេន បានបញ្ជាក់ជា "មតិណែនាំមកកងពល ៨០១" ផ្ញើមកកាន់ សារឿន ដោយបានបញ្ជាឱ្យចាត់វិធានការប្រឆាំងនឹងពួកខ្មាំងដែលធ្វើសកម្មភាព *"ដើម្បីបង្កប់ស៊ីរូងផ្ទៃក្នុងកងទ័ពយើង និងមូលដ្ឋាន"* ព្រមទាំងពួក *"ជនក្បត់"* ដែលកំពុងតែ *"បំផុសក្នុងប្រជាជនប្រឆាំងសហករណ៍ ប្រឆាំងមាគ៌ាបដិវត្តន៍សង្គមនិយមរបស់យើង"*។[1046] នេះជាភស្តុតាងបង្ហាញថាមតិណែនាំនេះត្រូវបានបញ្ជាចំពោះកងពលហើយដែលបង្ហាញយ៉ាងច្បាស់នូវស្វ័យភាព អំណាច និងឥទ្ធិពលដែលពួកគេត្រូវបំពេញ ។

៣៣៩. នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ សារឿន បានរាយការណ៍ត្រឡប់ទៅ សុន សេន អំពីសកម្មភាពផ្សេងៗ មានដូចជាការបម្រើខ្មាំង ផែនការបះបោរអាវុធដោយមានជំនួយពីខាងក្រៅ និងបានបញ្ជាក់ថាព័ត៌មានទាំងនេះបានមកពីការសួរចម្លើយយុវជន ដែលបានចាប់បាន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ក្នុងកង ៨៣ ។ សារឿន ក៏បានបញ្ជាក់ថា *"អ្នកសង្ស័យថាខ្មាំងត្រូវចាប់ដាច់ខាត"* និងសន្យាថានឹង *"សហការជាមួយមូលដ្ឋានដើម្បីបោសសម្អាតខ្មាំងឱ្យអស់"* ព្រមទាំងបានបន្ថែមទៀតថាការរៀបចំមួយចំនួនត្រូវធ្វើឡើងដើម្បី *"រៀបចំកម្លាំងមួយចំនួន សហការជាមួយមូលដ្ឋាន ដើម្បីចាប់ខ្មាំង"* ។[1047] គាត់បានផ្តល់ការពន្យល់ថា *"ចំពោះអ្នកដែលខ្មាំងឆ្លើយដាក់ ត្រូវពិនិត្យឯកសារ ហើយស្នើចាប់ខ្លួនបណ្តោះអាសន្ន"* ខណៈដែល *"អ្នកសេរី ដើរហើរ ឬល្មើសវិន័យអប់រំហើយមិនស្តាប់ ត្រូវមានវិធានការដកទុកមួយជុំតាមដាន"*។ ជាចុងក្រោយគាត់បានបន្ថែមថាគាត់ *"វង់ចាំមតិណែនាំរបស់បក្ស"*។[1048]

៣៤០. នៅក្នុងកិច្ចប្រជុំទ្វេភាគីជាមួយនឹងកម្មាភិបាលកងពលលេខ ៨០១ នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៧៦ សុន សេន បានណែនាំពួកគេម្តងទៀតឱ្យ *"ប្រុងប្រយ័ត្នក្នុងកងទ័ព និងប្រជាជនមូលដ្ឋាន"* ។[1049] មានរបាយការណ៍ជាបន្តបន្ទាប់ត្រូវបានធ្វើ ឬចម្លងជូន សុន សេន អំពីសកម្មភាពខ្មាំង ការចាប់ខ្លួន និងការសួរយកចម្លើយអ្នកដែលចាប់បាន នៅតាមទីតាំងផ្សេងៗក្នុងភូមិភាគឦសាន មានតាំងពីតំបន់ ១០១ , តំបន់ ១០២ , តំបន់ ១០៤ និងតំបន់ ១០៧ ផងដែរ ។[1050] ជាចម្លើយតបនឹងរបាយការណ៍បែបនេះ សុន សេន បានដាក់បញ្ជាថាឱ្យមានការសហការជាមួយគណៈភូមិភាគ គណៈតំបន់ គណៈស្រុក និងបានរាយការណ៍ជូនអង្គការអំពីអ្វីដែលគេបានធ្វើកន្លងមក។[1051]

## ៦.៣. ការបោសសម្អាតក្នុងកងពលលេខ ៨០១

៣៤១. ចាប់ពីខែ ធ្នូ ឆ្នាំ ១៩៧៦ មានការពិភាក្សាជាពិសេសរវាង សុន សេន និង សារឿន ព្រមទាំងកម្មាភិបាលសំខាន់ៗនានារបស់កងពលលេខ ៨០១ អំពីការបោសសម្អាតកម្មាភិបាលក្នុងកងពលលេខ ៨០១ និងកម្មាភិបាលកម្រិតស្រុក នៅក្នុងរចនាសម្ព័ន្ធនយោបាយរបស់ភូមិភាគឦសាន ដោយ សុន សេន បញ្ជាបន្ថែមថា *"ខាងផ្ទៃក្នុងកងទ័ពត្រូវអប់រំ និងសម្រិតសម្រាំងឱ្យស្អាត"* ។[1052] សារឿន ជូនដំណឹងដល់ សុន សេន អំពីលទ្ធផលនៃការសួរចម្លើយកម្មាភិបាលស្រុកដែលត្រូវបានចាប់ខ្លួន[1053] និងបានធានាចំពោះ សុន សេន ថាគាត់ *"កំពុង*



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

*តែតាមដានសមាសភាពដែលអន្តរាយដល់បដិវត្តន៍ទាំងថ្មី ទាំងចាស់* " នៅក្នុងកងពលលេខ ៨០១ ដែលត្រូវបានចោទប្រកាន់ថា "*អន្តរាយដល់បដិវត្តន៍ គឺ អ្នកទំនាស់នឹងមាគ៌ា និងពួកខ្មាំងឆ្លើយដាក់ ទាំងចាស់ ទាំងថ្មី* "។ [1054] ខណៈដែលគាត់ស្នើសុំតាមលិខិតឆ្លើយឆ្លង នាខែមីនា ឆ្នាំ ១៩៧៧ ជាមួយ សុន សេន "*ដកកម្មាភិបាលកងវរៈមួយចំនួនចេញពីអង្គភាពដោយសមមិត្តទាំងនោះអនុវត្តមាគ៌ាច្រើនតែផ្ទុយ មហាជនគេមិនជឿ អប់រំកសាងមិនព្រមកែប្រែ ទិសវិវត្តន៍ថយក្រោយ*" ។ [1055]

៣៤២. ប្រធានមន្ទីរសន្តិសុខអូរកន្សែងឈ្មោះ នោម សែ រំលឹកឡើងវិញថា មន្ទីរសន្តិសុខនៅអូរកន្សែង "*បង្កើតឡើងនៅពេលដែលមានសភាពការណ៍ចលាចលខ្មាំងផ្ទៃក្នុង កើតឡើងទូទាំងប្រទេស* "។[1056] សាក្សីឈ្មោះ ជិន គីមថុង ដែលជាអនុប្រធានមន្ទីរសន្តិសុខនេះ អះអាងថា គាត់ត្រូវបានគេចាត់តាំងមកគ្រប់គ្រងនៅមន្ទីរសន្តិសុខនេះ នៅពេលសភាពការណ៍"*មានភាពច្របូកច្របល់ ដោយមានការចុះពិនិត្យប្រវត្តិរូបយោធាទូទាំងប្រទេស*"[1057] ខណៈដែលអតីតកម្មាភិបាលម្នាក់របស់កងពលចងចាំថា មានការនិយាយអំពីការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង[1058] ។

៣៤៣. ជាងនេះទៀត ការបង្កើតមន្ទីរសន្តិសុខអូរកន្សែងស្របពេលនឹង ឬធ្វើឡើងបន្ទាប់ពីការចាប់ឃុំខ្លួន និងសម្លាប់លេខាភូមិភាគឦសាន ម៉ែន សាន ហៅ យ៉ា ដែលត្រូវបានចាប់មកមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៧៦ ។[1059] ម៉ែន សាន ហៅ យ៉ា ត្រូវបានជំនួសដោយ អ៊ុម ណោង ហៅ រី[1060] ហៅ វង់[1061] ដែលបានក្លាយជាលេខាភូមិភាគឦសាន[1062] ។ អំឡុងឆ្នាំ ១៩៧៧ កងពលលេខ ៨០១ បានទទួលរងនូវការបោសសម្អាតយ៉ាងធ្ងន់ធ្ងរ ជាមួយនឹងកម្មាភិបាលថ្នាក់វរៈសេនាធំ និងវរៈសេនាតូច ក្នុងចំណោមនោះពួកគេត្រូវបានចាប់ និងបញ្ជូនមកកាន់មន្ទីរសន្តិសុខ ស-២១ ខណៈពេលដែលកម្មាភិបាលថ្នាក់ទាប និងយុទ្ធជនធម្មតាត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខអូរកន្សែង ។



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

៣៨៤. ការចាប់ខ្លួនហាក់ធ្វើឡើងមានពាក់ព័ន្ធនឹងការចាប់ខ្លួនរបស់លេខាភូមិភាគឧត្តរឈ្មោះ កុយ ធួន ហៅ ធុច[1063] ព្រមទាំងពាក់ព័ន្ធនឹងករណីបោសសម្អាតនៅភូមិភាគនោះ ដែលបានកើតឡើងនៅក្នុងអំឡុងពេលជាមួយគ្នា ។ អ្នកទោសនៅមន្ទីរសន្តិសុខអូរកន្សែង គឺជាយុទ្ធជនកងពលលេខ ៨០១ មកពីអង្គភាពចំណុះផ្សេងៗ ដោយអ្នកខ្លះត្រូវបានចាប់ខ្លួនតាមការផ្តួចផ្តើមរបស់អង្គភាពទាំងនោះ បន្ទាប់ពីត្រូវបានគេចោទប្រកាន់ថា ជាសមាសភាពសេរី និងជាកងទ័ពដែលមិនគោរពវិន័យយោធា[1064] ឬ បាននិយាយរិះគន់បដិវត្តន៍[1065] ខណៈពេលដែលអ្នកផ្សេងៗទៀត ត្រូវបានគេចាប់ខ្លួនដោយសារពួកគេមានជាប់ពាក់ព័ន្ធនឹងការឆ្លើយដាក់នៅក្នុង "ចម្លើយសារភាព" ដែលបានផ្ញើមកពីភ្នំពេញ[1066]។ អ្នកទោសត្រូវបានគេចាប់ខ្លួនពីកងវរៈសេនាធំលេខ ៨១ , កងវរៈសេនាធំលេខ ៨២ និង កងវរៈសេនាធំលេខ ៨៣ ដោយដឹកតាមឡាននៅពេលយប់មកកាន់មន្ទីរសន្តិសុខអូរកន្សែង ។[1067]

### ៦.៤. ការទទួលខុសត្រូវចំពោះបុគ្គលដែលបញ្ជូនមក មន្ទីរសន្តិសុខ ស-២១

៣៨៥. ជនរងគ្រោះដែលជាកម្មាភិបាលរបស់កងពលលេខ ៨០១ ជាច្រើននាក់ត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ មានដូចជាឈ្មោះ ឡៃ សារឹម ជាប្រធានពេទ្យកងពល[1068] ដែលដឹកនាំកងវរៈសេនាតូចលេខ ៨០៥[1069] ជាអង្គភាពពេទ្យ ៨០៥[1070] របស់កងពល ៨០១ ឬជាមន្ទីរពេទ្យ ៨០៥[1071] ហើយត្រូវបានចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី ០៣ ខែ មករា ឆ្នាំ ១៩៧៧[1072]។ មេបញ្ជាការកងវរៈសេនាធំលេខ ៨១ ដំបូងមានឈ្មោះ កែវ សារឿន[1073] ហៅ សេង ជាសមាជិកគណៈកងពលលេខ ៨០១ ត្រូវបានចាប់ខ្លួននៅអំឡុងខែ មេសា ឬខែ ឧសភា ឆ្នាំ ១៩៧៧[1074]។ ជំនួយការកងពលឈ្មោះ ប៉ោ សំអុន ត្រូវបានចាប់ខ្លួននៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ១៩៧៧ ។[1075] ទន្ទឹមនឹងនោះ ឈ្មោះ នួន ឡួច ហៅ ផាត់ ជាលេខាកងវរៈសេនាតូចលេខ ៨០២ ត្រូវបានចាប់ខ្លួននៅថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៧[1076] និងឈ្មោះ អៀង ប៉ាង ហៅ ហាន ជាមេបញ្ជាការកងវរៈសេនាតូចលេខ ៨០៣ ក៏ត្រូវបានចាប់ខ្លួននៅថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៧៧[1077] ។



*E.C.C.C* C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

៣៤៦. មិនតែប៉ុណ្ណោះ មានកម្មាភិបាលថ្នាក់ទាបជាច្រើនក៏ត្រូវបានចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខ ស-២១ ផងដែរ ដូចជាឈ្មោះ ស្បោង រុន មកពីមន្ទីរកងពល ត្រូវបានបញ្ជូនមកកាន់មន្ទីរសន្តិសុខ ស-២១ នាថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៧៧ ។[1078] ទាក់ទិននឹងដំណើរការបោសសម្អាតនេះ សុន សេន បានធ្វើកំណត់សំគាល់នាថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៧៧ នៅលើ "ចម្លើយសារភាព" របស់មន្ទីរសន្តិសុខ ស-២១ ចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៧៧ របស់ឈ្មោះ សួរ ទូន ហៅ ម៉ៅ ដោយបានបញ្ជាឲ្យ សារឿន ឲ្យដកយកឈ្មោះពាក់ព័ន្ធនឹងកងពលលេខ ៨០១ និងបាននិយាយថាពួកគាត់នឹងជួបគ្នាដើម្បីធ្វើការងារនេះ ។[1079]

៣៤៧. ពាក់ព័ន្ធនឹង "បញ្ហាសមមិត្ត កែវ សារឿន"[1080] និងការដក សំអុន[1081] គឺជាប្រធានបទនៃការសម្រេចរវាងកងពលលេខ ៨០១ និង សុន សេន មុនពេលពួកគេត្រូវបានចាប់ខ្លួន ខណៈដែល អ៊ុង រ៉ែន បញ្ជាក់ថាកាលគាត់នៅជាកម្មាភិបាលរបស់សេនាធិការកំពុងរៀនសូត្រនៅភ្នំពេញជាមួយ សួរ សារឿន មានទូរលេខមួយបានផ្ញើមកចោទប្រកាន់ថា កែវ សារឿន បានប្រព្រឹត្តអំពើអសីលធម៌ជាមួយនារីជាកម្មាភិបាលយោធា ហើយនៅពេលគាត់ត្រឡប់មកភូមិភាគឦសានវិញ កែវ សារឿន ត្រូវបានចាប់ខ្លួន[1082]។ អ៊ុង រ៉ែន បានអះអាងថាពេលមកដល់ភូមិភាគឦសាន គាត់ត្រូវបានតែងតាំងជាអនុលេខាកងពលលេខ ៨០១ ទទួលបន្ទុកគ្រប់គ្រងកងទ័ព និងបោះទីតាំងនៅតំបន់បានលុង/តំបន់បឹងកន្សែង ។[1083]

៣៤៨. ចាប់ពីខែ ធ្នូ ឆ្នាំ ១៩៧៦ មក សារឿន បានចាប់ផ្តើមរាយការណ៍អំពីការចាប់ខ្លួន "យួន" ដោយអង្គភាពនានានៃកងពលលេខ ៨០១[1084] ហើយលេខាភូមិភាគឦសានឈ្មោះ អ៊ុម ណេង ហៅ វី ក៏បានរាយការណ៍ពីការចាប់ខ្លួនពួកគេដោយខាងកងពលផងដែរ[1085]។ នៅក្នុងសារទូរលេខនៅថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៧៧ ដែលបានផ្ញើជូន "បងជាទីគោរព" ក្នុងនោះដែរលេខាភូមិភាគឦសាន អ៊ុម ណេង ហៅ វី បានជូនដំណឹងអំពីការ "*ចាប់បានកងទ័ពយួនចំនួន ២០៩ នាក់ ក្នុងនេះមាននារី ៩ នាក់ នៅម្តុំអូរល្អក់ ខាងត្បូងផ្លូវលេខ ១៩ ចម្ងាយ ៤ គីឡូ សឹងទាំងអស់ជា ជនជាតិចារ៉ាយ និយាយខ្មែរប៉ែឡាំ* " ដែលបានឆ្លើយថាជាប្រជាជនមកសុំចុះចូលក្នុងទឹកដីកម្ពុជា ប៉ុន្តែត្រូវបានគេវាយតម្លៃថាជា "ខ្មាំងខាងក្រោមក



E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បង្កប់”។[1086] ក្នុងសារទូរលេខនេះក៏បានសរសេរបន្ថែមផងដែរថា “សុំមតិអង្គការបន្ថែម” និង “ស្នើសម្រេចកម្រិតខ្ពស់” ចំពោះខ្មាំងទាំងនោះភ្លាម ។[1087]

៣៤៩. ទោះបីជាចម្លើយរបស់អង្គការមិនមានក៏ដោយ វាបង្ហាញថារបាយការណ៍នេះពាក់ព័ន្ធនឹងអ្នកទោសជនជាតិចារ៉ាយជាក្រុមតែមួយដែលត្រូវបានចាប់នៅតំបន់អូរយ៉ាដាវ និងត្រូវបានសម្លាប់តាមបញ្ជារបស់ សូរ សារឿន[1088] ដោយប្រើប្រាស់កម្លាំងរួមទាំងអង្គភាពសន្តិសុខមកពីតំបន់កងកាំភ្លើងធំនៃកងវរៈសេនាតូចលេខ ៨០៣[1089] និងបុគ្គលិកនៃមន្ទីរសន្តិសុខអូរកន្សែងខ្លួនឯងផ្ទាល់[1090]។ អ្នកទោសវៀតណាមមួយក្រុមផ្សេងទៀតត្រូវបានចាប់ខ្លួននៅចុងឆ្នាំ ១៩៧៨ ផងដែរ នៅតំបន់អូរយ៉ាដាវ និងត្រូវបានសម្លាប់ដូចគ្នានៅអូរកន្សែង តាមបញ្ជារបស់ សូរ សារឿន ។[1091] មានការបញ្ជូនអ្នកទោសជាជនជាតិចារ៉ាយចំនួនជាង ១០០ (មួយរយ) នាក់ ក្នុងនោះចំនួន ៥ (ប្រាំ) នាក់ ឬ ៦ (ប្រាំមួយ) នាក់ ជាស្ត្រី មកកាន់មន្ទីរសន្តិសុខអូរកន្សែង ដោយបានចោទប្រកាន់ថាជាអតីតទាហានធៀវគី (ជាអតីតទាហានរដ្ឋាភិបាលវៀតណាមខាងត្បូង) ។[1092]

៣៥០. ការសម្លាប់នៅឆ្នាំ ១៩៧៨ នេះ ត្រូវបានធ្វើឡើងបន្ទាប់ពីការបោសសម្អាតបន្ថែមទៀតនៅភូមិភាគឦសាន ។ បន្ទាប់មកលេខាភូមិភាគឦសាន ឈ្មោះ អ៊ុម ណេង ហៅ វី[1093] ហៅ វង្ស[1094] បានធ្វើអត្តឃាតដោយខ្លាចការចាប់ខ្លួននៅពាក់កណ្ដាលឆ្នាំ ១៩៧៨ បន្ទាប់មកគាត់ត្រូវបានជំនួសក្នុងអំឡុងពេលមួយដោយអនុលេខាបក្ស នួន ជា ដែលបានឡើងធ្វើជាលេខាភូមិភាគឦសាន [1095]។ នាពេលបន្ទាប់មកទៀត សូរ សារឿន បានក្លាយជាលេខាភូមិភាគឦសានតាមព្រឹត្តិហេតុរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1096] ជាមួយនឹងឈ្មោះ ខឹម ខេង ដែលជាប្រធានកងពលភូមិភាគរបស់ភូមិភាគឦសាន[1097]។

៣៥១. តាមរយៈការសិក្សាទៅលើរចនាសម្ព័ន្ធ និងតួនាទីរបស់កងពលលេខ ៨០១ សហចៅក្រមស៊ើបអង្កេតមិនបានរកឃើញនូវទំនាក់ទំនងទាំងអង្គច្បាប់ និងអង្គហេតុរបស់កងពលលេខ ៨០១ ជាមួយនឹង **មាស មុត** ឡើយ ។



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01596122



## ៧. មន្ទីរសន្តិសុខរបស់កងទ័ពបដិវត្តន៍កម្ពុជា និង ទីតាំងសម្លាប់ផ្សេងទៀត

៣៥២. ផ្អែកលើភស្តុតាងនៅក្នុងសំណុំរឿង គ្មានភស្តុតាងណាបង្ហាញផ្អែកតាមផ្លូវច្បាប់ និងភាពជាក់ស្តែងរបស់ **មាស មុត** នៅក្នុងមន្ទីរសន្តិសុខរបស់កងទ័ពបដិវត្តន៍កម្ពុជា និងទីតាំងសម្លាប់ផ្សេងទៀត ទាក់ទងនឹងតួនាទី និងការចូលរួមរបស់គាត់នៅក្នុងអំពើឧក្រិដ្ឋកម្មដូចបានលើកឡើងខាងលើ ។ បន្ថែមពីលើនេះ ទាក់ទងនឹងបញ្ហានេះគឺមានភាពមិនច្បាស់លាស់ថា ការិយាល័យសហព្រះរាជអាជ្ញា មានបំណងចង់ឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតលើមន្ទីរសន្តិសុខរបស់កងទ័ពបដិវត្តន៍កម្ពុជាទាំងអស់ ដោយសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមិនបានលើកឡើងពីកងពលផ្សេងទៀត ឬការិយាល័យសហព្រះរាជអាជ្ញាគ្រាន់តែបង្ហាញ ដោយគ្មានបំណងចង់ឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតបន្ថែមលើមន្ទីរសន្តិសុខរបស់កងពល ដែលមិនបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ។ អង្គហេតុទាំងនេះមិនជាប់ទាក់ទងនឹង **មាស មុត** ឡើយ ។[1098]

៣៥៣. ឆ្លើយតបទៅនឹងសំណើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជាក់ថាការិយាល័យសហព្រះរាជអាជ្ញាមិនមានបំណងចង់ឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបអង្កេតលើមន្ទីរសន្តិសុខរបស់កងពលនៃកងទ័ពបដិវត្តន៍កម្ពុជាទាំងអស់ ឬទីកន្លែងឧក្រិដ្ឋកម្មផ្សេងទៀតឡើយ ។[1099]

### ជំពូក ៤. ការពិចារណាលើភស្តុតាង

៣៥៤. ភាគច្រើនលើសលុបនៃភស្តុតាងដែលត្រូវបានប្រើប្រាស់នៅក្នុងសំណុំរឿងលេខ 00៣ និងដែលទទួលបាននូវសច្ចធារណ៍នៃភាពជឿជាក់ខ្ពស់គឺរួមមាន៖

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរសព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។

E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

-កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលបានធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងពេលស៊ើបសួរ ដែលត្រូវបានរៀបចំក្រោមការត្រួតពិនិត្យតាមនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

-ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ បានមកពីសំណុំរឿងផ្សេងទៀតរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយដែលត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿងលេខ ០០៣ ដោយសារតែមានភាពពាក់ព័ន្ធជាមួយនឹងការចោទប្រកាន់នានា ។

៣៥៥. ចំណែកកិច្ចសម្ភាសន៍ ខ្លឹមសារដកស្រង់របស់សារព័ត៌មាន ឬរបស់សៀវភៅប្រវត្តិសាស្ត្រ និងភស្តុតាងផ្សេងៗទៀត ដែលត្រូវបានប្រមូលមកដោយមិនមានការត្រួតពិនិត្យតាមនីតិវិធីតុលាការ ឬដោយស្ថាប័នណាមួយដែលមិនស្ថិតក្រោមអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺមានតម្លៃសច្ចធារណ៍ទាបជាងឯកសារដែលយើងបានរៀបរាប់ខាងលើ ។

៣៥៦. ការស្តាប់ចម្លើយដែលធ្វើឡើងដោយការិយាល័យសហព្រះរាជអាជ្ញា ក្នុងអំឡុងពេលស៊ើបអង្កេតបឋម បើទោះបីជាត្រូវបានរៀបចំជាពិសេសសម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការស្តាប់ចម្លើយនេះមិនត្រូវបានធ្វើឡើង ដោយមានការស្បថនោះឡើយ ហើយត្រូវបានរៀបចំឡើងដោយភាគីដែលមានផលប្រយោជន៍នៅក្នុងសំណុំរឿង ។

៣៥៧. ទាក់ទងនឹងចម្លើយសារភាព អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម មានការហាមឃាត់ដាច់ខាត មិនឱ្យពឹងផ្អែកទៅលើព័ត៌មាន ដែលមាននៅក្នុងឯកសារទទួលបានដោយការធ្វើទារុណកម្ម[1100] និងមិនឱ្យប្រើប្រាស់ចម្លើយបែបនេះនៅក្នុងការសួរដេញដោលសាក្សី ។[1101] ចម្លើយសារភាពរបស់អ្នកទោស ដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានសន្មតថាធ្វើឡើងដោយទារុណកម្ម ។ នេះគឺជាសច្ចធារណ៍អាចបដិសេធបាន ។[1102] ប៉ុន្តែព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពនៅមន្ទីរសន្តិសុខ



E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ស-២១ ផ្តល់ឲ្យដោយបុគ្គលមិនមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ឧទាហរណ៍ចំណារ ដោយអ្នកធ្វើទារុណកម្ម មិនស្ថិតក្រោមការហាមឃាត់នេះឡើយ ។[1103]

៣៥៨. មាត្រា ១៥ ក៏មិនបានហាមឃាត់ការប្រើប្រាស់ព័ត៌មានមាននៅក្នុងចម្លើយ ដែលធ្វើឡើង ដោយទារុណកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកសាក្សី និងអាចឈានទៅ ស្តាប់ចម្លើយពួកគាត់ដែរ ។[1104] ហេតុដូច្នេះ មិនមានការហាមឃាត់ មិនឲ្យប្រើប្រាស់នូវ ភ័ស្តុតាងរបស់សាក្សីដែលត្រូវបានកំណត់នៅក្នុងចម្លើយ ដែលទទួលបានដោយការធ្វើ ទារុណកម្ម ដូចជាចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ និងការស្តាប់ចម្លើយនាពេល បន្ទាប់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។[1105]

៣៥៩. ជាការកត់សម្គាល់ជារួម ពាក់ព័ន្ធឯកសារជាភ័ស្តុតាងក្នុងសំណុំរឿង ឃើញថាដោយសារ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង Siegfried BLUNK យល់ថា ការស៊ើបអង្កេត មានលក្ខណៈពេញលេញរួចហើយ តាមរយៈការសម្ភាសន៍សាក្សីសំខាន់ៗ និងការផ្ទេរ ភ័ស្តុតាងក្នុងសំណុំរឿងលេខ ០០២ ដែលមានជាង ២.០០០ (ពីរពាន់) ឯកសារ ដោយរួម មាន ៤៨.០០០ (បួនម៉ឺនប្រាំបីពាន់) ទំព័រ សហចៅក្រមស៊ើបអង្កេតទាំងពីរ បានសម្រេច បិទការស៊ើបអង្កេតរបស់ខ្លួននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ។[1106] យោងទៅតាម គោលការណ៍នេះ សហចៅក្រមស៊ើបអង្កេតជាតិ នៅតែរក្សាជំហរលើការអនុវត្តនូវ ឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការពិចារណាតែភ័ស្តុតាងទាំងឡាយណាដែលបានដាក់បញ្ចូលនៅ មុនថ្ងៃបិទការស៊ើបសួរដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតទាំងពីររូបតែ ប៉ុណ្ណោះ។

## ជំពូក ៥. លក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គល

៣៦០. មិនមានការកំណត់ជាក់លាក់នូវលក្ខណៈវិនិច្ឆ័យសម្រាប់ពិចារណាថា ជនណាមួយស្ថិតនៅ ក្នុងយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការពិចារណា និង



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

កត្តាដែលត្រូវបានយកមកពិចារណាមាន តួនាទី និងកម្រិតនៃការចូលរួមរបស់ជនត្រូវចោទ ព្រមទាំងបរិបទនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចេតនារបស់អ្នករៀបចំច្បាប់ និងទ្រឹស្តីព្រហ្មទណ្ឌមួយចំនួនទៀត ។

## ផ្នែកទី ១. ច្បាប់ និងយុត្តិសាស្ត្រស្តីពីយុត្តាធិការបុគ្គល

៣៦១. អនុលោមតាមមាត្រា ១ នៃកិច្ចព្រមព្រៀងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះហត្ថលេខានៅថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា") បានចែងថា " គោលបំណងរបស់កិច្ចព្រមព្រៀងនេះ គឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ ០៦ មករា ១៩៧៩ " ។[1107]

៣៦២. មាត្រា ១ នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[1108] បានចែងថា "ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩"។[1109]



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596126



៣៦៣. មាត្រា ២ ថ្មី របស់ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចែងថា "ត្រូវបានបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ ពោលគឺសាលាដំបូង និងតុលាការកំពូល ដើម្បីជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋ និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជា ដែលពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទំនៀមទម្លាប់អន្តរជាតិ និង ការរំលោភទៅលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃ ០៦ ខែ មករា ឆ្នាំ ១៩៧៩" ។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះអំពើឧក្រិដ្ឋខាងលើនេះហៅថា "ជនសង្ស័យ" ។[1110]

៣៦៤. អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ឌុច បានបកស្រាយពាក្យ " មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើជនពីរប្រភេទគឺ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត និងជនដែលមិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ប៉ុន្តែជាជនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ។ ហេតុនេះលក្ខណៈវិនិច្ឆ័យទាំងនេះមានលក្ខណៈត្រួតលើគ្នាមិនមែនដាច់ដោយឡែកពីគ្នាទេ ។[1111] ប៉ុន្តែការកំណត់លក្ខណៈវិនិច្ឆ័យថាជា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" គឺជាទម្រង់នៃអំណាចឆន្ទានុសិទ្ធិនៃការចោទប្រកាន់របស់សហព្រះរាជអាជ្ញា និងការស៊ើបអង្កេតដោយឯករាជ្យពីសំណាក់សហចៅក្រមស៊ើបអង្កេត ។

៣៦៥. មេដឹកនាំជាន់ខ្ពស់សំដៅលើមន្ត្រីជាន់ខ្ពស់ ចូលរួមគ្នាក្នុងការរៀបចំនូវគោលនយោបាយការអនុវត្ត និងតាមដានមើលការអនុវត្តនយោបាយទាំងនោះ ។[1112] តាមឯកសារពិភាក្សាបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មេដឹកនាំជាន់ខ្ពស់សំដៅដល់សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មការមជ្ឈិមបក្សកម្ពុជាប្រជាធិបតេយ្យ។ លក្ខណៈវិនិច្ឆ័យ ដើម្បីសម្រេចថា បុគ្គលណាមួយជាជនទទួលខុសត្រូវខ្ពស់បំផុត មានធាតុផ្សំចំនួន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២ (ពីរ) រួមមាន (១) ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ និង (២) កម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ ។[1113]

៣៦៦. ដើម្បីវាយតម្លៃធាតុទីមួយ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានផ្អែកទៅលើកត្តានានាដូចជា (១) ចំនួនជនរងគ្រោះ (២) ដែនកំណត់ភូមិសាស្ត្រ និងពេលវេលា ព្រមទាំងរបៀបនៃការប្រព្រឹត្ត និង (៣) ចំនួននៃអង្គហេតុនីមួយៗដែលកើតមានឡើង[1114]។

៣៦៧. ចំណែកឯធាតុទីពីរ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) បានផ្តោតការពិចារណាជាមូលដ្ឋានទៅលើចំណុចដូចជា (ក) កម្រិតនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម (ខ) ឋានានុក្រម ឬមុខតំណែងរបស់ជនត្រូវចោទ រួមបញ្ចូលទាំង (គ) ចំនួននៃអ្នកនៅក្រោមបង្គាប់ និងថ្នាក់លើរបស់គាត់ និងភាពអចិន្ត្រៃយ៍នៃមុខតំណែង ។[1115] ការពិចារណាដូចគ្នានេះត្រូវបានយកមកប្រើផងដែរដោយអង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។[1116]

៣៦៨. មេដឹកនាំជាន់ខ្ពស់ ដែលពុំបានចូលរួមអ្វីជាធំដុំនៅក្នុងសកម្មភាពល្មើសនៃរបបកម្ពុជាប្រជាធិបតេយ្យ អាចស្ថិតនៅក្រៅក្របខណ្ឌនៃយុត្តាធិការរបស់តុលាការ ដោយហេតុថាបុគ្គលនោះពុំមែនជាអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ។ ផ្ទុយមកវិញបុគ្គលណាម្នាក់ដែលស្ថិតនៅក្នុងឋានានុក្រមថ្នាក់ក្រោម អាចត្រូវបានចាត់ទុកថាជាអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត អាស្រ័យលើការចូលរួមចំណែកដោយឡែកៗរបស់បុគ្គលនោះចំពោះអំពើឃោរឃៅ ។ វិសាលភាពនៃសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់ និងអានុភាពនៃអំពើទាំងនោះ គឺជាចំណុចត្រូវពិនិត្យមើលដ៏ត្រឹមត្រូវមួយ ។ ដូច្នេះការពិចារណាអំពីយុត្តាធិការបុគ្គល ក៏មិនខុសគ្នានឹងការពិចារណាដែលត្រូវធ្វើនៅពេលកំណត់ទោសដែរ ។



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

៣៦៩. ដើម្បីសម្រេចថាតើបុគ្គលណាស្ថិតនៅក្នុងចំណោមអ្នកទាំងឡាយ “ដែលទទួលខុសត្រូវខ្ពស់បំផុត” គឺមិនត្រឹមតែផ្ដោតលើអានុភាពជាក់ស្ដែងអំពីតួនាទីផ្លូវការដែលបុគ្គលម្នាក់មាននៅក្នុងឋានានុក្រមប៉ុណ្ណោះទេ គេគួរតែពិចារណាផងដែរទៅលើកម្រិតដែលបុគ្គលនោះបានចូលរួមចំណែកក្នុងការសម្រេចលើគោលនយោបាយ និង/ឬ ការអនុវត្តគោលនយោបាយ ។

៣៧០. ក្នុងសំណុំរឿងលេខ ០០១ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ឌុច ជាជនដែលទទួលខុសត្រូវខ្ពស់បំផុត ពាក់ព័ន្ធជាមួយមន្ទីរសន្តិសុខ ស-២១ ។ អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា ៖

> “*ការស៊ើបអង្កេតបានបង្ហាញថា ខណៈដែល ឌុច មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់អាចត្រូវបានពិចារណាស្ថិតចូលក្នុងប្រភេទនៃបុគ្គលទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋ និងការបំពារបំពានធ្ងន់ធ្ងរដែលត្រូវបានប្រព្រឹត្តឡើងក្នុងចន្លោះថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃ ០៦ ខែ មករា ឆ្នាំ ១៩៧៩ ដោយពិចារណានូវឋានានុក្រមជាផ្លូវការនៃអំណាច និងមានប្រសិទ្ធិភាព ព្រមទាំងការចូលរួមដោយផ្ទាល់ក្នុងឋានៈជាអនុប្រធាន និងក្រោយមកជាប្រធានមន្ទីរសន្តិសុខ ស-២១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការមជ្ឈិមបក្ស*” ។[1117]

៣៧១. ឌុច គឺជាប្រធានមន្ទីរសន្តិសុខ ស-២១ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្ស[1118] ទទួលឃុំឃាំង សម្លាប់កម្មាភិបាល និងមេដឹកនាំរបស់ខ្មែរក្រហម ដែលត្រូវបានចាប់មកពីគ្រប់ភូមិភាគទូទាំងប្រទេស ។[1119] មនុស្សជាងមួយម៉ឺនពីរពាន់នាក់ ត្រូវបានគេធ្វើទារុណកម្ម សម្លាប់[1120] ដោយផ្ទាល់ និងប្រយោលក្រោមការដឹកនាំ និងគ្រប់គ្រងដ៏មានឥទ្ធិពល និងមានប្រសិទ្ធភាពរបស់ ឌុច ក្នុងក្របខណ្ឌអនុវត្តគោលនយោបាយរបស់បក្ស ។ ឌុច បានធ្វើកិច្ចការងារផ្ទាល់ក្នុងរឿងមន្ទីរសន្តិសុខ ស-២១ ជាមួយមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ ដូចជា នួន ជា និង សុន សេន ។[1121] ឌុច គ្រប់គ្រង ពិនិត្យមើលចម្លើយសារភាព សរសេរចំណារលើចម្លើយសារភាព[1122] និង



ECCC CETC CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

ស្នើទៅថ្នាក់ដឹកនាំដើម្បីសម្រេចចាប់ជនសង្ស័យ[1123] ដែលត្រូវបានគេឆ្លើយដាក់ក្នុងចម្លើយសារភាព ។[1124] ឌុច បានសម្របសម្រួលនូវការចាប់ខ្លួន រៀបចំ និងបង្រៀនពីរបៀបសួរចម្លើយ តាមដានពិនិត្យការសួរចម្លើយ និងការសម្លាប់អ្នកទោសជាដើម ។[1125]

៣៧២. បន្ថែមពីលើនេះ មន្ទីរសន្តិសុខ ស-២១ គឺជាមន្ទីរសន្តិសុខសំខាន់បំផុតមួយរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចាត់ទុកជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ដោយបានរាយការណ៍ទៅថ្នាក់ដឹកនាំខ្ពស់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជា ធ្វើប្រតិបត្តិការពាសពេញផ្ទៃប្រទេស និងទទួលកម្មាភិបាលឋានៈខ្ពស់ និងអ្នកទោសសំខាន់ៗ បញ្ជូនស្ទើរតែគ្រប់ទីកន្លែងទូទាំងប្រទេសទៅមន្ទីរសន្តិសុខ ស-២១ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូល ។[1126]

៣៧៣. ផ្អែកលើអង្គហេតុ និងខ្លឹមសារនៃសេចក្តីដកស្រង់ខាងលើ លក្ខណៈវិនិច្ឆ័យជាចម្បងក្នុងការសម្រេចថា ឌុច ជាជនទទួលខុសត្រូវខ្ពស់បំផុត ជាសំខាន់ផ្តោតលើការចូលរួមផ្ទាល់ អំណាច និងឥទ្ធិពលក្នុងការធ្វើសេចក្តីសម្រេច និងចាត់ចែង ។

៣៧៤. ចំនួនជនរងគ្រោះនេះ គឺជាលទ្ធផលផ្ទាល់ និងជាក់ស្តែងនៃអំពើរបស់ ឌុច ។ ឌុច បានអនុវត្តដោយផ្ទាល់ ដោយមានប្រសិទ្ធភាព និងដោយពេញលេញចំពោះការអនុវត្តនូវបញ្ជារបស់ថ្នាក់លើ ដើម្បីសួរចម្លើយកម្មាភិបាលជាន់ខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងស៊ីវិល និងយោធា ដើម្បីឈានទៅរកខ្សែខ្មាំង ចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ជាបន្តបន្ទាប់ ។ ឌុច មិនបានចាត់វិធានការណាមួយដើម្បីទប់ស្កាត់នូវបទល្មើសឡើយ ទោះបីជាខ្លួនអាចមានលទ្ធភាពនឹងធ្វើការងារ ដែលអាចបន្ធូរបន្ថយការចាប់សម្លាប់ក៏ដោយ ដូចជាការផ្តល់អាហារគ្រប់គ្រាន់ដែលមន្ទីរសន្តិសុខ ស-២១ មាន ។[1127] នេះបង្ហាញថា ឌុច មានអំណាច និងជម្រុញឲ្យមានការស្លាប់ និងសម្លាប់ដោយផ្ទាល់ ។



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ផ្នែកទី ២. សមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣៧៥. អង្គជំនុំជម្រះតុលាការកំពូល បានទទួលស្គាល់យ៉ាងច្បាស់អំពីជំហារពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយប្រៀបធៀបទៅនឹងតុលាការផ្សេងទៀតដោយលើកឡើងថា "(...) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានអត្ថិភាពនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អនុវត្តនូវសមត្ថកិច្ចផ្តាច់មុខ និងពុំមានការបញ្ជូនរឿងក្តីណាមួយទៅតុលាការមួយផ្សេងទៀតឡើយ" ។[1128] សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ បានបង្ហាញឲ្យឃើញអំពីជម្រើសរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្ទេរយុត្តាធិការទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជាជាងការអនុវត្តយុត្តាធិការរបស់តុលាការជាតិខ្លួន ។[1129]

៣៧៦. សរុបមក យើងយល់ឃើញថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬយុត្តាធិការបទល្មើសរបស់តុលាការកម្ពុជា *ធម្មតា* ទៅលើព្រឹត្តិការណ៍នានា ដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។[1130]

## ផ្នែកទី ៣. ការបកស្រាយចង្អៀត និងគោលការណ៍ "វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនត្រូវចោទ"

៣៧៧. គោលការណ៍ "វិមតិសង្ស័យបានប្រយោជន៍ដល់ជនត្រូវចោទ" និងការបកស្រាយចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ ដែលត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ[1131] ដោយប្រព័ន្ធច្បាប់ព្រហ្មទណ្ឌកម្ពុជា[1132] និងតុលាការព្រហ្មទណ្ឌអន្តរជាតិ[1133] គឺជាគោលការណ៍ក្នុងចំណោមកត្តាផ្សេងទៀតដើម្បីឲ្យយើងធ្វើការអនុវត្តឆន្ទានុសិទ្ធិ ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

៣៧៨. ជាការពិត ដែលមិនអាចប្រកែកបានដែលថា ដោយសារមានសម្ពាធ ពីការរំពឹងរបស់សាធារណជន ពីសំណាក់សារព័ត៌មាន ដែលព្រួយបារម្ភពីនិទណ្ឌភាពចំពោះអំពើឃោរឃៅជាទ្រង់ទ្រាយធំដែលមិនអាចប្រកែកបាន របៀបវារៈនយោបាយ ព្រមជាមួយនឹងការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រកន្លងមក ដែលជាញឹកញយនៅក្នុងសេណារីយ៉ូរបៀបនេះ ពិរុទ្ធភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទហាក់ដូចជាហួសពីការពិភាក្សាដេញដោលតាំងពីដំបូង ប៉ុន្តែដំណើរការនីតិវិធីតុលាការ ពុំមែនគ្រាន់តែជាការយល់ស្រប និងការបញ្ជាក់ជាផ្លូវការចំពោះទស្សនៈទូទៅផ្នែកប្រវត្តិសាស្ត្រដែលមានស្រាប់នោះទេ ។[1134]

៣៧៩. លោក រ៉ូប៊ឺត ជេកសាន់ (Robert H. Jackson) បានថ្លែង នៅក្នុងសន្និសីទនៃសមាគមអាមេរិកកាំងនៃច្បាប់អន្តរជាតិកាលពីថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៤៥ ស្តីពីវិធីសាស្ត្រតុលាការដ៏ចម្រូងចម្រាស់ ក្នុងការដាក់ទោសលើឧក្រិដ្ឋជនសង្គ្រាមនៃរបបណាហ្ស៊ី (Nazi) នៅមុនពេលចាប់ផ្តើមការជំនុំជម្រះនូរ៉ឹមប៊ឺក (Numemberg) ថា "នោះគឺជាហានិភ័យមួយក្នុងចំណោមហានិយភ័យនានា ដែលត្រូវមាននៅពេលណាដែលការជំនុំជម្រះបានចាប់ផ្តើម ។ គោលការណ៍ចុងក្រោយគឺ តុលាការមិនត្រូវយកបុគ្គលណាម្នាក់មកជំនុំជម្រះ ក្រោមទម្រង់នៃកិច្ចដំណើរការនីតិវិធីតុលាការ ប្រសិនបើតុលាការមិនចង់មើលឃើញបុគ្គលរូបនោះមានសេរីភាពក្នុងករណីរកមិនឃើញពិរុទ្ធភាព" ។[1135]

៣៨០. ច្បាស់ណាស់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការមួយដែលស្វែងរកយុត្តិធម៌តាមបែបជ្រើសរើស យោងតាមគោលបំណងនៃពាក្យពេចន៍ដែលបានចែង ពីព្រោះមានតែមនុស្សមួយក្រុមតូចតែប៉ុណ្ណោះ ដែលនឹងត្រូវយកមកចោទប្រកាន់នៅក្នុងតុលាការកម្ពុជា ចំពោះអំពើឃោរឃៅបានប្រព្រឹត្តឡើងនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺ អ្នកទាំងឡាយដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់តុលាការ ។[1136]

៣៨១. ការចុះកិច្ចព្រមព្រៀងដោយអវត្តមាននៃយុត្តាធិការដែលនៅសេសសល់ផ្សេងទៀត នៅក្នុងតុលាការជាតិកម្ពុជាគឺជាជម្រើសមនសិការនយោបាយ នៅក្នុងអំឡុងពេលនៃការចរចារ



E.C.C.C. * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ដោយបានថ្លឹងថ្លែងលើការអំពាវនាវឱ្យមានការធ្វើសមាហរណកម្មខ្មែរក្រហម ដែលនៅសេសសល់ចូលក្នុងសង្គមជាមួយនឹងគោលបំណងចង់បានការបញ្ចប់តាមផ្លូវតុលាការ ការផ្សះផ្សាជាតិ និងការស្វែងរកការពិត និងយុត្តិធម៌ដល់ជនរងគ្រោះ ព្រមទាំងសម្រាប់គ្រួសារ និងសង្គមរបស់ពួកគេទាំងមូល។[1137]

៣៨២. បើទោះបីជាគ្មានជនល្មើសណាម្នាក់បានអះអាងនូវភាពអយុត្តិធម៌ ពីព្រោះមានបុគ្គលជាច្រើនទៀតពុំត្រូវបានចោទប្រកាន់ ទោះបីជាពួកគេបានប្រព្រឹត្តនូវបទល្មើសដូចគ្នាក៏ដោយ ដរាបណាពួកគេទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការចោទប្រកាន់តាមបែបជ្រើសរើសនៅក្នុងក្របខណ្ឌយុត្តាធិការជ្រើសរើសបែបនេះ អាចបង្ហាញនូវភាពយុត្តិធម៌តាមផ្លូវសីលធម៌ ។[1138] ហេតុនេះហើយ ការវាយតម្លៃដ៏ហ្មត់ចត់លើភ័ស្តុតាងប្រឆាំងនឹងបុគ្គលមួយចំនួនតូច ដែលកំពុងត្រូវបានស៊ើបអង្កេតគឺជាការចាំបាច់បំផុត ។[1139]

៣៨៣. យោងតាមទស្សនៈនៃគោលនយោបាយព្រហ្មទណ្ឌទូទៅ វាពិបាកឱ្យសាធារណជន និងជនរងគ្រោះទទួលយកនូវលទ្ធភាពនៃការលើកលែងទោសលើទាហានដែលបានប្រព្រឹត្តបទល្មើសយ៉ាងព្រៃផ្សៃ សាហាវយង់ឃ្នងដោយផ្ទាល់នៅក្នុងរបបខ្មែរក្រហម ។ [1140]

៣៨៤. ដើម្បីបញ្ជាក់ឡើងវិញនូវសម្តីដែលបានលើកឡើងខាងលើ គេបានដឹងអំពីចន្លោះប្រហោងនេះនៅក្នុងអំឡុងពេលចរចារវាងភាគីជាតិ និងភាគីអន្តរជាតិ។ វាក៏ជាលក្ខណៈទូទៅនៃប្រព័ន្ធយុត្តាធិការ (ដែលមានលក្ខណៈ) អន្តរជាតិ ដែលបានបង្កើតឡើងដើម្បីបញ្ចប់សេណារីយ៉ូក្រោយជម្លោះតាមផ្លូវតុលាការ ។ វិធីសាស្ត្របែបជ្រើសរើស សម្រាប់យុត្តាធិការលើនិទណ្ឌភាពតាមរយៈការចរចាជាក់ស្តែងចំពោះអតីតពួកខ្មែរក្រហមទាំងមូល នឹងទំនងជាពុំពេញចិត្ត និងអយុត្តិធម៌ចំពោះមនុស្សភាគច្រើន ។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវគោរពតាមសេចក្តីសម្រេច តាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់ ក្រោយទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ហើយម្យ៉ាងទៀតការងារនេះមិនត្រូវ និងមិនអាចប្រដូចនឹងសច្ចធារណ៍និរទោស ឬសច្ចធារណ៍ដោយស្វ័យប្រវត្តិនៃការ...



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ខុសត្រូវខ្ពស់ចំពោះបុគ្គល ដែលត្រូវបាននាំមកចំពោះមុខតុលាការដោយសារការចោទប្រកាន់របស់ការិយាល័យសហព្រះរាជអាជ្ញានោះឡើយ ។[1141] សច្ចធារណ៍បែបនេះប្រសិនបើសន្មតមែននោះ ត្រូវធ្វើឡើងក្នុងលក្ខណៈផ្សេងពីនេះ។

៣៨៥. ក្រោយរយៈពេលកន្លងហួសយូរមក ភ័ស្តុតាងសំខាន់ខ្លះតាមរយៈសាក្សី ឬប្រភពផ្សេងទៀតអាចធ្លាក់ដុនដាបដល់កម្រិតមួយពិបាកនឹងរកព័ត៌មានលម្អិតដែលអាចទុកចិត្តបាន ហើយសាក្សីអាចពិបាកនឹងមកផ្តល់សក្ខីកម្ម ។[1142]ករណីនេះពុំមែនជាការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវឱ្យមេធាវីការពារក្តី នៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេ ឬជាការនាំឱ្យក្លាយជាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬការផ្តន្ទាទោសនោះឡើយ ។ មេធាវីការពារក្តីមានសិទ្ធិទទួលបាននូវការវាយតម្លៃឱ្យបានសមហេតុផលលើភ័ស្តុតាង និងការបកស្រាយច្បាប់នៅក្នុងឋានានុក្រមតុលាការនៃអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាគ្រប់ជាន់ថ្នាក់ ដោយគិតចាប់ផ្តើមពីការិយាល័យសហចៅក្រមស៊ើបអង្កេត។[1143]

### ផ្នែកទី ៤. បរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ និងប្រព័ន្ធនៃការធ្វើការសម្រេចចិត្ត

៣៨៦. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាមានការប្រជុំទៀងទាត់ក៏ដោយ ក៏ការធ្វើសេចក្តីសម្រេចនៅក្នុងឋានានុក្រមខ្មែរក្រហម ពុំមែនធ្វើឡើងក្នុងដំណើរប្រជាធិបតេយ្យផ្លូវការមួយដែលអាចឱ្យមានការបញ្ចេញមតិយោបល់ដោយសេរី ហើយនាំឱ្យមានការពិភាក្សាគ្នាដោយសមភាពនោះទេ ។ សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់កំពូល ហើយបន្ទាប់មកត្រូវបានអនុវត្តដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពីផលវិបាកក្នុងការអនុវត្តបញ្ជា ឬពីលទ្ធផលដែលចេញពីការអនុវត្តបញ្ជាទាំងនោះឡើយ ក៏ប៉ុន្តែផលវិបាកនឹងមានលក្ខណៈធ្ងន់ធ្ងរ រហូតមានការដាក់ទណ្ឌកម្ម ឬសម្លាប់ចោលទាំងក្រុមគ្រួសារ ប្រសិនបើបញ្ជាទាំងនោះពុំត្រូវបានគោរពតាម ។[1144]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596134



៣៨៧. កម្មាភិបាលថ្នាក់ក្រោមៗមានតួនាទីផ្សព្វផ្សាយគោលនយោបាយ និង/ឬ អនុវត្តបញ្ជាតែមួយមុខគត់ ហើយមិនត្រូវបានផ្តល់លទ្ធភាពស្វែងយល់លម្អិត នៅក្នុងពេលអនុវត្តគោលនយោបាយទាំងនោះឡើយ ។ ករណីបុគ្គលម្នាក់បានបង្កើតគំនិតផ្តួចផ្តើមរបស់ខ្លួននៅក្នុងកាលៈទេសៈទាំងនេះ ឬក៏យ៉ាងណានោះ គឺពុំមែនជាលក្ខណៈវិនិច្ឆ័យមួយដែលអាចនឹងឱ្យបុគ្គលនោះស្ថិតក្នុងប្រភេទអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ។ អង្គហេតុនៅតែបង្ហាញថា ទោះក្នុងពេលណាៗក៏ដោយ ការកំណត់ន័យលើខ្លឹមសារនៃគោលនយោបាយ និងមធ្យោបាយអនុវត្តគោលនយោបាយស្ថិតនៅលើថ្នាក់កំពូលដែលអាចជ្រៀតជ្រែកតាមចិត្តចង់របស់ពួកគេ ។[1145]

៣៨៨. ករណីនេះរួមផ្សំជាមួយនឹងការប្រើប្រាស់ស៊ីសង្វាក់គ្នាភាគច្រើន នូវប្រព័ន្ធទំនាក់ទំនងខ្សែបណ្តោយនៅក្នុងខ្សែសង្វាក់នៃការបញ្ជា និងគោលការណ៍នៃការរក្សាការសម្ងាត់ជាប់មកជាមួយដែលជាទូទៅពុំអនុញ្ញាត ឬយ៉ាងហោចណាស់ពុំលើកទឹកចិត្ត ឬជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានយុទ្ធសាស្ត្រ និងប្រតិបត្តិតាមលក្ខណៈសមភាពនៃខ្សែទទឹងនៅតាមថ្នាក់ក្រោមៗនៃការដឹកនាំរបស់ថ្នាក់លើ។ ជាក់ស្តែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គេបានបង្កើតនូវប្រព័ន្ធស្វ័យទិតៀន និងការរាយការណ៍ទិតៀនពីអ្នកដទៃ ពីមិត្តភ័ក្រជិតស្និទ្ធ និងសូម្បីតែពីសមាជិកក្រុមគ្រួសារខ្លួនឯង ដើម្បីបង្ហាញនូវភាពស្មោះស្ម័គ្ររបស់ខ្លួនចំពោះអង្គការ ដែលបានបង្កើតឱ្យមានបរិយាកាសមិនទុកចិត្តគ្នាទៅវិញទៅមក រវាងមនុស្សគ្រប់ស្រទាប់វណ្ណៈ ព្រោះតែការបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ។[1146]

៣៨៩. អង្គហេតុពាក់ព័ន្ធរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានបង្ហាញក្នុងផ្នែកខាងលើ និងក្នុងកថាខណ្ឌទី ៧៧, ៩៣ , និង ១០១-១០៣ ខាងលើ ត្រូវបានដឹងឮជាសាធារណៈ ជាសត្យានុម័តស្ទើរតែមិនចាំបាច់មានភ័ស្តុតាងមកបញ្ជាក់ផង ។ វាជាទម្រង់នយោបាយដឹកនាំមួយពិសេសគ្មានក្នុងបណ្តាប្រទេសផ្សេងទៀតធ្វើដូចទេ ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ផ្នែកទី ៥. ចេតនារបស់អ្នកបង្កើតច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

៣៩០. ក្រោយថ្ងៃរំដោះ ០៧ មករា ឆ្នាំ ១៩៧៩ បើទោះបីជាប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា មិនទាន់មានដំណើរការក្តី ដោយសារឆន្ទៈក្នុងការស្វែងរកការពិត និងយុត្តិធម៌សម្រាប់ជនរងគ្រោះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតឲ្យមានតុលាការជាផ្លូវការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ នៅក្នុងក្រឹត្យច្បាប់លេខ ០១ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៧៩ បានចែងអំពីយុត្តាធិការថា *"ដើម្បីវិនិច្ឆ័យបទឧក្រិដ្ឋពូជសាសន៍របស់បន ប៉ុល ពត-អៀង សារី"*។[1147] មេដឹកនាំមានដូចជា អៀង សារី និង ប៉ុល ពត ត្រូវបានផ្តន្ទាទោសដោយកំបាំងមុខពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មមួយចំនួនទៀតនៅក្នុងខែ សីហា ឆ្នាំ ១៩៧៩ ។[1148]

៣៩១. ក្នុងឆ្នាំ ១៩៩៤ ក្រោយការបោះឆ្នោតជាសកលនៅឆ្នាំ ១៩៩៣ ដែលនាពេលនោះក្រុមអតីតកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យមិនបានចូលរួម ហើយនៅតែបង្កសង្គ្រាមស៊ីវិលជាមួយគ្នានោះ រាជរដ្ឋាភិបាលក្នុងគោលបំណងចម្បងនៃការផ្សះផ្សាជាតិ បញ្ចប់សង្គ្រាមដើម្បីស្វែងរកសុខសន្តិភាព បានអនុម័តនូវច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ ។[1149] ច្បាប់នេះបានលើកលែងទោសដល់ក្រុមកម្មាភិបាល ដែលបានចុះចូលជាមួយរាជរដ្ឋាភិបាលក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយច្បាប់នេះចូលជាធរមាន ។ ទោះបីជាយ៉ាងនេះក៏ដោយ ច្បាប់នោះក៏មិនបានអនុគ្រោះទោសដល់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយបទល្មើសដែលត្រូវបានលុបលាងនោះគឺជាបទល្មើសចែងក្នុងច្បាប់ជាតិតែប៉ុណ្ណោះ។ ជាក់ស្តែង មាត្រា ៦ នៃច្បាប់នេះបានបញ្ញត្តិយ៉ាងច្បាស់ថា *"ចំពោះមេដឹកនាំនៃក្រុមកម្ពុជាប្រជាធិបតេយ្យ មិនអាចមានការអនុគ្រោះដូចមានចែងក្នុងច្បាប់នេះឡើយ"* ។[1150] នេះបង្ហាញអំពីចេតនារបស់រាជរដ្ឋាភិបាលក្នុងការផ្សះផ្សាជាតិ និងស្របពេលគ្នានេះ ទុកច្រកសម្រាប់រកយុត្តិធម៌ជូនជនរងគ្រោះ តាមរយៈការមិនអនុគ្រោះដល់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលអាចជាមុខសញ្ញាដ៏ចង្អៀតសម្រាប់តុលាការ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION

ដែលអាចនឹងត្រូវបានបង្កើតនាពេលខាងមុខ ។ មុខសញ្ញាអាចជាមេដឹកនាំកំពូល ដែលមាន អៀង សារី, ខៀវ សំផន និង ប៉ុល ពត ដែលពេលនោះគេដឹងឮជាទូទៅ ។

៣៩២. នៅអំឡុងខែ កញ្ញា ឆ្នាំ ១៩៩៦ ក្នុងគោលបំណងស្វែងរកសន្តិភាព ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា បានចេញព្រះរាជក្រឹត្យលើកលែងទោសប្រហារជីវិត តាមខ្លឹមសារនៃសាលក្រមកំបាំងមុខនៅឆ្នាំ ១៩៧៩ និងទោសតាមបទល្មើសកំណត់ដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ ឆ្នាំ ១៩៩៤ ដល់ លោក អៀង សារី ។[1151] ឆន្ទៈនយោបាយក្នុងគោលបំណងផ្សះផ្សាជាតិ បញ្ចប់សង្គ្រាម បញ្ចប់ជម្លោះប្រដាប់អាវុធក្នុងឆ្នាំ ១៩៩៨ នយោបាយរបស់រាជរដ្ឋាភិបាលដែលហៅថា "នយោបាយឈ្នះៗ" បាននាំឲ្យមានសមាហរណកម្ម កងទ័ពខ្មែរក្រហមចូលទៅក្នុងកងទ័ពជាតិ ជាមួយការធានារក្សានូវកម្មសិទ្ធិ ការរស់នៅ និងមុខរបររបស់ពួកគេ ។

៣៩៣. នាឆ្នាំ ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានទាក់ទងជាមួយនឹងអង្គការសហប្រជាជាតិ ដើម្បីបង្កើតនូវតុលាការ ដើម្បីវិនិច្ឆ័យសេចក្តីជនទទួលខុសត្រូវលើបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។[1152]ជាក់ស្តែងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអនុម័តក្នុងឆ្នាំ ២០០១ មុននឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យមានរូបរាងឡើងក្នុង ខែ មិថុនា ឆ្នាំ ២០០៣ ។ កាលបរិច្ឆេទបានបង្ហាញនូវរយៈពេលជិត ១០ (ដប់) ឆ្នាំ ចាប់តាំងពីឆ្នាំ ១៩៩៧ រហូតដល់ថ្ងៃដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចាប់ផ្តើមដំណើរពេញលេញនៅក្នុងឆ្នាំ ២០០៦ ក្រោយវិធានផ្ទៃក្នុងបានចូលជាធរមាន ។

៣៩៤. ដំណើរនៃការចរចាបង្កើតកិច្ចព្រមព្រៀងប្រកបដោយភាពប្រុងប្រយត្ន័ ដើម្បីធានានូវការផ្សះផ្សាជាតិ និងការស្វែងរកយុត្តិធម៌ឆ្លងកាត់នូវការពិភាក្សាយ៉ាងក្តៅគគុកលើខ្លឹមសារ ជា



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596137



ពិសេស បញ្ញាយុត្តាធិការផ្ទះបញ្ជាំងនូវភាពជាម្ចាស់ និងអធិបតេយ្យភាពនៃកម្ពុជា ។ ខ្លឹមសារនៃបទប្បញ្ញត្តិមួយចំនួន ដែលបង្កប់នូវមន្ទិលអធម្មនុញ្ញភាពដូចជា ទោសប្រហារជីវិត បញ្ហាអាជ្ញាយុកាលនៃការចោទប្រកាន់ និងភាពប្រតិសកម្មនៃច្បាប់ ត្រូវបានស្នើដាក់ជូនក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដើម្បីពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ ។ ក្រុមប្រឹក្សាធម្មនុញ្ញបានរកឃើញថា មាត្រាទាំងអស់នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែមាត្រា ៣ ដែលយោងដល់ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ទាក់ទិននឹងការដាក់ទោសប្រហារជីវិត ដែលនាំឲ្យផ្នែកនេះនៃមាត្រា ៣ មិនស្របនឹងរដ្ឋធម្មនុញ្ញ ។[1153] ជាលទ្ធផលមិនមានទោសប្រហារជីវិតសម្រាប់បទល្មើសទាំងនោះទេ ពីព្រោះបើមិនដូចនេះទេ វាផ្ទុយនឹងមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ ដែលបានលុបចោលនូវទោសប្រហារជីវិត ។

៣៩៥. ដំណាក់កាលដំបូងនៃការចរចារៀបចំកិច្ចព្រមព្រៀង ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពាក្យ "**មេដឹកនាំ**"ត្រូវបានប្រើប្រាស់ ប៉ុន្តែក្រោយមកពាក្យនេះត្រូវបានដាក់ "ជាន់ខ្ពស់" ជាបន្ថែម ដើម្បីកម្រិតយកតែមេដឹកនាំមួយចំនួនតូចតែប៉ុណ្ណោះ ដែលអាចចាត់ចូលក្នុងសមត្ថកិច្ចរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នេះសំដៅទៅលើតែសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និងសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស។ ទោះបីមិនមានតារាងបញ្ជីឈ្មោះជនទាំងនោះ ក៏ប៉ុន្តែក្រុមការងារទំនងជាសំដៅជាសំខាន់លើមេដឹកនាំកំពូលមានដូចជា ប៉ុល ពត , នួន ជា , ខៀវ សំផន , សុន សេន , អៀង សារី , កែ ពក , អៀង ធីរិទ្ធិ , វ៉ាន់ រិទ្ធ និង តា ម៉ុក ជាអាទិ៍ ។[1154] ខណៈដែលបុគ្គលទាំងនោះ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និង/ឬ ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស ។[1155]

៣៩៦. អំឡុងពេលនៃការចរចា កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ត្រូវបានរកឃើញថានៅរស់រានមានជីវិត ហើយក្រោយមកត្រូវបានឃុំឃាំងនៅមន្ទីរឃុំឃាំងនៃតុលាការយោធា ។[1156] អាស្រ័យហេតុនេះ ពាក្យថា "**ជនដែលទទួលខុសត្រូវ**" ត្រូវ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01596138



បានដាក់បញ្ចូលនៅក្នុងខ្លឹមសារនៃមាត្រា ២ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បន្ទាប់ពីមានការពិភាក្សាយ៉ាងផុសផុលទាំងភាគីអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានឯកភាពបន្ថែមនូវពាក្យ"ខ្ពស់បំផុត" ទៅលើកម្រងពាក្យថា "ជនដែលទទួលខុសត្រូវ" ដែលមានស្រាប់បន្ថែម ដោយមានកម្រងពាក្យពេញថា "**ជនដែលទទួលខុសត្រូវខ្ពស់បំផុត**" ។ ភាគីហាក់មានជំហរស្រដៀងគ្នាអំពីបុគ្គលដែលនឹងស្ថិតក្រោមយុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាមេដឹកនាំជាន់ខ្ពស់ និង ឌុច ដែលជាកម្មាភិបាលម្នាក់ដែលជាជនទទួលខុសត្រូវខ្ពស់បំផុត។ ជារួមគេអាចនិយាយបានថា ពាក្យ "**ជនដែលទទួលខុសត្រូវខ្ពស់បំផុត**" ត្រូវបានដាក់បញ្ចូលសម្រាប់តែករណីពិសេសលើអតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ នេះមានន័យថា ប្រសិនបើអតីតប្រធានមន្ទីរសន្តិសុខ ស-២១ មិនត្រូវបានរកឃើញទេ ច្បាស់ណាស់ថាកម្រងពាក្យនេះនឹងមិនមានវត្តមានក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឡើយ ។

៣៩៧. ការដាក់បញ្ចូល ឌុច ក្នុងន័យថាជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនេះ ជាបុគ្គលដែលដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ កៀកកិតនឹងការប្រព្រឹត្ត មានស្វ័យភាពក្នុងការងារ និងអំណាចតាមការអនុវត្តជាក់ស្តែង (De Facto Authority) ។ ខណៈដែលបុគ្គលទាំងពីរប្រភេទនេះត្រូវបានចាត់ចូលជាជនស្ថិតក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទាំងពាក្យថា "**ជាន់ខ្ពស់**" និង "**ខ្ពស់បំផុត**" សុទ្ធតែឆ្លុះបញ្ចាំងឱ្យឃើញថាមានចំនួនមេដឹកនាំតិចតួចបំផុត ដែលអាចស្ថិតក្នុងយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

៣៩៨. បញ្ហាយុត្តាធិការដ៏ចង្អៀតបែបនេះ ត្រូវបានលើកឡើងដោយតំណាងរាជរដ្ឋាភិបាលកម្ពុជានាពេលប្រជុំនៅរដ្ឋសភា ដើម្បីពិភាក្សា និងអនុម័តលើសេចក្តីព្រៀងច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឈរលើមូលដ្ឋាននៃខ្លឹមសារដ៏ជាក់លាក់ថា



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

ជនមុខសញ្ញាត្រូវតែមានចំនួនតិច និងមិនទូលំទូលាយដោយសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់តែប៉ុណ្ណោះ ។[1157] ជំហរនេះបានបង្ហាញជាដដែលៗបន្តបន្ទាប់មកទៀត ។[1158]

៣៩៩. ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចែងនូវសំឡេងសម្រាប់អនុម័តសេចក្តីសម្រេចអង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូល និងអង្គស៊ើបអង្កេត មានការិយាល័យសហព្រះរាជអាជ្ញា និងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមន្ត្រីក្នុងអង្គនីមួយៗត្រូវធ្វើការងាររួមគ្នា ។ រាល់ការសម្រេចដែលចេញពីអង្គភាពទាំងនេះ សុទ្ធតែត្រូវទាមទារឱ្យមានការចូលរួមពីភាគីកម្ពុជា ។ អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រម ៤ (បួន) រូប យ៉ាងតិច ក្នុងចំណោមចៅក្រម ៥ (ប្រាំ) រូប ខណៈដែលអង្គជំនុំជម្រះតុលាការកំពូល តម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រម ៥ (ប្រាំ) រូប យ៉ាងតិច ក្នុងចំណោមចៅក្រម ៧ (ប្រាំពីរ) រូប រីឯអង្គបុរេជំនុំជម្រះ តម្រូវឱ្យមានសំឡេងគាំទ្រដោយចៅក្រម ៤ (បួន) រូប យ៉ាងតិច ក្នុងចំណោមចៅក្រម ៥ (ប្រាំ) រូប ។[1159] នេះបង្ហាញពីប្រព័ន្ធនៃអង្គជំនុំជម្រះ ដែលមានចៅក្រមជាភាគីជាតិចូលរួមច្រើន ខុសពីតុលាការអន្តរជាតិផ្សេងទៀត ដូច្នេះជាប្រភេទថ្មីដែលមានឈ្មោះថា “អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា” ។[1160]

៤០០. ការចែងតម្រូវឱ្យមានដំណើរការងាររួមគ្នាជា “សហ” ក្រៅពីផ្តល់នូវភាពជាម្ចាស់ដោយប្រយោល យន្តការនេះផ្តល់លទ្ធភាពនូវការខ្វែងយោបល់របស់ចៅក្រមភាគីជាតិ ឬអន្តរជាតិពាក់ព័ន្ធនឹងដំណើរការនៃកិច្ចនីតិវិធី ហើយដំណោះស្រាយអាចធ្វើឡើងតាមបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ ។ យោងតាមឯកសារនៃចរចាបង្កើតឱ្យមានកិច្ចព្រមព្រៀង បញ្ហាខ្វែងយោបល់គ្នានេះត្រូវបានពិភាក្សាយ៉ាងផុសផុល ហើយយន្តការនៃដំណោះស្រាយតាមរយៈអង្គបុរេជំនុំជម្រះត្រូវបានអនុម័តយក ក្រោយមកជាមួយនឹងការព្រមព្រៀងតាមភាគីជាតិ ដែលស្នើឱ្យមានសំឡេងរបស់ចៅក្រមជាតិច្រើនជាងនៅក្នុងអង្គនីមួយៗ ដែលពីមុនត្រូវបានស្នើដាក់សំឡេងចៅក្រមអន្តរជាតិច្រើនជាង ។[1161] នេះបានបង្ហាញពីចេតនារបស់ភាគីជាតិជាអ្នកតាក់តែងច្បាប់ ។ ជារួមប្រព័ន្ធនៃរបៀបរបបនីតិវិធីនៃការសម្រេចរបស់



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

សហព្រះរាជអាជ្ញាក្តី សហចៅក្រមស៊ើបអង្កេតក្តី ចៅក្រមនៃអង្គជំនុំជម្រះក្តី ជាទឡ្ហីករណ៍ផ្ទុះបញ្ជាំងដល់ការបកស្រាយបញ្ញាច្បាប់ស្តីអំពីយុត្តាធិការនេះកាន់តែច្បាស់ មិនអាចប្រកែកបានឡើយ ពីយុត្តាធិការចង្អៀត ធានាដល់ការផ្សះផ្សាជាតិ សុខសន្តិភាព និងជាគោលបំណងនៃការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ ប្រព័ន្ធនៃដំណើរការនីតិវិធីនេះ ជាលក្ខណៈពិសេសដាច់ដោយឡែកខុសពីតុលាការផ្សេងទៀត ។

៤០១. ជាចុងក្រោយឆ្លើយតបនឹងបញ្ហាលើកលែងទោស ភាគីទាំងពីរបានឯកភាពបញ្ចូលមាត្រា ៤០ ថ្មី ដែលមានខ្លឹមសារទុកអំណាចឲ្យតុលាការជាអ្នកសម្រេច ពាក់ព័ន្ធការលើកលែងទោសដែលត្រូវបានធ្វើកន្លងមក ។ មាត្រានេះបង្ហាញពីការគោរពដល់អង្គតុលាការ និងក៏អាចបង្ហាញពីចេតនាមិនឲ្យជនសង្ស័យ ដែលជាមេដឹកនាំជាន់ខ្ពស់ដូចជា អៀង សារី រួចខ្លួនពីការទទួលខុសត្រូវ ។ បន្ថែមពីលើនេះ ក្នុងអត្ថន័យថាការកាត់ទោសមេដឹកនាំកំពូលទាំងនេះនឹងមិនរាលដាលដល់កម្មាភិបាលនៅថ្នាក់ក្រោមឡើយ ក្រៅពី ឌុច ដែលមានឈ្មោះក្នុងគំនិតនៃអ្នកធ្វើច្បាប់ ។

៤០២. ក្នុងខែ មីនា ឆ្នាំ ១៩៩៩ ក្នុងអំឡុងពេលនៃការចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឈិត ជឿន ឬ អ៊ុង ជឿន ហៅ តា ម៉ុក ត្រូវបានចាប់ខ្លួនក្នុងខែ មីនា ឆ្នាំ ១៩៩៩ ក្នុងបទចោទថាបានប្រព្រឹត្តបទឧក្រិដ្ឋ (ប្រល័យពូជសាសន៍) ក្នុងតួនាទីជាមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ[1162] ហើយ ឌុច ជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ត្រូវបានចាប់ខ្លួននៅក្នុងខែ ឧសភា ឆ្នាំ ១៩៩៩ ជាមួយនឹងបទចោទប្រឆាំងនឹងសន្តិសុខជាតិ និង បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិតាមច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នាឆ្នាំ ២០០១ ។[1163] នៅក្នុងឆ្នាំ ២០០៣ អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនមាន លោក ឈូក រីន ត្រូវបានកាត់ទោសដោយតុលាការជាតិពីបទភេរវកម្មសម្លាប់ជនបរទេស ។ ការកាត់ទោសនេះធ្វើឡើងអនុលោមតាមច្បាប់ជាតិចំពោះកម្មាភិបាល ដែលបានប្រព្រឹត្តបទល្មើសក្រោយថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩ តែប៉ុណ្ណោះ ។ នេះមិនបង្ហាញពីចេតនាចាកឆ្ងាយពី



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

មុខសញ្ញាមេដឹកនាំជាន់ខ្ពស់តិចតួច ដែលនឹងត្រូវទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៤០៣. នៅក្នុងដំណើរការនៃការរៀបចំការចរចាលើកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សុទ្ធតែមានជំហរ និងឆន្ទៈដ៏ច្បាស់លាស់ដោយសង្កត់ធ្ងន់ និងផ្តល់តំលៃខ្ពស់បំផុតលើការរក្សាបាននូវសុខសន្តិភាព និងការផ្សះផ្សាជាតិ ដោយបានសំដែងនូវក្តីបារម្ភអំពីអសន្តិសុខ ដែលនឹងអាចកើតមានឡើងពីការចោទប្រកាន់ណាមួយនៅក្នុងការដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលអាចនាំឲ្យប៉ះពាល់ដល់ការផ្សះផ្សាជាតិ ដែលទើបតែបានមកវិញទាំងលំបាក ។ [1164]

៤០៤. អង្គការសហប្រជាជាតិកន្លងមកបានអនុម័តសេចក្តីសម្រេចនាថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដោយបានបង្ហាញនូវការទទួលស្គាល់ពីការបារម្ភរបស់ប្រជាជន និងរាជរដ្ឋាភិបាលកម្ពុជាក្នុងដំណើរការស្វែងរកយុត្តិធម៌ ដែលអាចនាំឲ្យប៉ះពាល់ស្ថេរភាព ការបង្រួបបង្រួមជាតិ និងសុខសន្តិភាព ។[1165] ជាលទ្ធផលគោលបំណង ០២ (ពីរ) ក្នុងន័យថ្លឹងថ្លែងគឺ "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ" ត្រូវបានឯកភាពឲ្យសរសេរបញ្ចូលទៅក្នុងកិច្ចព្រមព្រៀង ។[1166] ការបារម្ភអំពីយុត្តិធម៌ និងការផ្សះផ្សាជាតិ ត្រូវបានបង្ហាញក្នុងបុព្វកថានៃកិច្ចព្រមព្រៀងបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូចគ្នានេះដែរ វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏មានចែងអំពីប្រយោគនេះដែរ ។

៤០៥. ក្នុងន័យនេះ គោលបំណងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងចេតនារបស់អ្នករៀបចំតាក់តែងកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានន័យយ៉ាងច្បាស់ថា បុគ្គលដែលនឹងស្ថិតចូលក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺពិតជាមានចំនួនតិចតួចបំផុត ដោយសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់ដែលមានអំណាច និងជនដែលទទួលខុសត្រូវខ្ពស់បំផុត ដែលបានចូលរួមយ៉ាងសកម្មក្នុង



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ការប្រព្រឹត្តបទឧក្រិដ្ឋ និងកៀកជិតនឹងទង្វើប្រព្រឹត្តតាមរយៈអំណាច និងឥទ្ធិពលជាក់ស្តែង ហួសពីអំណាចផ្លូវការដែលមាន ។

៤០៦. ជនជាមុខសញ្ញាទាំងនោះរួមមាន នួន ជា , អៀង សារី , ខៀវ សំផន , អៀង ធីរិទ្ធ , ឌុច , និង តា ម៉ុក ជាមេដឹកនាំជាន់ខ្ពស់ដែលបានស្លាប់ក្នុងឆ្នាំ ២០០៦ ហើយគាត់ជាមេដឹកនាំរបស់ យឹម ទិត្យ រឹង កែ ពក ជាអតីតលេខាភូមិភាគកណ្តាល បានស្លាប់ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលគាត់ជាចៅហ្វាយនាយរបស់ អោ អាន ហើយ សុន សេន ជាចៅហ្វាយនាយ របស់ មាស មុត បានស្លាប់នាថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ១៩៩៧ និង ប៉ុល ពត បានស្លាប់នាថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៨ ។

៤០៧. ជាសរុប ក្រោយពីបានពិនិត្យមើលសារតារនៃការស្វែងរកយុត្តិធម៌ មុនការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជំហររបស់ភាគីក្នុងអំឡុងពេលធ្វើច្បាប់ និងកិច្ចព្រមព្រៀងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការបកស្រាយច្បាប់ព្រហ្មទណ្ឌតាមអត្ថន័យចង្អៀត យុត្តាធិការបែបជ្រើសរើស ខ្លឹមសារជាក់ស្តែងនៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ព្រមទាំងជំហររបស់ភាគី ជាពិសេសភាគីជាតិតាំងពីមុនការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ផ្តោតលើការផ្សះផ្សាជាតិ និងការស្វែងរកយុត្តិធម៌ វាទាមទារឲ្យមានការថ្លឹងថ្លែង ដោយផ្តោតលើមេដឹកនាំជាន់ខ្ពស់ជាមុខសញ្ញាតិចតួច តូចចង្អៀត ។ តំណាងរដ្ឋាភិបាលក្នុងអំឡុងពេលពិភាក្សាច្បាប់នៅរដ្ឋសភាជាតិបានបង្ហាញនូវជំហរនេះ ។[1167] សហចៅក្រមស៊ើបអង្កេតទាំងជាតិ និងអន្តរជាតិ ធ្លាប់បានអះអាងនូវការគោរពស្មារតីនៃភាគីចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។[1168]



CO-INVESTIGATING JUDGES *E.C.C.C* C.E.T.C *CO-JUGES D'INSTRUCTION

## ជំពូក ៦. សំអាងហេតុ និងសន្និដ្ឋាន

៤០៨. ដូចបានអះអាងនៅខាងលើ សហចៅក្រមស៊ើបអង្កេតជាតិ នឹងផ្តល់សំអាងហេតុមុននឹងសន្និដ្ឋានអំពីយុត្តាធិការបុគ្គលក្នុងសំណុំរឿងលេខ ០០៣ ។ យើងនឹងពិចារណាអំពី តួនាទី និងការចូលរួមរបស់ មាស មុត ផ្អែកតាមភ័ស្តុតាងដាក់នៅក្នុងសំណុំរឿង មុនថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១។

### តួនាទី និង អំណាច របស់ មាស មុត ក្នុងបរិបទនៃការសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនៃរបបកម្ពុជាប្រជាធិបតេយ្យ

៤០៩. របបកម្ពុជាប្រជាធិបតេយ្យចន្លោះឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ មានគោលដៅកសាងសង្គមទៅជារបបសង្គមនិយម ។ ដើម្បីសម្រេចតាមគោលដៅនេះ របបនេះបានបណ្តេញប្រជាជនទៅតាមមូលដ្ឋានដើម្បីចូលរួមធ្វើកសិកម្ម ដែលជាវិស័យមួយចម្បងសម្រាប់ដំណើរនៃរបបរបស់ខ្លួន។

៤១០. របបកម្ពុជាប្រជាធិបតេយ្យមានរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់លើ និងមូលដ្ឋានយ៉ាងជាក់លាក់ដែលសម្រេចចាត់ចែង និងគ្រប់គ្រងការងារជាលក្ខណៈសមូហភាព។ ក្នុងចំណោមស្ថាប័នកំពូលៗ មានគណៈកម្មាធិការមជ្ឈិមបក្ស ដែលមានសមាជិកជាង ៣០ (សាមសិប) រូប ជាស្ថាប័នមានអំណាចកំពូល សម្រាប់ធ្វើការលើកិច្ចការងារចម្បងៗរបស់ប្រទេសជាតិ និង គណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមានសមាជិកចំនួន ៧ (ប្រាំពីរ) រូប ក្នុងនោះមាន ប៉ុល ពត , នួន ជា, សោ ភឹម , តា ម៉ុក , អៀង សារី , វន វ៉េត និង សុន សេន ។ ទោះបីជាយ៉ាងនេះក្តី អំណាចកំពូល និងអំណាចសម្រេចស្ថិតនៅក្នុងដៃគណៈកម្មាធិការអចិន្ត្រៃយ៍ ជាអ្នកត្រួតត្រាលើគោលនយោបាយទាំងអស់ រាប់ទាំងកិច្ចការសន្តិសុខខាងក្នុង និងខាងក្រៅ កសិកម្ម សុខភាព និងសង្គម ជាអាទិ៍។



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUDGES D'INSTRUCTION *

៤១១. តាំងពីមុនឆ្នាំ ១៩៧៥ បក្សបានតម្រូវឱ្យប្រជាជនរស់នៅជាសហករណ៍ ក្នុងតំបន់ដែលខ្លួនបានរំដោះ ហើយបក្សជាអ្នកប្រមូលយកផល និងទ្រព្យសម្បត្តិឯកជន ដោយបានកំណត់របបអាហារ ផលិតផលកសិកម្ម ការងារ ការស្លៀកពាក់ ការនិយាយស្តី ការធ្វើដំណើរ ដោយបានលុបបំបាត់ចោលនូវទីផ្សារ រូបិយវត្ថុ និងកម្មសិទ្ធិឯកជន ។

៤១២. បក្សបានបង្ខំឱ្យប្រជាពលរដ្ឋធ្វើស្រូវឱ្យបាន ៣ (បី) តោនក្នុងមួយហិចតា ហើយភោគផលភាគច្រើនត្រូវប្រគល់ជូនបក្ស សម្រាប់គោលបំណងធ្វើការនាំចេញទៅក្រៅប្រទេសដើម្បីជាថ្នូរក្នុងការទិញសព្វាវុធ ។ កម្មាភិបាល មិនមានសិទ្ធិអំណាចអន្តរាគមន៍ ដើម្បីបន្ធូរបន្ថយស្ថានភាពលំបាកនេះទេ ពីព្រោះនេះជាគោលនយោបាយរបស់បក្ស ដែលត្រូវតែគោរពតាមជាដាច់ខាត ។

៤១៣. ដើម្បីសម្រេចតាមទិសដៅរបស់ខ្លួន របបកម្ពុជាប្រជាធិបតេយ្យបានអនុវត្ត និងប្រកាន់យកនូវគោលនយោបាយវិសុទ្ធកម្មក្រៅ និងក្នុងបក្ស ដែលមានតាំងពីមុនឆ្នាំ ១៩៧៥ ក្នុងគោលបំណងបំផ្លាញនូវរចនាសម្ព័ន្ធចាស់ វណ្ណៈសក្តិភូមិ នាយទុន សាសនា និងពូជសាសន៍ ។ របបនេះបានបង្កើតឱ្យមានមន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្សសរុបចំនួន ១៩៥ (មួយរយកៅសិបប្រាំ) កន្លែង (កថាខណ្ឌទី ៩៧) នៅទូទាំងប្រទេស ដើម្បីលត់ដំ អប់រំកែប្រែ ឬឈានទៅដល់ការធ្វើទារុណកម្មដើម្បីបង្ហាញខ្សែក្សែត់ ឬសម្លាប់ទាំងគ្រួសារ ។

៤១៤. របបកម្ពុជាប្រជាធិបតេយ្យមានរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលស៊ីវិល ចែកចេញជា ភូមិភាគ តំបន់ ស្រុក និង ឰសហករណ៍ ដែលធ្វើការងារជាខ្សែសង្វាក់ថ្នាក់បណ្តាយពីមជ្ឈិមចុះដល់មូលដ្ឋាន ។ គោលនយោបាយ ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈការជួបប្រជុំផ្សព្វផ្សាយកម្រិតភូមិភាគ តំបន់ ស្រុក និងសហករណ៍ និងបញ្ជូនទៅថ្នាក់ក្រោមតាមឋានានុក្រមដឹកនាំ ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01596145



៤១៥. កងទ័ពមានកងពលភូមិភាគ និងកងពលមជ្ឈិម ដែលចែកចេញជាកងពល ។ សុន សេន ដែលជាសមាជិកនៃគណៈកម្មាធិការយោធា និងជាអគ្គសេនាធិការកងទ័ព បានអះអាងថា កងទ័ពរបស់បក្សត្រូវតែស្អាតស្អំ ស្មោះត្រង់នឹងបក្ស ចូលរួមបង្រ្កាបខ្មាំងការពារទឹកដី ។ គាត់បានដាក់បញ្ហាដាច់ខាតឲ្យគាស់រំលើង និងឈានទៅកម្ទេចសមាសភាពមិនល្អក្នុងកងទ័ព ហើយដែលកងពលទាំងអស់ត្រូវតែគោរព និងអនុវត្តតាម (កថាខណ្ឌទី ២៣០ , ២៤៧ និង ២៤៩)។

៤១៦. កងពលលេខ ១៦៤ មាន **មាស មុត** ជាលេខាកងពល ដែលមាន ៤ (បួន) កងវរៈសេនាធំ ដែលក្នុងចំណោមនោះ មានកងវរៈសេនាធំលេខ ១៤០ ទទួលបន្ទុកកិច្ចការជើងទឹក ក្នុងដែនកោះ ក្នុងទឹកដីកំពង់សោមតែប៉ុណ្ណោះ (កថាខណ្ឌទី ១៩១) ។ កងវរៈសេនាធំនីមួយៗ មានមេបញ្ជាការទទួលបន្ទុករៀងៗខ្លួន (កថាខណ្ឌទី ១៩៣-១៩៦) ។ **មាស មុត** ជាលេខាទទួលបន្ទុកនយោបាយ (កថាខណ្ឌទី ១៨២) ផ្តោតសំខាន់លើការងារផ្សព្វផ្សាយគោលនយោបាយរបស់បក្ស ។ គាត់មានអនុលេខាចំនួន ២ (ពីរ) រូប ទៀត ដែលម្នាក់ទទួលបន្ទុកយោធា (កថាខណ្ឌទី ១៩០) ។ តាមភ័ស្តុតាង អនុលេខានេះក៏បានទាក់ទងការងារផ្ទាល់ជាមួយ សុន សេន ផងដែរ (កថាខណ្ឌទី ២៨៥)។ សក្ខីកម្មរបស់សាក្សីសំខាន់ៗ បានអះអាងថា កងពលលេខ ១ នៃភូមិភាគបស្ចិម ក៏ទទួលការងារដែនទឹកសមុទ្រផងដែរ ក៏ប៉ុន្តែក្នុងភូមិសាស្រ្តខេត្តកោះកុង (កថាខណ្ឌទី ២១៩)។

៤១៧. កងពលលេខ ១៦៤ ទទួលភារកិច្ចដោយផ្នែកលើដែនទឹក ដែលជាបញ្ហាអធិបតេយ្យភាពរបស់កម្ពុជាប្រជាធិបតេយ្យ ។ ក្នុងហេតុផលនេះហើយ គណៈកម្មាធិការអចិន្ត្រៃយ៍បានដាក់កងពលលេខ ១៦៤ ជាកងពលមជ្ឈិមក្រោមការគ្រប់គ្រងផ្ទាល់របស់ខ្លួន (កថាខណ្ឌទី ១៧៣) ។ កងពលលេខ ១៦៤ ជាកងពលមួយក្នុងចំណោមកងពលមជ្ឈិមចំនួន ១២ (ដប់ពីរ) ។ តាមឋានានុក្រមកងពលលេខ ១៦៤ ស្ថិតនៅក្រោមសេនាធិការ និងគណៈកម្មាធិការយោធា ដែលមាន សុន សេន , តា ម៉ុក , នួន ជា និង ប៉ុល ពត ជាប្រធាន (កថាខណ្ឌទី ១៥៣)។



150
E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤១៨. មាស មុត ជាជំនួយការនៃគណៈកម្មាធិការមជ្ឈិមក្នុងលំដាប់ទីបួន ក៏ប៉ុន្តែមិនមានសិទ្ធិចូលរួមធ្វើសេចក្តីសម្រេចក្នុងគណៈកម្មាធិការនេះទេ (កថាខណ្ឌទី ១១០) ។ គាត់ក៏មិនមែនជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ។ ប្រសិនបើវាជាការពិតដូចការអះអាងរបស់សាក្សីភាគតិច ថាគាត់ជាអនុប្រធានសេនាធិការមែន គាត់ទំនងជាកាន់តួនាទីនេះក្នុងអំឡុងពេលប្រហែល ១ ខែ ក្នុងស្ថានភាពច្របូកច្របល់ មុនការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ ១៩៧៩ (កថាខណ្ឌទី ១៦៣) ។ មិនតែប៉ុណ្ណោះ មាស មុត មិនមែនជាបុគ្គលក្នុងចំណោមបុគ្គលទាំង ១៣ (ដប់បី) រូប ដែលមានសិទ្ធិបញ្ជាឱ្យចាប់ខ្លួន និងបញ្ជាសម្លាប់ទេ (កថាខណ្ឌទី ១៦៩) ។

៤១៩. មាស មុត ស្ថិតនៅក្រោមកម្មាភិបាលប្រហែលចំនួន ៥០ (ហាសិប) រូប និង មានឋានៈស្មើកម្មាភិបាលជាច្រើនទៀត រាប់បញ្ចូលទាំងលេខាភូមិភាគ និងលេខាកងពល ។ ឋានៈទាំងនោះរួមមាន ១-សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សពេញសិទ្ធិ ៧ (ប្រាំពីរ) នាក់ , ២-សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បម្រុង ២ (ពីរ) នាក់ (កថាខណ្ឌទី ៧១) , ៣-សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ពេញសិទ្ធិ និងត្រៀម ជាង ៣០ (សាមសិប) នាក់ (កថាខណ្ឌទី ១០៩ ) , ៤-គណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម ៦ (ប្រាំមួយ) នាក់ (កថាខណ្ឌទី ១៥៣) , ៥-សេនាធិការ មាន សុន សេន អនុប្រធានរបស់គាត់ និងសមាជិក (កថាខណ្ឌទី ១៥៩)។

៤២០. កម្មាភិបាលគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាមគោលនយោបាយបក្ស ក្នុងដំណើរការកសាងរបបកុំម្មុយនីស្ត តាមរយៈការផ្សព្វផ្សាយគោលនយោបាយ ការសម្របសម្រួលក្នុងការចាប់ខ្លួន ការបញ្ជូនអ្នកទោស តាមបញ្ជាពីថ្នាក់លើ ។ ជនដែលមិនអនុវត្តតាម ឬរិះគន់គោលនយោបាយ នឹងត្រូវបានគេចោទថាជាជនក្បត់ និងត្រូវបានកម្ទេច ។ នៅឆ្នាំ ១៩៧៦ ហ៊ូ យន់ ត្រូវចាប់ខ្លួន និងសម្លាប់ដោយសារបានផ្តល់យោបល់ស្នើឱ្យចាយលុយ បើកផ្សារ ផ្ទុយពីការសម្រេចរបស់ ប៉ុល ពត , នួន ជា និង តា ម៉ុក (កថាខណ្ឌទី ៩៨ , ៩៩) ។ ជាក់ស្តែង



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

ក្នុងអំឡុងពេលជាង ៣ (បី) ឆ្នាំ កម្មាភិបាលជាន់ខ្ពស់ចំនួនជាង ៦០ (ហុកសិប) រូប និងសមាជិកសេនាធិការភាគច្រើន ត្រូវបានចាប់យកសួរចម្លើយ ដាក់ឃុំឃាំង និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ។ ប្រជាជនជាង ១.៧០០.០០០ (មួយលានប្រាំពីរសែន) នាក់ បានស្លាប់ និងត្រូវបានសម្លាប់ក្នុងរយៈពេលជាង ៣ (បី) ឆ្នាំ នៃរបបនេះ (កថាខណ្ឌទី ១០១)។

## ការចូលរួមរបស់ មាស មុត

៤២១. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានចោទប្រកាន់ **មាស មុត** ជាចម្បងពាក់ព័ន្ធនឹងការសហការចាប់បញ្ជូនកងទ័ពនៃកងពលលេខ ១៦៤ មកមន្ទីរសន្តិសុខ ស-២១ ជាទីកន្លែងដែលពួកគេត្រូវបានសម្លាប់ និងការចូលរួមបង្ក្រាបលើកងទ័ព និងប្រជាពលរដ្ឋបរទេសដែលបានទន្ទ្រានចូលមកក្នុងដែនសមុទ្រកម្ពុជា ។

៤២២. ក្នុងនាមជាលេខាកងពលលេខ ១៦៤ **មាស មុត** បានចូលរួមគាំទ្រគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងការបង្ក្រាបខ្មាំងស៊ីរូងផ្ទៃក្នុង ផ្សព្វផ្សាយគោលនយោបាយដល់កងទ័ពក្នុងកងពលលេខ ១៦៤ ។ នេះស្តែងឡើងតាមរយៈការចូលរួមប្រជុំដឹកនាំដោយ សុន សេន ជាមួយលេខា និងអនុលេខាកងពលដទៃទៀត ។

៤២៣. ឯកសារជាផ្លូវការ និងសម្ងាត់ ដ៏គួរឱ្យទុកចិត្តបានរបស់របបកម្ពុជាប្រជាធិបតេយ្យចំនួន ២៨៦ (ពីររយប៉ែតសិបប្រាំមួយ) ឯកសារ (កថាខណ្ឌទី ២២០ ដល់ ២២៥) មានដូចជាចម្លើយសារភាព សារទូរលេខ សារតាមទូរស័ព្ទសម្ងាត់ កំណត់ហេតុនៃការប្រជុំ ដែលបង្ហាញពីវត្តមាននៃការចូលរួមរបស់ **មាស មុត** ការឆ្លើយឆ្លងរវាងគាត់ និង សុន សេន ។ ទោះបីជាយ៉ាងនេះក្តី វាមិនបានបង្ហាញពីការផ្តួចផ្តើម ការបញ្ជាឱ្យចាប់ខ្លួន ឬសម្លាប់ដោយ **មាស មុត** ទេ ក្រៅតែពីការរាយការណ៍ពីស្ថានភាពទូទៅ និងស្ថានភាពខ្មាំងនៅក្នុងកងពលលេខ ១៦៤ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរសព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៤២៤. មានភ័ស្តុតាងបង្ហាញពីការសម្របសម្រួលចំពោះការចាប់បញ្ជូនទាហាននៃកងពលលេខ ១៦៤ ទៅកាន់មន្ទីរសន្តិសុខ ស-២១ ។ វិសុទ្ធកម្មកងទ័ព ជារឿងចាំបាច់ដាច់ខាត ត្រូវតែធ្វើ ដូចដែល ប៉ុល ពត និង សុន សេន បានប្រកាសដើម្បីកម្ទេចខ្មាំង និងការពារទឹកដី ។ មន្ទីរសន្តិសុខ ស-២១ ជាយន្តការដ៏សំខាន់ដើម្បីអនុវត្តគោលនយោបាយ ពាក់ព័ន្ធសន្តិសុខពេញផ្ទៃប្រទេស ។ វាស្ថិតក្រោម សុន សេន និងគ្រប់គ្រងផ្ទាល់ទៅលើកងពលលេខ ១៦៤ ដែលជាកងទ័ពជើងទឹករបស់មជ្ឈិម ។ កម្មាភិបាល ឬកងទ័ពដែលត្រូវចាប់បញ្ជូនមកកាន់មន្ទីរសន្តិសុខ ស-២១ គឺដើម្បីសួរយកចម្លើយ ហើយស្របតាមគោលនយោបាយ ពួកគេនឹងត្រូវសម្លាប់ (កថាខណ្ឌទី ២៦៩)។ អាស្រ័យហេតុនេះ ការសម្រេចចាប់បញ្ជូន កម្មាភិបាល ឬបុគ្គលណាមួយមកកាន់មន្ទីរសន្តិសុខ ស-២១ គឺជាការសម្រេចរបស់គណៈ កម្មាធិការមជ្ឈិម គឺ ប៉ុល ពត និង នួន ជា តាមយោបល់របស់ សុន សេន និងមានការ សហការពីមេដឹកនាំស្ថាប័ន ។

៤២៥. តាមកថាខណ្ឌទាំងពីរខាងលើ ទាំងការសម្របសម្រួល ការចាប់បញ្ជូនខ្លួនទៅមន្ទីរសន្តិសុខ ស-២១ ក៏ដូចជាការបង្ក្រាបក្នុងដែនទឹក វាទំនងថា **មាស មុត** គ្មានសិទ្ធិអំណាចច្រើនទេ ។ ការអះអាងនេះគាំទ្រដោយខ្លឹមសារនៃសេចក្តីសម្រេចចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៧៦ ដែលបង្ហាញថានៅតំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច ។ ចំណែកនៅកងទ័ពមជ្ឈិម ត្រូវសេនាធិការសម្រេច (កថាខណ្ឌទី ២៣២) ។

៤២៦. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបានបង្ហាញថា មានមនុស្សប្រហែល ១៧.០០០ (មួយម៉ឺនប្រាំពីរពាន់) នាក់ ស្ថិតក្រោមការទទួលខុសត្រូវរបស់ **មាស មុត** ក្នុងនោះមានទាហានចំនួនជាង ៨.០០០ (ប្រាំបីពាន់) នាក់ (កថាខណ្ឌទី ១៨៩) ។ ភ័ស្តុតាងដែលប្រមូលបាន មិនបានបញ្ជាក់ពីចំនួនទាំងនេះទេ ។ តាមរយៈបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ មានអ្នកទោសដែលជាអតីតសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជាចំនួនជាង ៥.០០០ (ប្រាំពាន់) នាក់ ដែលជាប់ពាក់ព័ន្ធនឹងការសម្រិតសម្រាំងផ្ទៃក្នុងជួរកងទ័ព ហើយត្រូវបានចាប់បញ្ជូនទៅកាន់មន្ទីរសន្តិសុខ ស-២១ ។ ចំនួនសរុបនៃការបញ្ជូនអ្នកទោសទៅមន្ទីរសន្តិសុខ ស-២១

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ ភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។

ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

នៅក្នុងឆ្នាំ ១៩៧៧ យើងបានឃើញថា កងពលលេខ ១៦៤ មានកងទ័ពប្រហែល ៤២ (សែសិបពីរ) ទៅ ៦៧ (ហុកសិបប្រាំពីរ) នាក់ [1169] និងមួយចំនួនទៀត ត្រូវបានចាប់មកពីសមុទ្របញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ។ ចំនួននេះទំនងជាត្រឹមត្រូវប្រសិនបើយើងប្រៀបធៀប ទិន្នន័យកងពលលេខ ១៦៤ ចន្លោះឆ្នាំ ១៩៧៥ និង ឆ្នាំ ១៩៧៧ (កថាខណ្ឌទី ១៨៩) ។ ចំនួនជនរងគ្រោះផ្ទាល់ក្នុងកងពលលេខ ១៦៤ តិចជាងគេ បើប្រៀបធៀបជាមួយនឹងកងពលលេខ ៥០២ , កងពលលេខ ៨០១ , ភូមិភាគនិរតី , ភូមិភាគពាយ័ព្យ និងភូមិកណ្តាល (អតីតភូមិភាគឧត្តរ) ជាអាទិ៍ ដែលទទួលរងការបង្ក្រាប និងបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ ដូចគ្នា។

## ការចូលរួមរបស់ មាស មុត មិនសកម្ម មិនកៀកកិត នៅនឹងអំពើឧក្រិដ្ឋកម្ម

៤២៧. សហចៅក្រមស៊ើបអង្កេតជាតិបានពិចារណាអំពីគោលការណ៍នៃភាពស៊ីគ្នារវាងយុត្តិសាស្ត្រ (Uniformity of Jurisprudence) ។ ក្នុងន័យនេះ សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណាយុត្តិសាស្ត្រក្នុងសំណុំរឿងលេខ ០០១ និងប្រៀបធៀបតួនាទី ព្រមទាំងការចូលរួមរបស់ ឌុច និង **មាស មុត** ។ ការប្រៀបធៀបរបៀបនេះ ក៏ត្រូវបានធ្វើដោយអង្គជំនុំជម្រះកន្លងមកផងដែរ។

៤២៨. **មាស មុត** មានតួនាទី និងមិនមានអំណាចច្រើនទេ ។ ការចូលរួមរបស់គាត់ មិនសកម្ម មិនជុំកំភួន និងមិនបានកៀកកិតនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ។ ចំនួនជនរងគ្រោះនៃអំពើផ្ទាល់របស់ **មាស មុត** មានភាពខុសគ្នាឆ្ងាយណាស់ រវាងផលវិបាកនៃអំពើផ្ទាល់នៃទង្វើរបស់ ឌុច ។

**តាមសំអាងហេតុខាងលើ យើងសម្រេច ÷**

៤២៩. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមានយុត្តាធិការបុគ្គលលើ **មាស មុត ឡើយ។**

៤៣០. **លើកលែងការចោទប្រកាន់** ប្រឆាំង **មាស មុត** ។

ថ្ងៃ ពុធ ៦ រោច ខែ កត្តិក ឆ្នាំ ច សំរឹទ្ធស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**សហចៅក្រមស៊ើបអង្កេតជាតិ**

**National Co- Investigating Judge**

**National Co-juge d'instruction**

**ចៅក្រម យូ ប៊ុនឡេង**

---

[1] ឯកសារសំណុំរឿង ០០៣ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងករណីទ័ពបដិវត្តន៍កម្ពុជា ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ។

[2] ឯកសារសំណុំរឿង ០០៣ D13 សេចក្តីជូនដំណឹងស្តីពីការបញ្ចប់កិច្ចស៊ើបសួរ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១១ ។

[3] ឯកសារសំណុំរឿង ០០៣ D52 ដីកាបញ្ជូនសំណុំរឿងមូលទៅពិនិត្យ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។

[4] ឯកសារសំណុំរឿង ០០៣ D52/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ។

[5] ក្នុងចំណោមសក្ខីកម្មទាំងនោះ មានមួយចំនួនត្រូវបានពិនិត្យ និងពិចារណា ក៏ប៉ុន្តែមិនត្រូវបានប្រើក្នុងដីកានេះទេ ដោយសារមិនមានព័ត៌មានពាក់ព័ន្ធ៖

ឯកសារសំណុំរឿង ០០៣ D1.3.32.43 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **សៅ ខេ** ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D2/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **អ៊ូ លាង** ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០១០ ។ ឯកសារសំណុំរឿង ០០៣ D3/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ណុប ហាត** ឬ លី ហាត ហៅ ណុប ហុន ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១០ ។ ឯកសារសំណុំរឿង ០០៣ D5/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ប៉ាន រុំ** ឬ ប៉ាន ភារុំ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១០ ។ ឯកសារសំណុំរឿង ០០៣ D12/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ម៉ៅ ផាត** ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១០ ។ ឯកសារសំណុំរឿង ០០៣ D13/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **សាយ តាយ** ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១០ ។ ឯកសារសំណុំរឿង ០០៣ D14/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **មាំង ប្លូលីន** ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១០ ។ ឯកសារសំណុំរឿង ០០៣ D17/2 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **អ៊ិន សារឿន** ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ។ ឯកសារសំណុំរឿង ០០៣ D4.1.241 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ភី ភួន** ថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D4.1.246 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ប៉ែន អេន** ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D4.1.247 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ម៉ម ណៃ** ហៅ ចាន់ ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D4.1.249 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **នឹម គឹមស្រ៊ាង** ហៅ នឹម អឹម ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D4.1.250 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ហ៊ឹម ហ៊ុយ** ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D4.1.251 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **លក ម៉េងស៊ាន** ឬ ស្រ៊ុន ស៊ាន ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D4.1.343 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ចៀម សឿ** ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៧ ។ ឯកសារសំណុំរឿង ០០៣ D4.1.344 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡាច មាន** ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៧ ។ ឯកសារសំណុំរឿង ០០៣ D4.1.345 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ម៉ម ណៃ** ហៅ ចាន់ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៧ ។ ឯកសារសំណុំរឿង ០០៣ D4.1.363 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ប៉ែស ម៉ាត់** ហៅ លី ទ្រី ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨ ។ ឯកសារសំណុំរឿង ០០៣ D4.1.365 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី **ឡាច វល័ក្ខកល្យាណ** ហៅ កល្យាណ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ

---

